កម្មវិធីពន្លកចំណេះ ដំណាក់កាលទី២ ៖
ទិន្នន័យ និងការពិភាក្សា ដើម្បីការអភិវឌ្ឍនៅកម្ពុជា

# ការវិភាគបែបគុណវិស័យស្តីពី សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម នៅក្នុងដំណើរការស្រាវជ្រាវគោលនយោបាយ និងការពិភាក្សានៅកម្ពុជា

ក្រុមការងាររៀបចំ

Navaz Kotwal, Linda Jones,
Muyleng Khan, and Dolgion Aldar



Australian Aid

PONLOK CHOMNES

# សេចក្តីថ្លែងអំណរគុណ

ការវិភាគស្តីពីសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម នៅក្នុងដំណើរការស្រាវជ្រាវគោលនយោបាយ និងការពិភាក្សានៅកម្ពុជានេះ ទទួលបានធាតុចូលពីចំណេះដឹង និងបទពិសោធន៍របស់អ្នកពាក់ព័ន្ធ និងអង្គការ/ស្ថាប័នជាច្រើន។ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រចំពោះអ្នកចូលរួមទាំងអស់ដែលបានចែករំលែកទស្សនៈរបស់ពួកគេតាមរយៈបទសម្ភាសន៍ ការពិគ្រោះយោបល់ និងការពិភាក្សានានា។ ភាពបើកចំហ ការឆ្លុះបញ្ចាំង និងបទពិសោធន៍ជីវិតជាក់ស្តែងរបស់ពួកគេ គឺជាមូលដ្ឋានសម្រាប់ផ្សារភ្ជាប់ការវិភាគនេះទៅនឹងបរិបទគោលនយោបាយ និងការស្រាវជ្រាវជាក់ស្តែង។

យើងខ្ញុំសូមទទួលស្គាល់នូវការរួមចំណែករបស់អ្នកសម្ភាសន៍ និងអ្នកសម្របសម្រួលទាំងអស់ ដែលការចូលរួមប្រកបដោយការយកចិត្តទុកដាក់  ក្រមសីលធម៌  និងបរិយាបន្នរបស់ពួកគេ  បានជំរុញឱ្យមានការចូលរួមប្រកបដោយអត្ថន័យពីក្រុមគោលដៅផ្សេងៗនៅទីតាំងចម្រុះ។ ការងាររបស់ពួកគេមានសារៈសំខាន់យ៉ាងខ្លាំងចំពោះគុណភាព និងភាពស៊ីជម្រៅនៃលទ្ធផលទាំងនេះ។

យើងខ្ញុំក៏សូមថ្លែងអំណរគុណចំពោះការគាំទ្ររបស់រាជរដ្ឋាភិបាលកម្ពុជា ដែលកិច្ចសហប្រតិបត្តិការ និងការចូលរួមរបស់រាជរដ្ឋាភិបាលបានជួយឱ្យការវិភាគនេះលេចចេញជារូបរាងឡើង។ ការយល់ឃើញ និងការចូលរួមរបស់សមភាគីរដ្ឋាភិបាលនៅកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ មានសារៈសំខាន់ណាស់សម្រាប់ការស្វែងយល់ពីការអនុវត្តរបស់ស្ថាប័ន ឧបសគ្គ និងឱកាសក្នុងការពង្រឹងការរួមបញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម។

យើងខ្ញុំសូមថ្លែងអំណរគុណចំពោះរដ្ឋាភិបាលអូស្ត្រាលី   សម្រាប់ការគាំទ្រដល់កម្មវិធីពន្លកចំណេះ   (កម្មវិធីពន្លកចំណេះដំណាក់កាលទី២) ដែលក្នុងនោះ មានការវិភាគសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម។ ការប្តេជ្ញាចិត្តជាបន្តបន្ទាប់របស់រដ្ឋាភិបាលអូស្ត្រាលីចំពោះ  សមភាពយេនឌ័រ  ពិការភាព  និងបរិយាបន្នសង្គម  និងការចូលរួមបែបស្ថាបនានៅក្នុងដំណើរការវិភាគទាំងមូល បានជួយពង្រឹងទាំងទិសដៅ និងភាពម៉ត់ចត់នៃរបាយការណ៍នេះ។

យើងខ្ញុំសូមថ្លែងអំណរគុណដល់ក្រុមការងារកម្មវិធីពន្លកចំណេះដំណាក់កាលទី២ (Meloney C. Lindberg, Mehr Latif, ម៉ែន ពិចិត្រ និង ជ័យ ម៉ារ៉ាមី) ដែលបានជួយសម្របសម្រួល និងផ្តល់ធាតុចូលផ្នែកបច្ចេកទេសនៅគ្រប់ដំណាក់កាលទាំងអស់នៃការវិភាគ ចាប់តាំងពីការរៀបចំ និងការប្រមូលទិន្នន័យ រហូតដល់ការពិនិត្យឡើងវិញ និងការបញ្ចប់សេចក្តី។ យើងខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះដៃគូយុទ្ធសាស្ត្រទាំងអស់របស់កម្មវិធីពន្លកចំណេះ ដំណាក់កាលទី២ ដែលកិច្ចសហប្រតិបត្តិការរយៈពេលវែង  ជំនាញបច្ចេកទេស  និងការប្តេជ្ញាចិត្តចំពោះការអភិវឌ្ឍប្រកបដោយបរិយាបន្នរបស់ពួកគេ បានជួយទ្រទ្រង់ និងពង្រឹងកម្មវិធីនេះ។ ភាពជាដៃគូ និងការចូលរួមរបស់ពួកគេបានផ្តល់មូលដ្ឋានគ្រឹះដល់សមត្ថភាពរបស់កម្មវិធីពន្លកចំណេះ ដំណាក់កាលទី២ ក្នុងការបង្កើតទិន្នន័យដែលគួរឱ្យទុកចិត្ត គាំទ្រដល់កំណែទម្រង់គោលនយោបាយ និងលើកកម្ពស់សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម នៅទូទាំងប្រទេសកម្ពុជា។

យើងខ្ញុំសូមអរគុណចំពោះក្រុមអ្នកជំនាញផ្នែកសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ដែលបានផ្តល់មតិយោបល់យ៉ាងល្អិតល្អន់ ក្នុងអំឡុងពេលនៃការពិនិត្យឡើងវិញជុំមុនៗ ហើយធាតុចូលរបស់ពួកគេបានជួយធ្វើឱ្យការវិភាគនេះកាន់តែច្បាស់លាស់ និងធ្វើឱ្យប្រសើរឡើងនូវភាពពាក់ព័ន្ធនៃការវិភាគនេះសម្រាប់គោលនយោបាយ និងការអនុវត្ត។

លើសពីនេះ យើងខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តមបណ្ឌិត ហ៊ុល សៀងហេង មកពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ សហការីនៃក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី (លោកស្រី Evangeline Larsen និងលោកស្រី សំ ចាន់ធីតា) ផ្នែកជំនួយកិច្ចការបរិយាបន្នពិការភាពរបស់ក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី (Asahel Bush, Lucy Daniel និង Suzi Chinnery) និងលោកស្រី បូ មករា មកពីគម្រោង ACCESS ដំណាក់កាលទី២ ដែលបានផ្តល់ធាតុចូលដ៏មានតម្លៃ។

ជាចុងក្រោយ យើងខ្ញុំសូមកោតសរសើរចំពោះការងារស្នូលរបស់លោកស្រី Linda Jones និងកញ្ញា ខន មុយឡេង ដែលបានរៀបចំសេចក្តីព្រាងដំបូងនៃការវិភាគ សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម នេះ និងបង្កើតបានជាមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់ការកែលម្អ និងការអភិវឌ្ឍជាបន្តបន្ទាប់។

# មាតិកា


សេចក្តីថ្លែងអំណរគុណ i
បញ្ជីប្រអប់ v
អក្សរកាត់ vi
ខ្លឹមសារសង្ខេប 1

០១ សេចក្តីផ្តើម ១៥

០២ ការរៀបចំការស្រាវជ្រាវ វិធីសាស្ត្រ និងក្របខណ្ឌវិភាគ ១៩

២.១. ការរៀបចំការស្រាវជ្រាវ ២១
២.២. ក្របខណ្ឌវិភាគ ២១
២.៣. សំណួរគោលនៃការស្រាវជ្រាវ ២៥
២.៤. ការជ្រើសរើសអ្នកចូលរួម និងទីតាំងចុះមូលដ្ឋាន ២៥
២.៥. ឧបករណ៍ស្រាវជ្រាវ ការប្រមូល និងការវិភាគទិន្នន័យ ៣០
២.៦. ក្រុមស្រាវជ្រាវ និងប្រមូលទិន្នន័យ ៣១
២.៧. ដែនកំណត់នៃការសិក្សា ៣២

# ០៣ លទ្ធផលនៃការស្រាវជ្រាវ ៣៣


## ៣.១ រដ្ឋាភិបាល៖ អ្នកតាក់តែង និងអ្នកអនុវត្តគោលនយោបាយ ៣៤

៣.១.១ ទិដ្ឋភាពទូទៅនៃក្របខណ្ឌគោលនយោបាយ និងការអនុវត្តពាក់ព័ន្ធនឹងទិន្នន័យ និងការពិគ្រោះយោបល់ ៣៥
៣.១.២ សមភាពយេនឌ័រនៅក្នុងរចនាសម្ព័ន្ធរដ្ឋាភិបាល និងដំណើរការគោលនយោបាយ ៣៧
៣.១.៣. បរិយាបន្នពិការភាពនៅក្នុងការអភិវឌ្ឍគោលនយោបាយ និងប្រព័ន្ធសេវាសាធារណៈ ៣៩
៣.១.៤. បរិយាបន្នសង្គម៖ ជនជាតិភាគតិច ជនជាតិដើមភាគតិច ភូមិសាស្ត្រ សេដ្ឋកិច្ចសង្គម និងអាយុ ៤២
៣.១.៥. អន្តរប្រសព្វ៖ ឧបសគ្គត្រួតគ្នា និងចំណុចខ្វះចន្លោះក្នុងគោលនយោបាយ ៤៣
៣.១.៦. ការដាក់បញ្ចូល សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម នៅថ្នាក់ក្រោមជាតិ ៤៤
៣.១.៧. បញ្ហាប្រឈម៖ ចំណុចរាំងស្ទះដល់ការដាក់បញ្ចូល សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ៤៦
៣.១.៨. អនុសាសន៍៖ ទស្សនៈរបស់រដ្ឋាភិបាលស្តីពីការពង្រឹងការដាក់បញ្ចូល សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ៥៥

---

## ៣.២ ស្ថាប័នវិស័យស្រាវជ្រាវ ៥៧

៣.២.១. ទិដ្ឋភាពទូទៅនៃវិស័យស្រាវជ្រាវ ៥៨
៣.២.២. ការអនុវត្ត សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម នៅក្នុងស្ថាប័នស្រាវជ្រាវ ៦០
៣.២.៣. សមភាពយេនឌ័រនៅក្នុងអាជីពស្រាវជ្រាវ ការដឹកនាំ និងការបង្កើតចំណេះដឹង ៦៣
៣.២.៤. បរិយាបន្នពិការភាពនៅក្នុងការស្រាវជ្រាវ និងការអនុវត្តរបស់ស្ថាប័ន ៦៨
៣.២.៥. បរិយាបន្នសង្គម៖ ជាតិពន្ធុ អត្តសញ្ញាណជាជនជាតិដើមភាគតិច យុវជន ភូមិសាស្ត្រ ទំនោរផ្លូវភេទ និងវិសមភាពសេដ្ឋកិច្ចសង្គម ៧៦
៣.២.៦. អន្តរប្រសព្វ៖ ការយល់ដឹងអំពីឧបសគ្គត្រួតគ្នា និងអត្តសញ្ញាណត្រួតគ្នា ៧៨
៣.២.៧. បញ្ហាប្រឈម៖ ការប្តេជ្ញាចិត្ត ជាមួយនឹងតថភាពជាក់ស្តែងដ៏លំបាក ៨១
៣.២.៨. អនុសាសន៍៖ ទស្សនៈរបស់ស្ថាប័នស្រាវជ្រាវចំពោះការគាំទ្រដល់ការដាក់បញ្ចូល សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ៨៣

---

## ៣.៣ សមាជិកសហគមន៍ ៨៦

៣.៣.១. បរិបទដែលជះឥទ្ធិពលលើការចូលរួម ៨៧
៣.៣.២. សមភាពយេនឌ័រ៖ ឧបសគ្គ និងអាទិភាពសម្រាប់ការចូលរួមរបស់ស្ត្រី ៨៨
៣.៣.៣. បរិយាបន្នពិការភាព៖ ឧបសគ្គ និងអាទិភាពសម្រាប់ជនមានពិការភាព ៩១
៣.៣.៤. បរិយាបន្នសង្គម (ជាតិពន្ធុ អត្តសញ្ញាណជាជនជាតិដើមភាគតិច យេនឌ័រ ទំនោរផ្លូវភេទ ភូមិសាស្ត្រ ស្ថានភាពសេដ្ឋកិច្ចសង្គម អាយុ) ៩៦
៣.៣.៥. អន្តរប្រសព្វ៖ ឧបសគ្គត្រួតគ្នា និងតម្រូវការដែលមិនទាន់បានបំពេញ ៩៩
៣.៣.៦. អនុសាសន៍៖ ទស្សនៈរបស់សហគមន៍ស្តីពីការលុបបំបាត់ឧបសគ្គ និងការចាប់យកឱកាស ១០១

04

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍ ១០៣


៤.១. សេចក្តីសន្និដ្ឋាន ១០៤

៤.២. អនុសាសន៍ពាក់ព័ន្ធនឹង សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ១០៧

- ក្រសួងស្ថាប័នរដ្ឋាភិបាល និងអាជ្ញាធរថ្នាក់ក្រោមជាតិ ១០៧
- ស្ថាប័នវិស័យស្រាវជ្រាវ ១១០
- សហគមន៍ និងសង្គមស៊ីវិល ១១២

៤.៣. ឱកាសសម្រាប់កម្មវិធីពន្លកចំណេះ ១១៣


# ឯកសារយោង ១១៥

# ឧបសម្ព័ន្ធ ១១៨


ឧបសម្ព័ន្ធ ១. សទ្ទានុក្រម ១១៨

- ទស្សនទានស្នូលនៃ សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ១១៨
- ទស្សនទានទាក់ទងនឹងវិស័យស្រាវជ្រាវ និងគោលនយោបាយ ១២១

ឧបសម្ព័ន្ធ ២. បញ្ជីរាយនាមអង្គការ និងស្ថាប័នដែលបានពិគ្រោះយោបល់ ១២៤

ឧបសម្ព័ន្ធ ៣. កាលវិភាគស្រាវជ្រាវបឋម ១២៦

ឧបសម្ព័ន្ធ ៤. ការណែនាំសម្រាប់បទសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ ១៣១

ឧបសម្ព័ន្ធ ៥. ការណែនាំសម្រាប់ការពិភាក្សាក្រុមគោលដៅ ១៤០

ឧបសម្ព័ន្ធ ៦. ក្របខណ្ឌវិភាគយេនឌ័រនៅកន្លែងការងារ ១៤៣

ឧបសម្ព័ន្ធ ៧. ទិដ្ឋភាពទូទៅនៃក្របខណ្ឌគោលនយោបាយ និងច្បាប់ជាតិ ១៤៥

# បញ្ជីប្រអប់


ប្រអប់ទី ១៖ ការកំណត់និយមន័យនៃអន្តរប្រសព្វ

ប្រអប់ទី ២៖ ការយល់ដឹងពីក្រសួងកិច្ចការនារី

ប្រអប់ទី ៣៖ បរិយាបន្នពិការភាពនៅក្រសួងមហាផ្ទៃ

ប្រអប់ទី ៤៖ បរិយាបន្នពិការភាពនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ប្រអប់ទី ៥៖ ក្រសួងបរិស្ថាន៖ អ្វីដែលជាឧបសគ្គរារាំងការដាក់បញ្ចូល សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម

ប្រអប់ទី ៦៖ ការដាក់បញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ទៅក្នុងក្របខណ្ឌថវិការបស់កម្ពុជា៖ ទស្សនៈពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ប្រអប់ទី ៧៖ ចំណុចខ្វះចន្លោះក្នុងគោលនយោបាយពិការភាព និងការសម្របសម្រួលអន្តរក្រសួង

ប្រអប់ទី ៨៖ បញ្ហាប្រឈមក្នុងការជំរុញបរិយាបន្នយេនឌ័រ និងពិការភាព ក្នុងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ

ប្រអប់ទី ៩៖ របៀបដែលក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា យល់ដឹង និងអនុវត្ត សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម និងការលំបាកក្នុងការអនុវត្ត

ប្រអប់ទី ១០៖ របៀបដែលកម្មវិធីពន្លកចំណេះដំណាក់កាលទី២ បញ្ជ្រាបសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ទៅក្នុងការផ្សារភ្ជាប់ការស្រាវជ្រាវជាមួយនឹងគោលនយោបាយ

ប្រអប់ទី ១១៖ បញ្ហាប្រឈមរបស់អ្នកស្រាវជ្រាវជាស្ត្រី

ប្រអប់ទី ១២៖ សេចក្តីសង្ខេបលទ្ធផលសំខាន់ៗពីកិច្ចប្រជុំសហការរៀបចំគោលការណ៍ណែនាំស្តីពីបរិយាបន្ន និងជើងឯកពិការភាពប្រចាំស្ថាប័ន

ប្រអប់ទី ១៣៖ ឧបសគ្គធំៗដែលរារាំងការចូលរួម និងអាទិភាពសម្រាប់ជនមានពិការភាព នៅក្នុងដំណើរការស្រាវជ្រាវ និងដំណើរការរបស់សហគមន៍៖ សេចក្តីសង្ខេបលទ្ធផលពីការពិភាក្សាក្រុមគោលដៅ

# អក្សរកាត់

| | | |
|---|---|---|
| ACCESS | Australia-Cambodia Cooperation for Equitable Sustainable Services | កម្មវិធីសហប្រតិបត្តិការ អូស្ត្រាលី-កម្ពុជា ដើម្បីការផ្តល់សេវាប្រកបដោយនិរន្តរភាព និងសមធម៌ |
| AVI | Asian Vision Institute | វិទ្យាស្ថានចក្ខុវិស័យអាស៊ី |
| CAPRED | Cambodia Australia Partnership for Resilient Economic Development | កម្មវិធីភាពជាដៃគូ កម្ពុជា-អូស្ត្រាលី សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយភាពធន់ |
| CCRS | Cambodian Center for Regional Studies | មជ្ឈមណ្ឌលខ្មែរសិក្សាកិច្ចការតំបន់ |
| CCWC | Commune Committee for Women and Children | គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ (គ.ក.ន.ក) |
| CDHS | Cambodia Demographic and Health Survey | អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា |
| CDPO | Cambodian Disabled People's Organisation | អង្គការជនពិការកម្ពុជា |
| CDRI | Cambodia Development Resource Institute | វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា |
| CEDAW | Convention on the Elimination of All Forms of Discrimination Against Women | អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ |
| CICP | Cambodian Institute for Cooperation and Peace | វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និង សន្តិភាព |
| CIWA | Cambodian Indigenous Women Association | សមាគមស្ត្រីជនជាតិដើមភាគតិចកម្ពុជា |
| CIYA | Cambodia Indigenous Youth Association | សមាគមយុវជនជនជាតិដើមភាគតិចកម្ពុជា |
| CKS | Centre for Khmer Studies | មជ្ឈមណ្ឌលខេមរសិក្សា |
| CPS | Centre for Policy Studies | មជ្ឈមណ្ឌលសិក្សាគោលនយោបាយ |
| CRPD | Convention on the Rights of Persons with Disabilities | អនុសញ្ញាស្តីពីសិទ្ធិជនពិការ |
| CSEAS | Center for Southeast Asian Studies | មជ្ឈមណ្ឌលសិក្សាអាស៊ីអាគ្នេយ៍ |
| CSOs | Civil Society Organisations | អង្គការសង្គមស៊ីវិល |
| DAC | Disability Action Council | ក្រុមប្រឹក្សាសកម្មភាពជនពិការ |
| DAWG | Disability Action Working Group | ក្រុមការងារសកម្មភាពជនពិការ |
| DFAT | Department of Foreign Affairs and Trade (Australian Government) | ក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី |

| | | |
|---|---|---|
| DWCCC | District Women and Children Consultative Committee | គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ក្រុង ស្រុក ខណ្ឌ |
| EU | European Union | សហភាពអឺរ៉ុប |
| FAO | Food and Agriculture Organization of the United Nations | អង្គការស្បៀង និងកសិកម្មសហប្រជាជាតិ |
| FF | Future Forum | វេទិកាអនាគត |
| FGD | Focus Group Discussion | ការពិភាក្សាក្រុមគោលដៅ |
| FPAR | Feminist Participatory Action Research | ការសិក្សាស្រាវជ្រាវបែបចូលរួមផ្អែកលើគោលការណ៍ហ្វេមីនីស្ត |
| FPIC | Free, Prior and Informed Consent | ការយល់ព្រមជាមុន ដោយសេរី និងទទួលបានព័ត៌មានគ្រប់គ្រាន់ |
| GADC | Gender and Development for Cambodia | អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា |
| GBV | Gender-Based Violence | អំពើហិង្សាផ្អែកលើយេនឌ័រ |
| GEDSI | Gender Equality, Disability, and Social Inclusion | សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម |
| GMAG | Gender Mainstreaming Action Group | ក្រុមការងារបញ្ជ្រាបយេនឌ័រ |
| GRB | Gender-Responsive Budgeting | ការរៀបចំថវិកាឆ្លើយតបនឹងយេនឌ័រ |
| HR | Human Resources | ធនធានមនុស្ស |
| IDPoor | Identification of Poor Households Programme | កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ |
| IFAD | International Fund for Agricultural Development | មូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍកសិកម្ម |
| INGO | International Non-Governmental Organisation | អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ |
| IP | Indigenous Peoples | ជនជាតិដើមភាគតិច |
| IPO | Indigenous Peoples Organisation | អង្គការជនជាតិដើមភាគតិច |
| KAS | Konrad-Adenauer-Stiftung | មូលនិធិ Konrad-Adenauer-Stiftung |
| KII | Key Informant Interview | បទសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ |

| | | |
|---|---|---|
| LGBTQIA+ | Lesbian, Gay, Bisexual, Transgender, Queer/ Questioning, Intersex, Asexual/Aromantic, and other gender-diverse or sexually diverse identities | ស្រីស្រឡាញ់ស្រី ប្រុសស្រឡាញ់ប្រុស មនុស្សស្រឡាញ់ទាំងពីរភេទ អ្នកប្តូរយេនឌ័រ អ្នកដែលមិនកំណត់ថាខ្លួនជាមនុស្សប្រុស ឬមនុស្សស្រី អន្តរភេទ មនុស្សអភេទ និងអ្នកផ្សេងៗទៀត (ក្រុមLGBTQIA+) |
| LSMS | Living Standards Measurement Survey | អង្កេតវាស់ស្ទង់កម្រិតជីវភាពរស់នៅ |
| MAFF | Ministry of Agriculture, Forestry and Fisheries | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| M&E | Monitoring and Evaluation | ការត្រួតពិនិត្យ និងវាយតម្លៃ |
| MEF | Ministry of Economy and Finance | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MEL | Monitoring, Evaluation and Learning | ការត្រួតពិនិត្យ វាយតម្លៃ និងរៀនសូត្រ |
| MISTI | Ministry of Industry, Science, Technology and Innovation | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍ |
| MoE | Ministry of Environment | ក្រសួងបរិស្ថាន |
| MoEYS | Ministry of Education, Youth and Sport | ក្រសួងអប់រំ យុវជន និងកីឡា |
| MFAIC | Ministry of Foreign Affairs and International Cooperation | ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ |
| MoH | Ministry of Health | ក្រសួងសុខាភិបាល |
| MoI | Ministry of Interior | ក្រសួងមហាផ្ទៃ |
| MoP | Ministry of Planning | ក្រសួងផែនការ |
| MoSVY | Ministry of Social Affairs, Veterans and Youth Rehabilitation | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| MoWA | Ministry of Women's Affairs | ក្រសួងកិច្ចការនារី |
| MRD | Ministry of Rural Development | ក្រសួងអភិវឌ្ឍន៍ជនបទ |
| NCDM | National Committee for Disaster Management | គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ |
| NDC | Nationally Determined Contribution | ផែនការជាតិរួមចំណែកឆ្លើយតបការប្រែប្រួលអាកាសធាតុ |
| NDSP | National Disability Strategic Plan | ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព |
| NGO | Non-Governmental Organisation | អង្គការមិនមែនរដ្ឋាភិបាល |
| NIDIR | National Institute of Diplomacy and International Relations | វិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិ |

| | | |
|---|---|---|
| NIS | National Institute of Statistics | វិទ្យាស្ថានជាតិស្ថិតិ |
| NISA | National Institute of Social Affairs | វិទ្យាស្ថានជាតិសង្គមកិច្ច |
| NR | Neary Rattanak | ផែនការយុទ្ធសាស្ត្រនារីរតនៈ |
| NSDP | National Strategic Development Plan | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| NSDS | National Strategy for Development of Statistics | យុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ |
| NSPPF | National Social Protection Policy Framework | ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម |
| NUBB | National University of Battambang | សាកលវិទ្យាល័យជាតិបាត់ដំបង |
| OPD | Organisation of Persons with Disabilities | អង្គការតំណាងជនមានពិការភាព |
| PONLOK CHOMNES II | Ponlok Chomnes II: Data and Dialogue for Development in Cambodia | កម្មវិធីពន្លកចំណេះ ដំណាក់កាលទី ២៖ ទិន្នន័យ និងការពិភាក្សា ដើម្បីការអភិវឌ្ឍនៅកម្ពុជា |
| PPCIL | Phnom Penh Center for Independent Living | មជ្ឈមណ្ឌលជីវិតរស់នៅដោយឯករាជ្យនៃជនពិការភ្នំពេញ |
| PUC | Pannasastra University of Cambodia | សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា |
| PWCCC | Provincial Women and Children Consultative Committee | គណកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមារខេត្ត |
| PwD | Person / People with Disability / Disabilities | ជនមានពិការភាព |
| REDD+ | Reducing Emissions from Deforestation and Forest Degradation | ការកាត់បន្ថយការបំភាយឧស្ម័នដែលបណ្តាលមកពីការបាត់បង់ និងរេចរឹលព្រៃឈើ |
| RGC | Royal Government of Cambodia | រាជរដ្ឋាភិបាលកម្ពុជា |
| ROCK | Rainbow Community Kampuchea | អង្គការសហគមន៍ឥន្ទធនូកម្ពុជា |
| RUPP | Royal University of Phnom Penh | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| SDG | Sustainable Development Goal | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
| SGD | Small Group Discussion | ការពិភាក្សាជាក្រុមតូចៗ |
| UC | The University of Cambodia | សាកលវិទ្យាល័យកម្ពុជា |
| UN | United Nations | អង្គការសហប្រជាជាតិ |
| UNDP | United Nations Development Program | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ |
| USAID | United States Agency for International Development | ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ |
| WPM | Women Peace Makers | អង្គការនារីដើម្បីសន្តិភាព |

# ខ្លឹមសារសង្ខេប

របាយការណ៍នេះបង្ហាញការវិភាគអំពីថាតើសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម (GEDSI) ត្រូវបានដាក់បញ្ចូលដូចម្ដេចទៅក្នុងដំណើរការស្រាវជ្រាវគោលនយោបាយ និងការពិភាក្សានៅកម្ពុជា ដោយផ្ដោតជាពិសេសលើវិស័យស្រាវជ្រាវ និងការអនុវត្តដែលទទួលបានការគាំទ្រក្រោមកម្មវិធីពន្លកចំណេះ ដំណាក់កាលទី ២។ របាយការណ៍នេះពិនិត្យមើលទាំងប្រព័ន្ធស្ថាប័ន និងបទពិសោធន៍ជីវិតជាក់ស្ដែង ដើម្បីកំណត់ថាតើបរិយាបន្នរីកចម្រើនត្រង់ចំណុចណាខ្លះ នៅមានភាពមិនស្មើគ្នាត្រង់ចំណុចណាខ្លះ និងអ្វីខ្លះដែលត្រូវការចាំបាច់ ដើម្បីឈានឆ្ពោះទៅរកការដាក់បញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ឱ្យកាន់តែប្រកបដោយអត្ថន័យ និងស៊ីសង្វាក់គ្នា។

## គោលបំណងនៃការសិក្សា

ការវិភាគសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម នេះ ត្រូវបានអនុវត្តក្រោម**កម្មវិធីពន្លកចំណេះ ដំណាក់កាលទី២៖ ទិន្នន័យ និងការពិភាក្សា ដើម្បីការអភិវឌ្ឍនៅកម្ពុជា (កម្មវិធីពន្លកចំណេះ ដំណាក់កាលទី២)** ដែលទទួលបានការគាំទ្រពីរដ្ឋាភិបាលអូស្ត្រាលី។ ការសិក្សានេះពិនិត្យមើលថាតើភាពគ្របដណ្ដប់នៃ សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ជះឥទ្ធិពលដូចម្ដេចលើការចូលរួមក្នុងប្រព័ន្ធអេកូឡូស៊ីនៃការស្រាវជ្រាវ និងគោលនយោបាយនៅកម្ពុជា។

**ការវិភាគនេះគឺដើម្បី៖**

- វិភាគអំពីឧបសគ្គ ឱកាស និងតម្រូវការជាក់លាក់របស់ស្ត្រី ជនមានពិការភាព ក្រុមស្រលាញ់ភេទដូចគ្នា (LGBTQIA+) ជនជាតិដើមភាគតិច និងជនជាតិភាគតិច យុវជន និងក្រុមជួបការលំបាកផ្សេងទៀត ក្នុងការចូលរួមជាមួយដំណើរការស្រាវជ្រាវ និងដំណើរការគោលនយោបាយ។
- វាយតម្លៃថាតើស្ថាប័នរដ្ឋាភិបាល ស្ថាប័នស្រាវជ្រាវ និងសហគមន៍ ដាក់បញ្ចូលគោលការណ៍ សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ទៅក្នុងការអនុវត្តជាក់ស្ដែងយ៉ាងដូចម្ដេច។
- កំណត់យុទ្ធសាស្ត្រជាក់ស្ដែង និងអាចអនុវត្តបាន ដើម្បីពង្រឹងការបង្កើតទិន្នន័យ និងការពិភាក្សាគោលនយោបាយប្រកបដោយបរិយាបន្ន។

ការស្រាវជ្រាវនេះត្រូវបានធ្វើឡើង ដើម្បីឆ្លើយតបសំណួរគោលដូចខាងក្រោម និងក្នុងគោលបំណងផ្តល់ព័ត៌មានជាក់ស្តែងដល់ការងារនាពេលអនាគត និងលើកកម្ពស់កម្រិតស្តង់ដារក្នុងការដាក់បញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម៖

## សំណួរស្រាវជ្រាវទី ១

**តើមន្ត្រីរដ្ឋាភិបាលបញ្ជ្រាប ឬដាក់បញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម យ៉ាងដូចម្តេច? តើពួកគេជួបប្រទះបញ្ហាប្រឈមអ្វីខ្លះ ហើយតើការគាំទ្របន្ថែមអ្វីខ្លះដែលនឹងជួយពង្រឹងការដាក់បញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ទៅក្នុងការងាររបស់ពួកគេ?**

## សំណួរស្រាវជ្រាវទី ២

**តើអ្នកស្រាវជ្រាវ បញ្ជ្រាប ឬដាក់បញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម យ៉ាងដូចម្តេច? តើពួកគេជួបប្រទះបញ្ហាប្រឈមអ្វីខ្លះ ហើយតើការគាំទ្រអ្វីខ្លះដែលនឹងជួយបញ្ជ្រាបសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ឱ្យកាន់តែមានប្រសិទ្ធភាពទៅក្នុងការអនុវត្តការស្រាវជ្រាវ?**

## សំណួរស្រាវជ្រាវទី ៣

**តើមានឧបសគ្គ ឱកាស អាទិភាព និងតម្រូវការជាក់លាក់អ្វីខ្លះ សម្រាប់ស្ត្រី ជនមានពិការភាព បុគ្គលស្រលាញ់ភេទដូចគ្នា និងក្រុមជួបការលំបាកផ្សេងទៀតនៅក្នុងសង្គម ក្នុងការចូលរួមក្នុងវិស័យស្រាវជ្រាវ និងដំណើរការគោលនយោបាយ?**

## សំណួរស្រាវជ្រាវទី ៤

**តើធ្វើដូចម្តេចទើបអាចកាត់បន្ថយឧបសគ្គ និងទាញប្រយោជន៍ពីឱកាស ដើម្បីធ្វើឱ្យប្រសើរឡើងដល់ការចូលរួមរបស់ក្រុមអ្នកជួបការលំបាក នៅក្នុងវិស័យស្រាវជ្រាវ និងដំណើរការគោលនយោបាយ ដែលអាចឱ្យពួកគេទទួលបានការគាំទ្រកាន់តែប្រសើរ?**

ដោយផ្តោតចម្បងលើបទពិសោធន៍ជីវិតជាក់ស្តែង ទន្ទឹមគ្នានឹងការអនុវត្តរបស់ស្ថាប័ន ការសិក្សានេះរំលេចឱ្យឃើញចំណុចខ្វះខាតជាប្រព័ន្ធនៅក្នុងការកំណត់របៀបវារៈ សំឡេង និងឥទ្ធិពល ព្រមទាំងកំណត់បានចំណុចចាប់ផ្តើមជាក់ស្តែងសម្រាប់ការពង្រឹងបរិយាបន្ននៅទូទាំងវិស័យស្រាវជ្រាវរបស់កម្ពុជា។

## ក្របខណ្ឌវិភាគ

ការវិភាគនេះបានអនុវត្តក្របខណ្ឌយេនឌ័រនៅកន្លែងធ្វើការ (Gender at Work Framework) របស់ក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី ដែលចាត់ទុកថា សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម មិនមែនជាធាតុផ្សំដាច់ដោយឡែកពីគ្នានោះទេ ប៉ុន្តែជាធាតុផ្សំប្រទាក់ក្រឡាគ្នា ដែលជះឥទ្ធិពលដល់ការផ្លាស់ប្តូរស្ថាប័ន និងសង្គម។ ក្របខណ្ឌនេះបានណែនាំដល់ការរៀបចំសំណួរស្រាវជ្រាវ ឧបករណ៍ និងការវិភាគ ដោយផ្តោតទាំងលើប្រព័ន្ធផ្លូវការ (ច្បាប់គោលនយោបាយ ការរៀបចំស្ថាប័ន) និងភាពគ្របដណ្តប់ក្រៅផ្លូវការ (បទដ្ឋានសង្គម ទំនាក់ទំនងអំណាច និង ការអនុវត្តប្រចាំថ្ងៃ)។

ក្របខណ្ឌនេះ ផ្តល់លទ្ធភាពឱ្យការសិក្សាងាកចេញពីវិធីសាស្ត្រដោះស្រាយបញ្ហាដាច់ពីគ្នា ដោយរំលេចនូវចំណុចខ្វះចន្លោះជាប្រព័ន្ធ និងកំណត់រកឱកាសសម្រាប់បរិយាបន្នប្រកបដោយការផ្លាស់ប្រែ។

ជាតុផ្សំប្រទាក់ក្រឡាគ្នាទាំងបួន ដែលតម្រឹមតម្រង់ការវិភាគនេះ រួមមាន៖

ពិនិត្យមើលថាតើបទដ្ឋាន តួនាទី និងការរំពឹងទុក ជះឥទ្ធិពលយ៉ាងដូចម្តេចដល់ការទទួលបានអាជីព ស្រាវជ្រាវ មុខតំណែងដឹកនាំ និងវេទិកា/ឱកាស ពិភាក្សាគោលនយោបាយ និងថាតើជំនាញរបស់នរណាដែលត្រូវបានគេឱ្យតម្លៃ។

ចាប់យកទិដ្ឋភាពនៃភាពងាយរងគ្រោះ ដូចជា ជាតិពន្ធុ អត្តសញ្ញាណជាជនជាតិដើមភាគតិច ទំនោរផ្លូវភេទ ភូមិសាស្ត្រ ស្ថានភាពសេដ្ឋកិច្ចសង្គម និងអាយុ។




វាយតម្លៃថាតើអាកប្បកិរិយា ការបង្កភាពងាយស្រួល ការអនុវត្តរបស់អង្គការ/ស្ថាប័ន និងប្រព័ន្ធសម្របសម្រួល ជួយជំរុញ ឬរឹតត្បិតការចូលរួម យ៉ាងដូចម្តេច។

ការស្វែងយល់អំពីរបៀបដែលអត្តសញ្ញាណត្រួតគ្នា (ឧទាហរណ៍ ស្ត្រីមានពិការភាព យុវជនជាជនជាតិដើមភាគតិច) បង្កើតជាឧបសគ្គកាន់តែច្រើន ដែលជារឿយៗ មិនត្រូវបានគេមើលឃើញនៅក្នុងគោលនយោបាយ និងការស្រាវជ្រាវ។

# វិធីសាស្ត្រ

ការវិភាគនេះប្រើប្រាស់ **វិធីសាស្ត្រគុណវិស័យបែបចូលរួម** ដោយផ្តោតអាទិភាពលើភាពគួរឱ្យទុកចិត្ត ការបង្កភាពងាយស្រួល និងបរិយាបន្ន។

ក្រុមស្រាវជ្រាវផ្ទាល់ ក៏មានសមាសភាពចម្រុះផងដែរ គឺរួមមានស្ត្រី ជនមានពិការភាព និងអ្នកស្រាវជ្រាវជាជនជាតិដើមភាគតិច ដែលជួយពង្រឹងដល់បរិយាបន្ន និងការបកស្រាយលទ្ធផលស្រាវជ្រាវឱ្យកាន់តែស៊ីជម្រៅ។

## ការពិភាក្សាក្រុមគោលដៅ

មានការពិភាក្សាជាក្រុមចំនួន ៥២ ដែលមានអ្នកចូលរួមសរុប ២៧៨ នាក់ (ស្ត្រី ៦២% ជនមានពិការភាព ១២% និងក្រុមស្រលាញ់ភេទដូចគ្នា ១៧%) នៅរាជធានីភ្នំពេញ ខេត្តបាត់ដំបង សៀមរាប កំពត និងរតនគិរី។ ការជ្រើសរើសទីតាំងទាំងនេះ គឺដើម្បីឆ្លុះបញ្ចាំងពីភាពចម្រុះផ្នែកភូមិសាស្ត្រ និងសង្គមរបស់កម្ពុជា ដើម្បីធានាបាននូវសំឡេងតំណាងមកពីតំបន់ទីក្រុង តំបន់ជនបទ និងសហគមន៍ជនជាតិដើមភាគតិច។



## បទសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់

បទសម្ភាសន៍ចំនួន ៣២ ត្រូវបានធ្វើឡើងជាមួយអ្នកឆ្លើយតបចំនួន ៧៤ នាក់ (ស្ត្រី ៣៦ នាក់ និងជនមានពិការភាព ១ នាក់) មកពីបណ្តាក្រសួងនានា សាកលវិទ្យាល័យ វិទ្យាស្ថានស្រាវជ្រាវ អង្គការសង្គមស៊ីវិល និងបណ្តាញផ្សេងៗ។ អ្នកឆ្លើយតប ត្រូវបានជ្រើសរើសដោយគ្រោងទុកជាមុន ដើម្បីរាប់បញ្ចូលទាំងតួអង្គ សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ដែលមានស្រាប់ និងក្រុមផ្សេងទៀត ដែលមិនសូវមានគេមើលឃើញ។



## ការពិនិត្យទិន្នន័យបន្ទាប់បន្សំ

ស្ថិតិជាតិ ឯកសារវិស័យសិក្សាធិការ ឯកសារកម្មវិធី និងក្របខណ្ឌគោលនយោបាយ ត្រូវបានយកមកវិភាគ ដើម្បីធ្វើបរិបទកម្មទៅលើលទ្ធផលបែបគុណវិស័យ។



## លទ្ធផល

នៅក្នុងស្ថាប័នរដ្ឋាភិបាល វិស័យស្រាវជ្រាវ និងសហគមន៍ ការដាក់បញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ត្រូវបានគេទទួលស្គាល់កាន់តែខ្លាំង និងឆ្លុះបញ្ចាំងឱ្យឃើញតាមរយៈការចូលរួមកាន់តែច្រើនឡើង។ ទោះជាយ៉ាងណា ការដាក់បញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម នៅតែមិនសូវមានឥទ្ធិពលលើរបៀបវារៈនៃការស្រាវជ្រាវ ការពិភាក្សាគោលនយោបាយ និងការធ្វើសេចក្តីសម្រេចចិត្ត ហើយវាមិនទាន់ត្រូវបានចាក់ឫសជ្រៅទៅក្នុងប្រព័ន្ធស្ថាប័ននៅឡើយទេ។ ឧបសគ្គមិនមែនកើតមានតែចំពោះតួអង្គជាក់លាក់ណាមួយនោះទេ ប៉ុន្តែវាបានលេចឡើងនៅទូទាំងដំណើរការទាំងមូលនៃការប្រែក្លាយទិន្នន័យទៅជាគោលនយោបាយ ដែលការខ្វះខាតទិន្នន័យប្រកបដោយបរិយាបន្ន បានរួមចំណែកធ្វើឱ្យមានភាពជាតំណាងតិចតួចនៅក្នុងការពិភាក្សា និងរឹតត្បិតទៅលើកម្រិតដែលទស្សនៈចម្រុះអាចជះឥទ្ធិពលដល់លទ្ធផលគោលនយោបាយ។ ចលនការទាំងនេះជះឥទ្ធិពលលើគ្នាទៅវិញទៅមក ដែលបញ្ជាក់ពីភាពចាំបាច់ក្នុងការផ្លាស់ប្តូរពីកិច្ចខិតខំប្រឹងប្រែងដាច់ដោយឡែកពីគ្នា ទៅជាវិធីសាស្ត្រមានលក្ខណៈជាប្រព័ន្ធ ដែលមានការសម្របសម្រួលប្រសើរជាងមុន ដើម្បីពង្រឹងការដាក់បញ្ចូល សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម នៅគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការគោលនយោបាយ។

នៅក្នុងធាតុផ្សំទាំងបួននៃសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម វឌ្ឍនភាពបានរំលេចច្បាស់ជាងគេលើផ្នែកសមភាពយេនឌ័រ ដែលគោលនយោបាយ និងយន្តការដែលមានស្រាប់ បានជួយគាំទ្រដល់ការបង្កើនការចូលរួម ទោះបីជាមិនទាន់មានឥទ្ធិពលខ្លាំងក៏ដោយ។ បរិយាបន្នពិការភាពសម្រេចបានវឌ្ឍនភាពតិចតួចបំផុត ព្រោះនៅតែមានភាពខ្វះចន្លោះទាក់ទងនឹងការបង្កភាពងាយស្រួល ការអនុវត្តរបស់ស្ថាប័ន និងភាពជាតំណាង។ ជារឿយៗ បរិយាបន្នសង្គមយ៉ាងទូលំទូលាយ ដែលរួមបញ្ចូលទាំងជាតិពន្ធុ ភូមិសាស្ត្រ និងទំនោរផ្លូវភេទ នៅតែមិនទាន់ទទួលបានការយកចិត្តទុកដាក់គ្រប់គ្រាន់ ទាំងក្នុងដំណើរការស្រាវជ្រាវ និងដំណើរការគោលនយោបាយ។ អន្តរប្រសព្វ ជាចំណុចមួយដែលត្រូវបានឆ្លុះបញ្ចាំងតិចតួចបំផុតនៅក្នុងការអនុវត្តជាក់ស្តែង ពោលគឺមិនសូវមានការយកចិត្តទុកដាក់ទៅលើរបៀបដែលភាព ត្រួតគ្នាស៊ីគ្នាញាំងឱ្យមានការផាត់ចេញ ហើយកត្តានេះធ្វើឱ្យគេបន្តមើលរំលងក្រុមដែលកំពុងប្រឈមមុខនឹងភាពងាយរងគ្រោះកាន់តែច្រើន។

## រដ្ឋាភិបាល – អ្នកតាក់តែង និងអ្នកអនុវត្តគោលនយោបាយ

បច្ចុប្បន្ន ក្រសួងស្ថាប័នរដ្ឋាភិបាលកាន់តែទទួលស្គាល់សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ជាកិច្ចការអាទិភាព ប៉ុន្តែការដាក់បញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម គឺនៅមានកម្រិត មិនទាន់ស៊ីសង្វាក់គ្នានៅឡើយ។ គោលនយោបាយនានាដូចជា គោលនយោបាយ និងផែនការសកម្មភាពស្តីពីសមភាពយេនឌ័រ និងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព បានផ្តល់ក្របខណ្ឌផ្សេងៗ ប៉ុន្តែការអនុវត្តនៅមានលក្ខណៈមិនប្រមូលផ្តុំ និងជារឿយៗ ខ្វះខាតធនធានគាំទ្រ។

**សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ត្រូវបានដាក់បញ្ចូលទៅក្នុងក្របខណ្ឌគោលនយោបាយ ប៉ុន្តែការអនុវត្តជាក់ស្តែងនៅខ្សោយ។**

ខណៈដែលក្រសួងនានាបានលើកឡើងពីអាទិភាពសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ការអនុវត្តច្រើនតែធ្វើឡើងដាច់ដោយឡែកពីគ្នា។ ភាគច្រើន ការដាក់បញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម អាស្រ័យលើនាយកដ្ឋានជាក់លាក់ ឬការគាំទ្រពីខាងក្រៅ ជាជាងការត្រូវបានដាក់បញ្ចូលជាប្រព័ន្ធទៅក្នុងប្រព័ន្ធផែនការ ប្រព័ន្ធរៀបចំថវិកា និងប្រព័ន្ធត្រួតពិនិត្យ។

**ការបញ្ជ្រាបយេនឌ័រមានភាពល្អប្រសើរជាងបរិយាបន្នទូទៅ។**

ការដាក់បញ្ចូលសមភាពយេនឌ័រ ធ្វើបានល្អគួរសម ជាពិសេសតាមរយៈយន្តការ និងអាណត្តិដែលបានបង្កើតឡើងរួចជាស្រេច។ ទោះជាយ៉ាងណា ការងារនេះច្រើនតែត្រូវបានអនុវត្តក្នុងទម្រង់ជាការអនុលោមតាមកាតព្វកិច្ច ដោយមិនសូវមានការយកចិត្តទុកដាក់លើការផ្លាស់ប្តូរចនាសម្ព័ន្ធស៊ីជម្រៅ ឬឥទ្ធិពលលើការធ្វើសេចក្តីសម្រេចចិត្ត។ បច្ចុប្បន្ន ស្ត្រីមានតំណាងកាន់តែច្រើននៅក្នុងរចនាសម្ព័ន្ធរដ្ឋាភិបាល ប៉ុន្តែតួនាទីជាអ្នកដឹកនាំគឺនៅមានកម្រិត។ ជារឿយៗ ការដាក់បញ្ចូលយេនឌ័រត្រូវបានគេចាត់ទុកថាជាការបំពេញកាតព្វកិច្ច ជាជាងរបៀបវារៈសម្រាប់ការផ្លាស់ប្រែ។

**បរិយាបន្នពិការភាព នៅតែមានវឌ្ឍនភាពតិចតួច។**

ក្រសួងស្ថាប័ននៅតែជួបប្រទះការលំបាកទាក់ទងនឹងការបង្កភាពងាយស្រួល ការសម្របសម្រួល និងការអនុវត្ត។ កម្ពុជាមានគោលនយោបាយស្តីពីពិការភាព ប៉ុន្តែខ្វះយន្តការជាក់ស្តែងសម្រាប់ការអនុវត្ត ដែលធ្វើឱ្យជនមានពិការភាពត្រូវបានផាត់ចេញពីសេវា និងការធ្វើសេចក្តីសម្រេចចិត្ត។

**បរិយាបន្នសង្គម - តួអង្គថ្នាក់ក្រោមជាតិដើរតួនាទីយ៉ាងសំខាន់ ប៉ុន្តែមានសមត្ថភាពមិនគ្រប់គ្រាន់។**

ជនជាតិភាគតិច ប្រជាជនរស់នៅជនបទ និងយុវជន នៅតែមានតំណាងតិចតួចនៅក្នុងការពិភាក្សាគោលនយោបាយ។ រចនាសម្ព័ន្ធថ្នាក់ក្រោមជាតិ ដូចជា គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ បានផ្តល់ជាចំណុចចាប់ផ្តើមសម្រាប់ការជំរុញបរិយាបន្ន ប៉ុន្តែធនធានសមត្ថភាពបច្ចេកទេស និងសិទ្ធិអំណាចនៅមានកម្រិត បានត្រឹមរឹតត្បិតសមត្ថភាពរបស់អាជ្ញាធរថ្នាក់ក្រោមជាតិក្នុងការជះឥទ្ធិពលលើដំណើរការគោលនយោបាយ ឬធានាឱ្យមានការចូលរួមប្រកបដោយអត្ថន័យពីក្រុមជួបការលំបាក។

**អន្តរប្រសព្វ មិនត្រូវបានដោះស្រាយជាលក្ខណៈប្រព័ន្ធ។**

គោលនយោបាយកម្រគិតគូរដល់ទម្រង់នៃភាពងាយរងគ្រោះត្រួតគ្នាណាស់។ ហេតុនេះហើយទើបក្រុមគោលដៅ ដូចជាស្ត្រីជនជាតិដើមភាគតិចដែលមានពិការភាព ឬយុវជននៅជនបទ ភាគច្រើននៅតែត្រូវបានគេមើលរំលងនៅក្នុងការរៀបចំ និងអនុវត្តគោលនយោបាយ។

## ស្ថាប័នវិស័យស្រាវជ្រាវ៖ អ្នកស្រាវជ្រាវ និងស្ថាប័នស្រាវជ្រាវ

ស្ថាប័នរដ្ឋាភិបាលនៅកម្ពុជា បានបង្ហាញការប្តេជ្ញាចិត្តកាន់តែខ្លាំងចំពោះការដាក់បញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ដែលគាំទ្រដោយក្របខណ្ឌជាតិស្តីពីសមភាពយេនឌ័រ និងបរិយាបន្នពិការភាព។ ទោះជាយ៉ាងណា ការដាក់បញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ទៅក្នុងដំណើរការគោលនយោបាយ នៅតែមិនស៊ីសង្វាក់គ្នា និងជារឿយៗ មានត្រឹមការប្តេជ្ញាចិត្តជាផ្លូវការ ជាជាងការអនុវត្តជាក់ស្តែង។

| | |
|---|---|
| **សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ត្រូវបានគេទទួលស្គាល់ ប៉ុន្តែមិនត្រូវបានអនុវត្តជាប្រព័ន្ធទេ។** | ខណៈដែលគោលការណ៍សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ត្រូវបានគេទទួលស្គាល់ គេកម្រដាក់បញ្ចូលគោលការណ៍ទាំងនោះទៅក្នុងការរៀបចំការស្រាវជ្រាវ វិធីសាស្ត្រ ឬការអនុវត្តរបស់ស្ថាប័នណាស់។ |
| **នៅតែមានឧបសគ្គក្នុងអាជីពស្រាវជ្រាវ និងភាពជាអ្នកដឹកនាំ។** | អ្នកស្រាវជ្រាវជាស្ត្រីប្រឈមមុខនឹងឧបសគ្គ ដែលរារាំងដល់វឌ្ឍនភាពអាជីពការងារ ភាពជាអ្នកដឹកនាំ និងការទទួលបានការទទួលស្គាល់។ ភាពលំអៀងជាប្រព័ន្ធបានកម្រិតឥទ្ធិពលរបស់ពួកគេនៅក្នុងការកំណត់របៀបវារៈ និងការបង្កើតចំណេះដឹង។ |
| **បរិយាបន្នពិការភាពស្ទើរតែពុំមានវត្តមាននៅក្នុងប្រព័ន្ធស្រាវជ្រាវ។** | ជនមានពិការភាពភាគច្រើនមិនបានប្រកបអាជីពស្រាវជ្រាវ និងមិនត្រូវបានដាក់បញ្ចូលទៅក្នុងការអនុវត្តរបស់ស្ថាប័ន។ ការបង្កភាពងាយស្រួលដូចជាក្នុងការជ្រើសរើសបុគ្គលិក ការចូលរួម និងការផ្សព្វផ្សាយ នៅមានតិចតួចនៅឡើយ។ |
| **របៀបវារៈនៃការស្រាវជ្រាវ មិនបានឆ្លុះបញ្ចាំងពេញលេញពីភាពចម្រុះក្នុងសង្គមទេ។** | ជនជាតិភាគតិច ក្រុមស្រលាញ់ភេទដូចគ្នា និងសំឡេងពីជនបទ ត្រូវបានលើកឡើងតិចតួចនៅក្នុងរបៀបវារៈស្រាវជ្រាវ ជាហេតុនាំឱ្យការស្រាវជ្រាវផ្តល់នូវទិន្នន័យ ដែលមិនបានឆ្លុះបញ្ចាំងពេញលេញពីភាពចម្រុះរបស់កម្ពុជា។ |
| **អន្តរប្រសព្វ កម្រត្រូវបានដាក់បញ្ចូលទៅក្នុងការវិភាគ។** | ការស្រាវជ្រាវហាក់ពិចារណាដាច់ដោយឡែកពីគ្នាលើធាតុផ្សំនីមួយៗនៃសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ដែលធ្វើឱ្យមានការយល់ដឹងតិចតួចអំពីភាពងាយរងគ្រោះដែលត្រួតគ្នា។ ដូច្នេះ ទិន្នន័យអាចមើលរំលងក្រុមជួបការលំបាកទាំងនេះ។ |
| **ឧបសគ្គផ្នែករចនាសម្ព័ន្ធបានរឹតត្បិតវឌ្ឍនភាព។** | ភាពមានកម្រិតនៃការផ្តល់មូលនិធិ កង្វះឧបករណ៍អនុវត្តន៍ និងកង្វះការលើកទឹកចិត្តកម្រិតស្ថាប័ន បានរាំងស្ទះដល់សមត្ថភាពរបស់អង្គការស្ថាប័នក្នុងការដាក់បញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ឱ្យកាន់តែស៊ីជម្រៅ។ បើគ្មានស្តង់ដារច្បាស់លាស់ ឬយន្តការគណនេយ្យភាពទេ ការប្តេជ្ញាចិត្តនឹងនៅតែមិនស៊ីសង្វាក់គ្នា។ |

# សហគមន៍ និងសង្គមស៊ីវិល

ទស្សនៈរបស់សហគមន៍បានគូសបញ្ជាក់ថា ការចូលរួមនៅតែប្រឈមនឹងឧបសគ្គយ៉ាងច្រើន ជាពិសេសសម្រាប់អ្នកដែលប្រឈមមុខនឹងទម្រង់ជាច្រើននៃភាពងាយរងគ្រោះក្នុងពេលតែមួយ។ ទោះបីជាមានឱកាសចូលរួម ប៉ុន្តែឱកាសទាំងនេះច្រើនតែមានតិចតួច និងមិនសូវមានឥទ្ធិពល។

**ស្ត្រីប្រឈមមុខនឹងឧបសគ្គផ្នែកវេទនាសម្ព័ន្ធ និងសង្គម ដែលរារាំងដល់ការចូលរួមរបស់ពួកគេ។**

ការចូលរួមរបស់ស្ត្រីត្រូវបានរឹតត្បិតដោយបទដ្ឋានសង្គម ភារៈថែទាំគ្រួសារ និងការទទួលបានព័ត៌មានតិចតួច។ សូម្បីតែនៅពេលចូលរួមក្នុងការពិគ្រោះយោបល់ ក៏ជារឿយៗ សម្លេងស្ត្រីក៏មិនសូវមានការជះឥទ្ធិពលលើការសម្រេចចិត្តដែរ។

**ជនមានពិការភាពជួបប្រទះការផាត់ចេញជាប្រព័ន្ធ។**

អ្នកចូលរួមបានរាយការណ៍ពីមជ្ឈដ្ឋាន ដែលមិនបង្កភាពងាយស្រួលចេញចូល ឧបសគ្គក្នុងការប្រាស្រ័យទាក់ទង និងការរើសអើងដែលនៅតែបន្តកើតមានឡើង។ កត្តាទាំងនេះបានរឹតត្បិតការចូលរួម ទាំងក្នុងសកម្មភាពស្រាវជ្រាវ និងការពិភាក្សាគោលនយោបាយ ជាហេតុធ្វើឱ្យអាទិភាពរបស់ជនមានពិការភាពត្រូវបានគេមើលរំលង។

**ក្រុមងាយរងគ្រោះ នៅតែមានតំណាងតិចតួចនៅក្នុងដំណើរការគោលនយោបាយ។**

សហគមន៍ជនជាតិដើមភាគតិច ជនជាតិភាគតិច ក្រុមស្រលាញ់ភេទដូចគ្នា និងប្រជាជននៅជនបទ បានរាយការណ៍ថា ពួកគេមានឱកាសតិចតួចក្នុងការចូលរួមឱ្យបានពេញលេញ ហើយឧបសគ្គផ្នែកភាសា តំបន់ភូមិសាស្ត្រដាច់ស្រយាល និងការរើសអើង រឹតតែបង្អាក់ការចូលរួម។

**ឧបសគ្គនៃអន្តរប្រសព្វ នៅតែមិនសូវទទួលបានការយកចិត្តទុកដាក់។**

ក្រុមដែលប្រឈមមុខនឹងការអន្តរប្រសព្វ ដូចជា ស្ត្រីជនជាតិដើមភាគតិចដែលមានពិការភាព ជួបប្រទះការផាត់ចេញដ៏ស្មុគស្មាញ។ ការពិតទាំងនេះកម្រត្រូវបានស្តែងចេញនៅក្នុងដំណើរការផ្លូវការ ឬការឆ្លើយតបគោលនយោបាយណាស់។

**អង្គការសហគមន៍មូលដ្ឋានបានផ្តល់នូវចំណុចចាប់ផ្តើម/ច្រកចូលដ៏សំខាន់។**

អង្គការតាមមូលដ្ឋាន និងអង្គការតំណាងជនមានពិការភាព ដើរតួនាទីយ៉ាងសំខាន់ក្នុងការបន្លឺសំឡេងរបស់ពួកគេ។ ទោះជាយ៉ាងណា ការចូលរួមរបស់ពួកគេជាមួយស្ថាប័នស្រាវជ្រាវ និងជាមួយអ្នកតាក់តែងគោលនយោបាយ គឺនៅមានកម្រិត និងជារឿយៗ ធ្វើឡើងទៅតាមគម្រោងជាក់លាក់ប៉ុណ្ណោះ។

# អនុសាសន៍

## សម្រាប់ក្រសួងស្ថាប័នរដ្ឋាភិបាល និងអាជ្ញាធរថ្នាក់ក្រោមជាតិ

**គាំទ្រការសម្របសម្រួលអន្តរក្រសួង ដោយពង្រឹងយន្តការដែលមានស្រាប់** ដើម្បីធានាថា អាទិភាពសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម (ក្រៅពីសមភាពយេនឌ័រ) មិនត្រូវបានដោះស្រាយដាច់ដោយឡែកពីគ្នានោះទេ ប៉ុន្តែត្រូវបានដាក់បញ្ចូលទៅក្នុងវិស័យគោលនយោបាយទាំងអស់។ ការងារនេះទាមទារទាំងកិច្ចសហការតាមខ្សែផ្តេកនៅកម្រិតថ្នាក់ជាតិ និងការផ្សារភ្ជាប់តាមខ្សែបញ្ឈរទៅកាន់អាជ្ញាធរថ្នាក់ក្រោមជាតិ។

**ធ្វើការវិភាគអន្តរប្រសព្វ នៅក្នុងការរៀបចំ និងការវាយតម្លៃគោលនយោបាយ** ដោយធានានូវការពិចារណាយ៉ាងជិតដល់លើអត្តសញ្ញាណត្រួតគ្នា ដូចជា ស្ត្រីជនជាតិដើមភាគតិចដែលមានពិការភាព នៅក្នុងការធ្វើផែនការ ការអនុវត្ត និងការត្រួតពិនិត្យ

---

**បញ្ជ្រាបសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម (ជាពិសេសបរិយាបន្នពិការភាព)** ទៅក្នុងប្រព័ន្ធរៀបចំថវិកា និងប្រព័ន្ធត្រួតពិនិត្យ ដើម្បីប្រែក្លាយការប្តេជ្ញាចិត្តទៅជាការបែងចែកធនធាន និងលទ្ធផលដែលអាចវាស់វែងបាន។ បើគ្មានការគាំទ្រផ្នែកហិរញ្ញវត្ថុ និងរចនាសម្ព័ន្ធគណនេយ្យភាពទេ សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម អាចនៅត្រឹមតែជាពាក្យសន្យា។

**ធ្វើស្ថាប័នូបនីយកម្មគណនេយ្យភាពសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម នៅក្នុងប្រព័ន្ធរដ្ឋាភិបាល** ដោយកំណត់អាណត្តិ ថវិកា និងខ្សែបណ្តាញរាយការណ៍ច្បាស់លាស់ដល់មន្ត្រីបង្គោលទទួលបន្ទុកយេនឌ័រ និងពិការភាព និងផ្សារភ្ជាប់ការអនុវត្តការងារផ្នែក សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ទៅនឹងដំណើរការធ្វើផែនការ និងវាយតម្លៃរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់។

---

**វិនិយោគលើសមត្ថភាពរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ (គ.ក.ន.ក.)** និងតួអង្គថ្នាក់ខេត្ត ដើម្បីអនុវត្តគោលនយោបាយប្រកបដោយបរិយាបន្ន។ ការបណ្តុះបណ្តាលធនធាន និងការគាំទ្រផ្នែកបច្ចេកទេស ជាតម្រូវការចាំបាច់ដើម្បីឈានហួសពីចេតនា និងធានាថា អាជ្ញាធរមូលដ្ឋានអាចឱ្យក្រុមជួបការលំបាកចូលរួមប្រកបដោយអត្ថន័យ។

**ដាក់បញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម (ជាពិសេសបរិយាបន្នពិការភាព)** ទៅក្នុងប្រព័ន្ធធ្វើផែនការ ប្រព័ន្ធរៀបចំថវិកា និងប្រព័ន្ធ ត្រួតពិនិត្យ ដើម្បីប្រែក្លាយការប្តេជ្ញាចិត្តទៅជាការបែងចែកធនធាន និងលទ្ធផលដែលអាចវាស់វែងបាន ជាជាងនៅត្រឹមជានីតិវិធី ឬជានិមិត្តរូប។

**ពង្រឹងស្តង់ដារនៃការពិគ្រោះយោបល់ប្រកបដោយបរិយាបន្ន និងបង្កភាពងាយស្រួល** ដោយដាក់ចេញលក្ខខណ្ឌតម្រូវការអប្បបរមាសម្រាប់ការបង្កភាពងាយស្រួល (ឧទាហរណ៍ លទ្ធភាពចេញចូលជាក់ស្តែង ការបកប្រែ ការដាក់អក្សររត់ពីក្រោម ឯកសារដែលបង្កភាពងាយស្រួល និងការគាំទ្រដល់ការចូលរួម) និងធានាថា ស្តង់ដារទាំងនេះត្រូវបានអនុវត្តយ៉ាងខ្ជាប់ខ្ជួននៅគ្រប់ក្រសួង និងដំណើរការថ្នាក់ក្រោមជាតិ។

---

**កែលម្អប្រព័ន្ធទិន្នន័យឱ្យច្បាមយក និងប្រើប្រាស់ទិន្នន័យមានលក្ខណៈអន្តរប្រសព្វ** រួមទាំងការបែងចែកទិន្នន័យឱ្យបានច្បាស់លាស់ (ភេទ ពិការភាព អាយុ ជាតិពន្ធុ ទីតាំង) និងឧបករណ៍ជាក់ស្តែង ដើម្បីអនុវត្តទិន្នន័យទាំងនេះនៅក្នុងការរៀបចំគោលនយោបាយ ការធ្វើផែនការ និងការរៀបចំថវិកា។

---

**ពង្រឹងការអនុវត្តនៅថ្នាក់ក្រោមជាតិ និងការទទួលយកមតិយោបល់** ដោយវិនិយោគលើសមត្ថភាពរបស់ គ.ក.ន.ក. និងតួអង្គថ្នាក់ខេត្ត និងធានាថា ទស្សនៈរបស់សហគមន៍ផ្តល់ជាតុចូលដល់ការធ្វើផែនការ និងត្រូវបានឆ្លុះបញ្ចាំងនៅក្នុងសេចក្តីសម្រេចនានា។

**អនុវត្តវិធីសាស្រ្តអន្តរប្រសព្វ នៅក្នុងការរៀបចំ និងការវាយតម្លៃគោលនយោបាយ** ដោយប្រើប្រាស់ឧបករណ៍ជាក់ស្តែង (ឧ. ការគូសផែនទីអ្នកពាក់ព័ន្ធ ការវិភាគផ្អែកលើលក្ខណៈបុគ្គល) ដើម្បីធានានូវការដោះស្រាយទម្រង់នៃភាពលំបាកត្រួតគ្នា។

## សម្រាប់ក្រសួងស្ថាប័នរដ្ឋាភិបាល និងអាជ្ញាធរថ្នាក់ក្រោមជាតិ

**កំណត់សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ជាស្តង់ដារគុណភាពចម្បងនៃការស្រាវជ្រាវ** មិនមែនជាលក្ខខណ្ឌតម្រូវរបស់ម្ចាស់ជំនួយនោះទេ ដោយបញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ទៅក្នុងគោលនយោបាយស្ថាប័ន លក្ខណៈវិនិច្ឆ័យមូលនិធិ និងប្រព័ន្ធអភិបាលកិច្ច និងដាក់បញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ទៅក្នុងវដ្តទាំងមូលនៃការស្រាវជ្រាវ តាមរយៈការជ្រើសរើសសំណាកប្រកបដោយបរិយាបន្ន វិធីសាស្ត្របែបចូលរួម ការបែងចែកទិន្នន័យជាប្រភេទ និងការវិភាគអន្តរប្រសព្វ។

---

**ពង្រឹងភាពជាម្ចាស់របស់ថ្នាក់ដឹកនាំ និងការលើកទឹកចិត្តកម្រិតស្ថាប័ន** ដោយតម្រូវឱ្យថ្នាក់គ្រប់គ្រងជាន់ខ្ពស់ផ្តល់ធនធាន និងផ្តោតអាទិភាពលើការអនុវត្តការស្រាវជ្រាវប្រកបដោយបរិយាបន្ន និងផ្សារភ្ជាប់ការអនុវត្តការងារផ្នែកសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ទៅនឹងប្រព័ន្ធរបស់ស្ថាប័ន។

---

**លើកកម្ពស់សមភាពយេនឌ័រក្នុងអាជីពស្រាវជ្រាវ** ដោយដោះស្រាយឧបសគ្គផ្នែករចនាសម្ព័ន្ធដែលរារាំងដល់ការរីកចម្រើនរបស់ស្ត្រី បង្កើតម៉ាគាសម្រាប់ការណែនាំ និងភាពជាអ្នកដឹកនាំ និងទទួលស្គាល់ជំនាញរបស់ស្ត្រី នៅក្នុងការកំណត់របៀបវារៈ និងការបង្កើតចំណេះដឹង។

---

**ជំរុញបរិយាបន្នពិការភាពក្នុងការអនុវត្តរបស់ស្ថាប័ន** ដោយបង្កើនការបង្កភាពងាយស្រួលនៅក្នុងការជ្រើសរើសបុគ្គលិក ការចូលរួម និងការផ្សព្វផ្សាយ។ ស្ថាប័នស្រាវជ្រាវគួរតែអនុវត្តបរិយាបន្នជាគំរូ ដោយផ្តល់ការសម្របសម្រួលដល់ជនមានពិការភាព ទាំងនៅក្នុងតួនាទីជាបុគ្គលិក និងដំណើរការស្រាវជ្រាវ។

**ធានាឱ្យមានជាតំណាងរបស់ក្រុមដែលត្រូវបានផាត់ចេញនៅក្នុងរបៀបវារៈនៃការស្រាវជ្រាវ** តាមរយៈការដាក់បញ្ចូលត្រៀមជាស្រេចនូវវត្តមានរបស់ជនជាតិភាគតិច ក្រុមស្រឡាញ់ភេទដូចគ្នា និងសំឡេងពីជនបទ។ ការងារនេះទាមទារឱ្យមានការផ្លាស់ប្តូរពីការដាក់បញ្ចូលត្រឹមតែជានិមិត្តរូប ទៅជាការចូលរួមមួយដ៏ពិតប្រាកដក្នុងការកំណត់អាទិភាពនៃការស្រាវជ្រាវ។

---

**ដោះស្រាយឧបសគ្គផ្នែករចនាសម្ព័ន្ធនៅក្នុងអាជីពស្រាវជ្រាវ** ជាពិសេសសម្រាប់ស្ត្រី និងក្រុមដែលត្រូវបានផាត់ចេញ តាមរយៈការណែនាំ គន្លងឆ្ពោះទៅរកភាពជាអ្នកដឹកនាំ ការទទួលស្គាល់ និងការបែងចែកបន្ទុកការងារឱ្យកាន់តែមានសមធម៌។

---

**ពង្រីកភាពជាតំណាងនៅក្នុងរបៀបវារៈស្រាវជ្រាវ** ដោយចាប់ដៃគូជាមួយអង្គការតំណាងជនមានពិការភាព អង្គការតាមមូលដ្ឋាន និងស្ថាប័នក្នុងស្រុក ដើម្បីសហការរៀបចំការស្រាវជ្រាវ ដែលឆ្លុះបញ្ចាំងពីទស្សនៈចម្រុះ និងទស្សនៈដែលមិនសូវមានភាពតំណាង។

---

**វិនិយោគលើសមត្ថភាព និងឧបករណ៍ជាក់ស្តែង សម្រាប់ការស្រាវជ្រាវប្រកបដោយបរិយាបន្ន** រួមទាំងការបណ្តុះបណ្តាល ការរៀនសូត្រពីគ្នា និងទម្រង់ឯកសារដែលបង្កភាពងាយស្រួល (ភាសាសាមញ្ញ រូបភាព សំឡេង និងលទ្ធផលពហុភាសា)។

## សម្រាប់សហគមន៍ និងសង្គមស៊ីវិល

**ផ្លាស់ប្តូរពីការពិគ្រោះយោបល់ ទៅជាការចូលរួម** និងការសហការរៀបចំប្រកបដោយអត្ថន័យ ដោយដាក់បញ្ចូលតំណាងសហគមន៍ និងអង្គការតំណាងជនមានពិការភាពនៅក្នុងដំណើរការស្រាវជ្រាវ និងដំណើរការគោលនយោបាយ រួមទាំងការកំណត់របៀបវារៈ ការបកស្រាយទិន្នន័យ និងការធ្វើសេចក្តីសម្រេចចិត្ត។

**កាត់បន្ថយឧបសគ្គជាក់ស្តែង និងឧបសគ្គផ្នែករចនាសម្ព័ន្ធដែលរារាំងដល់ការចូលរួម** ដោយផ្តល់ការឧបត្ថម្ភគាំទ្រដល់ការធ្វើដំណើរ ការបកប្រែឯកសារ ការបកប្រែភាសាសញ្ញា ឯកសារដែលបង្កភាពងាយស្រួល និងវិធីសាស្ត្រទាក់ទាញការចូលរួម ដែលសមស្របតាមវប្បធម៌។

**ពង្រឹងសមត្ថភាពរបស់អង្គការតំណាងជនមានពិការភាព និងអង្គការសហគមន៍មូលដ្ឋាន** ដើម្បីចូលរួមក្នុងដំណើរការស្រាវជ្រាវ និងដំណើរការគោលនយោបាយ រួមទាំងជំនាញក្នុងការប្រើប្រាស់ទិន្នន័យ ការចូលរួមក្នុងគោលនយោបាយ និងការតស៊ូមតិប្រកបដោយសុវត្ថិភាព។

**ពង្រឹងយន្តការកម្រិតសហគមន៍សម្រាប់បរិយាបន្នពិការភាព** ដោយធានាថា ជនមានពិការភាពមិនត្រឹមតែត្រូវបានពិគ្រោះយោបល់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងចូលរួមយ៉ាងសកម្មក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងការត្រួតពិនិត្យគំនិតផ្តួចផ្តើមនៅមូលដ្ឋានផងដែរ។

**បង្កើតយន្តការទទួលមតិយោបល់ត្រឡប់ និងយន្តការគណនេយ្យភាពច្បាស់លាស់** ដើម្បីធានាការឆ្លុះបញ្ចាំងធាតុចូលរបស់សហគមន៍នៅក្នុងសេចក្តីសម្រេចចិត្ត ដែលជួយពង្រឹងទំនុកចិត្ត និងការចូលរួមជាប់លាប់។

**កសាងសម្ព័ន្ធភាពរវាងអង្គការកម្រិតមូលដ្ឋាន និងស្ថាប័នស្រាវជ្រាវ** ដើម្បីបន្លឺសំឡេងចម្រុះ។ ភាពជាដៃគូអាចលុបបំបាត់គម្លាតរវាងបទពិសោធន៍ជីវិតជាក់ស្តែង និងទិន្នន័យស្ថាប័នដើម្បីធានាថា ទស្សនៈរបស់សហគមន៍ផ្តល់ជាធាតុចូលដល់ការពិភាក្សាគោលនយោបាយថ្នាក់ជាតិ។

# សេចក្តីសន្និដ្ឋាន

ប្រទេសកម្ពុជាសម្រេចបានវឌ្ឍនភាពពាក់ព័ន្ធនឹងគោលបំណងនៃគោលនយោបាយសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ប៉ុន្តែនៅតែមានចំណុចខ្វះខាតធំៗ នៅក្នុងការអនុវត្តជាក់ស្តែង។ ស្ថាប័នរដ្ឋាភិបាល ស្ថាប័នស្រាវជ្រាវ និងសហគមន៍ សុទ្ធតែប្រឈមការលំបាកក្នុងការដាក់បញ្ជ្រាបសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ជាពិសេសក្នុងការដោះស្រាយបញ្ហាអន្តរប្រសព្វ។

ការពង្រឹង សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម នៅក្នុងដំណើការទាំងមូលនៃការប្រែក្លាយទិន្នន័យទៅជាគោលនយោបាយ គឺជារឿងចាំបាច់សម្រាប់ភាពស្របច្បាប់ និងប្រសិទ្ធភាពក្នុងការតាក់តែងគោលនយោបាយ។ ការបង្កើតចំណេះដឹងប្រកបដោយបរិយាបន្ន ត្រូវធានាបានថា ទស្សនៈចម្រុះផ្តល់ជាតុចូលដល់ការសម្រេចចិត្ត ដែលធ្វើឱ្យគោលនយោបាយកាន់តែឆ្លើយតបនឹងតម្រូវការ និងមានសមធម៌។

ការវិភាគនេះអំពាវនាវឱ្យមានវិធីសាស្ត្រជាប្រព័ន្ធ ដែលមានការសម្របសម្រួល និងអន្តរប្រសព្វ សម្រាប់ការដាក់បញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ឱ្យចាក់គ្រឹះរឹងមាំនៅក្នុងកំណែទម្រង់ស្ថាប័ន ការអនុវត្តការស្រាវជ្រាវ និងការចូលរួមរបស់សហគមន៍។ តាមរយៈការដាក់បញ្ចូលគោលការណ៍សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ទៅក្នុងប្រព័ន្ធអេកូឡូស៊ីនៃការស្រាវជ្រាវនៅកម្ពុជា កម្មវិធីពន្លកចំណេះ ដំណាក់កាលទី២ និងដៃគូរបស់ខ្លួន អាចជួយផ្លាស់ប្តូរដំណើរការគោលនយោបាយឱ្យទៅជាវេទិកាប្រកបដោយបរិយាបន្នយ៉ាងពិតប្រាកដ ដែលឆ្លុះបញ្ចាំងពីតថភាព និងបំណងប្រាថ្នារបស់ប្រជាពលរដ្ឋគ្រប់រូប។




# ០១

# សេចក្ដីផ្ដើម




ការវិភាគស្តីពីសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គមនេះ ពិនិត្យមើលថាតើចលនការនៃ សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ជះឥទ្ធិពលដូចម្តេចលើការចូលរួមក្នុងប្រព័ន្ធអេកូឡូស៊ីនៃការស្រាវជ្រាវ និងគោលនយោបាយនៅកម្ពុជា។ របាយការណ៍នេះផ្តល់នូវការវាយតម្លៃរួមបញ្ចូលគ្នាអំពីអ្នកដែលបានចូលរួមក្នុងការបង្កើតចំណេះដឹង អ្នកដែលនៅតែត្រូវបានគេផាត់ចេញ ព្រមទាំងកត្តារចនាសម្ព័ន្ធ និងកត្តាស្ថាប័ន ដែលជំរុញឱ្យមានលំនាំទាំងនេះ។ គោលបំណងនៃរបាយការណ៍នេះ គឺផ្តល់ការយល់ដឹងច្បាស់លាស់ និងផ្អែកលើទិន្នន័យអំពីឧបសគ្គទាំងនេះ និងកំណត់នូវចំណុចចាប់ផ្តើមជាក់ស្តែងសម្រាប់ការពង្រឹងបរិយាបន្នក្នុងវិស័យស្រាវជ្រាវនៅកម្ពុជា។

ការងារនេះស្ថិតក្រោមកម្មវិធីពន្លកចំណេះដំណាក់កាលទី២៖ ទិន្នន័យ និងការពិភាក្សាដើម្បីការអភិវឌ្ឍនៅកម្ពុជា (កម្មវិធីពន្លកចំណេះដំណាក់កាលទី២) ដោយមានការគាំទ្រពីរដ្ឋាភិបាលអូស្ត្រាលី។ កម្មវិធីនេះខិតខំពង្រឹងការតាក់តែងគោលនយោបាយ ដែលផ្អែកលើទិន្នន័យ និងប្រកបដោយបរិយាបន្ន តាមរយៈការធ្វើឱ្យប្រសើរជាងមុននូវរបៀបដែលចំណេះដឹងត្រូវបានបង្កើតឡើង ផ្សព្វផ្សាយ និងប្រើប្រាស់ក្នុងដំណើរការគោលនយោបាយសាធារណៈ។ ក្នុងនោះ ការពិចារណាលើ សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម គឺជាចំណុចស្នូលនៃគោលដៅនេះ។ នៅពេលដែលស្ត្រី ជនមានពិការភាព យុវជន ក្រុមស្រឡាញ់ភេទដូចគ្នា និងក្រុមដែលត្រូវបានផាត់ចេញផ្សេងទៀត ប្រឈមនឹងការរឹតត្បិតក្នុងការទទួលបានឱកាសស្រាវជ្រាវ ឬឱកាសចូលរួមក្នុងគោលនយោបាយ ទស្សនៈ និងបទពិសោធន៍ជីវិតជាក់ស្តែងរបស់ពួកគេ ច្រើនតែមិនត្រូវបានដាក់បញ្ចូលទៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត ហើយជាលទ្ធផលវិស័យស្រាវជ្រាវអាចនឹងពង្រីក ជាជាងលុបបំបាត់គម្លាតដែលមានស្រាប់។

បរិយាបន្ននៅក្នុងដំណើរការស្រាវជ្រាវ និងដំណើរការគោលនយោបាយ មិនមានន័យត្រឹមតែភាពជាតំណាងនោះទេ ប៉ុន្តែវាក៏ជះឥទ្ធិពលផងដែរទៅលើអ្នកដែលកំណត់របៀបវារៈនៃការស្រាវជ្រាវ អ្នកដែលត្រូវបានគេចាត់ទុកថាមានចំណេះដឹងគួរឱ្យទុកចិត្ត អ្នកដែលអាចចូលរួមប្រកបដោយអត្ថន័យនៅក្នុងការស្រាវជ្រាវ និងការពិភាក្សា អ្នកដែលមានសំឡេងអាចជះឥទ្ធិពលដល់ការសម្រេចចិត្ត និងរបៀបដែលទិន្នន័យត្រូវបានផ្សព្វផ្សាយ និងទទួលយកទៅអនុវត្តក្នុងដំណើរការគោលនយោបាយ។[1] កង្វះភាពចម្រុះនៅក្នុងស្ថាប័នស្រាវជ្រាវ បណ្តាញសិក្សា និងអង្គការសង្គមស៊ីវិល ដែលធ្វើឱ្យប៉ះពាល់ដល់គុណភាព និងភាពពាក់ព័ន្ធនៃទិន្នន័យដែលបានបង្កើតឡើង។ ដូច្នេះ ការពង្រឹងសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម នៅក្នុងដំណើរការទាំងមូលនៃការប្រែក្លាយទិន្នន័យទៅជាគោលនយោបាយ គឺជារឿងចាំបាច់សម្រាប់ការធ្វើឱ្យប្រសើរឡើងទាំងភាពស្របច្បាប់ និងប្រសិទ្ធភាពនៃគោលនយោបាយសាធារណៈនៅក្នុងគ្រប់បរិបទទាំងអស់ រួមទាំងកម្ពុជាផងដែរ។

ទោះបីជាការវិភាគនេះផ្អែកលើមេរៀនដែលទទួលបានពីកម្មវិធីពន្លកចំណេះដំណាក់កាលទី២ ប៉ុន្តែវាក៏មានអនុភាពគ្របដណ្តប់លើសពីកម្មវិធីមួយនេះផងដែរ។ លទ្ធផលទាំងនេះឆ្លើយតបដោយផ្ទាល់ទៅនឹងអាទិភាពទូលំទូលាយរបស់រដ្ឋាភិបាលលើកំណែទម្រង់រដ្ឋបាលសាធារណៈ វិមជ្ឈការសមភាពយេនឌ័រ បរិយាបន្នពិការភាព និងការតាក់តែងគោលនយោបាយផ្អែកលើទិន្នន័យ។ គំនិតផ្តួចផ្តើមដែលកំពុងដំណើរការ ដូចជា ការអនុវត្តគោលនយោបាយ និងផែនការសកម្មភាពស្តីពីសមភាពយេនឌ័រ ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម និងកិច្ចខិតខំប្រឹងប្រែងពង្រឹងការស្រាវជ្រាវគោលនយោបាយ និងប្រព័ន្ធទិន្នន័យ សុទ្ធតែពឹងផ្អែកលើទិន្នន័យដែលគួរឱ្យទុកចិត្ត និងប្រកបដោយបរិយាបន្ន។ គម្លាតដែលបន្តលេចឡើង រវាងគោលបំណងនៃគោលនយោបាយ និងការអនុវត្តជាក់ស្តែង បានគូសបញ្ជាក់ពីភាពចាំបាច់នៃការដាក់បញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ឱ្យចាក់ឫសជ្រៅទៅក្នុងរបៀបដែលការស្រាវជ្រាវត្រូវបានចាត់តាំងឱ្យអនុវត្ត បង្កើតឡើង និងប្រើប្រាស់។ ដូច្នេះ ការដោះស្រាយគម្លាតទាំងនេះ មិនមែនជាក្តីកង្វល់សម្រាប់តែកម្មវិធីណាមួយនោះទេ ប៉ុន្តែជាបញ្ហាជាប្រព័ន្ធដែលប៉ះពាល់ដល់គុណភាព ភាពពាក់ព័ន្ធ និងភាពស្របច្បាប់នៃការសម្រេចចិត្តលើគោលនយោបាយនៅក្នុងវិស័យនានា។

គោលបំណងនៃការសិក្សានេះគឺដើម្បីស្វែងយល់ និងវិភាគអំពីបរិយាបន្ននៅក្នុងវិស័យស្រាវជ្រាវ និងដើម្បីកំណត់មធ្យោបាយជាក់ស្តែងសម្រាប់ពង្រឹងការចូលរួម។ ការសិក្សានេះ៖

- វិភាគអំពីឧបសគ្គ ឱកាស និងតម្រូវការជាក់លាក់របស់ស្ត្រី ជនមានពិការភាព និងក្រុមផ្សេងទៀតដែលជួបការលំបាកក្នុងសង្គមក្នុងការចូលរួមជាមួយដំណើរការស្រាវជ្រាវ និងដំណើរការគោលនយោបាយ

- កំណត់យុទ្ធសាស្ត្រសម្រាប់ការដាក់បញ្ចូលគោលការណ៍សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ឱ្យកាន់តែមានប្រសិទ្ធភាពទៅក្នុងវិស័យស្រាវជ្រាវនៅកម្ពុជា

- កំណត់សកម្មភាពជាក់ស្តែង ដែលស្ថាប័ន និងបណ្តាញនានា អាចយកទៅអនុវត្តដើម្បីពង្រឹងបរិយាបន្ន។

នៅកម្ពុជា ការប៉ាន់ប្រមាណយេនឌ័រ ការសិក្សាអំពីពិការភាព និងការវិភាគបរិយាបន្នសង្គម ត្រូវបានធ្វើឡើងជាច្រើនមកហើយ។ អ្វីដែលការវិភាគសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គមនេះបំពេញបន្ថែម គឺទស្សនៈបែបគុណវិស័យនៅកម្រិតប្រព័ន្ធ ស្តីពីរបៀបថាតើបរិយាបន្នដំណើរការដូចម្តេចនៅក្នុងប្រព័ន្ធអេកូឡូស៊ីទាំងមូលនៃការស្រាវជ្រាវឆ្ពោះទៅគោលនយោបាយ។ ជំនួសឱ្យការវាយតម្លៃលទ្ធផលតែនៅក្នុងវិស័យ ឬក្រុមប្រជាជនណាមួយ ការវិភាគនេះពិនិត្យមើលថាតើអំណាច ការចូលរួម និងភាពគួរឱ្យជឿទុកចិត្ត ត្រូវបានតម្រឹមតម្រង់ដូចម្តេចនៅក្នុងស្ថាប័ន ការស្រាវជ្រាវ និងការអនុវត្ត។ តាមរយៈការផ្តោតសំខាន់ទាំងលើបទពិសោធន៍ជីវិតជាក់ស្តែង

[1] UN Women (2018). Turning promises into action: Gender equality in the 2030 Agenda for Sustainable Development.

និងការអនុវត្តរបស់ស្ថាប័ន ការវិភាគនេះលាតត្រដាងនូវចំណុចខ្វះចន្លោះ ដែលជារឿយៗ ត្រូវបានគេមើលរំលងនៅក្នុងការសិក្សាបែបបរិមាណឬការវាយតម្លៃតាមមូលបទដាច់ដោយឡែក ជាពិសេសជុំវិញការកំណត់របៀបវារៈ សំឡេង និងឥទ្ធិពលនៅក្នុងការបង្កើត និងប្រើប្រាស់ទិន្នន័យ។

ការវិភាគនេះទាញយកទិន្នន័យពីប្រតិចារិកនៃការពិគ្រោះយោបល់ កំណត់ហេតុបទសម្ភាសន៍ និងឯកសារផ្សេងទៀត ដែលប្រមែប្រមូលដោយកម្មវិធីពន្លកចំណេះដំណាក់កាលទី២ រួមជាមួយនឹងការតាមដានបន្តចំគោលដៅ ក្នុងករណីចាំបាច់។ ការរៀបរាប់ដោយផ្ទាល់របស់អ្នកចូលរួមអំពីការប្រឡូកក្នុងវិស័យសិក្សា តួនាទីស្រាវជ្រាវ និងវេទិកាពិភាក្សាគោលនយោបាយ បានផ្តល់នូវការយល់ដឹងដ៏មានតម្លៃអំពីឧបសគ្គជាប្រព័ន្ធ និងឱកាសថ្មីៗកំពុងកើតមាន។

ការវិភាគនេះក៏ពិនិត្យមើលផងដែរលើស្នូលនៃឧបសគ្គធំៗ ដែលរារាំងការដាក់បញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ទៅក្នុងស្ថាប័នរដ្ឋាភិបាល អាជីពស្រាវជ្រាវ ការអនុវត្តរបស់ស្ថាប័ន ការផ្សព្វផ្សាយ និងការចូលរួមក្នុងគោលនយោបាយ។ ការវិភាគនេះរំលេចឱ្យឃើញភាពងាយរងគ្រោះ/ការលំបាក ដែលបណ្តាលមកពីកត្តាអន្តរប្រសព្វ ដែលជះឥទ្ធិពលលើការទទួលបានឱកាស និងឥទ្ធិពល ព្រមទាំងគូសផែនទីបង្ហាញពីកត្តាដែលជំរុញឱ្យមានការផាត់ចេញដោយស្ថាប័ន។

ការវិភាគនេះគឺសម្រាប់ជាប្រយោជន៍ដល់តួអង្គផ្សេងៗ ដែលពាក់ព័ន្ធនៅក្នុងប្រព័ន្ធអេកូឡូស៊ីនៃវិស័យស្រាវជ្រាវ និងគោលនយោបាយនៅកម្ពុជា។ អ្នកទទួលផលចម្បងពីការវិភាគនេះ រួមមានគ្រឹះស្ថានស្រាវជ្រាវ សាកលវិទ្យាល័យ ស្ថាប័នស្រាវជ្រាវ និងស្ថាប័នthink tanks អង្គការសង្គមស៊ីវិល និងបណ្តាញដែលចូលរួមក្នុងការបង្កើតទិន្នន័យ និងការពិភាក្សាគោលនយោបាយ ព្រមទាំងស្ថាប័នរដ្ឋាភិបាល ដែលពឹងផ្អែកលើការស្រាវជ្រាវសម្រាប់ជាមូលដ្ឋានដល់ការសម្រេចចិត្តលើគោលនយោបាយ។ ការវិភាគនេះក៏មានប្រយោជន៍ផងដែរសម្រាប់ដៃគូអភិវឌ្ឍន៍ និងកម្មវិធីនានា ដែលគាំទ្រដល់អភិបាលកិច្ច ការស្រាវជ្រាវ និងបរិយាបន្នសង្គម។ ទោះបីមានមូលដ្ឋានពីកម្មវិធីពន្លកចំណេះដំណាក់កាលទី២ ប៉ុន្តែលទ្ធផល និងអនុសាសន៍ទាំងនេះមានភាពពាក់ព័ន្ធសម្រាប់តួអង្គជាច្រើន ដែលកំពុងខិតខំពង្រឹងបរិយាបន្ននៅក្នុងប្រព័ន្ធអេកូឡូស៊ីចំណេះដឹងរបស់កម្ពុជា។

## ផ្នែកផ្សេងៗនៃរបាយការណ៍នេះ





# ០២

# ការរៀបចំការស្រាវជ្រាវ វិធីសាស្ត្រ និងក្របខណ្ឌវិភាគ



ការវិភាគនេះត្រូវបានរៀបចំឡើងជាសំនួរបែបគុណវិស័យដោយមានការចូលរួម លើរបៀបដែលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ដំណើរការនៅក្នុងប្រព័ន្ធអេកូឡូស៊ីនៃវិស័យស្រាវជ្រាវ និងគោលនយោបាយរបស់កម្ពុជា។ តាំងពីដើមដំបូងមក ការស្រាវជ្រាវនេះបានផ្តោតអាទិភាពលើភាពគួរឱ្យជឿទុកចិត្ត ការបង្កភាពងាយស្រួល និងបរិយាបន្ន ទាំងក្នុងការរៀបចំ និងការអនុវត្ត។ ឧបករណ៍ប្រមូលទិន្នន័យត្រូវបានរៀបចំឡើងជាភាសាខ្មែរ ការចុះប្រមូលទិន្នន័យនៅមូលដ្ឋានត្រូវបានអនុវត្តដោយអ្នកសម្ភាសន៍ដែលបានឆ្លងកាត់ការបណ្តុះបណ្តាល និងជ្រើសរើសចេញពីអង្គការដៃគូរបស់កម្មវិធីពន្លកចំណេះដំណាក់កាលទី២ ដែលស៊ាំនឹងបរិបទ និងភាសា ហើយជំហានផ្ទៀងផ្ទាត់ជាច្រើនត្រូវបានដាក់បញ្ចូលទៅក្នុងដំណើរការនេះ ដើម្បីសាកល្បងការបកស្រាយ និងពង្រឹងភាពជឿជាក់បាន។ ការធ្វើដូច្នេះ គឺដើម្បីធានាថាទិន្នន័យឆ្លុះបញ្ចាំងតថភាពជីវិតជាក់ស្តែងឱ្យបានច្បាស់លាស់បំផុតតាមដែលអាចធ្វើទៅបាន ហើយទន្ទឹមនឹងនោះ បំពេញតាមស្តង់ដារដែលមានការទទួលស្គាល់ សម្រាប់ការស្រាវជ្រាវបែបគុណវិស័យ។

វិធីសាស្ត្រស្រាវជ្រាវរួមបញ្ចូលគ្នានូវទិន្នន័យបឋមបែបគុណវិស័យ ការពិនិត្យឯកសារបន្ទាប់បន្សំតាមគោលដៅ និងក្របខណ្ឌវិភាគយ៉ាងស៊ីសង្វាក់គ្នា ដែលផ្អែកលើគោលការណ៍សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម។ ជំនួសឱ្យការចាត់ទុកការចូលរួមគ្រាន់តែជាលទ្ធផលនៅចុងបញ្ចប់ ការសិក្សានេះបានបញ្ជ្រាបការអនុវត្តបែបចូលរួមទៅក្នុងដំណើរការស្រាវជ្រាវទាំងមូល ចាប់ពីការជ្រើសរើសអ្នកឆ្លើយតប និងការរៀបចំឧបករណ៍ រហូតដល់ការបកស្រាយទិន្នន័យ។ វិធីសាស្ត្រនេះមិនត្រឹមតែអនុញ្ញាតឱ្យអ្នកឆ្លើយតប ចែករំលែកបទពិសោធន៍របស់ពួកគេប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយតម្រឹមតម្រង់របៀបនៃការយល់ដឹងអំពី បរិយាបន្ន ការផាត់ចេញ និងឥទ្ធិពល នៅក្នុងដំណើរការស្រាវជ្រាវ និងដំណើរការគោលនយោបាយផងដែរ។ គោលដៅគឺដើម្បីច្បាមយកទាំងចលនការក្នុងស្ថាប័ន និងបទពិសោធន៍ជីវិតជាក់ស្តែង និងនាំយកទស្សនៈទាំងនេះទៅដាក់បញ្ចូលគ្នាតាមរបៀបមួយ ដែលអាចផ្តល់ជាតុចូលដល់សកម្មភាពជាក់ស្តែងសម្រាប់កម្មវិធីពន្លកចំណេះដំណាក់កាលទី២ និងវិស័យស្រាវជ្រាវទាំងមូល។

## ២.១. ការរៀបចំការស្រាវជ្រាវ

វិធីសាស្ត្រនេះឆ្លុះបញ្ចាំងការពិចារណាចំនួនបី ដែលតម្រឹមតម្រង់ការរៀបចំការស្រាវជ្រាវជារួម។ ទីមួយ សហគមន៍ស្រាវជ្រាវ និងសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម នៅកម្ពុជាមានទំហំតូច ដែលអាចឱ្យក្រុមការងារមានលទ្ធភាពពេញលេញក្នុងការទាក់ទងទៅកាន់វិទ្យាស្ថានស្រាវជ្រាវ បណ្ដាញ និងអ្នកអនុវត្តន៍។ ទីពីរ ការសិក្សានេះបានខិតខំស្វែងរកក្រុមដែលសំឡេងរបស់ពួកគេហាក់ត្រូវបានគេមើលរំលងនៅក្នុងការពិភាក្សាអំពីការស្រាវជ្រាវ និងគោលនយោបាយថ្នាក់ជាតិ។ នេះរាប់បញ្ចូលទាំងជនមានពិការភាព ក្រុមស្រលាញ់ភេទដូចគ្នា សហគមន៍ជនជាតិដើមភាគតិច និងជនជាតិភាគតិច យុវជន ចាស់ជរា និងក្រុមប្រជាជននៅជនបទ។
ទីបី  ការសិក្សានេះបានប្រើប្រាស់វិធីសាស្ត្រជ្រើសរើសសំណាកគំរូដែលមានគោលដៅ   ប៉ុន្តែប្រកបដោយបរិយាបន្ន។

ដើម្បីសម្រេចបានគោលដៅទាំងនេះ ការសិក្សាបានប្រើប្រាស់ប្រភពផ្ដល់ទិន្នន័យចំនួនបី គឺការពិភាក្សាក្រុមគោលដៅ នៅកម្រិតសហគមន៍ បទសម្ភាសន៍អ្នកផ្ដល់ព័ត៌មានសំខាន់ ជាមួយរដ្ឋាភិបាល ស្ថាប័ន និងអ្នកអនុវត្តន៍ និងប្រភពបន្ទាប់បន្សំ ដែលជួយធ្វើបរិបទកម្ម និងផ្ទៀងផ្ទាត់លទ្ធផល។ ការផ្ទៀងផ្ទាត់បែបត្រីកោណវិធីលើប្រភពទិន្នន័យទាំងនេះ បានផ្ដល់នូវទស្សនៈប្រកបដោយតុល្យភាពមួយអំពីការអនុវត្តរបស់ស្ថាប័ន បរិយាកាសគោលនយោបាយ និងបទពិសោធន៍ជីវិតជាក់ស្ដែងរបស់ក្រុមដែលជួបការលំបាកក្នុងសង្គម។

## ២.២. ក្របខណ្ឌវិភាគ

ការវិភាគនេះបានអនុវត្តក្របខណ្ឌសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ដែលក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលីនិយមប្រើប្រាស់ គឺក្របខណ្ឌយេនឌ័រនៅកន្លែងធ្វើការ[២]  ដូចដែលបានរៀបរាប់នៅក្នុង កំណត់សម្គាល់នៃការអនុវត្តល្អក្នុងការវិភាគសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម (ក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី, ខែឧសភា ឆ្នាំ២០២៣)។[៣]
ក្របខណ្ឌនេះបានផ្ដល់ធាតុចូលដល់ការរៀបចំសំណួរស្រាវជ្រាវ ឧបករណ៍ និងដំណើរការប្រមូលទិន្នន័យ ព្រមទាំងការជ្រើសរើសក្រុមអាទិភាពសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម និងវិធីសាស្ត្រវិភាគជារួម។ ក្របខណ្ឌនេះត្រូវបានប្រើប្រាស់ដើម្បីពិនិត្យមើលទាំងប្រព័ន្ធផ្លូវការ រួមមានគោលនយោបាយ ច្បាប់ និងការរៀបចំស្ថាប័ន និងកត្តាក្រៅផ្លូវការ ដូចជា បទដ្ឋានសង្គម ទំនាក់ទំនងអំណាច និងការអនុវត្តប្រចាំថ្ងៃ ដែលជះឥទ្ធិពលលើបរិយាបន្ន និងការផាត់ចេញ។ ជំនួសឱ្យការចាត់ទុកយេនឌ័រ ពិការភាព និងបរិយាបន្នសង្គមជាកត្តាដាច់ដោយឡែកពីគ្នា ឬជាកត្តាបន្ថែមបន្តបន្ទាប់គ្នា ការវិភាគនេះពិចារណាពីអន្តរប្រសព្វ ដើម្បីវាយតម្លៃថាតើកត្តាទាំងនេះមានទំនាក់ទំនងគ្នាដូចម្ដេច ដើម្បីជះឥទ្ធិពលលើការចូលរួម ការទទួលស្គាល់ចំណេះដឹង និងការធ្វើសេចក្ដីសម្រេចចិត្តនៅកម្រិតផ្សេងៗនៃការអនុវត្ត។

[២] ក្របខណ្ឌយេនឌ័រនៅកន្លែងធ្វើការ (Gender at Work Framework) គូសបញ្ជាក់ពីទំនាក់ទំនងរវាងសមភាពយេនឌ័រ ការផ្លាស់ប្ដូរស្ថាប័ន និងអំណាចគ្របដណ្ដប់នៅក្នុងស្ថាប័ន និងសហគមន៍។ ក្របខណ្ឌនេះអាចប្រើប្រាស់សម្រាប់ស្វែងរកឱកាស និងឧបសគ្គរាំងសមភាពយេនឌ័រ ដើម្បីគូសវាសយុទ្ធសាស្ត្រសម្រាប់ការផ្លាស់ប្ដូរ និងណែនាំដល់កិច្ចខិតខំប្រឹងប្រែងវាយតម្លៃ ដើម្បីកំណត់វឌ្ឍនភាព។ ក្របខណ្ឌយេនឌ័រនៅកន្លែងធ្វើការ - Gender at Work

[៣] ការវិភាគសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម – កំណត់សម្គាល់នៃការអនុវត្តល្អ Gender equality, disability and social inclusion analysis – Good practice note

# ក្របខណ្ឌយេនឌ័រនៅកន្លែងការងារ

កម្រិតបុគ្គល

## មនសិការ និងសមត្ថភាពរបស់បុគ្គល

ឧ. ចំណេះដឹង ជំនាញ មនសិការនយោបាយ ការប្ដេជ្ញាចិត្ត ធ្វើការផ្លាស់ប្ដូរ

## លក្ខខណ្ឌ និងធនធានរបស់បុគ្គល

ឧ. សំឡេង សេរីភាពពីអំពើហិង្សា លទ្ធភាពទទួលបានសេវាសុខាភិបាល និងការអប់រំ

ក្រៅផ្លូវការ

ផ្លូវការ

## បទដ្ឋានក្រៅផ្លូវការ និងការអនុវត្តដែលមានលក្ខណៈផាត់ចេញ

ឧ. តួនាទីយេនឌ័រជាក់លាក់ ការបែងចែកការងារផ្ទះសម្បែង

## វិធាន និងគោលនយោបាយផ្លូវការ

ឧ. នៅក្នុងរដ្ឋធម្មនុញ្ញ ច្បាប់ គោលនយោបាយកន្លែងការងារ

ជាប្រព័ន្ធ

4 Source: Gender at Work Framework; https://genderatwork.org/resources/gender-at-work-framework/

## ការវិភាគនេះផ្តោតលើធាតុផ្សំបួនដែលប្រទាក់ក្រឡាគ្នា ៖

១ **សមភាពយេនឌ័រ** ពិនិត្យមើលថាតើបទដ្ឋាន តួនាទី និងការរំពឹងទុកលើយេនឌ័រ ជះឥទ្ធិពលដូចម្តេចដល់ការទទួលបានអាជីពស្រាវជ្រាវ តំណែងជាអ្នកដឹកនាំ និងឱកាសចូលរួមក្នុងការពិភាក្សាគោលនយោបាយ និងពិនិត្យថាតើជំនាញរបស់នរណាដែលត្រូវបានគេឱ្យតម្លៃនៅក្នុងស្ថាប័ន។

២ **បរិយាបន្នពិការភាព** ពិចារណាលើរបៀបដែលឥរិយាបទនៅក្នុងសង្គម ការបង្កភាពងាយស្រួលទាំងផ្នែករូបវន្ត និងឌីជីថល ការអនុវត្តការងាររបស់ស្ថាប័ន និងប្រព័ន្ធសម្របសម្រួលជួយជំរុញ ឬរឹតត្បិតដល់ការចូលរួមរបស់ជនដែលមានពិការភាព។

៣ **បរិយាបន្នសង្គមជារួម** ច្បាមយកកត្តា/ធាតុផ្សំបន្ថែមទៀត ដែលបង្កជាភាពងាយរងគ្រោះបន្ថែម រួមមានជាតិពន្ធុ អត្តសញ្ញាណជាជនជាតិដើមភាគតិច ទំនោរផ្លូវភេទ ភូមិសាស្រ្ត ស្ថានភាពសេដ្ឋកិច្ចសង្គម និងអាយុ ដែលជះឥទ្ធិពលលើការទទួលបានការអប់រំ បណ្តាញធនធាន និងការចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្ត។

៤ **អន្តរប្រសព្វ** ត្រូវបានចាត់ទុកថាជាកែវឆ្លុះនៃការវិភាគបែបឆ្លងវិស័យ ជាជាងកត្តា និងធាតុផ្សំដាច់ដោយឡែកមួយ។ ធាតុផ្សំនេះទទួលស្គាល់ថា ជារឿយៗ ការផាត់ចេញបណ្តាលមកពីអន្តរកម្មរវាងអត្តសញ្ញាណជាច្រើន និងកត្តារចនាសម្ព័ន្ធផ្សេងៗ ហើយគេមិនអាចយល់បានទេអំពីឧបសគ្គដែលកំពុងជួបប្រទះ ជាឧទាហរណ៍ ស្ត្រីជនជាតិដើមភាគតិចដែលមានពិការភាព ឬយុវជនដែលជាអ្នកស្រឡាញ់ភេទដូចគ្នានៅតាមជនបទ ដោយមិនពិចារណាតែលើកត្តា និងធាតុផ្សំតែមួយនោះទេ។

ប្រអប់ទី 1

## ការកំណត់និយមន័យនៃអន្តរប្រសព្វ

អន្តរប្រសព្វ[៥] ទទួលស្គាល់ថា មនុស្សជួបប្រទះវិសមភាព និងការផាត់ចេញតាមវិធីផ្សេងៗគ្នា អាស្រ័យលើថាតើទិដ្ឋភាពច្រើនយ៉ាងនៃអត្តសញ្ញាណរបស់ពួកគេ មានទំនាក់ទំនងគ្នាយ៉ាងដូចម្តេច។ យេនឌ័រ ពិការភាព អាយុ ជាតិពន្ធុ វណ្ណៈក្នុងសង្គម ទំនោរផ្លូវភេទ ទីកន្លែង និងកត្តាផ្សេងៗទៀត គឺមានទំនាក់ទំនងគ្នា។ កត្តាទាំងនេះត្រួតគ្នា និងរួមបញ្ចូលគ្នា ដើម្បីកំណត់លទ្ធភាពរបស់មនុស្សក្នុងការទទួលបានអំណាច ធនធាន ឱកាស និងការធ្វើសេចក្តីសម្រេចចិត្ត។

វិធីសាស្ត្របែបអន្តរប្រសព្វ គ្របដណ្តប់លើសពីការវិភាគកត្តាតែមួយ។ វិធីសាស្ត្រនេះជួយពន្យល់អំពីមូលហេតុ ដែលបុគ្គលឬក្រុមដែលត្រូវប្រឈមមុខនឹងទម្រង់ស្រដៀងគ្នានៃភាពដែលត្រូវបានផាត់ចេញ អាចជួបប្រទះបញ្ហាទាំងនោះតាមរបៀបខុសគ្នាៗ និងហេតុអ្វីបានជាអ្នកខ្លះងាយរងគ្រោះខ្លាំងជាងអ្នកដទៃទៀត។ នៅក្នុងការងារ សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ចំណុចនេះមានន័យថាជាការវិភាគអំពីរបៀបដែលអត្តសញ្ញាណត្រួតគ្នា ឫអន្តរប្រសព្វ ជះឥទ្ធិពលលើបទពិសោធន៍ជីវិតជាក់ស្តែង និងការធានាថា គោលនយោបាយ និងកម្មវិធីនានាឆ្លើយតបទៅនឹងតថភាពដ៏ស្មុគស្មាញទាំងនេះ ជាជាងការអនុវត្តដំណោះស្រាយតែមួយសម្រាប់គ្រប់បញ្ហាទាំងអស់។

ក្នុងជាតុផ្សំទាំងបួននេះ ការវិភាគពិនិត្យមើលយន្តការដែលជំរុញឱ្យមានការផាត់ចេញ និងបរិយាបន្ន។ យន្តការទាំងនេះរួមមានវិធានស្ថាប័នទាំងផ្លូវការ និងក្រៅផ្លូវការ ការលើកទឹកចិត្តនៅក្នុងប្រព័ន្ធស្រាវជ្រាវ និងគោលនយោបាយ អនុវត្តក្នុងការកម្រិតលទ្ធភាពទទួលបានជំនួយមូលនិធិ និងកំណត់អំពីរបៀបវារៈ ព្រមទាំងអំណាចគ្របដណ្តប់ដែលកំណត់ថាតើចំណេះដឹងរបស់នរណា ត្រូវបានផ្តល់ភាពស្របច្បាប់ និងយកទៅអនុវត្ត។ តាមរយៈការអនុវត្តក្របខណ្ឌនេះយ៉ាងខ្ជាប់ខ្ជួនជាមួយក្រុមអ្នកចូលរួម ទីតាំង និងបរិបទស្ថាប័នផ្សេងៗ ការវិភាគនេះរកឃើញលំនាំនៃឧបសគ្គជាប្រព័ន្ធ ក៏ដូចជាចំណុចដែលអាចធ្វើការផ្លាស់ប្តូរ។ ប្រភពទិន្នន័យបន្ទាប់បន្សំ ត្រូវបានប្រើប្រាស់នៅពេលចាំបាច់ ដើម្បីធ្វើបរិបទកម្ម និងធ្វើការផ្ទៀងផ្ទាត់លទ្ធផលទាំងនេះ។

[5] នៅឆ្នាំ១៩៨៩ បញ្ញវន្តច្បាប់ Kimberlé Crenshaw បានបង្កើតពាក្យ អន្តរប្រសព្វ (Intersectionality) ដើម្បីពណ៌នាអំពីរបៀបដែលទម្រង់ផ្សេងៗគ្នានៃការរើសអើង អំណាច និងឯកសិទ្ធិ ធ្វើអន្តរកម្មជាមួយគ្នានៅក្នុងជីវិតរស់នៅរបស់ស្ត្រីស្បែកខ្មៅ ក្នុងលក្ខណៈដែលត្រូវបានគេផាត់ចោល នៅពេលដែលការរើសអើងយេនឌ័រ និងការរើសអើងពូជសាសន៍ ត្រូវបានចាត់ទុកថាជារឿងដាច់ដោយឡែកពីគ្នា។ ចាប់តាំងពីពេលនោះមក ពាក្យនេះត្រូវបានពង្រីកបន្ថែម ដើម្បីពណ៌នាអំពីទម្រង់ត្រួតគ្នានៃការជិះជាន់ និងវិសមភាព ដែលកើតចេញពីគុណសម្បត្តិ និងគុណវិបត្តិផ្នែករចនាសម្ព័ន្ធ ដែលជះឥទ្ធិពលលើបទពិសោធន៍ និងឱកាសសង្គមរបស់បុគ្គល ឬក្រុមណាមួយ។ ពាក្យនេះពណ៌នាអំពីប្រព័ន្ធនៃការរើសអើង ដែលត្រួតគ្នា ឬពឹងផ្អែកលើគ្នាទៅវិញទៅមក ទាក់ទងនឹងអាយុ ពិការភាព ជាតិពន្ធុ យេនឌ័រ ទីតាំងភូមិសាស្ត្រ ភេទ ស្ថានភាពសេដ្ឋកិច្ចសង្គម ទំនោរផ្លូវភេទ។ល។

## ២.៣. សំណួរគោលនៃការស្រាវជ្រាវ

សំណួរស្រាវជ្រាវត្រូវបានទាញចេញពីអាណត្តិនៃភារកិច្ចនេះ ហើយត្រូវបានសម្រិតសម្រាំងបន្ថែមតាមរយៈការពិភាក្សាជាមួយក្រុមការងារកម្មវិធីពន្លកចំណេះ ដំណាក់កាលទី២។ គោលដៅគឺដើម្បីប្រមូលព័ត៌មាន ដែលឆ្លើយតបដោយផ្ទាល់ទៅនឹងសំណួរទាំងនេះ តាមរយៈការពិភាក្សាក្រុមគោលដៅ និងបទសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ ដែលបានរៀបចំឱ្យស្របទៅនឹងក្រុមគោលដៅនីមួយៗ។ ប្រភពបន្ទាប់បន្សំត្រូវបានប្រើប្រាស់ ដើម្បីបំពេញបន្ថែមដល់ទិន្នន័យបឋម និងប្រើប្រាស់ជាឯកសារយោង នៅត្រង់ចំណុចដែលពាក់ព័ន្ធ។ ដើម្បីធានាភាពស៊ីសង្វាក់គ្នា និងភាពងាយស្រួលក្នុងការអាន ផ្នែក "លទ្ធផល" យកលំនាំតាមកម្រងសំណួរស្រាវជ្រាវដដែល ដូចមានរៀបរាប់ខាងក្រោម៖

១. តើមន្ត្រីរដ្ឋាភិបាលបញ្ជ្រាប ឬដាក់បញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម យ៉ាងដូចម្តេច? តើពួកគេជួបប្រទះបញ្ហាប្រឈមអ្វីខ្លះ ហើយតើការគាំទ្របន្ថែមអ្វីខ្លះដែលនឹងជួយពង្រឹងការដាក់បញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ទៅក្នុងការងាររបស់ពួកគេ?
២. តើអ្នកស្រាវជ្រាវ បញ្ជ្រាប ឬដាក់បញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម យ៉ាងដូចម្តេច? តើពួកគេជួបប្រទះបញ្ហាប្រឈមអ្វីខ្លះ ហើយតើការគាំទ្រអ្វីខ្លះដែលនឹងជួយបញ្ជ្រាបសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ឱ្យកាន់តែមានប្រសិទ្ធភាពទៅក្នុងការអនុវត្តការស្រាវជ្រាវ?
៣. តើមានឧបសគ្គ ឱកាស អាទិភាព និងតម្រូវការជាក់លាក់អ្វីខ្លះសម្រាប់ស្ត្រី ជនមានពិការភាព ក្រុមអ្នកស្រឡាញ់ភេទដូចគ្នា និងក្រុមមិនសូវទទួលបានការយកចិត្តទុកដាក់ផ្សេងទៀតនៅក្នុងសង្គម ក្នុងការចូលរួមក្នុងវិស័យស្រាវជ្រាវ និងដំណើរការគោលនយោបាយ?
៤. តើធ្វើដូចម្តេចទើបអាចកាត់បន្ថយឧបសគ្គ និងទាញប្រយោជន៍ពីឱកាស ដើម្បីធ្វើឱ្យប្រសើរឡើងដល់ការចូលរួមរបស់ក្រុមមិនសូវទទួលបានការយកចិត្តទុកដាក់នានា នៅក្នុងវិស័យស្រាវជ្រាវ និងដំណើរការគោលនយោបាយ ដែលអាចឱ្យពួកគេទទួលបានការគាំទ្រកាន់តែប្រសើរ?

## ២.៤. ការជ្រើសរើសអ្នកចូលរួម និងទីតាំងចុះមូលដ្ឋាន

### បទសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់

ការជ្រើសរើសអ្នកផ្តល់ព័ត៌មានសំខាន់ ផ្អែកតាមការពិគ្រោះយោបល់ជាមួយក្រុមការងារកម្មវិធីពន្លកចំណេះដំណាក់កាលទី២ ក្រុមអ្នកជំនាញផ្នែកសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម និងបណ្តាញនានានៅទូទាំងរដ្ឋាភិបាល សង្គមស៊ីវិល និងវិស័យសិក្សាធិការ។ ការជ្រើសរើសផ្តោតសំខាន់លើបុគ្គលដែលមានបទពិសោធន៍ជាក់ស្តែងក្នុងការស្រាវជ្រាវ ការចូលរួមក្នុងគោលនយោបាយ ឬការដាក់បញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម។ ដោយសារតែវិស័យនេះមានទំហំតូច ក្រុមស្រាវជ្រាវអាចទាក់ទងទៅកាន់អង្គការ/ស្ថាប័នជាច្រើន ដោយមិនធ្វើឱ្យបាត់បង់ភាពស៊ីជម្រៅ។ សរុបមក ក្រុមស្រាវជ្រាវបានធ្វើបទសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ចំនួន ៣២លើក ជាមួយអ្នកឆ្លើយតបចំនួន ៧៤ នាក់ ដែលជាតំណាងមកពីក្រសួងស្ថាប័នរដ្ឋាភិបាល សាកលវិទ្យាល័យ វិទ្យាស្ថានស្រាវជ្រាវ អង្គការតំណាងជនមានពិការភាព បណ្តាញស្ត្រី កម្មវិធីអភិវឌ្ឍន៍ និងអង្គការតាមមូលដ្ឋាន។

វិធីសាស្ត្រជ្រើសរើស ធ្វើឡើងតាមគោលដៅ និងមានគោលបំណងរាប់បញ្ចូលទាំងតួអង្គសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ដែលមានស្រាប់ និងក្រុមដែលមិនសូវទទួលបានការយកចិត្តទុកដាក់។ ក្រុមស្រាវជ្រាវបានខិតខំដាក់បញ្ចូលទស្សនៈពីក្រុមអ្នកស្រឡាញ់ភេទដូចគ្នា ជនមានពិការភាព ក្រុមជនជាតិដើមភាគតិច និងជនជាតិភាគតិច ព្រមទាំងសហគមន៍ជនបទ។ ការចូលរួមជាមួយអង្គការតាមមូលដ្ឋាន អង្គការតំណាងជនមានពិការភាព និងភាគីពាក់ព័ន្ធក្នុងជួររដ្ឋាភិបាល បានជួយឱ្យយើងចូលទៅដល់អ្នកឆ្លើយតប ដែលប្រហែលជាមិនអាចមើលឃើញឬសម្គាល់បាន តែតាមរយៈបណ្តាញស្ថាប័នមួយមុខនោះឡើយ។

### តារាងទី 1៖ បញ្ជីរាយនាមអ្នកផ្តល់ព័ត៌មានសំខាន់

| ប្រភេទ | ស្ថាប័ន | ចំនួនអ្នកចូលរួម (KIIs) |
|---|---|---|
| រាជរដ្ឋាភិបាល | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្រសួងកិច្ចការនារី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារខេត្ត | ៤៨ នាក់ (ប្រុស ២២, ស្រី ២៦) |
| សាកលវិទ្យាល័យ | សាកលវិទ្យាល័យអង្គរ សាកលវិទ្យាល័យជាតិបាត់ដំបង វិទ្យាស្ថានជាតិសង្គមកិច្ច | ៥ នាក់ (ប្រុស ៤, ស្រី ១) |
| កម្មវិធី | កម្មវិធីភាពជាដៃគូ កម្ពុជា-អូស្ត្រាលី សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយភាពធន់ (CAPRED) កម្មវិធីសហប្រតិបត្តិការ អូស្ត្រាលី-កម្ពុជា ដើម្បីការផ្តល់សេវាប្រកបដោយនិរន្តរភាព និងសមធម៌ (ACCESS) អង្គការ (UN Women) និង Cowater | ៥ នាក់ (ស្រី ៥) |
| ក្រុមអ្នកជំនាញផ្នែកសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម | អង្គការនារីដើម្បីសន្តិភាព (WPM) អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា (GADC) និងអង្គការជនពិការកម្ពុជា (CDPO) | ៣ នាក់ (ស្រី ៣) |
| អង្គការជនជាតិដើមភាគតិច/ស្ត្រី (IPO/WO) | សមាគមយុវជនជនជាតិដើមភាគតិចកម្ពុជា (CIYA) និងសមាគមស្ត្រីជនជាតិដើមភាគតិចកម្ពុជា (CIWA) អង្គការសហគមន៍ឥន្ទធនូកម្ពុជា (ROCK) | ៥ នាក់ (ប្រុស ១, ស្រី ៤) |
| បណ្តាញ | បណ្តាញស្ត្រីក្នុងវិស័យស្រាវជ្រាវ | ២ នាក់ (ស្រី ២) |
| វិទ្យាស្ថានស្រាវជ្រាវ | វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) មជ្ឈមណ្ឌលសិក្សាគោលនយោបាយ (CPS) មជ្ឈមណ្ឌលខេមរសិក្សា និង (CKS) វេទិកាអនាគត (FF) | ៦ នាក់ (ប្រុស ៣, ស្រី ៣) |

# ការពិភាក្សាក្រុមគោលដៅ និងកម្រិតសហគមន៍

ការជ្រើសរើសខេត្ត និងស្រុកសម្រាប់ការពិភាក្សាក្រុមគោលដៅ ត្រូវបានកំណត់តាមរយៈការពិគ្រោះយោបល់ជាមួយ កម្មវិធីពន្លកចំណេះ ដំណាក់កាលទី២ ដៃគូថ្នាក់ខេត្ត និងភាគីពាក់ព័ន្ធរបស់រដ្ឋាភិបាល រួមទាំងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ (គ.ក.ន.ក) ផងដែរ។ ការជ្រើសរើសទីតាំងចំនួនប្រាំ គឺដើម្បីឆ្លុះបញ្ចាំងពីភាពចម្រុះផ្នែកភូមិសាស្ត្រ និងសង្គមរបស់ប្រទេសកម្ពុជា។ ទីតាំងទាំងប្រាំនោះ រួមមានរាជធានីភ្នំពេញ ខេត្តបាត់ដំបង សៀមរាប កំពត និងរតនគិរី។




## រាជធានីភ្នំពេញ

ត្រូវបានជ្រើសរើសដោយសារតែតួនាទីស្នូលរបស់ទីតាំងនៅក្នុងការស្រាវជ្រាវថ្នាក់ជាតិ និងការពិភាក្សាគោលនយោបាយ ព្រមទាំងមានប្រជាជនចម្រុះ។

## ខេត្តបាត់ដំបង

ត្រូវបានរួមបញ្ចូលដោយសារតែខេត្តនេះសំបូរជនមានពិការភាពច្រើន និងមានមជ្ឈមណ្ឌលពិការភាព និងស្ថានីតិសម្បទា។

## ខេត្តសៀមរាប

ត្រូវបានជ្រើសរើសដោយសារតែខេត្តនេះសំបូរដោយកម្លាំងពលកម្មងាយរងគ្រោះ ដែលពាក់ព័ន្ធនឹងវិស័យទេសចរណ៍។

## ខេត្តកំពត

តំណាងឱ្យតំបន់ឆ្នេរ ដែលមានចំនួនប្រជាជនជាជនជាតិភាគតិចច្រើនគួរឱ្យកត់សម្គាល់។

## ខេត្តរតនគិរី

ត្រូវបានជ្រើសរើសដើម្បីតំណាងឱ្យសហគមន៍ជនជាតិដើមភាគតិច នៅតំបន់ភ្នំ។

អាផ្ទាធរមូលដ្ឋាន ជាពិសេស គ.ក.ន.ក. បានគាំទ្រដល់ការចុះផ្សព្វផ្សាយ និងជួយធានាឱ្យមានការចូលរួមពីក្រុមដែលតែងតែត្រូវបានផាត់ចេញពីការស្រាវជ្រាវផ្លូវការ។ នៅទូទាំងទីតាំងទាំងប្រាំ ក្រុមស្រាវជ្រាវបានធ្វើការពិភាក្សាចំនួន ៥២ លើកជាមួយអ្នកចូលរួមសរុប ២៧៨ នាក់ (តារាងទី១) ដែលរួមមានស្ត្រី និងបុរសជនមានពិការភាព ក្រុមអ្នកស្រឡាញ់ភេទដូចគ្នា យុវជន ចាស់ជរា ព្រមទាំងជនជាតិភាគតិច និងជនជាតិដើមភាគតិច។ បទពិសោធន៍ជីវិតជាក់ស្តែងរបស់ពួកគេ បានបង្កើតបានជាមូលដ្ឋានដ៏សំខាន់សម្រាប់ការវិភាគ និងអនុសាសន៍។

វិធីសាស្ត្រជ្រើសរើសសំណាកដោយចេតនានេះ ត្រូវបានរៀបចំឡើងដើម្បីរក្សាតុល្យភាព រវាងការតំណាងស្ថាប័ន និងការដាក់បញ្ចូលក្រុមដែលមិនសូវមានតំណាង ក្នុងគោលបំណងធានាថាការវិភាគនេះឆ្លុះបញ្ចាំងទាំងទស្សនៈកម្រិតប្រព័ន្ធ និងបទពិសោធន៍ជីវិតជាក់ស្តែងនៅទូទាំងបរិបទចម្រុះរបស់ប្រទេសកម្ពុជា។

តារាងទី 2៖ សមាសភាពអ្នកចូលរួមក្នុងការពិភាក្សាក្រុមគោលដៅ តាមក្រុមអ្នកពាក់ព័ន្ធ ទីតាំង និងលក្ខណៈសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម (រួមទាំងអន្តរប្រសព្វ)

| ប្រភេទ | ស្ថាប័ន | ចំនួនសរុប | ចំនួនស្ត្រី | LGBTQIA+ | ជនមានពិការភាព | ជនជាតិដើមភាគតិច/ជនជាតិភាគតិច | ភាពប្រទាក់ក្រឡា |
|---|---|---|---|---|---|---|---|
| រដ្ឋាភិបាល (ថ្នាក់ស្រុក) ការពិភាក្សា ១០ លើក | គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារក្រុង ស្រុក ខណ្ឌ (គ.ក.ស.ក) + មន្ត្រីបង្គោលទទួលបន្ទុកជីវភាព/ការប្រែប្រួលអាកាសធាតុ | ៣២ | ២៤ | ០ | ០ | ៣ | ស្ត្រីមកពីសហគមន៍ជនជាតិដើមភាគតិចចំនួន ២នាក់ ស្ត្រីវ័យចំណាស់ចំនួន ៦ នាក់ |
| រដ្ឋាភិបាល (ថ្នាក់ឃុំ) ការពិភាក្សា ១០ លើក | គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំ-សង្កាត់ (គ.ក.ន.ក) + មន្ត្រីបង្គោលទទួលបន្ទុកជីវភាព/ការប្រែប្រួលអាកាសធាតុ | ៦៧ | ៥៨ | ០ | ១ | ១០ | យុវតីមកពីសហគមន៍ជនជាតិដើមភាគតិចចំនួន ៣នាក់ ស្ត្រីវ័យចំណាស់ចំនួន ៧ នាក់, ស្ត្រីមានពិការភាពចំនួន ១ នាក់ |
| ក្រុមគោលដៅសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ការពិភាក្សា ២០ លើក | រាជធានីភ្នំពេញ | ៣០ | ១៧ | ៩ | ៧ | ៤ | យុវជនដែលជាក្រុមស្រឡាញ់ភេទដូចគ្នា ចំនួន ៩ នាក់ យុវតីចំនួន ៦នាក់ (យុវតីមានសាវតារជាជនជាតិភាគតិចចំនួន ៤នាក់) ស្ត្រីមានពិការភាពចំនួន ២ នាក់ |
| | ខេត្តបាត់ដំបង | ៣៣ | ៥ | ៨ | ៩ | ០ | ស្ត្រីមានពិការភាពចំនួន ៥នាក់ យុវជនដែលជាក្រុមស្រឡាញ់ភេទដូចគ្នាចំនួន ៨ នាក់ |
| | ខេត្តសៀមរាប | ២៩ | ២០ | ៧ | ៦ | ១ | ស្ត្រីមានពិការភាពចំនួន ៥នាក់ |
| | ខេត្តកំពត | ៣១ | ១៩ | ៨ | ៨ | ១០ | យុវជនដែលជាក្រុមស្រឡាញ់ភេទដូចគ្នាចំនួន ៧ នាក់, យុវតីមានសាវតារជាជនជាតិភាគតិចចំនួន ២ នាក់ យុវតីចំនួន ៤ នាក់ អ្នកដែលមានវ័យចំណាស់និងមានសាវតារជាជនជាតិភាគតិចចំនួន ១ នាក់ ស្ត្រីវ័យចំណាស់និងមានសាវតារជាជនជាតិភាគតិចចំនួន ៨ នាក់ ស្ត្រីមានពិការភាពចំនួន ៣ នាក់ ស្ត្រីវ័យចំណាស់ចំនួន ១ នាក់ |
| | ខេត្តរតនគិរី | ៣៦ | ២៥ | ១២ | ២ | ៣៦ | ស្ត្រីមានពិការភាព និងមកពីសហគមន៍ជនជាតិដើមភាគតិចចំនួន ១ នាក់ យុវជនដែលជាក្រុមស្រឡាញ់ភេទដូចគ្នា មកពីសហគមន៍ជនជាតិដើមភាគតិចចំនួន ១២ នាក់ យុវតីមកពីសហគមន៍ជនជាតិដើមភាគតិចចំនួន ៦ នាក់ |
| ការពិភាក្សាអង្គការសង្គមស៊ីវិល | អង្គការមិនមែនរដ្ឋាភិបាលក្នុងមូលដ្ឋានចំនួន ១០ - អង្គការតំណាងជនមានពិការភាព / អង្គការស្ត្រី/ អង្គការជនជាតិដើមភាគតិច នៅខេត្តកំពត សៀមរាប បាត់ដំបង និងរតនគិរី | ២០ | ១០ | ៣ | ០ | ៣ | មិនបានកត់ត្រាអំពីអន្តរប្រសព្វទេ |

# គោលការណ៍ស្រាវជ្រាវ

| | |
|---|---|
| គោលការណ៍មិនបង្កហានិភ័យ | ក្រុមស្រាវជ្រាវបានចាត់វិធានការនានា ដើម្បីកាត់បន្ថយនូវហានិភ័យដែលអាចកើតមានចំពោះអ្នកចូលរួម អ្នកផ្តល់បទសម្ភាសន៍ និងអ្នកស្រាវជ្រាវនៅកម្រិតមូលដ្ឋាន។ វិធានការទាំងនេះរួមមាន ការទទួលបានការយល់ព្រមសម្រាប់បទសម្ភាសន៍ និងការពិភាក្សាក្រុមគោលដៅទាំងអស់ ការធានានូវបរិយាកាសដែលមានសុវត្ថិភាព និងអព្យាក្រឹត្យ ការចៀសវាងសំណួរដែលអាចបង្កជម្លោះ ឬមិនសមរម្យ ការប្រើប្រាស់ភាសាច្បាស់លាស់ និងប្រកបដោយការគោរព ព្រមទាំងការរក្សានូវអភិក្រមប្រកបដោយវិជ្ជាជីវៈ និងការយកចិត្តទុកដាក់នៅក្នុងដំណើរការនេះទាំងមូល។ អត្តសញ្ញាណរបស់អ្នកឆ្លើយតបទាំងអស់ត្រូវបានការពារ ដោយរក្សាអនាមិកភាព និងការសម្ងាត់ លុះត្រាតែមានការអនុញ្ញាតយ៉ាងច្បាស់លាស់។ |
| គោលការណ៍មិនទុកនរណាម្នាក់ចោល | ស្របតាមរបៀបវារៈឆ្នាំ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ការស្រាវជ្រាវនេះបានអនុវត្តនូវចក្ខុបរិយាបន្នសង្គមដ៏រឹងមាំមួយ។ ក្រុមស្រាវជ្រាវបានធានាថា សំឡេងរបស់ស្ត្រី ជនមានពិការភាព សហគមន៍ជនជាតិដើមភាគតិច និងក្រុមមិនសូវទទួលបានការយកចិត្តទុកដាក់ផ្សេងទៀត គឺជាចំណុចស្នូលនៅក្នុងដំណើរការស្រាវជ្រាវទាំងមូល។ |
| គោលការណ៍ការការពារកុមារ | ដោយអនុលោមតាមគោលនយោបាយការពារកុមាររបស់ក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី (DFAT) អ្នកស្រាវជ្រាវនៅមូលដ្ឋានទាំងអស់បានទទួលការណែនាំអំពីអាកប្បកិរិយាសមរម្យពេលនៅក្បែរកុមារ។ ទោះបីជាការស្រាវជ្រាវនេះមិនពាក់ព័ន្ធដោយផ្ទាល់ជាមួយកុមារក៏ដោយ កម្មវិធីពន្លកចំណេះ ដំណាក់កាលទី២ និងក្រុមស្រាវជ្រាវបានផ្តោតអាទិភាពខ្ពស់លើការអនុលោមតាមកិច្ចការពារកុមារយ៉ាងពេញលេញ។ |

៦ ការប្រែក្លាយពិភពលោករបស់យើង៖ របៀបវារៈឆ្នាំ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព | នាយកដ្ឋានកិច្ចការសេដ្ឋកិច្ច និងសង្គម

៧ គោលនយោបាយការពារកុមារ ឆ្នាំ២០២៥ | ក្រសួងការបរទេស និងពាណិជ្ជកម្ម រដ្ឋាភិបាលអូស្ត្រាលី

## ២.៥. ឧបករណ៍ស្រាវជ្រាវ ការប្រមូល និងការវិភាគទិន្នន័យ

គោលការណ៍ណែនាំការសម្ភាសន៍ និងឧបករណ៍ពិភាក្សា ត្រូវបានបង្កើតឡើងដោយផ្ទាល់ចេញពីសំណួរគោលនៃការស្រាវជ្រាវ និងគោលបំណងរបស់កម្មវិធីពន្លកចំណេះ ដំណាក់កាលទី២។ សម្រាប់បទសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ ឧបករណ៍ទាំងនេះផ្តោតលើការអនុវត្តក្នុងស្ថាប័នៈ របៀបកំណត់អាទិភាព របៀបអនុវត្តការស្រាវជ្រាវ របៀបដែលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គមត្រូវបានរួមបញ្ចូល ឬមើលរំលង និងថាតើអង្គការនានាមានយល់ឃើញដូចម្តេចចំពោះតួនាទីរបស់ខ្លួនក្នុងការជះឥទ្ធិពលលើគោលនយោបាយ។

សម្រាប់ការពិភាក្សាក្រុមគោលដៅ ឧបករណ៍ត្រូវបានរៀបចំឡើង ដើម្បីទាញយកបទពិសោធន៍ជីវិតជាក់ស្តែង និងទស្សនៈក្នុងមូលដ្ឋានស្តីពីរបៀបដែលដំណើរការស្រាវជ្រាវ និងដំណើរការគោលនយោបាយជះឥទ្ធិពលលើសហគមន៍។ អ្នកចូលរួមត្រូវបានលើកទឹកចិត្តឱ្យនិយាយអំពីបញ្ហាប្រឈមដែលពួកគេបានជួបប្រទះ ក្នុងការសម្តែងក្តីកង្វល់ ការទទួលបានព័ត៌មាន  ការចូលរួមក្នុងការពិគ្រោះយោបល់ និងការទទួលបានការគាំទ្រពីរដ្ឋាភិបាល  ឬតួអង្គសង្គមស៊ីវិល។ ឧបករណ៍ទាំងនេះត្រូវបានប្រើប្រាស់ប្រកបដោយភាពបត់បែន ដើម្បីសម្របតាមសាវតារ និងកម្រិតផាសុកភាពរបស់អ្នកចូលរួម។ ក្នុងករណីជាច្រើន ក្រុមស្រាវជ្រាវបានធ្វើការកែសម្រួលភ្លាមៗ ដើម្បីធានាថា សំណួរបង្កភាពងាយស្រួលយល់សម្រាប់អ្នកចូលរួមដែលមានពិការភាព អ្នកដែលមិនសុាំនឹងដំណើរការស្រាវជ្រាវ ឬអ្នកដែលប្រើប្រាស់ភាសាក្នុងតំបន់។

ការវិភាគត្រូវបានធ្វើឡើងជាបន្តបន្ទាប់ នៅពេលដែលទិន្នន័យទទួលបានពីការស្រាវជ្រាវឯកសារ ការពិគ្រោះយោបល់ បទសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ និងការពិភាក្សាជាក្រុម។ លទ្ធផលដែលបង្ហាញក្នុងរបាយការណ៍នេះ ឆ្លុះបញ្ចាំងពីការសំយោគបញ្ចូលគ្នានូវប្រភពទិន្នន័យបឋម និងប្រភពទិន្នន័យបន្ទាប់បន្សំ ដោយផ្អែកលើសំណួរស្រាវជ្រាវ និងក្របខណ្ឌវិភាគ សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម។ កំណត់ហេតុសម្ភាសន៍ និងការពិភាក្សា ត្រូវបានចងក្រង រៀបចំ និងពិនិត្យឡើងវិញជាប្រព័ន្ធ ដើម្បីកំណត់រកមូលបទដែលលេចឡើងដដែលៗ ចំណុចខ្វែងគំនិតគ្នា និងការយល់ដឹងថ្មីៗ ដែលលេចឡើងនៅទូទាំងក្រុមអ្នកឆ្លើយតប និងទីតាំងនានា។

ដើម្បីការពារការសម្ងាត់ ប្រភពទិន្នន័យបឋមមិនត្រូវបានបញ្ជាក់ឈ្មោះបុគ្គលនៅក្នុងរបាយការណ៍នោះទេ។ ឯកសារសាធារណៈ និងឯកសារកម្មវិធី ត្រូវបានដកស្រង់នៅត្រង់តែចំណុចដែលពាក់ព័ន្ធ។ ប្រភពទិន្នន័យបន្ទាប់បន្សំ ត្រូវបានដកស្រង់ជាចំណុចយោងដោយប្រើប្រាស់ទម្រង់ស្តង់ដារនៃការដកស្រង់លេខយោង រួមជាមួយនឹងតំណភ្ជាប់ទៅកាន់ប្រភពដើមដែលបានដាក់បញ្ចូល ប្រសិនបើមាន។ កំណត់ហេតុពីបទសម្ភាសន៍ និងការពិភាក្សាទាំងអស់ ត្រូវបានរក្សាទុកដោយសុវត្ថិភាពជាទិន្នន័យដើមដែលមិនទាន់បានវិភាគ ដើម្បីធានាឱ្យមានតម្លាភាព គណនេយ្យភាពប្រកបដោយក្រមសីលធម៌ និងលទ្ធភាពសម្រាប់ការពិនិត្យឡើងវិញនាពេលអនាគត ស្របតាមការអនុវត្តល្អក្នុងការស្រាវជ្រាវបែបគុណវិស័យ។

### ការពិនិត្យឡើងវិញលើទិន្នន័យបន្ទាប់បន្សំ

ដើម្បីបំពេញបន្ថែម និងផ្ទៀងផ្ទាត់ទិន្នន័យបឋម ការពិនិត្យឡើងវិញតាមគោលដៅលើប្រភពទិន្នន័យបន្ទាប់បន្សំត្រូវបានធ្វើឡើង។ ប្រភពទិន្នន័យបន្ទាប់បន្សំ រួមមានស្ថិតិថ្នាក់ជាតិ ឯកសារពាក់ព័ន្ធក្នុងវិស័យសិក្សាធិការ ឯកសារកម្មវិធី សេចក្តីសង្ខេបគោលនយោបាយ យុទ្ធសាស្ត្ររបស់រដ្ឋាភិបាល និងព័ត៌មានពីគេហទំព័ររបស់អង្គការនានា។ ប្រភពទិន្នន័យបន្ទាប់បន្សំមានសារៈប្រយោជន៍ជាពិសេសនៅក្នុងវិស័យ ដែលអ្នកឆ្លើយតបមានការយល់ដឹងតិចតួចអំពីទិដ្ឋភាពស្ថាប័នទូលំទូលាយ ឬក្នុងករណីដែលត្រូវការទិន្នន័យបែបបរិមាណ ដើម្បីផ្តល់បរិបទដល់លទ្ធផលបែបគុណវិស័យ។ ការពិនិត្យឡើងវិញនេះ បានផ្តល់សាវតារដ៏សំខាន់ស្តីពីវិសមភាពយេនឌ័រ បរិយាបន្នពិការភាព ភាពងាយជួបការលំបាកនៅជនបទ និងរចនាសម្ព័ន្ធនៃវិស័យស្រាវជ្រាវ។

## ២.៦. ក្រុមស្រាវជ្រាវ និងប្រមូលទិន្នន័យ

សមាសភាពក្នុងក្រុមស្រាវជ្រាវស្នូល រួមមានអ្នកឯកទេស សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម អន្តរជាតិម្នាក់ និងទីប្រឹក្សាថ្នាក់ជាតិម្នាក់ ដែលមានបទពិសោធន៍ស្រាវជ្រាវទូលំទូលាយនៅកម្ពុជា។ ពួកគេបានសហការគ្នាលើការរៀបចំការស្រាវជ្រាវ ការប្រមូលទិន្នន័យ និងការវិភាគ ហើយបានដឹកនាំទាំងការស្រាវជ្រាវបឋម និងការស្រាវជ្រាវបន្ទាប់បន្សំ។ អ្នកស្រាវជ្រាវក្នុងមូលដ្ឋាន បានគាំទ្រដល់ការប្រមូលទិន្នន័យកម្រិតសហគមន៍ ដោយសម្របសម្រួលការពិភាក្សាក្រុមគោលដៅជាមួយក្រុមសហគមន៍ និងអង្គការសង្គមស៊ីវិល។ ក្រុមការងារបានសម្របសម្រួលជាមួយកម្មវិធីពន្លកចំណេះដំណាក់កាលទី២ ដោយទាញយកនូវចំណេះដឹងពីកម្មវិធី និងធាតុចូលបច្ចេកទេសពាក់ព័ន្ធ ហើយទន្ទឹមនឹងនោះ រក្សាបានឯករាជ្យភាពក្នុងការវិភាគ។

ការសិក្សានេះបានទទួលស្គាល់យ៉ាងច្បាស់ថា អត្តសញ្ញាណ និងជំហររបស់អ្នកស្រាវជ្រាវ អាចជះឥទ្ធិពលដល់ការប្រមូល និងការបកស្រាយទិន្នន័យ។ ដើម្បីដោះស្រាយបញ្ហានេះ ក្រុមស្រាវជ្រាវត្រូវបានរៀបចំឡើងឱ្យមានភាពចម្រុះបំផុត។ ក្រុមស្រាវជ្រាវដែលមានមូលដ្ឋាននៅរាជធានីភ្នំពេញ រួមបញ្ចូលស្ត្រីពីរនាក់ (ជនជាតិខ្មែរម្នាក់ និងកាណាដាម្នាក់) ដែលមកពីក្រុមអាយុខុសគ្នា។

ក្រុមចុះស្រាវជ្រាវនៅមូលដ្ឋានទាំងប្រាំពីរនាក់ រួមមានស្ត្រីប្រាំនាក់ និងបុរសពីរនាក់ ក្នុងនោះមានអ្នកស្រាវជ្រាវមានពិការភាពម្នាក់ និងអ្នកស្រាវជ្រាវជាជនជាតិដើមភាគតិចពីរនាក់។ សមាសភាពបែបនេះគាំទ្រដល់ការចូលរួមប្រកបដោយបរិយាបន្ន និងពង្រឹងការបកស្រាយលទ្ធផលនានា។

អ្នកចុះស្រាវជ្រាវនៅមូលដ្ឋាន សុទ្ធតែបានទទួលវគ្គបណ្តុះបណ្តាលរយៈពេលមួយថ្ងៃ ដឹកនាំដោយទីប្រឹក្សាអន្តរជាតិ និងជាតិ ដែលផ្តោតលើគោលបំណងនៃការសិក្សាស្រាវជ្រាវ បរិបទនៃកម្មវិធីពន្លកចំណេះដំណាក់កាលទី២ ទស្សនទានគន្លឹះនៃសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម និងការប្រើប្រាស់គោលការណ៍ណែនាំសម្រាប់ការពិភាក្សា។ អ្នកស្រាវជ្រាវទទួលបានការគាំទ្រជាបន្តបន្ទាប់ក្នុងអំឡុងពេលចុះមូលដ្ឋាន តាមរយៈការសម្របសម្រួលជាប្រចាំជាមួយទីប្រឹក្សាថ្នាក់ជាតិ និងអ្នកសម្របសម្រួលការស្រាវជ្រាវ។ វគ្គបណ្តុះបណ្តាលបន្តស្តីពីការការពារកុមារ ក៏ត្រូវបានធ្វើឡើងផងដែរ ដើម្បីពង្រឹងការអនុវត្តប្រកបដោយក្រមសីលធម៌។

សេចក្តីព្រាងនៃការវិភាគ ត្រូវបានរៀបចំឡើងដោយក្រុមស្រាវជ្រាវ និងចែករំលែកទៅកាន់ក្រុមពិគ្រោះយោបល់ ដើម្បីសុំមតិយោបល់ត្រឡប់។ ក្រុមពិគ្រោះយោបល់ រួមមានក្រុមអ្នកជំនាញផ្នែក សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ផ្នែកជំនួយកិច្ចការបរិយាបន្នពិការភាពរបស់ DFAT ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងគម្រោង ACCESS ដំណាក់កាលទី២។ ក្រោយមក វគ្គពិភាក្សាពិគ្រោះយោបល់តាមអនឡាញមួយត្រូវបានធ្វើឡើងដោយក្រុមស្រាវជ្រាវនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៤។ វគ្គនេះធ្វើឡើងជាភាសាអង់គ្លេស និងមានការចូលរួមពីអ្នកដែលបានពាក់ព័ន្ធក្នុងដំណើរការសម្ភាសន៍។ វគ្គជាភាសាខ្មែរក៏ត្រូវបានធ្វើឡើង ជាមួយភាគីពាក់ព័ន្ធថ្នាក់ក្រោមជាតិផងដែរ។

ផ្អែកលើធាតុចូល និងមតិយោបល់ដែលទទួលបាន អ្នកឯកទេសផ្នែកយេនឌ័រ និងការអភិវឌ្ឍម្នាក់ត្រូវបានជ្រើសរើសដើម្បីធ្វើការបន្តលើសេចក្តីព្រាង គាត់បានទទួលខុសត្រូវក្នុងការរៀបចំសេចក្តីព្រាងទីពីរ ដោយបូកសរុបធាតុចូល និងធ្វើការកែលម្អយ៉ាងច្រើន ដើម្បីឈានទៅបញ្ចប់ការវិភាគនេះជាចុងក្រោយ។

## ២.៧. ដែនកំណត់នៃការសិក្សា

ការវិភាគនេះផ្អែកជាចម្បងលើទិន្នន័យបែបគុណវិស័យ ដែលប្រមូលបានតាមរយៈការពិភាក្សាក្រុមគោលដៅ បទសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ និងការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងបំពេញបន្ថែមដោយការពិនិត្យឡើងវិញតាមគោលដៅលើឯកសារគោលនយោបាយ និងប្រភពបន្ទាប់បន្សំដែលត្រូវបានជ្រើសរើស។ ខណៈដែលវិធីសាស្ត្រនេះផ្តល់នូវការយល់ដឹងដ៏សម្បូរបែប និងស្របតាមបរិបទ ស្តីពីការដាក់បញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម នៅក្នុងដំណើរការស្រាវជ្រាវ និងដំណើរការគោលនយោបាយនៅកម្ពុជា វាក៏មានដែនកំណត់មួយចំនួនផងដែរ។

ទីមួយ ដូចទៅនឹងការសិក្សាបែបគុណវិស័យផ្សេងទៀតដែរ លទ្ធផលទាំងនេះមិនតំណាងឱ្យទិន្នន័យស្ថិតិទេ។ ក្រុមខ្លះមានតំណាងតិចតួចនៅក្នុងខេត្តមួយចំនួន  មិនមានពេលចូលរួម បានកម្រិតវិសាលភាពសម្រាប់បទសម្ភាសន៍ ដែលទាមទារការតាមដានបន្ថែម។ ទោះជាយ៉ាងណាចំនួនអ្នកឆ្លើយតបយ៉ាងច្រើន ភាពចម្រុះនៃទីតាំង និងភាពស៊ីសង្វាក់គ្នានៅក្នុងប្រភពទិន្នន័យនានា បានផ្តល់មូលដ្ឋានដ៏រឹងមាំមួយសម្រាប់ការវិភាគ និងការលើកអនុសាសន៍ជាបន្តបន្ទាប់។

ទីពីរ លទ្ធផលភាគច្រើនផ្អែកលើការយល់ឃើញ និងឆ្លុះបញ្ចាំងពីបទពិសោធន៍ និងទស្សនៈរបស់អ្នកដែលបានចូលរួមក្នុងការសិក្សានេះ។ ទោះបីជាមានកិច្ចខិតខំប្រឹងប្រែង ដើម្បីធានាភាពចម្រុះនៅទូទាំងក្រុមអ្នកពាក់ព័ន្ធ និងទីតាំងភូមិសាស្ត្រក៏ដោយ ក៏ប៉ុន្តែការវិភាគនេះប្រហែលជាមិនអាចច្បាមយកបទពិសោធន៍ពេញលេញទាំងអស់នៅគ្រប់ក្រសួង គ្រប់វិស័យ ឬក្រុមប្រជាជនទាំងអស់នោះទេ។

ទីបី ខណៈដែលការវិភាគពិនិត្យមើលជាតុផ្សំសំខាន់ៗនៃចំណុចប្រទាក់គ្នារវាងការស្រាវជ្រាវ និងគោលនយោបាយ វាក៏មិនបានបង្ហាញជាប្រព័ន្ធអំពីរបៀបដែលទិន្នន័យត្រូវបានបង្កើតឡើង ប្រើប្រាស់ និងប្រែក្លាយទៅជាការសម្រេចចិត្តលើគោលនយោបាយនៅទូទាំងវិស័យនានានោះទេ។ ដូច្នេះហើយទើបការវាយតម្លៃលើដំណើរការប្រែក្លាយទិន្នន័យទៅជាគោលនយោបាយ នៅតែជាការបង្ហាញជាឧទាហរណ៍ ជាជាងការវាយតម្លៃល្អិតល្អន់គ្រប់ជ្រុងជ្រោយ។

ជាចុងក្រោយ អនុសាសន៍ដែលបានបង្ហាញនៅទីនេះ គឺសំដៅឱ្យមានភាពជាក់ស្តែង និងអាចអនុវត្តទៅមុខបាន ប៉ុន្តែប្រហែលជាទាមទារឱ្យមានការផ្ទៀងផ្ទាត់ និងការកំណត់អាទិភាពបន្ថែមទៀត  តាមរយៈការពិគ្រោះយោបល់ជាមួយរដ្ឋាភិបាល និងភាគីពាក់ព័ន្ធសំខាន់ៗ។ ទិន្នន័យបន្ថែម រួមទាំងការវិភាគបន្ទាប់បន្សំដែលទូលំទូលាយជាងមុន និងទិន្នន័យរដ្ឋបាល នឹងជួយពង្រឹងមូលដ្ឋានភស្តុតាងសម្រាប់ការធ្វើឱ្យប្រសើរឡើងដល់ការងារនេះនាពេលអនាគត។



# ០៣

# លទ្ធផលនៃការស្រាវជ្រាវ



ទិដ្ឋភាពគោលនយោបាយរបស់កម្ពុជាក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះ បានឆ្លងកាត់ការអភិវឌ្ឍស្ថាប័នជាលំដាប់ ដោយរដ្ឋាភិបាល អ្នកស្រាវជ្រាវ និងសហគមន៍ សុទ្ធតែបានដើរតួនាទីនៅក្នុងរបៀបដែលចំណេះដឹងត្រូវបានបង្កើតឡើង បកស្រាយ និងប្រែក្លាយទៅជាសកម្មភាពសាធារណៈ។ បើទោះបីជាមានការប្តេជ្ញាចិត្តផ្នែកគោលនយោបាយចំពោះសមធម៌ និងបរិយាបន្នយ៉ាងណាក្តី ប៉ុន្តែដំណើរការនៃការប្រែក្លាយទិន្នន័យទៅជាគោលនយោបាយនៅតែរងឥទ្ធិពលពីដែនកំណត់ជាប្រព័ន្ធ សមត្ថភាពមិនស្មើគ្នា និងគម្លាតនៅក្នុងរបៀបដែលរដ្ឋចូលរួមជាមួយប្រជាពលរដ្ឋ ដែលបទពិសោធន៍ជីវិតជាក់ស្តែងរបស់ពួកគេ មិនត្រូវបានចាត់ចូលជាប្រភេទទិន្នន័យរដ្ឋបាលស្តង់ដារ។

លទ្ធផលត្រូវបានរៀបចំឡើងដោយពិនិត្យមើលកត្តាចំនួនបី គឺរដ្ឋាភិបាល អ្នកស្រាវជ្រាវ/ស្ថាប័នស្រាវជ្រាវ និងសហគមន៍ ដែលកត្តាទាំងនេះមិនមែនឈរនៅដាច់ដោយឡែកពីគ្នានោះទេ ប៉ុន្តែជាទីប្រសព្វនៃអំណាច និងចំណេះដឹងដែលមានទំនាក់ទំនងគ្នា។ សម្រាប់រដ្ឋាភិបាល និងស្ថាប័នស្រាវជ្រាវ ការយល់ដឹងហាក់ឆ្លុះបញ្ចាំងពីបញ្ហាផ្លូវការ និងជាប្រព័ន្ធច្រើនជាង។ នៅកម្រិតសហគមន៍ កត្តាផ្លូវការ និងកត្តាក្រៅផ្លូវការត្រូវបានលើកឡើងក្នុងកម្រិតស្មើគ្នា ដោយសមាជិកសហគមន៍និយាយអំពីការរើសអើង ឧបសគ្គរាំងការចូលរួម និងភាពលំអៀង ខណៈដែលអាជ្ញាធរថ្នាក់ក្រោមជាតិភាគច្រើនពណ៌នាអំពីការងាររបស់ពួកគេដោយឆ្លុះបញ្ចាំងពីកាតព្វកិច្ចក្រោមគោលនយោបាយ និងការផ្តល់សេវា។ រចនាសម្ព័ន្ធបែបនេះជួយឱ្យការវិភាគអាចឆ្លើយតបទៅនឹងសំណួរគោលនៃការស្រាវជ្រាវ ហើយទន្ទឹមនឹងនោះ បង្ហាញពីរបៀបដែលអត្តសញ្ញាណ និងវិសមភាពត្រួតគ្នានៅក្នុងប្រព័ន្ធទាំងមូល អាស្រ័យលើចក្ខុវិស័យដែលបានប្រើប្រាស់។

## ៣.១ រដ្ឋាភិបាល៖ អ្នកតាក់តែង និងអ្នកអនុវត្តគោលនយោបាយ

### សំណួរស្រាវជ្រាវទី១

តើមន្ត្រីរដ្ឋាភិបាលបញ្ជ្រាប ឬដាក់បញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គមយ៉ាងដូចម្តេច? តើពួកគេជួបប្រទះបញ្ហាប្រឈមអ្វីខ្លះ ហើយតើការគាំទ្របន្ថែមអ្វីខ្លះ ដែលនឹងជួយពង្រឹងការដាក់បញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ទៅក្នុងការងាររបស់ពួកគេ?

## ៣.១.១ ទិដ្ឋភាពទូទៅនៃក្របខណ្ឌគោលនយោបាយ និងការអនុវត្តពាក់ព័ន្ធនឹងទិន្នន័យ និងការពិគ្រោះយោបល់

ប្រទេសកម្ពុជាមិនមានច្បាប់គោលតែមួយ ដែលតម្រូវឱ្យមានការពិគ្រោះយោបល់ប្រកបដោយបរិយាបន្ននោះទេ ការសិក្សាសមិទ្ធិលទ្ធភាព និងការប្រើប្រាស់ទិន្នន័យនៅទូទាំងដំណើរការតាក់តែងគោលនយោបាយ និងច្បាប់ទាំងអស់នោះទេ។ ផ្ទុយទៅវិញ អភិក្រមរបស់រដ្ឋាភិបាលឆ្លុះបញ្ចាំងពីការប្រចាច់បញ្ចូលគ្នានូវលក្ខខណ្ឌតម្រូវផ្លូវច្បាប់តាមវិស័យជាក់លាក់ ការអនុវត្តផ្នែករដ្ឋបាល និងបទដ្ឋានគោលនយោបាយដែលតម្រឹមតម្រង់ដោយការប្តេជ្ញាចិត្តជាអន្តរជាតិ។ ច្បាប់ស្តីពីបរិស្ថាន រួមមានច្បាប់ស្តីពីការការពារបរិស្ថាន និងក្រមបរិស្ថាន និងធនធានធម្មជាតិ បានផ្តល់ជាករណីយុត្តិសាស្ត្រ ច្បាស់លាស់បំផុត សម្រាប់ការវាយតម្លៃផលប៉ះពាល់ជាកាតព្វកិច្ច និងការពិគ្រោះយោបល់ជាសាធារណៈក្នុងអំឡុងពេលរៀបចំផែនការ និងតាក់តែងគោលនយោបាយ។ ក្រៅពីវិស័យទាំងនេះ ការពិគ្រោះយោបល់ និងការប្រើប្រាស់ការស្រាវជ្រាវមិនត្រូវបានតម្រូវឱ្យអនុវត្តជាកាតព្វកិច្ចដោយលិខិតបទដ្ឋានគតិយុត្តឡើយ ប៉ុន្តែរំពឹងថានឹងធ្វើឡើងកាន់តែច្រើនឡើងនៅក្នុងការអនុវត្តជាក់ស្តែង ជាពិសេសសម្រាប់យុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិ។ ការប្តេជ្ញាចិត្តរបស់កម្ពុជាក្រោមក្របខណ្ឌអន្តរជាតិ ដូចជា អនុសញ្ញាស្តីពីការបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងនារីភេទ និងអនុសញ្ញាស្តីពីសិទ្ធិជនពិការ រួមជាមួយនឹងស្ថាប័នសម្របសម្រួល ក៏បានពង្រឹងការរំពឹងទុកជុំវិញទិន្នន័យ ការពិគ្រោះយោបល់ និងការរាយការណ៍ផងដែរ សូម្បីតែក្នុងករណីដែលចំណុចទាំងនេះមិនត្រូវបានចែងក្នុងច្បាប់ក៏ដោយ។

ក្នុងការអនុវត្តគោលនយោបាយ រដ្ឋាភិបាលតែងតែទទួលស្គាល់ពីតម្លៃនៃការស្រាវជ្រាវ ការត្រួតពិនិត្យ និងការចូលរួមពីភាគីពាក់ព័ន្ធ ជាពិសេសលើវិស័យដែលពាក់ព័ន្ធនឹងសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម។ គោលនយោបាយ និងផែនការសកម្មភាពជាតិភាគច្រើន រួមបញ្ចូលបទប្បញ្ញត្តិសម្រាប់ការត្រួតពិនិត្យ ការវាយតម្លៃ និងការពិនិត្យឡើងវិញតាមកាលកំណត់ ហើយគោលនយោបាយ និងផែនការសកម្មភាពជាតិជាច្រើនសង្កត់ធ្ងន់លើការតម្រូវឱ្យទាក់ទាញការចូលរួមពីក្រសួងស្ថាប័នពាក់ព័ន្ធ អាជ្ញាធរថ្នាក់ក្រោមជាតិ សង្គមស៊ីវិល និងសហគមន៍ដែលរងផលប៉ះពាល់។ ឧទាហរណ៍ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ (ធ្វើបច្ចុប្បន្នភាពឆ្នាំ២០២៤) គូសបញ្ជាក់ពីយន្តការសម្រាប់ការត្រួតពិនិត្យផ្អែកលើលទ្ធផល ការសម្របសម្រួលអន្តរក្រសួង និងការចូលរួមនៅថ្នាក់ក្រោមជាតិ។ ស្រដៀងគ្នានេះដែរ ផែនការយុទ្ធសាស្ត្រនារីរតនៈទី៦ និងផែនការសកម្មភាពយេនឌ័រតាមវិស័យពាក់ព័ន្ធ បានកំណត់ក្របខណ្ឌត្រួតពិនិត្យ និងលើកឡើងពីសារៈសំខាន់នៃការពិគ្រោះយោបល់ជាមួយសង្គមស៊ីវិល និងអាជ្ញាធរមូលដ្ឋាន ចំណែកក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០១៦-២០២៥ បានចែងយ៉ាងច្បាស់លាស់អំពីការសម្របសម្រួលពហុភាគី និងការចូលរួមរបស់សហគមន៍ក្នុងដំណើរការអនុវត្ត។

៩ រាជរដ្ឋាភិបាលកម្ពុជា ច្បាប់ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ (ឆ្នាំ១៩៩៦) និងក្រមបរិស្ថាន និងធនធានធម្មជាតិ (អនុម័តឆ្នាំ២០២៣) ដែលកំណត់កាតព្វកិច្ចឱ្យធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ និងការចូលរួមរបស់សាធារណជន ក្នុងអំឡុងនៃការធ្វើផែនការគម្រោង ការអភិវឌ្ឍគោលនយោបាយ និងដំណើរការអនុម័ត។

ទន្ទឹមនឹងនេះដែរ ក្រសួងមួយចំនួន រួមទាំងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានបង្កើតអង្គភាពស្រាវជ្រាវ ឬអង្គភាពវិភាគផ្ទៃក្នុង ដើម្បីគាំទ្រដល់ការតាក់តែងគោលនយោបាយ ការត្រួតពិនិត្យ និងការវាយតម្លៃ។ ទោះជាយ៉ាងណា តួនាទី និងមុខងាររបស់ក្រុមការងារទាំងនេះនៅតែមានលក្ខណៈក្រៅផ្លូវការ និងមិនជាប់លាប់ ដែលធ្វើឱ្យពួកគេមិនសូវមានសមត្ថភាពក្នុងការបង្កើត និងប្រើប្រាស់ទិន្នន័យជាប្រព័ន្ធនៅក្នុងវដ្តគោលនយោបាយទាំងមូល។

ក្នុងការអនុវត្តជាក់ស្តែង ការស្រាវជ្រាវ និងការបង្កើតចំណេះដឹងពាក់ព័ន្ធនឹងសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ភាគច្រើនទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុតាមរយៈកម្មវិធីគាំទ្រដោយម្ចាស់ជំនួយ ដែលធ្វើការជាដៃគូជាមួយរដ្ឋាភិបាល ជាជាងទទួលបានពីកញ្ចប់ថវិកាជាតិដាច់ដោយឡែក ដែលអាចកំណត់បានយ៉ាងច្បាស់លាស់។ ធនធានរដ្ឋាភិបាលសម្រាប់ សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម និងការបង្កើតទិន្នន័យ ជាទូទៅត្រូវបានដាក់បញ្ចូលទៅក្នុងថវិកាក្រសួងតាមវិស័យ និងផែនការជាតិ[១០] ខណៈដែលការវិនិយោគទ្រង់ទ្រាយធំលើការស្រាវជ្រាវ ទិន្នន័យ និងការពិភាក្សាគោលនយោបាយប្រកបដោយបរិយាបន្ន នៅតែបន្តជំរុញដោយដៃគូអភិវឌ្ឍន៍។ ជារួម ចំណុចនេះឆ្លុះបញ្ចាំងពីទម្រង់អភិបាលកិច្ចមួយ ដែលសារៈសំខាន់នៃការស្រាវជ្រាវ ទិន្នន័យ និងបរិយាបន្ន ហើយត្រូវបានទទួលស្គាល់ និងអនុវត្តយ៉ាងច្បាស់លាស់ ប៉ុន្តែការធ្វើស្ថាប័នូបនីយកម្ម នៅមានកម្រិតមិនស្មើគ្នានៅតាមវិស័យនានា និងបន្តពឹងផ្អែកយ៉ាងខ្លាំងលើការគាំទ្រពីខាងក្រៅដើម្បីប្រែក្លាយការប្តេជ្ញាចិត្តទៅជាការអនុវត្តជាប្រព័ន្ធ។

ក្នុងបទសម្ភាសន៍នានា មន្ត្រីរដ្ឋាភិបាលតែងតែពណ៌នាអំពីបរិយាកាសគោលនយោបាយមួយ ដែលទទួលស្គាល់តម្លៃរបស់ សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម និងកំពុងឈានទៅដាក់បញ្ចូល សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ឱ្យកាន់តែរឹងមាំនៅក្នុងប្រព័ន្ធទាំងមូល។ ការប្តេជ្ញាចិត្តទាំងនេះ ត្រូវបានពង្រឹងដោយក្របខណ្ឌជាតិ ដូចជាយុទ្ធសាស្ត្របញ្ចកោណ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ផែនការយុទ្ធសាស្ត្រនារីរតនៈទី៦ ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ផែនការមេស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ (២០១៨-២០៣០)[១១] និងការរួមចំណែករបស់កម្ពុជាដើម្បីអនុវត្តអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (NDC 3.0)។[១២] បន្ថែមពីលើនេះ គំនិតផ្តួចផ្តើមជាតិសំខាន់ៗជាច្រើន បាន និងកំពុងដំណើរការ រួមមានគោលនយោបាយថ្មីៗស្តីពីសមភាពយេនឌ័រ និងបរិយាបន្នសង្គម ដែលរំពឹងថានឹងត្រូវអនុវត្តនៅគ្រប់ក្រសួងស្ថាប័នទាំងអស់ នៅពេលត្រូវបានអនុម័ត។ ការវិវត្តន៍ទាំងនេះអាចផ្តល់នូវក្របខណ្ឌសកម្មភាពរួមមួយ និងជំរុញប្រទេសកម្ពុជាឆ្ពោះទៅរកការអនុវត្តសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ឱ្យបានកាន់តែរលូន និងមានភាពទូលំទូលាយ។

នៅពេលឆ្លុះបញ្ចាំងពីធាតុផ្សំទាំងបួននៃក្របខណ្ឌវិភាគ (សមភាពយេនឌ័រ បរិយាបន្នពិការភាព បរិយាបន្នសង្គម និងអន្តរប្រសព្វ) ទិន្នន័យបានបង្ហាញពីប្រព័ន្ធមួយដែលកំពុងវិវត្តឥតឈប់ឈរ ប៉ុន្តែនៅមិនទាន់មានកម្រិតស្មើគ្នា ដោយមានចំណុចខ្លាំងជាក់ច្បាស់នៅក្នុងគោលបំណងនៃគោលនយោបាយ ប៉ុន្តែនៅតែមានបញ្ហាប្រឈមក្នុងការអនុវត្ត។ ក្រសួងស្ថាប័នរដ្ឋាភិបាលនៅបន្តតម្រឹមតម្រង់របៀបនៃការបកស្រាយ ការអនុវត្ត និងការត្រួតពិនិត្យសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម នៅទូទាំងប្រព័ន្ធគោលនយោបាយ និងប្រព័ន្ធចំណេះដឹងនៅកម្ពុជា។ គោលនយោបាយថ្នាក់ជាតិ មានគោលបំណងមុតស្រួច ហើយបច្ចុប្បន្ន ក្រសួងភាគច្រើនបានបញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ទៅក្នុងយុទ្ធសាស្ត្រ កំណែទម្រង់ និងផែនការតាមវិស័យរបស់ខ្លួន។

៩ កម្មវិធីដូចជា កម្មវិធី ACCESS ដំណាក់កាលទី២ ដែលទទួលបានហិរញ្ញប្បទានពីអូស្ត្រាលី កម្មវិធី CAPRED និងកម្មវិធីពន្លកចំណេះ ធ្វើការដោយផ្ទាល់ជាមួយភាគីរដ្ឋាភិបាល ដើម្បីបញ្ជ្រាបគោលការណ៍សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ទៅក្នុងការអនុវត្តការធ្វើផែនការគោលនយោបាយ និងការវិនិយោគ និងការរៀបចំថវិកាថ្នាក់ក្រោមជាតិ។ ការផ្តល់មូលនិធិសម្រាប់ការអនុវត្ត និងការស្រាវជ្រាវទាក់ទងនឹងសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ភាគច្រើនត្រូវបានផ្តល់ជូនតាមរយៈកម្មវិធីរបស់ម្ចាស់ជំនួយ។ ក្រសួងស្ថាប័នរដ្ឋាភិបាលបែងចែកថវិកាផ្ទៃក្នុងសម្រាប់ការអនុវត្តផែនការជាតិ ប៉ុន្តែថវិកាទាំងនេះច្រើនតែត្រូវបានដាក់បញ្ចូលទៅក្នុងថវិកាតាមវិស័យដែលមានស្រាប់ (ក្រសួងកិច្ចការនារី ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល) ជាជាងបញ្ចូលទៅក្នុងបន្ទាត់ថវិកាដាច់ដោយឡែក ដែលបានកំណត់សម្រាប់ការស្រាវជ្រាវ ឬការត្រួតពិនិត្យសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម។

១០ ថវិការដ្ឋនៅមិនទាន់មានការបែងចែកដាច់ពីគ្នានៅឡើយ រវាងកញ្ចប់ថវិការបស់រដ្ឋាភិបាល និងធនធានខាងក្រៅ ដែលត្រូវបានបែងចែកជាពិសេសសម្រាប់គម្រោងដែលទាក់ទងនឹងសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម។

១១ ផែនការមេស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ ២០១៨-២០៣០

១២ https://ncsd.moe.gov.kh/node/add/resources

## ៣.១.២ សមភាពយេនឌ័រនៅក្នុងរចនាសម្ព័ន្ធរដ្ឋាភិបាល និងដំណើរការគោលនយោបាយ

សមភាពយេនឌ័រ គឺជាធាតុផ្សំមួយនៃសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ដែលត្រូវបានចាក់ឫសជ្រៅជាងគេទៅក្នុងរដ្ឋាភិបាល។ ក្រសួងមួយចំនួន រួមមានក្រសួងកិច្ចការនារី ក្រសួងផែនការ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងផ្សេងៗទៀត មានអាណត្តិបញ្ជ្រាបយេនឌ័រ ដែលត្រូវបានចែងយ៉ាងច្បាស់លាស់នៅក្នុងយុទ្ធសាស្ត្រ និងផែនការសកម្មភាពតាមវិស័យ។

*ផែនការយុទ្ធសាស្ត្រនារីរតនៈទី៥* (២០១៩-២០២៣)[១៣] និងផែនការយុទ្ធសាស្ត្រនារីរតនៈទី៦[១៤] របស់ក្រសួងកិច្ចការនារី នៅតែជាបង្គោលសម្រាប់អាទិភាពយេនឌ័រថ្នាក់ជាតិ ដោយមានការប្តេជ្ញាចិត្តចំពោះការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ភាពជាអ្នកដឹកនាំ និងការការពារពីអំពើហិង្សាផ្អែកលើយេនឌ័រ។[១៥] ផែនការយុទ្ធសាស្ត្រនារីរតនៈទី៦ ផ្សារភ្ជាប់នឹងក្របខណ្ឌគតិយុត្ត គោលនយោបាយ កម្មវិធីកំណែទម្រង់ និងគោលនយោបាយតាមវិស័យនានា ដើម្បីបំពេញការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល។ ទន្ទឹមនឹងនេះ ក្រសួងកិច្ចការនារីកំពុងរៀបចំគោលនយោបាយជាតិស្តីពីសមភាពយេនឌ័រ ដែលត្រូវបានលើកទឹកចិត្ត និងត្រៀមដាក់ជូនទីស្តីការគណៈរដ្ឋមន្ត្រី។ រួមបញ្ចូលគ្នា ក្របខណ្ឌទាំងនេះបានពង្រឹងការប្តេជ្ញាចិត្តរបស់កម្ពុជាក្រោមអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ និងបង្កើតបានជាឆ្អឹងខ្នងនៃការងារយេនឌ័រនៅទូទាំងវិស័យនានា។

[១៣] ផែនការយុទ្ធសាស្ត្រនារីរតនៈទី៥ (២០១៩-២០២៣)

[១៤] ផែនការយុទ្ធសាស្ត្រនារីរតនៈទី៦-អង់គ្លេស-V10_Web.pdf

[១៥] ក្រសួងកិច្ចការនារី បានដាក់ឱ្យដំណើរការ និងផ្សព្វផ្សាយជាផ្លូវការនូវផែនការយុទ្ធសាស្ត្រនារីរតនៈទី៦ ឆ្នាំ២០២៤-២០២៨ នៅថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី និងក្មេងស្រីនៅកម្ពុជា។ ផែនការយុទ្ធសាស្ត្រនារីរតនៈទី៦ គឺជាផែនការមេរយៈពេល ៥ ឆ្នាំ ដែលកំណត់នូវវិធានការចំនួន ៤១ ដោយផ្តោតលើការបញ្ជ្រាបយេនឌ័រតាមរយៈអភិក្រមបរិវត្តកម្មយេនឌ័រ រួមជាមួយនឹងកម្មវិធីអាទិភាពចំនួន ៦ ស្តីពីការលើកកម្ពស់ ១.ភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី ២.សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារ ៣.សុខុមាលភាពរបស់ស្ត្រី និងក្មេងស្រី ៤.ការការពារផ្លូវច្បាប់សម្រាប់ស្ត្រី និងក្មេងស្រី ៥.ស្ត្រីក្នុងភាពជាអ្នកដឹកនាំ និងអភិបាលកិច្ច និង ៦.ស្ត្រី និងការប្រែប្រួលអាកាសធាតុ។

ប្រអប់ទី ២

## ការចូលរួមពីក្រសួងកិច្ចការនារី

ក្រសួងកិច្ចការនារី បានពណ៌នាអំពីបរិយាកាសគោលនយោបាយមួយដែលកំពុងរីកវិសាលភាពបណ្តើរៗ ពីរបៀបវារៈរបស់ក្រសួងទៅជារបៀបវារៈថ្នាក់ជាតិ។ មន្ត្រីបានពន្យល់ថា ផែនការយុទ្ធសាស្ត្រនារីរតនៈទី៦ ត្រូវបានបង្កើតឡើងដោយសារតែ "ភាគីពាក់ព័ន្ធភាគច្រើនយល់ថា វាជារបស់ក្រសួងកិច្ចការនារីតែមួយគត់" ហើយក្រសួងចង់បានឧបករណ៍មួយដែលអាច "ជះឥទ្ធិពលដល់ក្រសួងផ្សេងទៀតឱ្យគិតគូរអំពីយេនឌ័រ"។ គោលនយោបាយនេះ ត្រូវបានបញ្ចប់ជាស្ថាពរជាផែនការយុទ្ធសាស្ត្រនារីរតនៈទី៦ និងត្រូវបានអនុម័តនៅក្នុងខែមីនា ឆ្នាំ២០២៤។

ដំណើរការអភិវឌ្ឍគោលនយោបាយ និងដំណើរការនៃការបញ្ជ្រាបយេនឌ័ររបស់ក្រសួងកិច្ចការនារី បង្ហាញពីវិធីសាស្ត្រដែលដឹកនាំដោយរដ្ឋ និងមានរចនាសម្ព័ន្ធច្បាស់លាស់ សម្រាប់ការចូលរួម និងការប្រើប្រាស់ទិន្នន័យ ដោយមានការសង្កត់ធ្ងន់កាន់តែច្បាស់លើការពិគ្រោះយោបល់ ជាជាងការរួមគ្នាកំណត់របៀបវារៈ។ ឯកសារយុទ្ធសាស្ត្រ ដូចជាគោលនយោបាយជាតិស្តីពីយេនឌ័រ និងផែនការយុទ្ធសាស្ត្រនារីរតនៈទី៥ ទទួលបានព័ត៌មានពីការវាយតម្លៃយេនឌ័ររៀងរាល់ប្រាំឆ្នាំនៅទូទាំងវិស័យចំនួនប្រាំមួយ ដោយទាញយកពីការប្រាបាច់បញ្ចូលគ្នានូវទិន្នន័យតាមដានផ្នែករដ្ឋបាល អង្កេតថ្នាក់ជាតិ (រួមទាំងអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា-CDHS និងកម្មវិធី ACCESS) ការពិនិត្យឡើងវិញលើឯកសារដែលមានស្រាប់ និងការប្រមូលទិន្នន័យបឋមតាមគោលដៅនៅក្នុងតំបន់ដែលបានជ្រើសរើស។ ការពិគ្រោះយោបល់មានច្រើនកម្រិត និងធ្វើតាមលំដាប់លំដោយ ដោយចាប់ផ្តើមឡើងបន្ទាប់ពីមានសេចក្តីព្រាងដំបូង និងគ្របដណ្តប់ដល់ក្រសួងស្ថាប័នថ្នាក់ជាតិ អាជ្ញាធរថ្នាក់ក្រោមជាតិ អង្គការសង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ និងអ្នកទទួលផលពីកម្មវិធីសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ដែលបានជ្រើសរើស ដោយទំហំនៃការចូលរួមត្រូវបានកំណត់ដោយថវិកាដែលមាន។ ការស្រាវជ្រាវ និងទិន្នន័យ ត្រូវបានយកមកធ្វើជាធាតុចូល រួមទាំងការសិក្សាដែលត្រូវបានចាត់តាំងឱ្យធ្វើ និងការស្រាវជ្រាវរបស់អង្គការសង្គមស៊ីវិលដែលបានជ្រើសរើស ដែលគុណភាពនៃវិធីសាស្ត្រ និងភាពតំណាងរបស់វាត្រូវបានចាត់ទុកថាគ្រប់គ្រាន់។ ទោះជាយ៉ាងណា ការចូលរួមភាគច្រើនមានទម្រង់ជាការពិគ្រោះយោបល់ ជាជាងការសហការបង្កើត ដោយក្រសួងកិច្ចការនារីនៅតែរក្សាការគ្រប់គ្រងលើការកំណត់ក្របខណ្ឌ អាទិភាព និងការផ្ទៀងផ្ទាត់។

ខណៈដែលផែនការសកម្មភាពបញ្ជ្រាបយេនឌ័រតាមវិស័យនៅទូទាំង ២៩ ក្រសួង មានលើកឡើងអំពីការត្រួតពិនិត្យ និងការរាយការណ៍ ការចូលរួមរបស់សហគមន៍ត្រូវបានលើកឡើងច្បាស់លាស់នៅដំណាក់កាលអនុវត្ត និងផ្ទៀងផ្ទាត់ ជាជាងនៅក្នុងការកំណត់សំណួរស្រាវជ្រាវ ឬទិសដៅគោលនយោបាយ។ អន្តរប្រសព្វ ត្រូវបានទទួលស្គាល់នៅក្នុងឧទាហរណ៍នៃការអនុវត្ត និងតាមរយៈយន្តការនានា ដូចជា ក្រុមការងារពិការភាព និងអនុវិស័យយេនឌ័រ-អាកាសធាតុ ប៉ុន្តែវាមិនត្រូវបានកំណត់ជាប់លាប់ជាកញ្ចក់ឆ្លុះបញ្ចាំងក្នុងការវិភាគ នៅក្នុងការរៀបចំការស្រាវជ្រាវ ឬក្របខណ្ឌនៃការត្រួតពិនិត្យនោះទេ។ ក្រសួងសាម៉ីមានក្រុមការងារបញ្ជ្រាបយេនឌ័រ (GMAGs) ទោះបីជាដំណើរការរបស់ពួកគេមិនមានភាពស៊ីសង្វាក់គ្នាក៏ដោយ។ នៅក្នុងក្រសួងមួយចំនួន GMAGs កម្រជួបប្រជុំគ្នា ហើយពឹងផ្អែកតែលើបុគ្គលដែលឆ្នើមម្នាក់ៗប៉ុណ្ណោះ និងនៅមិនទាន់មានធនធានគ្រប់គ្រាន់។

យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ (២០២៣-២០២៨)[១៦] បានពង្រឹងការប្ដេជ្ញាចិត្តទាំងនេះ។ សសរស្ដម្ភសំខាន់មួយ (បញ្ចកោណទី៤ ការអភិវឌ្ឍប្រកបដោយភាពធន់ ចីរភាព និងបរិយាបន្ន) បានគូសបញ្ជាក់ពីអាទិភាពចំនួនប្រាំ ដែលពាក់ព័ន្ធដោយផ្ទាល់នឹងសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម។ អាទិភាពមួយក្នុងចំណោមអាទិភាពទាំងប្រាំនេះ គឺភាពធន់ផ្អែកប្រជាសាស្ត្រ និងសមភាពយេនឌ័រ។[១៧]

ក្រសួងអប់រំ យុវជន និងកីឡា បានបញ្ជ្រាបយេនឌ័រទៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំរបស់ខ្លួន និងប្រមូលទិន្នន័យអប់រំដោយបំបែកតាមភេទ ចាប់ពីកម្រិតសាលារៀនឡើងទៅ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានអនុវត្តសៀវភៅគោលនយោបាយយេនឌ័រ ឆ្នាំ២០២៣-២០២៨ របស់ខ្លួន តាមរយៈក្រុមការងារបញ្ជ្រាបយេនឌ័រ (GMAG) និងគាំទ្រដល់ភាពជាអ្នកដឹកនាំរបស់ស្ត្រី ការផ្សព្វផ្សាយកសិកម្ម សន្តិសុខស្បៀង និងការងារពាក់ព័ន្ធនឹងអាកាសធាតុ។ គោលនយោបាយរបស់ក្រសួងសុខាភិបាល បានគូសបញ្ជាក់ពីវិសមភាពសុខភាពផ្អែកលើយេនឌ័រ ជាពិសេសសុខភាពមាតា និងសុខភាពបន្តពូជ។ ក្រសួងផ្សេងទៀត រួមមានក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងក្រសួងផែនការ ក៏បានលើកឡើងពីយេនឌ័រនៅក្នុងផែនការតាមវិស័យរបស់ខ្លួនផងដែរ ទោះបីជាកម្រិតនៃការអនុវត្តមានភាពខុសគ្នាក៏ដោយ។

គំនិតផ្ដួចផ្ដើមទាំងនេះ គឺជាជំហានដ៏សំខាន់ឆ្ពោះទៅរកការធ្វើស្ថាប័នូបនីយកម្មលើការពិចារណាយេនឌ័រ នៅក្នុងដំណើរការប្រែក្លាយទិន្នន័យទៅជាគោលនយោបាយនៅកម្ពុជា។ ជារួម និម្មាបនកម្មយេនឌ័របានផ្ដល់មូលដ្ឋានគ្រឹះរឹងមាំគួរសម សម្រាប់គោលនយោបាយ និងការស្រាវជ្រាវផ្អែកលើទិន្នន័យ។

## ៣.១.៣. បរិយាបន្នពិការភាពនៅក្នុងការអភិវឌ្ឍគោលនយោបាយ និងប្រព័ន្ធសេវាសាធារណៈ

បរិយាបន្នពិការភាពទទួលបានការចាប់អារម្មណ៍កាន់តែខ្លាំង ក្នុងពេលដែលកម្ពុជាអនុវត្តច្បាប់ស្ដីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ និងផែនការយុទ្ធសាស្ត្រជាតិស្ដីពីពិការភាព ឆ្នាំ២០១៩-២០២៣។[១៨] ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាស្ថាប័នដឹកនាំរបៀបវារៈនេះ ដោយមានការគាំទ្រពីក្រុមប្រឹក្សាសកម្មភាពជនពិការ។ គិតមកទល់ពេលនេះ មានក្រសួងចំនួន១៩ ហើយ ដែលបានបង្កើតក្រុមការងារសកម្មភាពជនពិការ។

បណ្ដាខេត្តទាំងអស់ក៏មានក្រុមប្រឹក្សាសកម្មភាពជនពិការផងដែរ។ នេះឆ្លុះបញ្ចាំងពីកិច្ចខិតខំប្រឹងប្រែងកាន់តែខ្លាំងក្នុងការរៀបចំការងារពាក់ព័ន្ធនឹងពិការភាពនៅថ្នាក់ក្រោមជាតិ។ ផែនការយុទ្ធសាស្ត្រជាតិស្ដីពីពិការភាព ឆ្នាំ២០២៤-២០២៨ ត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់ក្នុងទិវាជនមានពិការភាពអន្តរជាតិ នៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២៤។[១៩] ផែនការយុទ្ធសាស្ត្រនេះទាញចេញពីការពិគ្រោះយោបល់ជាមួយជនមានពិការភាព សង្គមស៊ីវិល ទីភ្នាក់ងារអង្គការសហប្រជាជាតិ និងភាគីពាក់ព័ន្ធរបស់រដ្ឋាភិបាល។ ផែនការយុទ្ធសាស្ត្រនេះគឺជាយុទ្ធសាស្ត្រជាតិផ្ដោតលើបរិយាបន្នដ៏សំខាន់មួយ ដែលកំពុងដំណើរការ។ បន្ទាប់ពីការប្រកាសដាក់ឱ្យប្រើប្រាស់ មានកិច្ចខិតខំប្រឹងប្រែងផ្សព្វផ្សាយជាបន្តបន្ទាប់នៅថ្នាក់ក្រោមជាតិ។

[១៦] រាជរដ្ឋាភិបាលកម្ពុជា យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព រាជធានីភ្នំពេញ ឆ្នាំ២០២៣។
[១៧] អាទិភាពបួនទៀតនៃយុទ្ធសាស្ត្របញ្ចកោណ រួមមាន i. ការគ្រប់គ្រងធនធានធម្មជាតិ បេតិកភណ្ឌវប្បធម៌ និងទេសចរណ៍ប្រកបដោយចីរភាព ii. ការអភិវឌ្ឍកសិកម្ម និងជនបទ iii. ការគ្រប់គ្រង និងទំនើបកម្មទីក្រុង iv. ចីរភាពបរិស្ថាន ភាពធន់នឹងអាកាសធាតុ និងការលើកកម្ពស់សេដ្ឋកិច្ចបៃតង។
[១៨] ផែនការយុទ្ធសាស្ត្រជាតិស្ដីពីពិការភាព ឆ្នាំ២០១៩-២០២៣ - Laws OD Mekong Datahub
[១៩] សារព័ត៌មាន Khmertimes, ខែធ្នូ ឆ្នាំ២០២៤, https://www.khmertimeskh.com/501602542/cambodia-launches-national-disability-strategic-plan-2024-2028/

តាមរយៈការអនុវត្តអនុក្រឹត្យលេខ ៣៧២ ស្តីពីការអនុវត្តកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ នៃមូលនិធិជាតិជំនួយសង្គម ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បាន និងកំពុងខិតខំលើកកម្ពស់កម្មវិធីជាតិជំនួយសង្គម។[២០] គោលបំណងចម្បងនៃកម្មវិធីនេះគឺការពង្រឹងសុខុមាលភាពគ្រួសារ និងកសាងសង្គមមួយដែលប្រកបដោយភាពធន់។ កម្មវិធីនេះមានគោលបំណងលើកកម្ពស់សុខុមាលភាពមាតា និងទារក និងដោះស្រាយបញ្ហាកង្វះអាហារូបត្ថម្ភ ជំរុញការចុះឈ្មោះចូលរៀនរបស់កុមារឱ្យបានទាន់ពេលវេលា និងសម្រាលការលំបាកផ្នែកជីវភាពរបស់ជនមានពិការភាព ចាស់ជរា និងអ្នករស់នៅជាមួយមេរោគអេដស៍/ជំងឺអេដស៍។ គ្រួសារក្រីក្រដែលកាន់ប័ណ្ណក្រីក្រ កម្រិត១ ឬកម្រិត២ (កម្មវិធីជាតិដែលកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ និងងាយរងគ្រោះ) មានសិទ្ធិចុះឈ្មោះចូលរួមក្នុងកម្មវិធីនេះ។

អង្គការជនពិការកម្ពុជា (CDPO) បានចូលរួមយ៉ាងសស្រាក់សស្រាំនៅក្នុងដំណើរការទាំងមូលនៃការពិគ្រោះយោបល់ និងការអនុវត្តនូវកម្មវិធីមួយនេះ។ នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៥ អង្គការ CDPO បានរៀបចំការពិភាក្សាមួយក្រោមប្រធានបទ "តួនាទីរបស់អង្គការតំណាងជនមានពិការភាព និងការរួមចំណែករបស់ពួកគេដល់កម្មវិធីគាំពារសង្គមនៅថ្នាក់ក្រោមជាតិ" ដោយប្រមូលផ្តុំអ្នកតាក់តែងគោលនយោបាយ និងអង្គការតំណាងជនមានពិការភាព។ ការពិភាក្សានេះបានបង្កើតវេទិកាជាក់ស្តែងមួយសម្រាប់ឱ្យជនមានពិការភាពលើកឡើងពីក្តីកង្វល់ ចែករំលែកបទពិសោធន៍ជីវិតជាក់ស្តែង និងដាក់សំណើជាក់លាក់ដោយផ្ទាល់ទៅអាជ្ញាធរពាក់ព័ន្ធ។ក្រសួងអប់រំ យុវជន និងកីឡា បានចាត់វិធានការមួយចំនួនដែលជាក់ស្តែងបំផុត តាមរយៈគោលការណ៍ណែនាំស្តីពីការអប់រំប្រកបដោយបរិយាបន្ន និងគម្រោងសាកល្បងដែលសំដៅបង្កើតបរិយាកាសសាលារៀនដែលអំណោយផលដល់ជនមានពិការភាព។

ក្រសួងសុខាភិបាល បានពង្រឹងសេវាពិនិត្យបឋម សេវាបញ្ជូន និងសេវាស្តារនីតិសម្បទា ទោះបីជាលទ្ធភាពទទួលបានសេវានៅមានកម្រិតមិនស្មើគ្នាក៏ដោយ ជាពិសេសនៅក្រៅតំបន់ទីប្រជុំជន។ ក្រសួងផែនការ  បានពង្រីកលទ្ធភាពទទួលបានទិន្នន័យបែកចែកតាមប្រភេទនៃពិការភាព ដោយបញ្ចូលម៉ូឌុលពិការភាពទៅក្នុងអង្កេតប្រជាសាស្ត្រ និងសុខភាពថ្នាក់ជាតិ។ ទន្ទឹមនឹងនេះ ក៏មានវឌ្ឍនភាពជាបន្តបន្ទាប់នៅក្នុងកិច្ចគាំពារសង្គមប្រកបដោយបរិយាបន្នពិការភាពផងដែរ។ កំណែទម្រង់ប្រព័ន្ធអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងកម្មវិធីជំនួយសង្គម បានធ្វើឱ្យប្រសើរឡើងដល់ការកំណត់អត្តសញ្ញាណជនមានពិការភាព និងលក្ខណៈសម្បត្តិគ្រប់គ្រាន់របស់ពួកគេក្នុងការទទួលបានអត្ថប្រយោជន៍ រួមទាំងរបបប្រាក់ឧបត្ថម្ភជូនជនមានពិការភាព និងការគ្របដណ្តប់ដោយមូលនិធិសមធម៌សុខាភិបាល។[២១]

កម្មវិធីសហប្រតិបត្តិការ អូស្ត្រាលី-កម្ពុជា ដើម្បីការផ្តល់សេវាប្រកបដោយនិរន្តរភាព និងសមធម៌ (ACCESS) របស់ក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី បានបង្កើតជាទិន្នន័យ និងការយល់ដឹងជាក់ស្តែងដ៏មានប្រយោជន៍ស្តីពីបរិយាបន្នពិការភាពនៅកម្ពុជា តាមរយៈភាពជាដៃគូរយៈពេលវែងរបស់ខ្លួនជាមួយរាជរដ្ឋាភិបាលកម្ពុជា។ កម្មវិធី ACCESS (បច្ចុប្បន្ន ACCESS 2) ធ្វើការដោយផ្ទាល់ជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រុមប្រឹក្សាសកម្មភាពជនពិការ និងដៃគូរដ្ឋាភិបាលផ្សេងទៀត ដើម្បីគាំទ្រដល់ការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព និងធ្វើឱ្យប្រសើរឡើងដល់ការផ្តល់សេវាប្រកបដោយបរិយាបន្នសម្រាប់ជនមានពិការភាព។ កម្មវិធីនេះក៏គាំទ្រផងដែរដល់អង្គការតំណាងជនមានពិការភាព និងរងគ្រោះពីអំពើហិង្សាផ្អែកលើយេនឌ័រ ដើម្បីចូលរួមក្នុងដំណើរការរៀបចំផែនការ និងគោលនយោបាយ ព្រមទាំងពង្រឹងសមត្ថភាពបច្ចេកទេសនៅកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ភាពជាដៃគូ និងកិច្ចខិតខំប្រឹងប្រែងចងក្រងឯកសារទាំងនេះ រួមទាំងរបាយការណ៍ប្រចាំឆ្នាំ និងការវាយតម្លៃនានា បានផ្តល់ជាទិដ្ឋភាពទូទៅដ៏សំខាន់ស្តីពីបញ្ហាប្រឈមនៅក្នុងប្រតិបត្តិការ គម្លាតសេវា និងយន្តការចូលរួមក្នុងបរិយាបន្នពិការភាព។ [២២]

[២០] រាជរដ្ឋាភិបាលកម្ពុជា (RGC) ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២៣ អនុក្រឹត្យលេខ ៣៧២ ស្តីពីការអនុវត្តកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ នៃមូលនិធិជាតិជំនួយសង្គម។

[២១] ការវាយតម្លៃជាយុទ្ធសាស្ត្រដោយឯករាជ្យ - ការគាំទ្ររបស់ DFAT ចំពោះការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ (IDPoor) នៅកម្ពុជា ដំណាក់កាលទី៣។ ការវាយតម្លៃនេះ កត់សម្គាល់ពីការពង្រីកយន្តការសម្រាប់ការកំណត់អត្តសញ្ញាណជនមានពិការភាព តាមរយៈប្រព័ន្ធទិន្នន័យអត្តសញ្ញាណកម្មពិការភាពថ្នាក់ជាតិ និងផ្សារភ្ជាប់ចំណុចនេះទៅនឹងការកំណត់គោលដៅនៃកិច្ចគាំពារសង្គម និងការបង្កើនលទ្ធភាពទទួលបានសេវាសម្រាប់ជនមានពិការភាព។

[២២] ACCESS 2 Program, Australia Cambodia Cooperation for Equitable Sustainable Services – Phase 2 (ACCESS 2), accessed January 29, 2026, https://access2cambodia.org/access-2-program/

ទន្ទឹមនឹងនេះ បរិយាបន្នពិការភាពនៅតែមិនសូវត្រូវបានឆ្លុះបញ្ចាំងក្នុងក្របខណ្ឌអភិវឌ្ឍន៍ជាតិជារួមនោះទេ។ ក្នុងយុទ្ធសាស្ត្របញ្ចកោណ ពិការភាពស្ទើរតែមិនត្រូវបានលើកឡើង ហើយការលើកឡើងទាំងនោះ ភាគច្រើនទាក់ទងនឹងអតីតយុទ្ធជន ជាជាងជនមានពិការភាពទូទៅ។ ភាពមិនសូវលេចធ្លោបែបនេះបង្ហាញថា ពិការភាពមិនទាន់ត្រូវបានដាក់បញ្ចូលពេញលេញជាបញ្ហាអភិវឌ្ឍន៍ឆ្លងវិស័យនៅកម្រិតយុទ្ធសាស្ត្រខ្ពស់បំផុតនៅឡើយទេ។ មានន័យថា រាជរដ្ឋាភិបាលនៅតែបន្តចាត់ទុកបញ្ហានេះជាបញ្ហាតាមវិស័យ ឬជាបញ្ហាសុខុមាលភាព ជាជាងធាតុផ្សំស្នូលនៃកំណើនប្រកបដោយបរិយាបន្ន អភិបាលកិច្ច និងការអភិវឌ្ឍមូលធនមនុស្ស។

ប្រអប់ទី ៣

## បរិយាបន្នពិការភាពនៅក្រសួងមហាផ្ទៃ

នៅខែធ្នូ ឆ្នាំ២០២៣ ក្រសួងមហាផ្ទៃ បានបង្កើតក្រុមការងារសកម្មភាពជនពិការ ដើម្បីផ្តល់ការណែនាំដល់ក្រសួងលើបញ្ហាពិការភាព និងពង្រឹងបរិយាបន្នជនមានពិការភាពនៅក្នុងជួរមន្ត្រីរបស់ខ្លួន។ ដឹកនាំដោយរដ្ឋលេខាធិការ និងធ្វើជាប្រធានកិត្តិយសដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្រុមការងារនេះមានកាតព្វកិច្ចផ្តល់យោបល់ផ្នែកគោលនយោបាយ គាំទ្រដល់ការអភិវឌ្ឍផែនការ និងយុទ្ធសាស្ត្រ និងដាក់សំណើកែសម្រួលច្បាប់ និងបទប្បញ្ញត្តិទាក់ទងនឹងពិការភាព តាមរយៈក្រុមប្រឹក្សាសកម្មភាពជនពិការកម្ពុជា។ ការផ្តោតសំខាន់របស់ក្រុមការងារនេះ គឺស្ថាប័នជាជាងការផ្តល់សេវា ដោយសង្កត់ធ្ងន់លើការធ្វើឱ្យប្រសើរឡើងនូវឋានៈ/ស្ថានភាព ការបណ្តុះបណ្តាល និងឱកាសការងាររបស់មន្ត្រីរាជការមានពិការភាពនៅក្នុងក្រសួងមហាផ្ទៃ ដែលបច្ចុប្បន្នមានត្រឹមតែ ០,៩៣ ភាគរយប៉ុណ្ណោះ។ ខណៈដែលគំនិតផ្តួចផ្តើមនេះបង្ហាញពីការបង្កើនការយកចិត្តទុកដាក់ចំពោះបរិយាបន្នពិការភាពនៅក្នុងរដ្ឋបាលសាធារណៈ វាក៏ចោទជាសំណួរពាក់ព័ន្ធនឹងការសម្របសម្រួលផងដែរ ព្រោះតាមច្បាប់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានតួនាទីទទួលខុសត្រូវលើសុខុមាលភាពរបស់ជនមានពិការភាព។ ចំណុចនេះរំលេចឱ្យឃើញភាពចាំបាច់នៃការកំណត់អាណត្តិច្បាស់លាស់ជាងមុន និងការតម្រឹមអន្តរក្រសួងឱ្យបានរឹងមាំ ដើម្បីបញ្ចៀសភារកិច្ចត្រួតគ្នា និងធានាឱ្យមានការអនុវត្តសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ប្រកបដោយសង្គតិភាព។

ប្រអប់ទី ៤
### បរិយាបន្នពិការភាពនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបរាប់អំពីអភិក្រមដែលមានរចនាសម្ព័ន្ធ ប៉ុន្តែទើបបានរៀបចំឡើងសម្រាប់បរិយាបន្នពិការភាព។ ក្រសួងមានក្រុមការងារសកម្មភាពជនពិការ ដែលត្រូវបានបង្កើតឡើង "ដើម្បីពិនិត្យមើលថាតើក្រសួងមានជ្រើសរើសជនមានពិការភាពឱ្យបម្រើការងារដែរ ឬទេ" និងដើម្បីបង្ហាញពីការប្តេជ្ញាចិត្តរបស់ក្រសួងចំពោះ "សមធម៌ និងសមភាព" ស្របតាមគោលនយោបាយរបស់រដ្ឋាភិបាល។ ក្រសួងបានផ្តល់ទិន្នន័យពិការភាពសម្រាប់បញ្ចូលទៅក្នុងដំណើរការថ្នាក់ជាតិ ដែលដឹកនាំដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា តាមរយៈការចូលរួមក្នុងការអនុវត្តជំរឿន សិក្ខាសាលា និងសន្និសីទស្តីពីពិការភាព។

មន្ត្រីបានកត់សម្គាល់ថា ការងារពាក់ព័ន្ធនឹងពិការភាព "មានភាពលំបាកជាងការងារពាក់ព័ន្ធនឹងយេនឌ័រ" ព្រោះវាទាមទារទិន្នន័យចំគោលដៅ និងការសម្របសម្រួលច្រើនជាង។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានការិយាល័យមួយសម្រាប់ទទួលបន្ទុកជនមានពិការភាព និងអង្គភាពថ្នាក់ខេត្តចំនួន ២៥ ដោយចាប់ផ្តើមពីបុគ្គលិកផ្ទៃក្នុង និងពង្រីកកិច្ចខិតខំប្រឹងប្រែងដល់កសិករ រួមទាំងកសិករមានពិការភាពផងដែរ។ ខណៈដែលក្រសួងមិនមានកញ្ចប់ថវិកាដាច់ដោយឡែក ការប្តេជ្ញាចិត្តរបស់ថ្នាក់ដឹកនាំ ក្រុមការងារសកម្មភាព និងភាពជាដៃគូ ត្រូវបានកំណត់ថាជាកត្តាដ៏សំខាន់ដែលជំរុញវឌ្ឍនភាព ដោយជួយធានាបាននូវ "ការគាំទ្រដោយមិនទុកនរណាម្នាក់ចោល"។

## ៣.១.៤. បរិយាបន្នសង្គម៖ ជនជាតិភាគតិច ជនជាតិដើមភាគតិច ភូមិសាស្ត្រ សេដ្ឋកិច្ចសង្គម និងអាយុ

បរិយាបន្នសង្គមនៅក្នុងមជ្ឈដ្ឋានស្រាវជ្រាវ និងគោលនយោបាយរបស់កម្ពុជា នៅតែមានកម្រិតមិនស្មើគ្នា។ ក្របខណ្ឌយេនឌ័រ និងពិការភាពមានមូលដ្ឋានស្ថាប័នច្បាស់លាស់ជាងមុន ដែលគាំទ្រដោយការប្តេជ្ញាចិត្តថ្នាក់ជាតិ ដូចជា យុទ្ធសាស្ត្របញ្ចកោណ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព។ ផ្ទុយទៅវិញ បរិយាបន្នសង្គមដែលទូលំទូលាយជាងនេះ នៅមានលក្ខណៈរប៉ាត់រប៉ាយ និងមានភាពខុសគ្នាខ្លាំងនៅតាមក្រសួងនានា និងកម្រិតរដ្ឋាភិបាលផ្សេងៗគ្នា។ ជនជាតិដើមភាគតិច ជនជាតិភាគតិច សហគមន៍ជនបទ និងជនក្រីក្រនៅទីក្រុង គឺជាក្រុមដែលត្រូវបានលើកឡើងញឹកញាប់បំផុតនៅក្នុងឯកសារថ្នាក់ជាតិ ប៉ុន្តែភាពស៊ីជម្រៅនៃការចូលរួមមានភាពខុសគ្នាខ្លាំង។[២៣] បទដ្ឋានសង្គម សមត្ថភាពផ្នែករដ្ឋបាល និងវិសមភាពផ្នែករចនាសម្ព័ន្ធ នៅតែបន្តជះឥទ្ធិពលលើថាតើនរណាខ្លះបានចូលរួមក្នុងដំណើរការស្រាវជ្រាវ និងថាតើនរណាខ្លះទទួលបានអត្ថប្រយោជន៍ពីការសម្រេចចិត្តលើគោលនយោបាយ។

២៣ ឯកសារគោលនយោបាយ និងផែនការជាតិរបស់កម្ពុជា តែងតែលើកឡើងអំពីជនជាតិដើមភាគតិច ជនជាតិភាគតិច សហគមន៍ជនបទ និងជនក្រីក្រនៅទីក្រុង ជាក្រុមអាទិភាព។ ទោះជាយ៉ាងណា កម្រិតនៃការចូលរួម និងភាពជាក់លាក់នៃការប្តេជ្ញាចិត្ត មានភាពខុសគ្នាខ្លាំងនៅក្នុងឯកសារនានា ចាប់តាំងពីរបាយការណ៍ជាតិស្តីពីស្ថានភាពប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គមរបស់ជនជាតិដើមភាគតិចនៅកម្ពុជា និងលិខិតបទដ្ឋានស្តីពីសិទ្ធិដីធ្លី រហូតដល់ក្របខណ្ឌសេដ្ឋកិច្ចសង្គមទូលំទូលាយ ដូចជា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម (២០២៤-២០៣៥)។ ក្នុងករណីជាច្រើន ក្រុមទាំងនេះត្រូវបានកំណត់ជាប្រជាជនអាទិភាព ប៉ុន្តែមិនត្រូវបានឆ្លុះបញ្ចាំងច្បាស់លាស់នៅក្នុងយន្តការអនុវត្ត ប្រព័ន្ធត្រួតពិនិត្យ ឬដំណើរការចូលរួមប្រកបដោយអត្ថន័យនោះទេ។

វិស័យមួយចំនួនបង្ហាញពីការយកចិត្តទុកដាក់ខ្លាំងជាងមុនចំពោះវិសមភាពសង្គម និងភូមិសាស្ត្រ។ ស្ថាប័នដែលបំពេញការងារពាក់ព័ន្ធនឹងទេសន្តរប្រវេសន៍ការងារ ការអភិវឌ្ឍយុវជន និងកិច្ចគាំពារសង្គម បានរំលេចទំនាក់ទំនងគ្នា កាន់តែច្បាស់លាស់រវាងការផាត់ចេញ ភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ច និងការទទួលបានសេវា។ ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ដែលមានក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាស្ថាប័នអនុវត្តផ្ទាល់ បានកំណត់កម្មករនិយោជិតក្រៅប្រព័ន្ធ ប្រជាជនវ័យចំណាស់ និងគ្រួសារងាយរងគ្រោះ ជាក្រុមអាទិភាព ដែលនេះជាសញ្ញានៃកិច្ចខិតខំប្រឹងប្រែង ដើម្បីតម្រឹមតម្រង់កិច្ចគាំពារសង្គមឱ្យស្របនឹងបទពិសោធន៍ជីវិតជាក់ស្តែង ជាជាងចាត់ទុកភាពក្រីក្រជាស្ថានភាពដែលមិនប្រែប្រួល។ ក្រសួងបរិស្ថាន ក៏តំណាងឱ្យឧទាហរណ៍លេចធ្លោមួយនៃការអនុវត្តការពិគ្រោះយោបល់កាន់តែទូលំទូលាយផងដែរ ជាពិសេសតាមរយៈការងាររបស់ក្រសួងលើការគ្រប់គ្រងតំបន់ការពារធម្មជាតិ និងការតម្រូវឱ្យមានការយល់ព្រមជាមុនដោយសេរី និងទទួលបានព័ត៌មានគ្រប់គ្រាន់ (FPIC) នៅក្នុងដំណើរការពាក់ព័ន្ធ។ សូម្បីតែនៅពេលដែលក្រសួងបរិស្ថានមិនបានចូលរួមដោយផ្ទាល់ក៏ដោយ ក៏ភាពជាដៃគូរបស់ក្រសួងជាមួយទីភ្នាក់ងារអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល តែងតែមានការចូលរួមពីជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋានដែរ។ នេះឆ្លុះបញ្ចាំងពីការយកចិត្តទុកដាក់ខ្លាំងជាងមុនចំពោះការចូលរួមប្រកបដោយអត្ថន័យ និងការធ្វើសេចក្តីសម្រេចដែលផ្អែកលើតថភាពក្នុងមូលដ្ឋាន។[២៤]

## ៣.១.៥. អន្តរប្រសព្វ៖ ឧបសគ្គត្រួតគ្នា និងចំណុចខ្វះចន្លោះក្នុងគោលនយោបាយ

អន្តរប្រសព្វ គឺជាកត្តាសំខាន់សម្រាប់ការស្វែងយល់អំពីរបៀបដែលទម្រង់ផ្សេងៗនៃភាពងាយរងគ្រោះ រួមបញ្ចូលគ្នាដើម្បីជះឥទ្ធិពលលើការទទួលបានចំណេះដឹង ការចូលរួមក្នុងដំណើរការគោលនយោបាយ និងបទពិសោធន៍នៃការទទួលបានសេវារដ្ឋ។ ទោះជាយ៉ាងណា អន្តរប្រសព្វនៅតែជាសសរស្តម្ភដែលមានការយល់ដឹងតិចតួចបំផុតនៅទូទាំងប្រព័ន្ធទិន្នន័យរបស់រដ្ឋាភិបាល។ ទោះបីជាពាក្យ "សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម" ត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយក៏ដោយ ប៉ុន្តែមន្ត្រីជាច្រើនបកស្រាយថា វាជាបញ្ជីត្រួតពិនិត្យលើធាតុផ្សំដាច់ដោយឡែកពីគ្នា ជាជាងជាកញ្ចក់ឆ្លុះបញ្ចាំងរបៀបដែលអត្តសញ្ញាណច្រើនយ៉ាង ជះឥទ្ធិពលលើគ្នាទៅវិញទៅមក។

គោលនយោបាយនានា ដូចជា ផែនការយុទ្ធសាស្ត្រនារីរតនៈទី៦ ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព និងក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម បានលើកឡើងពីក្រុមងាយរងគ្រោះជាច្រើន ប៉ុន្តែឯកសារទាំងនេះកម្រវិភាគពីរបៀបដែលយេនឌ័រ ពិការភាព ជាតិពន្ធុ ភូមិសាស្ត្រ និងភាពក្រីក្រ ជះឥទ្ធិពលលើគ្នាទៅវិញទៅមក។ នេះធ្វើឱ្យការឆ្លើយតបផ្នែកគោលនយោបាយ មានលក្ខណៈដាច់ដោយឡែកពីគ្នា៖ យេនឌ័រត្រូវបានដោះស្រាយដោយក្រុមការងារបញ្ជ្រាបយេនឌ័រ (GMAGs) ហើយពិការភាពត្រូវបានដោះស្រាយដោយក្រុមប្រឹក្សាសកម្មភាពជនពិការ និងមន្ត្រីបង្គោលពិការភាព។ បញ្ហាជនជាតិដើមភាគតិចត្រូវបានដោះស្រាយដោយក្រសួងអភិវឌ្ឍន៍ជនបទ ចំណែកបញ្ហាសេដ្ឋកិច្ចសង្គមត្រូវបានដោះស្រាយដោយក្រសួងផែនការ និងស្ថាប័នផ្សេងទៀត។ ការងាររប៉ាត់រប៉ាយបែបនេះ ធ្វើឱ្យរដ្ឋាភិបាលជួបការលំបាកក្នុងការបង្កើត ឬអនុវត្តទិន្នន័យ ដែលឆ្លុះបញ្ចាំងពីបទពិសោធន៍ជីវិតជាក់ស្តែងពិតប្រាកដ។

[២៤] ក្រសួងបរិស្ថាន។ *យុទ្ធសាស្ត្រជាតិ REDD+ កម្ពុជា ឆ្នាំ២០១៧-២០២៦*។ ភ្នំពេញ៖ រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០១៧។ មានការប្តេជ្ញាចិត្តចំពោះការការពារដែលស្របតាមស្តង់ដារអន្តរជាតិ រួមមាន ការយល់ព្រមជាមុនដោយសេរី និងមានព័ត៌មានគ្រប់គ្រាន់ (FPIC) ការចូលរួមរបស់អ្នកពាក់ព័ន្ធ និងការចូលរួមរបស់ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន នៅក្នុងការសម្រេចចិត្តលើការប្រើប្រាស់ដីធ្លី និងព្រៃឈើ។

ការវិភាគអន្តរប្រសព្វ មានតិចតួចបំផុតនៅក្នុងការស្រាវជ្រាវ ដែលចាត់តាំងដោយក្រសួង ឬស្ថាប័នទទួលបន្ទុកវិស័យសិក្សាធិការ។ ការសិក្សាភាគច្រើនមានការបែកចែកទិន្នន័យតាមភេទ និងជួនកាលតាមពិការភាព ឬភូមិសាស្ត្រ ប៉ុន្តែកម្រវិភាគអំពីរបៀបដែលអត្តសញ្ញាណទាំងនេះត្រួតគ្នាណាស់។ ឧទាហរណ៍ អង្កេតថ្នាក់ជាតិដូចជា អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា និងអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា ដើម្បីអភិវឌ្ឍនៅកម្ពុជា ជាទូទៅរាយការណ៍អំពីលទ្ធផលតាមភេទ និងទីតាំង ប៉ុន្តែមិនបានវិភាគអំពីទម្រង់នៃភាពងាយរងគ្រោះត្រួតគ្នាឡើយ ដូចជា ថាតើយេនឌ័រមានទំនាក់ទំនងដូចម្តេចជាមួយពិការភាព ជនជាតិ ឬស្ថានភាពភាពក្រីក្រ។ ស្រដៀងគ្នានេះដែរ ការស្រាវជ្រាវតាមវិស័យដែលចាត់តាំងដោយក្រសួងពាក់ព័ន្ធ ច្រើនតែចាត់ទុកយេនឌ័រ ពិការភាព និងភាពក្រីក្រ ជាធាតុផ្សំដាច់ដោយឡែកពីគ្នានៅក្នុងការវិភាគ ដែលបណ្តាលឱ្យមានការវិភាគស្របគ្នា ជាជាងការវិភាគបែបរួមបញ្ចូលគ្នា។[២៥] បើគ្មានការឆ្លុះបញ្ចាំងបែបនេះទេគោលនយោបាយងាយនឹងមើលរំលងប្រជាជន ដែលរងផលប៉ះពាល់ខ្លាំងបំផុតដោយវិសមភាពផ្នែករចនាសម្ព័ន្ធ រួមមាន ស្ត្រីជនជាតិដើមភាគតិចដែលមានពិការភាព យុវជនស្រលាញ់ភេទដូចគ្នា នៅជនបទ កម្មករចំណាកស្រុកដែលមានកម្រិតអប់រំទាប និងចាស់ជរារស់នៅខេត្តដាច់ស្រយាល។

> ការងាររបស់កម្មវិធីពន្លកចំណេះ ដំណាក់កាលទី២ ជាមួយក្រសួងនានា បានគូសបញ្ជាក់ពីតម្រូវការវិធីសាស្ត្រដែលកាន់តែមានលក្ខណៈរួមបញ្ចូល ដូចជា តាមរយៈដំណើរការសហការរៀបចំ វិធីសាស្ត្រស្រាវជ្រាវបែបចូលរួម និងការអភិវឌ្ឍសមត្ថភាពលើការបកស្រាយទិន្នន័យ ដែលគិតគូរពីសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម។ ទោះជាយ៉ាងណា ការទទួលយកទៅអនុវត្តជាប្រព័ន្ធ គឺនៅមានតិចតួចនៅឡើយ។

## ៣.១.៦. ការដាក់បញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម នៅថ្នាក់ក្រោមជាតិ

រចនាសម្ព័ន្ធថ្នាក់ក្រោមជាតិដើរតួនាទីសំខាន់ណាស់ក្នុងការប្រែក្លាយការប្តេជ្ញាចិត្តសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ថ្នាក់ជាតិទៅជាសកម្មភាពជាក់ស្តែង ព្រោះជារឿយៗ រដ្ឋបាលខេត្ត និងឃុំ-សង្កាត់ គឺជាចំណុចទំនាក់ទំនងដំបូង និងជាប់លាប់បំផុតជាមួយសហគមន៍។ ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែង ការចូលរួមនៅកម្រិតនេះ នៅតែផ្តោតជាចម្បងលើយេនឌ័រតែមួយមុខ។ ការពិចារណាសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម កាន់តែទូលំទូលាយដូចជា ពិការភាព ការផាត់ចេញពីសង្គម និងទម្រង់នៃការរើសអើងត្រួតគ្នា កម្រត្រូវបានបញ្ជ្រាបក្នុងជាប្រព័ន្ធណាស់។ នេះឆ្លុះបញ្ចាំងពីកង្វះសមត្ថភាព និងធម្មជាតិនៃការធ្វើសេចក្តីសម្រេច ដែលប្រមូលផ្តុំអំណាចខ្លាំង។

[២៥] National Institute of Statistics (NIS), Ministry of Planning. *Cambodia Demographic and Health Survey 2021–22*. Phnom Penh: Royal Government of Cambodia, 2023 - បែកចែកទិន្នន័យយ៉ាងទូលំទូលាយតាមភេទ អាយុ និងទីកន្លែងរស់នៅ ប៉ុន្តែមិនបានអនុវត្តក្របខណ្ឌវិភាគភាពអន្តរប្រសព្វ ទេ។ វិទ្យាស្ថានជាតិស្ថិតិ (NIS)។ NIS. *Cambodia Socio-Economic Survey 2022*. Phnom Penh: Ministry of Planning, 2023 - បង្ហាញសូចនាករភាពក្រីក្រ និងសុខុមាលភាពតាមភេទ និងភូមិសាស្ត្រ ដោយមានការវិភាគតិចតួចអន្តរប្រសព្វ។ Ministry of Women's Affairs. *Gender Mainstreaming Action Plan 2019–2023*. Phnom Penh: Royal Government of Cambodia, 2019 - ទទួលស្គាល់វិសមភាពយេនឌ័រ ប៉ុន្តែភាគច្រើនចាត់ទុកពិការភាព ជាតិពន្ធុ និងភាពក្រីក្រ ជាបញ្ហាកង្វល់គោលនយោបាយដាច់ដោយឡែកពីគ្នា ជាជាងបញ្ហាគោលនយោបាយត្រួតគ្នា។

## ថ្នាក់ខេត្ត

រដ្ឋបាលខេត្តផ្តល់ទិសដៅជាយុទ្ធសាស្ត្រ និងការសម្របសម្រួល។ យន្តការស្នូលមួយគឺគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារខេត្ត (គ.ក.ស.ក) ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៩។ ក្រោមការដឹកនាំដោយអភិបាល ឬអភិបាលរងខេត្ត គណៈកម្មាធិការនេះកៀរគរមន្ទីរកិច្ចការនារី មន្ទីរសង្គមកិច្ច អង្គការមិនមែនរដ្ឋាភិបាលក្នុងមូលដ្ឋាន និងថ្នាក់ដឹកនាំសហគមន៍ ដើម្បីផ្តល់ប្រឹក្សាលើគោលនយោបាយ និងកម្មវិធី ដែលបង្កផលប៉ះពាល់ដល់ស្ត្រី និងកុមារ។[២៦] រចនាសម្ព័ន្ធស្រដៀងគ្នានេះក៏មាននៅថ្នាក់ស្រុកផងដែរ គឺគណៈកម្មាធិការថ្នាក់ស្រុក ដោះស្រាយបញ្ហានៅតាមមូលដ្ឋានផ្ទាល់។

## ថ្នាក់ឃុំ-សង្កាត់

គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ-សង្កាត់ (គ.ក.ន.ក) ទទួលខុសត្រូវលើការងារជួរមុខពាក់ព័ន្ធនឹងសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម រួមមាន ការការពារ សុខុមាលភាព ជីវភាពរស់នៅ និងគំនិតផ្តួចផ្តើមពាក់ព័ន្ធនឹងអាកាសធាតុ។ គណៈកម្មាធិការនេះគាំទ្រដល់សេវាពាក់ព័ន្ធនឹងការការពារកុមារ សុខភាពមាតា ការទប់ស្កាត់ការបែកបាក់គ្រួសារ ការបង្កើតប្រាក់ចំណូល និងកសិកម្មធន់នឹងអាកាសធាតុ។[២៧] គណៈកម្មាធិការនេះមានសមាសភាពមន្ត្រីឃុំ-សង្កាត់ អង្គការមិនមែនរដ្ឋាភិបាលក្នុងមូលដ្ឋាន និងថ្នាក់ដឹកនាំសហគមន៍។ ចាប់តាំងពីឆ្នាំ២០២០ មក ខេត្តមួយចំនួនបានពង្រីកសមាជិកភាពរបស់គណៈកម្មាធិការនេះ ដើម្បីរួមបញ្ចូលយុវជន ចាស់ជរា ជនមានពិការភាព និងតំណាងជនជាតិដើមភាគតិចនៅតំបន់ជនជាតិដើមភាគតិច។ នៅតំបន់ជនជាតិដើមភាគតិច ដូចជា រតនគិរី និងមណ្ឌលគិរី តំណាងជនជាតិដើមភាគតិចក៏មានការចូលរួមផងដែរ។ ការផ្លាស់ប្តូរទាំងនេះដែលបច្ចុប្បន្ន កំពុងត្រូវបានពង្រីកទូទាំងប្រទេស ក្រោមការគាំទ្រពីកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ និងដៃគូផ្សេងទៀត មានគោលបំណងធ្វើឱ្យអភិបាលកិច្ចមូលដ្ឋានកាន់តែមានបរិយាបន្ន និងឆ្លើយតបទៅនឹងតម្រូវការចម្រុះរបស់សហគមន៍។

ការពិភាក្សាជាក្រុមជាមួយគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ-សង្កាត់ (គ.ក.ន.ក) និងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារខេត្ត (គ.ក.ស.ក) បានបង្ហាញថា ខណៈដែលសមាជិកប្រហែលជាមិនប្រើប្រាស់ពាក្យបច្ចេកទេស ដូចជាសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ការបញ្ជ្រាប ឬអន្តរប្រសព្វ ពួកគេពិតជាទទួលស្គាល់ភាពចាំបាច់នៃការផ្តោតអាទិភាពលើក្រុមងាយរងគ្រោះ រួមទាំងអ្នកដែលមានភាពងាយរងគ្រោះជាច្រើនទម្រង់។ ក្រុមគោលដៅសំខាន់ៗរួមមាន គ្រួសារក្រីក្រកម្រិត១ និងកម្រិត២ ជនមានពិការភាព ស្ត្រីមានផ្ទៃពោះ កុមារអាយុក្រោមពីរឆ្នាំ និងជនជាតិដើមភាគតិច។ គណៈកម្មាធិការទាំងនេះក៏គាំទ្រដល់កម្មវិធីជាតិគាំពារសង្គមផងដែរ រួមមានការឧបត្ថម្ភសាច់ប្រាក់ក្នុងអំឡុងវិបត្តិជំងឺកូវីដ-១៩ ការឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកម្មវិធីឧបត្ថម្ភសាច់ប្រាក់ក្នុងកញ្ចប់គ្រួសារ។

[២៦] RGC. 2016. Compilation of Key Legal Instruments of Sub-National Democratic Development Reform. https://ncdd.gov.kh/wp-content/uploads/2019/03/Compilation-of-legal-documents-on-SNDD-March-2016_En.pdf

[២៧] MOSVY. N.d. Handbook for Commune Committees for Women and Children (CCWC) https://bettercarenetwork.org/sites/default/files/2019-10/CCWC%20Handbook%20English%20V6%20Hi.pdf

## ៣.១.៧. បញ្ហាប្រឈម៖ ចំណុចរាំងស្ទះដល់ការដាក់បញ្ចូល សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម

ទោះបីជាមានការប្តេជ្ញាចិត្តច្បាស់លាស់ផ្នែកគោលនយោបាយ និងការយកចិត្តទុកដាក់កាន់តែខ្លាំងពីស្ថាប័នពាក់ព័ន្ធចំពោះសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ក៏ដោយ ប៉ុន្តែការដាក់បញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ទៅក្នុងប្រព័ន្ធរដ្ឋាភិបាលទាំងមូល នៅតែមានកម្រិតមិនស្មើគ្នា ហើយការអនុវត្តភាគច្រើនគឺមិនសូវមានភាពស៊ីសង្វាក់គ្នាឡើយ។ ជារឿយៗសមភាពយេនឌ័រត្រូវបានចាត់ទុកជាលក្ខខណ្ឌតម្រូវផ្នែករដ្ឋបាល ជាជាងកញ្ចក់ឆ្លុះបញ្ចាំងដ៏សំខាន់នៅក្នុងការវិភាគ។ ចំណុចនេះបានជះឥទ្ធិពលលើថាតើគោលនយោបាយត្រូវបានតាក់តែងដោយរបៀបណា ថាតើសំឡេងរបស់នរណាត្រូវបានដាក់បញ្ចូលក្នុងការពិគ្រោះយោបល់ និងថាតើទិន្នន័យត្រូវបានបកស្រាយដោយរបៀបណា។ ទន្ទឹមនឹងនេះ បរិយាបន្នពិការភាពនៅតែត្រូវបានរាំងស្ទះដោយកង្វះការបង្កភាពងាយស្រួល និងការរើសអើងដែលនៅបន្តកើតមាន ដោយជារឿយៗ គេយល់ថា ពិការភាពពាក់ព័ន្ធនឹងបញ្ហាវេជ្ជសាស្ត្រ ឬសុខុមាលភាព ជាជាងជាបញ្ហាផ្អែកលើសិទ្ធិ និងការចូលរួម។ សរុបមក បញ្ហាប្រឈមទាំងនេះឆ្លុះបញ្ចាំងពីឧបសគ្គដ៏ជ្រាលជ្រៅក្នុងផ្នែករចនាសម្ព័ន្ធ ស្ថាប័ន និងអាកប្បកិរិយា ដែលនៅតែបន្តជំរុញឱ្យមានការផាត់ចេញនៅក្នុងដំណើរការគោលនយោបាយ និងការធ្វើសេចក្តីសម្រេច ជាជាងកាត់បន្ថយការផាត់ចេញជាប្រព័ន្ធ។

**ផ្នែកខាងក្រោមនេះ គូសបញ្ជាក់ពីបញ្ហាប្រឈមជាក់លាក់ដែលបានរកឃើញតាមរយៈការស្រាវជ្រាវ៖**



១ **សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ត្រូវបានចាត់ទុកជាការបំពេញអនុលោមភាព ជាជាងកញ្ចក់ឆ្លុះបញ្ចាំងក្នុងការវិភាគ។** ជាញឹកញាប់ សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ត្រូវបានដាក់បញ្ចូលទៅក្នុងផែនការ និងទម្រង់ឯកសារនានា ដើម្បីបំពេញលក្ខខណ្ឌតម្រូវផ្លូវការ ដោយមិនមានឥទ្ធិពលលើការរៀបចំគោលនយោបាយ ការរៀបចំថវិកា ឬជម្រើសកម្មវិធីនោះទេ។ មន្ត្រីជាច្រើននៅតែបន្តបកស្រាយសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ថាជាសំណុំនៃធាតុផ្សំដាច់ដោយឡែកពីគ្នា ជាជាងស្វែងយល់អំពីរបៀបដែលអំណាច អត្តសញ្ញាណ និងការដែលត្រូវបានគេផាត់ចេញជះឥទ្ធិពលទៅលើគ្នា។ ចំណុចនេះបានកម្រិតភាពស៊ីជម្រៅនៃការវិភាគ និងជំរុញឱ្យមានការឆ្លើយតបដាច់ដោយឡែកពីគ្នានៅតាមក្រសួងនានា។

២ **ការយល់ដឹងអំពីទស្សនទាន នៅតូចចង្អៀត និងមានកម្រិតមិនស្មើគ្នា។** សមភាពយេនឌ័រនៅតែត្រូវបានគេប្រៀបផ្ទឹមយ៉ាងទូលំទូលាយទៅនឹងការចូលរួម និងភាពជាតំណាងរបស់ស្ត្រី ជាជាងការដេញដោលបទដ្ឋានយេនឌ័រ តួនាទី និងទំនាក់ទំនងអំណាចដែលមានស្រាប់ ដែលជះឥទ្ធិពលដល់ក្រុមទាំងអស់។ ជារឿយៗ គេយល់ថា ពិការភាពពាក់ព័ន្ធនឹងបញ្ហាវេជ្ជសាស្ត្រ ឬសុខុមាលភាព ដោយផ្តោតលើភាពចុះខ្សោយកាយសម្បទា ជាជាងឧបសគ្គផ្នែករចនាសម្ព័ន្ធ និងបរិស្ថាន។ បរិយាបន្នសង្គមដ៏ទូលំទូលាយ  រួមទាំងជាតិពន្ធុ អត្តសញ្ញាណជាជនជាតិដើមភាគតិច ទំនោរផ្លូវភេទ និងភូមិសាស្ត្រ ទទួលបានការយកចិត្តទុកដាក់តិចតួច និងជារឿយៗ ត្រូវបានបន្ថយមកត្រឹមការហៅជារួមថា "ក្រុមងាយរងគ្រោះ" ប៉ុណ្ណោះ។ អន្តរប្រសព្វគឺជាសសរស្តម្ភដែលគេយល់ដឹងតិចតួចបំផុត ដោយមានក្រសួងតិចតួចប៉ុណ្ណោះ ដែលវិភាគអំពីរបៀបដែលយេនឌ័រ ពិការភាព ភាពក្រីក្រ និងអត្តសញ្ញាណ ត្រួតគ្នា និងជះឥទ្ធិពលលើគ្នា នៅក្នុងការអនុវត្តជាក់ស្តែង។

៣

**មានក្រុមការងារបញ្ជ្រាបយេនឌ័រ (GMAGs) និងមន្ត្រីបង្គោលពិការភាព ប៉ុន្តែការបំពេញមុខងាររបស់ពួកគេមិនស៊ីសង្វាក់គ្នាឡើយ។** ស្ថាប័នជាច្រើននៅខ្វះអំណាចសម្រេចចិត្ត ថវិកាសម្រាប់ការអនុវត្ត ឬបុគ្គលិកដែលទទួលបានការបណ្ដុះបណ្ដាលបច្ចេកទេសច្បាស់លាស់។ ជារឿយៗ ការទទួលខុសត្រូវចំពោះ សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ត្រូវបានបន្ថែមទៅលើតួនាទីដែលមានស្រាប់ ដែលធ្វើឱ្យកាត់បន្ថយពេលវេលា និងផលជះលើការបំពេញការងារ។ ការសម្របសម្រួលនៅមានកម្រិត មិនទាន់ជាផ្លូវមួយ រវាងក្រសួងកិច្ចការនារី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងជំនាញ ដែលកាន់តែធ្វើឱ្យចុះខ្សោយដល់ការដាក់បញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ទៅក្នុងគោលនយោបាយតាមវិស័យ របៀបវារៈស្រាវជ្រាវ និងប្រព័ន្ធទិន្នន័យ។

---

៤

**ការវាយតម្លៃប្រព័ន្ធស្ថិតិជាតិចង្អុលបង្ហាញយ៉ាងច្បាស់អំពីភាពមិនស៊ីសង្វាក់គ្នាជាបន្តបន្ទាប់ រវាងតម្រូវការគោលនយោបាយ និងទិន្នន័យដែលមាន។** ខណៈដែលមានការតម្រឹមតម្រង់ជាមធ្យមសម្រាប់សូចនាករយុទ្ធសាស្ត្រកម្រិតខ្ពស់ (ភាពស្រដៀងគ្នាប្រហែលពីរភាគបី) ប្រព័ន្ធនេះមិនមានធនធានគ្រប់គ្រាន់ ដើម្បីបង្កើតទិន្នន័យលម្អិត បែកចែកទិន្នន័យជាប្រភេទ និងដាក់លាក់តាមបញ្ហាដែលត្រូវការចាំបាច់ ដើម្បីគាំទ្រដល់ការធ្វើសេចក្ដីសម្រេចផ្អែកលើទិន្នន័យឡើយ។ ក្របខណ្ឌថ្នាក់ជាតិ ដូចជាយុទ្ធសាស្ត្របញ្ចកោណ និងផែនការយុទ្ធសាស្ត្រនារីរតនៈទី៦ ទទួលបានជាតុចូលច្រើនគួរសមពីសូចនាករគោលដែលមានស្រាប់។ ផ្ទុយទៅវិញ ផែនការយុទ្ធសាស្ត្រជាតិស្ដីពីពិការភាព មិនទទួលបានទិន្នន័យគ្រប់គ្រាន់ទាល់តែសោះ គឺមិនមានទិន្នន័យណាមួយឆ្លើយតបស្របទៅនឹងគោលបំណងស្នូលរបស់ខ្លួនឡើយ ដែលនេះបញ្ជាក់ពីគម្លាតដ៏សំខាន់ទាក់ទងនឹងទិន្នន័យពិការភាព។ ការវិភាគអំពីភាពស៊ីសង្វាក់គ្នារវាងអាទិភាពគោលនយោបាយជាតិ និងសំណុំទិន្នន័យដែលមាន ដែលទាញយកជាចម្បងពី CAMSTAT (ថ្នាលទិន្នន័យសម្រាប់វិទ្យាស្ថានជាតិស្ថិតិ) បង្ហាញពីរបាយមិនស្មើគ្នានៃការគ្របដណ្ដប់ទិន្នន័យនៅតាមវិស័យនានា។

- **វិស័យដែលមានទិន្នន័យកាន់តែច្រើន** រួមមានសូចនាករម៉ាក្រូសេដ្ឋកិច្ច និងសូចនាករការងារមូលដ្ឋាន ដោយមានទិន្នន័យស្ដីពីអតិផរណា និងភាពអត់ការងារធ្វើ។ នេះបង្ហាញពីភាពបន្សុីគ្នាខ្លាំងទៅនឹងតម្រូវការគោលនយោបាយ។ សូចនាករអប់រំស្ដង់ដារ ដូចជាអត្រាបោះបង់ការសិក្សា និងអត្រារួមនៃការសិក្សា ក៏ត្រូវបានរួមបញ្ចូលបានយ៉ាងល្អ និងរាយការណ៍ជាប់លាប់ផងដែរ។ សូចនាករសុខភាពបន្តពូជ និងក្របខណ្ឌគតិយុត្តពាក់ព័ន្ធនឹងយេនឌ័រ គឺជាផ្នែកមួយផ្សេងទៀតដែលមានភាពរឹងមាំគួរសម ដោយមានទិន្នន័យគួរឱ្យជឿទុកចិត្តស្ដីពីអត្រាមរណភាពមាតា ការប្រើប្រាស់មធ្យោបាយពន្យារកំណើតទំនើប និងអត្ថិភាពនៃច្បាប់ ដែលដោះស្រាយបញ្ហាសមភាពយេនឌ័រ និងអំពើហិង្សាពីដៃគូស្និទ្ធស្នាល។ បន្ថែមពីលើនេះ សូចនាករពាក់ព័ន្ធនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ ដែលភាគច្រើនគឺមិនមាននោះទេកាលពីប៉ុន្មានឆ្នាំមុន ឥឡូវនេះ គឺអាចរកបានកាន់តែច្រើនចាប់ពីឆ្នាំ២០២០ មក។ ទិន្នន័យហេដ្ឋារចនាសម្ព័ន្ធ គឺអាចរកបានជាហូរហែនៅចន្លោះឆ្នាំ២០១៥ និង២០១៩ ប៉ុន្តែបច្ចុប្បន្ន ទិន្នន័យបែបនេះគឺមិនសូវមានជាហូរហែដូចមុនទេ។

- **វិស័យដែលមិនសូវមាន ឬខ្វះទិន្នន័យ** គឺអាចមើលឃើញច្បាស់ជាង និងទាក់ទងផ្ទាល់នឹងគោលនយោបាយ។ ពិការភាពបង្ហាញពីគម្លាតដ៏ធំបំផុតនៅក្នុងប្រព័ន្ធនេះ។ តាមធម្មតា សំណុំទិន្នន័យដែលមានស្រាប់ រាយការណ៍អំពីលទ្ធផលនៃការអប់រំ ឬការងារជារួម ដោយមិនមានកំណត់រកការចូលរួមរបស់ជនមានពិការភាពឡើយ ដូច្នេះ គេមិនអាចវាយតម្លៃបរិយាបន្ន ឬតាមដានវឌ្ឍនភាពធៀបនឹងការប្តេជ្ញាចិត្តរបស់ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពទី៣ បានឡើយ។ ភាគច្រើនសូចនាករនៃអភិបាលកិច្ច និងកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ក៏មិនមានផងដែរ រួមទាំងរង្វាស់ទាក់ទងនឹងដំណើរការប្រព័ន្ធតុលាការ ភាពត្រៀមខ្លួនរបស់អាជីវកម្ម និងប្រសិទ្ធភាពផ្នែកភស្តុភារ។ នៅក្នុងវិស័យយេនឌ័រ ទោះបីជាមានការចងក្រងឯកសារគោលនយោបាយ និងក្របខណ្ឌគតិយុត្តក៏ដោយ ប៉ុន្តែគេឃើញមានទិន្នន័យតិចតួចណាស់ស្តីពីការអនុវត្ត ដូចជាចំនួនយន្តការឆ្លើយតបពហុវិស័យទៅនឹងអំពើហិង្សាផ្អែកលើយេនឌ័រ ឬការមានកន្លែងថែទាំកុមារនៅក្នុងស្ថាប័នសាធារណៈ និងឯកជន។ ទិន្នន័យទាក់ទងនឹងបរិស្ថាន និងទេសចរណ៍ មិនស៊ីសង្វាក់គ្នា និងដាច់ពីគ្នា ដោយគ្មានកម្រងទិន្នន័យយូរអង្វែងដើម្បីគាំទ្រដល់ការវិភាគរយៈពេលវែងឡើយ។

---

៥ **ចំណុចខ្សោយអន្តរវិស័យនៅគ្រប់វិស័យទាំងអស់ គឺកង្វះទិន្នន័យបែកចែកតាមប្រភេទ។** សូចនាករជាច្រើនត្រូវបានប្រមូលតែនៅថ្នាក់ជាតិប៉ុណ្ណោះ និងមិនត្រូវបានបែកចែកតាមភេទ អាយុ ពិការភាព ឬទីតាំងភូមិសាស្ត្រនោះទេ។ ភាពមានកម្រិតបែបនេះ អាចមើលឃើញយ៉ាងច្បាស់នៅក្នុងការវិភាគផែនការយុទ្ធសាស្ត្រនារីរតនៈទី៦ គឺរាល់សូចនាករដែលទាមទារការបែកចែកតាមប្រជាសាស្ត្រ ត្រូវបានវាយតម្លៃថាមិនសូវស៊ីសង្វាក់គ្នា។

ប្រអប់ទី ៥

## ក្រសួងបរិស្ថាន៖ អ្វីដែលជាឧបសគ្គរាំងដល់ការបញ្ជ្រាបសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម

ក្រសួងបរិស្ថានបានចំណាយពេលជាច្រើនឆ្នាំ ដើម្បីបញ្ជ្រាបយេនឌ័រទៅក្នុងការងាររបស់ខ្លួន ប៉ុន្តែកម្រិតវឌ្ឍនភាពគឺមិនដូចគ្នាទេ។ មន្ត្រីបង្គោលយេនឌ័រត្រូវបំពេញតួនាទីនេះបន្ថែមលើការងារស្នូលប្រចាំថ្ងៃ ហើយដោយសារខ្វះថវិកាអនុវត្តន៍ ឬខ្វះការដឹកនាំផ្នែកបច្ចេកទេស ជារឿយៗ ការងារយេនឌ័រត្រូវបានកំណត់ត្រឹមតែការសម្រេចឱ្យបាននូវការចូលរួមជាមូលដ្ឋាន ជាជាងការវិភាគឱ្យបានស៊ីជម្រៅ។ ការផ្សារភ្ជាប់យេនឌ័រទៅនឹងបរិស្ថាន នៅតែជាបញ្ហាប្រឈមសម្រាប់នាយកដ្ឋានជាច្រើន ដែលមានសមត្ថភាពខ្លាំងលើការគ្រប់គ្រងធនធានធម្មជាតិ ជាងកិច្ចការពារបរិស្ថានជារួម។ ទិន្នន័យក៏ជាចំណុចរាំងស្ទះមួយទៀតផងដែរ៖ ព័ត៌មានភាគច្រើនដែលក្រសួងប្រើប្រាស់ គឺជាទិន្នន័យបន្ទាប់បន្សំ ដោយសារទិន្នន័យបំបែកតាមភេទ អាយុ និងពិការភាព នៅមិនទាន់ត្រូវបានប្រមូល ឬចែករំលែកជាប្រព័ន្ធនៅឡើយ។

រចនាសម្ព័ន្ធថវិកាបានធ្វើឱ្យបញ្ហានេះកាន់តែពិបាកដោះស្រាយ។ ការរៀបចំថវិកាឆ្លើយតបនឹងយេនឌ័រ មិនទាន់ត្រូវបានអនុវត្តពេញលេញទេ ហើយនៅពេលដែលថវិកាកម្មវិធីត្រូវបានកាត់បន្ថយ ការបែងចែកថវិកាសម្រាប់យេនឌ័រក៏ត្រូវបានកាត់បន្ថយទៅតាមនោះដែរ។ ជារឿយៗ ដៃគូអភិវឌ្ឍន៍ផ្តល់ហិរញ្ញប្បទានតាមរយៈអន្តរការី ជាជាងផ្តល់មកឱ្យក្រសួងផ្ទាល់ ដែលធ្វើឱ្យចុះខ្សោយដល់សមត្ថភាព និងភាពម្ចាស់ការរបស់ក្រសួង។ ទោះជាមានឧបសគ្គទាំងនេះក៏ដោយ ប៉ុន្តែក្រសួងបរិស្ថានមើលឃើញឱកាសពិតប្រាកដនៅក្នុងគំនិតផ្តួចផ្តើមសេដ្ឋកិច្ចបៃតង តួនាទីសេដ្ឋកិច្ចរបស់ស្ត្រីនៅក្នុងវិស័យ ដែលងាយរងគ្រោះដោយអាកាសធាតុ និងកំណែទម្រង់នាពេលខាងមុខលើផ្នែកទិន្នន័យ និងថវិកា។ ក្រសួងមានបំណងចង់សហការកាន់តែផ្ទាល់ជាមួយតួអង្គរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ដែលអាចជួយបំពេញចន្លោះប្រហោងទាំងនេះ និងជំរុញឱ្យការបញ្ជ្រាបយេនឌ័រគេបដណ្តប់លើសពីការបំពេញអនុលោមភាព។

ប្រអប់ទី ៦

## ការដាក់បញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ទៅក្នុងក្របខណ្ឌថវិការបស់កម្ពុជា៖ ទស្សនៈពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ថវិកាពាក់ព័ន្ធនឹងសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម នៅក្នុងប្រទេសកម្ពុជា ត្រូវបានរៀបចំឡើងនៅក្នុងប្រព័ន្ធថវិកាផ្អែកលើកម្មវិធី របស់រាជរដ្ឋាភិបាល ដែលតម្រូវឱ្យគ្រប់ក្រសួងទាំងអស់តម្រឹមតម្រង់គោលបំណងនៃគោលនយោបាយ និងកម្មវិធីរបស់ខ្លួនឱ្យស្របនឹងយុទ្ធសាស្ត្របញ្ចកោណ។ តាមគោលការណ៍នេះមានន័យថា សមភាពយេនឌ័រ ពិការភាពនិងបរិយាបន្នសង្គម គួរតែត្រូវបានរំលេចនៅក្នុងគោលបំណង នៃគោលនយោបាយ និងប្រែក្លាយទៅជាកម្មវិធី ដែលមានហិរញ្ញប្បទានជាពិសេសសម្រាប់ក្រសួង ដូចជាក្រសួងកិច្ចការនារី និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។ ក្រុមការងារយេនឌ័រនៅក្នុងក្រសួងនីមួយៗ មានភារកិច្ចផ្លូវការក្នុងការបញ្ជ្រាបការរៀបចំថវិកាឆ្លើយតបនឹងយេនឌ័រ ហើយមន្ត្រីរៀបចំផែនការបានបញ្ជាក់ជាថ្មីថា គ្រប់ក្រសួងទាំងអស់រំពឹងថានឹងត្រូវរៀបចំផែនការសម្រាប់សកម្មភាពពាក់ព័ន្ធនឹងសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម។ ផ្អែកតាមបទសម្ភាសន៍ជាមួយអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដំណើរការរៀបចំ និងពិនិត្យថវិកាបច្ចុប្បន្ន ផ្តោតអាទិភាពលើលទ្ធផលកម្មវិធី និងការតម្រឹមឱ្យស្របទៅនឹងគោលបំណងរបស់រាជរដ្ឋាភិបាល ជាជាងការតាមដានផលប៉ះពាល់នៃការបែងចែកចំណាយលើលទ្ធផលយេនឌ័រ ឬពិការភាព។ នៅក្នុងការអនុវត្តជាក់ស្តែង មិនទាន់មានបន្ទាត់ថវិកាជាក់លាក់ ឬការធ្វើចំណាត់ថ្នាក់មុខងារសម្រាប់យេនឌ័រ ឬពិការភាពនៅឡើយ ដែលធ្វើឱ្យលំបាកដល់ការតាមដានជាប្រព័ន្ធ។ ទោះបីជាថវិកាអាចត្រូវបានកំណត់ឡើង នៅពេលដែលសកម្មភាពទាំងនោះផ្តោតគោលដៅលើស្ត្រី ឬជនមានពិការភាពក៏ដោយ ប៉ុន្តែការចំណាយដោយប្រយោលលើសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម មិនត្រូវបានច្បាមយក ឬបំបែកជាប្រភេទឱ្យបានជាប់លាប់នោះទេ ហើយក៏មិនទាន់មានវិធីសាស្ត្រថ្នាក់ជាតិជារួមសម្រាប់អនុវត្តកិច្ចការនេះដែរ។ បញ្ហាប្រឈមរួមមាន កង្វះកញ្ចប់ថវិកាជាតិសម្រាប់សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម អាទិភាពជាច្រើនផ្សេងទៀតនៅក្នុងផ្នែកសារពើពន្ធ និងការកំណត់ខុសៗគ្នាលើការចំណាយពាក់ព័ន្ធនឹងយេនឌ័រ ឬពិការភាព នៅតាមវិស័យនីមួយៗ។ ដូច្នេះហើយ ទើបការរៀបចំថវិកាផ្តោតជាសំខាន់លើលទ្ធផលចុងក្រោយ របស់កម្មវិធី ជាជាងការវាស់វែងផលជះនៃការចំណាយសាធារណៈលើសមធម៌។



## បញ្ហាប្រឈមដែលពាក់ព័ន្ធនឹងពិការភាព

៦

**បរិយាបន្នពិការភាពនៅតែរាំងស្ទះដោយភាពមិនគ្រប់គ្រាន់នៃការបង្កភាពងាយស្រួលផ្នែករូបវន្ត និងការប្រាស្រ័យទាក់ទងគ្នានៅក្នុងប្រព័ន្ធរដ្ឋាភិបាល។** អគាររដ្ឋាភិបាល និងកន្លែងប្រជុំជាច្រើននៅតែមិនទាន់បង្កភាពងាយស្រួលសម្រាប់ឱ្យជនមានពិការភាពចូលប្រើប្រាស់ ខណៈដែលថ្នាលឌីជីថល និងការផ្សព្វផ្សាយជាសាធារណៈ កម្រផ្តល់ទម្រង់ឯកសារដែលងាយស្រួលយល់ ការបកប្រែភាសាសញ្ញា ឬការដាក់អក្សររត់ពីក្រោម។ គម្លាតទាំងនេះបានរឹតត្បិតដោយផ្ទាល់លើការចូលរួមប្រកបដោយអត្ថន័យរបស់ជនមានពិការភាពគ្រប់ប្រភេទ នៅក្នុងការពិភាក្សាគោលនយោបាយ និងដំណើរការធ្វើសេចក្តីសម្រេច។ កង្វះអ្នកបកប្រែភាសាសញ្ញាដែលមានសមត្ថភាព ធ្វើឱ្យបញ្ហាប្រឈមនេះកាន់តែស្មុគស្មាញថែមទៀត។ មិនមានទិន្នន័យផ្លូវការបច្ចុប្បន្នភាពស្តីពីចំនួនអ្នកបកប្រែភាសាសញ្ញានោះទេ ប៉ុន្តែរបាយការណ៍កាលពីឆ្នាំ២០២២ បានបង្ហាញថា ប្រទេសកម្ពុជាមានអ្នកបកប្រែភាសាសញ្ញាតិចជាង ២០ នាក់។ ចំនួនដ៏តិចតួចនេះបានរឹតត្បិតយ៉ាងខ្លាំងដល់ការទទួលបានការពិគ្រោះយោបល់ជាសាធារណៈ ព័ត៌មានផ្លូវការ និងសេវាសំខាន់ៗសម្រាប់ជនមានពិការភាពគ-ថ្លង់ ឬកម្សោយការស្តាប់។ ការណ៍នេះកាន់តែធ្វើឱ្យពួកគាត់ត្រូវបានផាត់ចេញពីការរៀបចំគោលនយោបាយ និងការចូលរួមក្នុងកិច្ចការសង្គម។[២៨]

---

៧

**ជនមានពិការភាព កម្រទទួលបានតួនាទីនៅក្នុងរដ្ឋាភិបាល។** បញ្ហាប្រឈមទាំងនេះកម្រិតទាំងការចូលរួមរបស់ជនមានពិការភាព និងភាពពាក់ព័ន្ធនៃគោលនយោបាយ ដែលត្រូវបានរៀបចំឡើងសម្រាប់ពួកគេ។ ទិន្នន័យផ្លូវការពីរាជរដ្ឋាភិបាលបង្ហាញថា ជនមានពិការភាពមានចំណែកដ៏តូចនៅក្នុងធនធានមន្ត្រីសាធារណៈ។ គិតត្រឹមចុងឆ្នាំ២០២៤ មានជនមានពិការភាពចំនួន ៣.៨១៦ នាក់ កំពុងបម្រើការងារនៅក្នុង ២៩ ក្រសួង និងស្ថាប័នរដ្ឋ ដែលស្មើនឹងប្រហែល ២ ភាគរយនៃមុខតំណែងក្នុងរដ្ឋាភិបាល។[២៩]

---

៨

**ការស្រាវជ្រាវក៏បង្ហាញផងដែរថា របាំងឥរិយាបថចំពោះជនមានពិការភាពនៅតែជាឧបសគ្គដ៏ធំ។** មន្ត្រីក្រសួងមួយចំនួនបានផ្តល់មតិថា បរិយាបន្នពិការភាពគឺជា "ការងារឯកទេស" ឬស្ថិតនៅក្រៅអាណត្តិរបស់ពួកគេ ដែលនេះបង្ហាញពីការយល់ដឹងចង្អៀតត្រឹមតែការបំពេញតាមកាតព្វកិច្ច ជាជាងការប្រើប្រាស់អភិក្រមបញ្ជ្រាបសិទ្ធិជនមានពិការភាព។ កត្តានេះបានជះឥទ្ធិពលទៅលើការសម្រេចថាតើទិន្នន័យណាខ្លះដែលគួរតែជាអាទិភាព ថាតើការពិគ្រោះយោបល់ត្រូវបានរៀបចំឡើងយ៉ាងដូចម្តេច និងថាតើសំឡេងរបស់នរណាខ្លះ ដែលជះឥទ្ធិពលលើជម្រើសគោលនយោបាយ។ មន្ត្រីជាច្រើននៅតែបន្តផ្តោតការយកចិត្តទុកដាក់ទៅលើប្រភេទនៃពិការភាព ជាជាងឧបសគ្គផ្នែករចនាសម្ព័ន្ធ និងមជ្ឈដ្ឋានជុំវិញខ្លួន។ ការណ៍នេះបានជះឥទ្ធិពលដល់របៀបដែលគោលនយោបាយត្រូវបានបង្កើតឡើង និងកម្រិតដល់ការបញ្ជ្រាបវិធានការបរិយាបន្នទៅក្នុងវដ្តគោលនយោបាយទាំងមូល។

[២៦] Secretary of State Em Chanmakara Calls for More Sign Language Interpreters to Meet Cambodia's Needs | News | DAC
The Phnom Penh Post | Government boosting digital inclusion for persons with disabilities

ប្រអប់ទី ៧

## ចំណុចខ្វះចន្លោះក្នុងគោលនយោបាយពិការភាព និងការសម្របសម្រួលអន្តរក្រសួង

អង្គការជនពិការកម្ពុជា (CDPO) រកឃើញថា ការគ្មានប័ណ្ណសម្គាល់ជនមានពិការភាព គឺជាឧបសគ្គដ៏បន្ទាន់បំផុតមួយចំពោះបរិយាបន្ន។ ខណៈដែលប្រព័ន្ធអត្តសញ្ញាណកម្មគ្រួសារក្រីក្រផ្តល់នូវគំរូដ៏មានប្រយោជន៍មួយ បច្ចុប្បន្ន ជនមានពិការភាពនៅខ្វះយន្តការប្រហាក់ប្រហែលគ្នានេះ សម្រាប់ទទួលស្គាល់ស្ថានភាពរបស់ពួកគេជាផ្លូវការ ឬផ្សារភ្ជាប់ពួកគេទៅនឹងអត្ថប្រយោជន៍គាំពារសង្គម។ អង្គការ CDPO បានកត់សម្គាល់ថា ល្អបំផុតគឺត្រូវរួមបញ្ចូលប័ណ្ណសម្គាល់ជនមានពិការភាព ជាមួយប្រព័ន្ធ IDPoor ដើម្បីអាចឱ្យមានការគាំទ្រចំគោលដៅ គឺស្រដៀងនឹងការឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រក្នុងអំឡុងវិបត្តិជំងឺកូវីដ-១៩ ដែរ។

វឌ្ឍនភាពលើបញ្ហានេះទាមទារឱ្យមានសកម្មភាពសម្របសម្រួលនៅទូទាំងក្រសួងមួយចំនួន ហើយនេះគឺជាចំណុចខ្សោយខ្លាំងបំផុតរបស់ប្រព័ន្ធនេះ។ ក្រសួងសុខាភិបាលមិនទាន់មានគោលនយោបាយច្បាស់លាស់ស្តីពីការលើកលែងកម្រៃសេវាសម្រាប់ជនមានពិការភាពនៅឡើយទេ។ អង្គការ CDPO កំពុងធ្វើការជាមួយក្រសួងសុខាភិបាល ដើម្បីធ្វើយុទ្ធសាស្ត្រដែលអាចអនុញ្ញាតឱ្យមានការថែទាំសុខភាពដោយឥតគិតថ្លៃ ប៉ុន្តែក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលជាស្ថាប័នដឹកនាំលើវិស័យពិការភាព មិនមានយន្តការ ដើម្បីចូលរួមជាមួយក្រសួងសុខាភិបាលដោយផ្ទាល់នោះទេ។ ដូច្នេះហើយទើបការអភិវឌ្ឍគោលនយោបាយមានលក្ខណៈដាច់ពីគ្នា យឺតយ៉ាវ និងពឹងផ្អែកលើទំនាក់ទំនងមិនផ្លូវការ។

អង្គការ CDPO ក៏បានគូសបញ្ជាក់ផងដែរអំពីគម្លាតក្នុងការស្រាវជ្រាវសំខាន់ៗ ដែលចាំបាច់ត្រូវយកចិត្តទុកដាក់ មុនពេលអាចធ្វើកំណែទម្រង់ប្រកបដោយអត្ថន័យ។ គម្លាតទាំងនេះ រួមមានការស្វែងយល់អំពីរបៀបដាក់បញ្ចូលពិការភាពទៅក្នុងរបបគាំពារសង្គម ការកំណត់ថាតើកិច្ចការនេះនឹងមានទម្រង់បែបណានៅក្នុងបរិបទជនបទ ការគូសផែនទីបង្ហាញពីរបៀបដែលពិការភាពប្រទាក់ក្រឡាជាមួយអត្តសញ្ញាណផ្សេងទៀត ការអភិវឌ្ឍក្របខណ្ឌតាមដាន និងវាយតម្លៃជាមូលដ្ឋាន ដើម្បីតាមដានវឌ្ឍនភាព។

បញ្ហាប្រឈមមិនមែនមានត្រឹមតែក្នុងផ្នែកបច្ចេកទេសនោះទេ ប៉ុន្តែក៏មានក្នុងផ្នែករចនាសម្ព័ន្ធផងដែរ៖ បញ្ហាពិការភាពមានលក្ខណៈអន្តរវិស័យ ប៉ុន្តែស្ថាប័នដែលទទួលខុសត្រូវលើការផ្តល់សេវា មិនត្រូវបានរៀបចំឡើងដើម្បីធ្វើប្រតិបត្តិការរួមគ្នានោះទេ។ ស្ថានភាពនេះ ធ្វើឱ្យជនមានពិការភាពគ្មានមធ្យោបាយច្បាស់លាស់ដើម្បីទទួលបានការគាំទ្រដែលពួកគេមានសិទ្ធិទទួលបាន។[៣០]

[៣០] ផ្អែកលើបទសម្ភាសន៍ជាមួយអង្គការជនពិការកម្ពុជា។

ប្រអប់ទី ៨

## បញ្ហាប្រឈមក្នុងការជំរុញបរិយាបន្នយេនឌ័រ និងពិការភាព ក្នុងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ

ក្រុមការងារនៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (គ.ជ.គ.ម) បានលើកឡើងដោយត្រង់ៗអំពីចន្លោះខ្វះខាតដែលនៅតែរារាំងដល់ការគ្រប់គ្រងគ្រោះមហន្តរាយប្រកបដោយបរិយាបន្ន។ "បញ្ហាប្រឈមធំបំផុតរបស់យើងគឺទិន្នន័យ"។ ទោះបីជាមានការណែនាំក៏ដោយ ប៉ុន្តែជារឿយៗ ក្រុមការងារចុះមូលដ្ឋានរាយការណ៍តែ "តួលេខរួមបញ្ចូលគ្នា" ប៉ុណ្ណោះ ក្នុងអំឡុងពេលមានអាសន្ន ហើយប្រព័ន្ធមួយចំនួន ដូចជា CAMD "មិនទាន់មានការបែកចែកទិន្នន័យជាប្រភេទនៅឡើយទេ"។ ពួកគេបានកត់សម្គាល់ថា ចំណុចនេះបានកម្រិតដល់ការកំណត់គោលដៅ ហើយបច្ចុប្បន្ន ពួកគេកំពុងរៀបចំទម្រង់រាយការណ៍ថ្មី ដើម្បីដោះស្រាយបញ្ហានេះ។

ពួកគេក៏បានទទួលស្គាល់ផងដែរនូវមូលដ្ឋានទិន្នន័យដ៏ចង្អៀត៖ "យើងពឹងផ្អែកតែលើទិន្នន័យរបស់រដ្ឋាភិបាលប៉ុណ្ណោះ" សូម្បីតែនៅពេលដែលអង្គការមិនមែនរដ្ឋាភិបាល និងដៃគូ អាចផ្តល់ព័ត៌មានដែលជាប្រយោជន៍ក៏ដោយ។ រដ្ឋបាលកម្រិតថ្នាក់ក្រោមជាតិមានសមត្ថភាពខុសគ្នា ដែលជះឥទ្ធិពលដល់ការរាយការណ៍យ៉ាងស៊ីសង្វាក់គ្នា។ ទោះបីជាគោលនយោបាយបានទទួលស្គាល់យេនឌ័រ និងពិការភាព ប៉ុន្តែក្រុមការងារបានពន្យល់ថា "ការយកទៅអនុវត្តជាក់ស្តែងនៅតែមានការលំបាក" ជាពិសេសសម្រាប់មន្ត្រីមូលដ្ឋាន ដែលគ្រប់គ្រងការឆ្លើយតបនឹងគ្រោះមហន្តរាយបន្ទាន់។

## បរិយាបន្នសង្គម និងអន្តរប្រសព្វ

៩ **បរិយាបន្នសង្គមជារួម គឺជាសសរស្តម្ភដែលត្រូវបានបញ្ជ្រាបតិចតួចបំផុតទៅក្នុងស្ថាប័ន។** មន្ត្រីរាជការតែងតែផ្អែកលើការកំណត់អត្តសញ្ញាណយ៉ាងទូលំទូលាយ ដូចជា "ក្រុមងាយរងគ្រោះ" ដែលធ្វើឱ្យមើលមិនឃើញភាពខុសគ្នាទាក់ទងនឹងជាតិពន្ធុ អត្តសញ្ញាណជាជនជាតិដើមភាគតិច ទំនោរផ្លូវភេទ ភូមិសាស្ត្រ និងភាពក្រីក្រ។

១០ **នៅតែមានគម្លាតធំៗសម្រាប់ជនជាតិដើមភាគតិច និងសហគមន៍ស្រលាញ់ភេទដូចគ្នា។** ជារឿយៗ ក្រុមជនជាតិដើមភាគតិច ត្រូវបានពិគ្រោះយោបល់នៅដំណាក់កាលចុងក្រោយនៃដំណើរការនីតិកម្ម និងមានឥទ្ធិពលតិចតួចលើសេចក្តីសម្រេច ដែលប៉ះពាល់ដល់ដីធ្លី ជីវភាពរស់នៅ និងអត្តសញ្ញាណវប្បធម៌របស់ពួកគេ។

ប្រអប់ទី ៩

## របៀបដែលក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គិតគូរ និងអនុវត្តសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម និងការលំបាកក្នុងការអនុវត្ត

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រៀបចំក្របខណ្ឌ សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ដែលឆ្លុះបញ្ចាំងពីបរិយាបន្ន ដោយផ្តោតលើយេនឌ័រ ពិការភាព និងអាយុ។ ក្រុមការងារបានពន្យល់ថា គ្រប់ដំណើរការគោលនយោបាយចាប់ផ្តើមពីទិន្នន័យ៖ ការពិនិត្យឯកសារពាក់ព័ន្ធ សៀវភៅស និងការប្រមូលទិន្នន័យបឋមពីមូលដ្ឋាននៅពេលចាំបាច់។ "បរិយាបន្នត្រូវបានបញ្ចូលទៅក្នុងរបៀបដែលយើងប្រមូល និងវិភាគព័ត៌មាន" ដោយពួកគេបានចង្អុលបង្ហាញពីក្របខណ្ឌវិភាគលើ៧កត្តា ដែលពិនិត្យមើលវប្បធម៌នៃការផ្តល់សេវា ការសម្រេចចិត្តរបស់ថ្នាក់ដឹកនាំ ការចូលរួម ថាតើគោលនយោបាយ និងប្រព័ន្ធទិន្នន័យពិតជាឆ្លុះបញ្ចាំងពីតម្រូវការរបស់ស្ត្រី ជនមានពិការភាព ចាស់ជរា និងក្រុមអន្តរប្រសព្វឬទេ។

បរិយាបន្នពិការភាពដំណើរការតាមរយៈយន្តការមួយចំនួន៖ ក្រុមប្រឹក្សាសកម្មភាពជនពិការ នាយកដ្ឋានសុខុមាលភាពជនពិការ និងមូលនិធិជនពិការ ដែលសុទ្ធសឹងតែធ្វើប្រតិបត្តិការពីកម្រិតថ្នាក់ជាតិដល់ថ្នាក់ឃុំ។ ប្រព័ន្ធចុះបញ្ជី ប័ណ្ណសម្គាល់ជនមានពិការភាព និងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ដែលនឹងចេញផ្សាយនាពេលខាងមុខ ជួយណែនាំក្រសួងស្ថាប័ននានាអំពីរបៀបដាក់បញ្ចូលពិការភាពទៅក្នុងផែនការសកម្មភាព។

ទោះជាយ៉ាងណា នៅមានចំណុចរាំងស្ទះមួយចំនួន។ ថវិកាសម្រាប់សេវាពិការភាពគឺ "មិនដែលគ្រប់គ្រាន់" នោះទេ ជាពិសេសសម្រាប់ការស្តារលទ្ធភាពពលកម្មនៅសហគមន៍។ ទិន្នន័យនៅតែជាបញ្ហាប្រឈម ដែលតម្រូវឱ្យមានការបែកចែកទិន្នន័យជាប្រភេទឱ្យបានកាន់តែច្បាស់ សមត្ថភាពប្រសើរជាងមុនក្នុងផ្នែកស្ថិតិ និងទិន្នន័យដែលកាន់តែអាចជឿទុកចិត្តបាន ដើម្បីណែនាំដល់អន្តរាគមន៍ចំគោលដៅ។



១១ **មិនមានផែនការសកម្មភាពជាតិសម្រាប់ជនជាតិដើមភាគតិចនោះទេ ហើយក្របខណ្ឌគតិយុត្តនៅតែមានភាពហួសសម័យ។** បញ្ហាពាក់ព័ន្ធនឹងក្រុមស្រលាញ់ភេទដូចគ្នា ទទួលបានការយកចិត្តទុកដាក់តិចតួចបំផុតនៅក្នុងគោលនយោបាយ ហើយភាគច្រើន មិនត្រូវបានបញ្ចូលទៅក្នុងការរៀបចំផែនការ និងការរាយការណ៍ផ្លូវការឡើយ។ សរុបជារួម បញ្ហាប្រឈមនៅតែមានទំហំធំធេង និងធ្ងន់ធ្ងរ ជាជាងការកាត់បន្ថយការផាត់ចេញ។

---

១២ **កង្វះសេចក្តីណែនាំលើការអនុវត្តគោលនយោបាយប្រកបដោយបរិយាបន្ន។** សូម្បីតែនៅពេលដែលគោលនយោបាយសំដៅដល់បរិយាបន្នក៏ដោយ ក៏ក្រសួងជាច្រើនខ្វះខាតឧបករណ៍ ស្តង់ដារ និងគោលការណ៍ណែនាំជាក់ស្តែងដែលចាំបាច់ក្នុងការប្រែក្លាយការប្តេជ្ញាចិត្តទាំងនេះទៅជាសកម្មភាពជាក់ស្តែង។ ជារឿយៗ កម្មវិធីនានាពឹងផ្អែកលើអភិក្រមស្តង់ដារ ដែលមិនបានឆ្លុះបញ្ចាំងពីភាពចម្រុះក្នុងសង្គម និងវប្បធម៌កម្ពុជា។ នៅពេលគ្មានសេចក្តីណែនាំច្បាស់លាស់ មន្ត្រីជួរមុខគ្មានទិសដៅច្បាស់លាស់អំពីរបៀបទាក់ទាញក្រុមដែលត្រូវបានផាត់ចេញឬរបៀបកែសម្រួលកម្មវិធី ដើម្បីបំពេញតម្រូវការខុសៗគ្នា។

## គម្លាតក្នុងការអនុវត្តនៅថ្នាក់ក្រោមជាតិ

១៣ **រចនាសម្ព័ន្ធថ្នាក់ក្រោមជាតិដើរតួនាទីសំខាន់ណាស់ក្នុងការប្រែក្លាយការប្តេជ្ញាចិត្តថ្នាក់ជាតិចំពោះសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ទៅជាសកម្មភាពជាក់ស្តែង ព្រោះជារឿយៗ រដ្ឋបាលថ្នាក់ខេត្ត និងឃុំ គឺជាចំណុចទំនាក់ទំនងដំបូង និងជាប់លាប់បំផុតជាមួយសហគមន៍។** ប៉ុន្តែនៅក្នុងការអនុវត្តជាក់ស្តែង ការចូលរួមនៅកម្រិតនេះភាគច្រើននៅតែកំណត់ត្រឹមបញ្ហាយេនឌ័រប៉ុណ្ណោះ។ ការពិចារណាលើសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម កាន់តែទូលំទូលាយដូចជា ពិការភាព ការផាត់ចេញពីសង្គម និងទម្រង់នៃភាពងាយរងគ្រោះចម្រុះដែលជាអន្តរប្រសព្វ កម្រត្រូវបានដាក់បញ្ចូលជាប្រព័ន្ធណាស់។ នេះឆ្លុះបញ្ចាំងពីកង្វះសមត្ថភាពផងលក្ខណៈមជ្ឈការខ្លាំងនៃការធ្វើសេចក្តីសម្រេចផង។

---

១៤ **មតិយោបល់ពីក្រុមគោលដៅសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម បានគូសបញ្ជាក់អំពីគម្លាតរវាងគោលនយោបាយថ្នាក់ជាតិ និងការអនុវត្តនៅថ្នាក់ក្រោមជាតិ។** បញ្ហាប្រឈមសំខាន់ៗ ដែលបានលើកឡើងដោយគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំ សង្កាត់ (គ.ក.ន.ក) រួមមានការខ្វះថវិកា បន្ទុកការងារជាច្រើន និងចំនួនបុគ្គលិកមិនគ្រប់គ្រាន់។ ទោះបីជាមានតំណាងរដ្ឋាភិបាលជាច្រើនត្រូវបានតែងតាំងឱ្យចូលរួមក្នុងគណៈកម្មាធិការនេះក៏ដោយ ប៉ុន្តែការងារភាគច្រើនត្រូវបានអនុវត្តដោយមន្ត្រីបង្គោល គ.ក.ន.ក តែម្នាក់ ដែលច្រើនតែជាសមាជិកាក្រុមប្រឹក្សាឃុំ។ ក្នុងករណីដែលគ្មានសមាជិកាក្រុមប្រឹក្សាឃុំ អ្នកស្ម័គ្រចិត្តសហគមន៍ជាស្ត្រីអាចត្រូវបានតែងតាំងជាមន្ត្រីបង្គោល។ មន្ត្រីបង្គោលទទួលខុសត្រូវលើការសម្របសម្រួលសកម្មភាព រៀបចំរបាយការណ៍ និងអនុវត្តគំនិតផ្តួចផ្តើម ដែលពាក់ព័ន្ធទៅនឹងស្ត្រី និងកុមារ។

## ៣.១.៨. អនុសាសន៍៖ ទស្សនៈរបស់រដ្ឋាភិបាលស្តីពីការពង្រឹងការដាក់បញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម

មន្ត្រីរាជការបានបង្ហាញម្តងហើយម្តងទៀតនូវការប្តេជ្ញាចិត្តយ៉ាងមុតមាំចំពោះសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ប៉ុន្តែបានសង្កត់ធ្ងន់ថា ការប្តេជ្ញាចិត្តនេះមិនទាន់បានប្រែក្លាយទៅជាការអនុវត្តជាក់ស្តែង និងស៊ីសង្វាក់គ្នានៅក្នុងគោលនយោបាយ ការស្រាវជ្រាវ និងការអនុវត្តនៅឡើយទេ។ ដើម្បីឱ្យឈានហួសពីចេតនា/គោលបំណង មន្ត្រីបានកំណត់នូវចង្កោមនៃការគាំទ្រជាក់ស្តែងនៅកម្រិតប្រព័ន្ធ ដែលត្រូវការចាំបាច់សម្រាប់ការដាក់បញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម នៅគ្រប់ដំណាក់កាលនៃដំណើរការប្រែក្លាយទិន្នន័យទៅជាគោលនយោបាយ។

### ២ ការពង្រីកការយល់ដឹងអំពីទស្សនទាន

ការដោះស្រាយគម្លាតទស្សនទាន ទាមទារឱ្យមានការពង្រីកការយល់ដឹងអំពី សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ឱ្យហួសពីនិយមន័យតូចចង្អៀត។ សមភាពយេនឌ័រគួរតែត្រូវបានកំណត់មិនត្រឹមតែជាការចូលរួមរបស់ស្ត្រីប៉ុណ្ណោះទេ ប៉ុន្តែក៏ជាការផ្លាស់ប្តូរបទដ្ឋានសង្គម តួនាទី និងអំណាចគ្របដណ្តប់ ដែលជះឥទ្ធិពលដល់ក្រុមទាំងអស់ផងដែរ។ ពិការភាពត្រូវតែដោះស្រាយតាមរយៈគំរូសង្គមដែលពិចារណាលើឧបសគ្គផ្នែករចនាសម្ព័ន្ធ និងបរិស្ថាន ខណៈដែលបរិយាបន្នទូលំទូលាយគួរតែរួមបញ្ចូលយ៉ាងច្បាស់លាស់នូវជាតិពន្ធុ អត្តសញ្ញាណជាជនជាតិដើមភាគតិច ទំនោរផ្លូវភេទ ភូមិសាស្ត្រ និងភាពក្រីក្រ។ អន្តរប្រសព្វ ដែលជារឿយៗ គឺជាទិដ្ឋភាពដែលមិនសូវមានអ្នកយល់ដឹង គួរតែត្រូវបានសង្កត់ធ្ងន់តាមរយៈការណែនាំចំគោលដៅវគ្គសិក្សារៀនសូត្រអន្តរក្រសួង និងឧទាហរណ៍ជាក់ស្តែង ដែលបង្ហាញពីរបៀបដែលអត្តសញ្ញាណត្រួតស៊ីគ្នា ជះឥទ្ធិពលដល់បទពិសោធន៍ជីវិតជាក់ស្តែង និងលទ្ធភាពទទួលបានសេវា។

### ១ ការជំរុញសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ឱ្យគ្របដណ្តប់លើសពីអនុលោមភាព

ដើម្បីជំរុញសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ឱ្យគ្របដណ្តប់លើសពីការបំពេញអនុលោមភាព គេចាំបាច់ត្រូវដាក់បញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ជាសមាសធាតុស្នូលនៃការរៀបចំគោលនយោបាយ និងកម្មវិធី ជាជាងគ្រាន់តែជាបញ្ជីផ្ទៀងផ្ទាត់។ ក្រសួងនានាគួរតែត្រូវបានតម្រូវឱ្យបង្ហាញអំពីរបៀបដែលការវិភាគសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ជួយតម្រង់ទិសយុទ្ធសាស្ត្រ ការរៀបចំថវិកា និងជម្រើសកម្មវិធី ដោយមានយន្តការគណនេយ្យភាពសម្រាប់វាយតម្លៃគុណភាពនៃការដាក់បញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ជាជាងត្រឹមតែសរសេរឱ្យមាន។ សិក្ខាសាលា និងវគ្គបណ្តុះបណ្តាលជាក់ស្តែង អាចជួយមន្ត្រីឱ្យមើលឃើញ សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ជាកញ្ចក់ឆ្លុះបញ្ចាំងការយល់ដឹងអំពីអំណាច អត្តសញ្ញាណ និងការផាត់ចេញ ដោយបង្ហាញពីរបៀបដែលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម អាចផ្តល់ព័ត៌មានដល់ការឆ្លើយតបឆ្លងវិស័យកាន់តែមានប្រសិទ្ធភាព។

### ៣ ការពង្រឹងសមត្ថភាពស្ថាប័ន និងការសម្របសម្រួល

ឧបសគ្គពាក់ព័ន្ធនឹងសមត្ថភាព និងស្ថាប័ន ត្រូវតែដោះស្រាយដោយការពង្រឹងយន្តការនានា ដូចជា ក្រុមការងារបញ្ជ្រាបយេនឌ័រ (GMAGs) និងមន្ត្រីបង្គោលពិការភាព។ អង្គភាពទាំងនេះគួរតែមានអាណត្តិច្បាស់លាស់ ថវិកាជាក់លាក់ និងបុគ្គលិកដែលទទួលបានការបណ្តុះបណ្តាលបច្ចេកទេស ជាជាងការពឹងផ្អែកលើបុគ្គលិកដែលមានបន្ទុកការងារច្រើនហួសប្រមាណ ដែលត្រូវទទួលបន្ទុកការងារសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម បន្ថែមលើតួនាទីដែលមានស្រាប់។ ការសម្របសម្រួលរវាងក្រសួងសាម៉ី រួមមានក្រសួងកិច្ចការនារី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងនាយកដ្ឋានបច្ចេកទេស គួរតែធ្វើឱ្យមានលក្ខណៈផ្លូវការដើម្បីកាត់បន្ថយការបំពេញការងារដាច់ដោយឡែកពីគ្នា និងធានាបាននូវការដាក់បញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម យ៉ាងស៊ីសង្វាក់គ្នាទៅក្នុងគោលនយោបាយតាមវិស័យ ការស្រាវជ្រាវ និងប្រព័ន្ធទិន្នន័យ។ ការកសាងសមត្ថភាពជាបន្តបន្ទាប់ ការណែនាំ និងការលើកទឹកចិត្តផ្អែកលើលទ្ធផលការងារ អាចពង្រឹងបន្ថែមនូវសិទ្ធិអំណាច និងឥទ្ធិពលនៅក្នុងរចនាសម្ព័ន្ធទាំងនេះ។

## ៤ ការដាក់បញ្ចូលអន្តរប្រសព្វនៅក្នុងប្រព័ន្ធទិន្នន័យ

ការអនុវត្តចក្ខុនៃអន្តរប្រសព្វនៅទូទាំងខ្សែចង្វាក់តម្លៃទិន្នន័យចាប់ពីការប្រមូលទិន្នន័យរហូតដល់ការបោះពុម្ពផ្សាយ និងការយកទៅប្រើប្រាស់ នឹងពង្រឹងទិន្នន័យសម្រាប់គោលនយោបាយ ដោយធានាថា សំឡេងរបស់ក្រុមដែលត្រូវបានផាត់ចេញត្រូវបានបង្ហាញ/ស្តែងឱ្យឃើញនៅក្នុងកំណត់ត្រារដ្ឋបាល ការស្ទង់មតិ/អង្កេត និងទិន្នន័យបង្កើតដោយប្រជាពលរដ្ឋ។ អភិក្រមនេះក៏នឹងផ្លាស់ប្តូរអំណាចគ្រប់ដណ្តប់នៅក្នុងអភិបាលកិច្ចទិន្នន័យផងដែរ ដោយទទួលស្គាល់ភាពជាម្ចាស់របស់សហគមន៍លើទិន្នន័យ និងដាក់បញ្ចូលនូវវិធានការការពារឯកជនភាព និងការប្រើប្រាស់ប្រកបដោយក្រមសីលធម៌។ តាមរយៈការបោះពុម្ពផ្សាយទិន្នន័យបែបអន្តរប្រសព្វក្នុងទម្រង់ដែលបង្កភាពងាយស្រួល និងការកសាងសមត្ថភាពក្នុងចំណោមក្រសួង អង្គការតំណាងជនមានពិការភាព និងសង្គមស៊ីវិល ដើម្បីវិភាគ និងចាត់វិធានការលើការយល់ដឹងទាំងនេះ កម្ពុជានឹងអាចបង្កើតទិន្នន័យកាន់តែលម្អិត ដើម្បីផ្តល់ព័ត៌មានដល់ការឆ្លើយតបគោលនយោបាយប្រកបដោយបរិយាបន្ន។ ការដាក់បញ្ចូលអន្តរប្រសព្វទៅក្នុងគោលនយោបាយ ផែនការ និងយុទ្ធសាស្ត្រ នឹងជួយអ្នកតាក់តែងគោលនយោបាយកំណត់រកវិសមភាពដែលមិនស្តែងឱ្យឃើញ រៀបចំអន្តរាគមន៍ចំគោលដៅ និងបង្កើតយន្តការផ្តល់មតិត្រឡប់ ដែលកសាងទំនុកចិត្ត និងតម្រូវការទិន្នន័យកាន់តែប្រសើរ ហើយជាទីបំផុត នឹងជួយជំរុញការប្តេជ្ញាចិត្តរបស់កម្ពុជាចំពោះការ "មិនទុកប្រជាពលរដ្ឋណាម្នាក់ចោល"។[៣១]

## ៦ ការពង្រឹងបរិយាបន្នសង្គម និងអន្តរប្រសព្វ

ការពង្រឹងបរិយាបន្នសង្គម និងអភិក្រមនៃអន្តរប្រសព្វទាមទារឱ្យស្ថាប័នជំរុញការចូលរួមរបស់ក្រុមដែលតែងត្រូវបានគេមើលរំលងនៅក្នុងដំណើរការគោលនយោបាយ រួមទាំងជនជាតិដើមភាគតិច និងសហគមន៍ស្រលាញ់ភេទដូចគ្នា។ ក្រសួងស្ថាប័នគួរជៀសវាងការប្រើពាក្យទូទៅ ដូចជា "ក្រុមងាយរងគ្រោះ" និងគួរអនុម័តការណែនាំច្បាស់លាស់ស្តីពីការកំណត់អត្តសញ្ញាណ និងការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋដែលមានលក្ខណៈចម្រុះ។ ការវិភាគអន្តរប្រសព្វ គួរតែជាលក្ខខណ្ឌតម្រូវនៅក្នុងការពិនិត្យឡើងវិញលើគោលនយោបាយនិងកម្មវិធី ដើម្បីបង្ហាញពីរបៀបដែលអត្តសញ្ញាណជាច្រើនជះឥទ្ធិពលដល់លទ្ធភាពទទួលបានអត្ថប្រយោជន៍ និងហានិភ័យ។ យុទ្ធនាការលើកកម្ពស់ការយល់ដឹង និងការកសាងសមត្ថភាព អាចពង្រឹងសារៈសំខាន់នៃការដាក់បញ្ចូលក្រុមដែលធ្លាប់តែរងគ្រោះ ទៅក្នុងការរៀបចំផែនការ និងការធ្វើសេចក្តីសម្រេចដោយធានាថា បរិយាបន្នមានគោលបំណងច្បាស់លាស់ និងប្រកបដោយអត្ថន័យ។ ដៃគូអភិវឌ្ឍន៍ត្រូវបានគេមើលឃើញថាដើរតួនាទីសំខាន់ក្នុងការគាំទ្រដល់អន្តរកាលនេះ ចាប់ពីការកសាងសមត្ថភាពបច្ចេកទេស និងការពង្រឹងប្រព័ន្ធទិន្នន័យរហូតដល់ការសាកល្បងអភិក្រមបែបបរិយាបន្ន និងការសម្របសម្រួលកិច្ចសហការអន្តរក្រសួង។ ការគាំទ្ររបស់ពួកគេត្រូវបានចាត់ទុកជាកត្តាសំខាន់ក្នុងការរំកិល សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គមឱ្យឈានហួសពីគោលបំណងគោលនយោបាយ ទៅជាការអនុវត្តជាក់ស្តែង និងប្រកបដោយចីរភាព។

## ៥ ការដោះស្រាយបញ្ហាប្រឈមដែលពាក់ព័ន្ធនឹងពិការភាព

បរិយាបន្នពិការភាពទាមទារឱ្យមានទាំងវិធានការផ្នែករចនាសម្ព័ន្ធ និងការចូលរួម។ ការិយាល័យរដ្ឋាភិបាល កន្លែងប្រជុំ និងថ្នាលឌីជីថល គួរតែធ្វើឱ្យមានភាពងាយស្រួលចេញចូល និងប្រើប្រាស់ ទាំងផ្នែករូបវន្ត និងឌីជីថល ដោយមានការរៀបចំ ដូចជា ជម្រាល ស្លាកសញ្ញា អក្សររត់ពីក្រោម និងការបកប្រែភាសាសញ្ញា។ គួរខិតខំលើកកម្ពស់ការជ្រើសរើសជនមានពិការភាពឱ្យចូលបម្រើការងារ តាមរយៈការកំណត់គោលដៅ ការផ្តល់ការណែនាំ និងគន្លងអភិវឌ្ឍន៍អាជីព ចំណែកការពិគ្រោះយោបល់លើគោលនយោបាយ ត្រូវតែរួមបញ្ចូលជនមានពិការភាពចម្រុះ តាំងពីដំណាក់កាលនៃការរៀបចំផែនការដំបូង។ ក្រសួងដែលបង្ហាញពីការអនុវត្តបរិយាបន្នប្រកបដោយប្រសិទ្ធភាព អាចត្រូវបានទទួលស្គាល់តាមរយៈការផ្តល់គ្រឿងលើកទឹកចិត្ត ឬពានរង្វាន់ ដើម្បីជំរុញឱ្យមានការអនុវត្តកាន់តែទូលំទូលាយ។

[៣១] Open Data Watch, *Guide: Integrating Intersectionality in Data Systems ( 2025 )*, https://opendatawatch.com/wp-content/uploads/2025/publications/Guide_Integrating-Intersectionality-in-Data-Systems.pdf. នេះគឺជាឯកសារណែនាំជាក់ស្តែង ដែលបោះពុម្ពផ្សាយដោយ Open Data Watch ក្រោមភាពជាដៃគូជាមួយ Data2X និងពន្យល់ពីរបៀបអនុវត្តចក្ខុនៃអន្តរប្រសព្វនៅក្នុងប្រព័ន្ធទិន្នន័យអភិវឌ្ឍន៍ ដើម្បីឱ្យទិន្នន័យឆ្លុះបញ្ចាំងកាន់តែប្រសើរអំពីបទពិសោធន៍ជាក់ស្តែងរបស់ប្រជាពលរដ្ឋ ដោយពិចារណាលើលក្ខណៈសង្គមជាច្រើន ដូចជា យេនឌ័រ អាយុ ជាតិពន្ធុ ពិការភាព និងប្រាក់ចំណូល។ ឯកសារនេះបង្ហាញពីគ្រប់ដំណាក់កាលនៃវដ្តទិន្នន័យ ចាប់ពីការសម្រេចចិត្តថាតើត្រូវប្រមូលទិន្នន័យអ្វីខ្លះ រហូតដល់របៀបដែលទិន្នន័យត្រូវបានបោះពុម្ពផ្សាយ ចូលប្រើប្រាស់ វិភាគ និងប្រើប្រាស់ក្នុងគោលនយោបាយ ដើម្បីធ្វើឱ្យទិន្នន័យកាន់តែប្រកបដោយបរិយាបន្ន និងមានប្រយោជន៍សម្រាប់ការធ្វើសេចក្តីសម្រេច។ ឯកសារនេះគូសបញ្ជាក់ពីការពិចារណាជាក់ស្តែង ដើម្បីកែលម្អគុណភាពទិន្នន័យ ទាក់ទាញឱ្យក្រុមងាយរងគ្រោះចូលរួមក្នុងដំណើរការទិន្នន័យ និងធានាថា ទិន្នន័យពិតជាត្រូវបានប្រើប្រាស់ ដើម្បីជំរុញឱ្យមានការផ្លាស់ប្តូរជាវិជ្ជមាន។

## ៣.២ ស្ថាប័នវិស័យស្រាវជ្រាវ

### សំណួរស្រាវជ្រាវទី ២

តើអ្នកស្រាវជ្រាវបញ្ជ្រាប ឬដាក់បញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គមយ៉ាងដូចម្ដេច? តើពួកគេជួបប្រទះបញ្ហាប្រឈមអ្វីខ្លះ? ហើយតើការគាំទ្រអ្វីខ្លះ ដែលនឹងជួយបញ្ជ្រាបសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ឱ្យកាន់តែមានប្រសិទ្ធភាពទៅក្នុងការអនុវត្តការស្រាវជ្រាវ?

ផ្នែកនេះបង្ហាញពីលទ្ធផលទាក់ទងនឹងរបៀបដែលអ្នកស្រាវជ្រាវបញ្ជ្រាប និងដាក់បញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ទៅក្នុងការងាររបស់ពួកគេ។ ផ្នែកនេះពិនិត្យមើលអភិក្រម ដែលពួកគេកំពុងប្រើប្រាស់ក្នុងពេលបច្ចុប្បន្ន បញ្ហាប្រឈមជាក់ស្ដែងដែលពួកគេកំពុងជួបប្រទះក្នុងការអនុវត្ត សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ឱ្យបានជាប់លាប់ និងការគាំទ្រ ឬធាតុចូលបន្ថែម ដែលអាចជួយពង្រឹងការដាក់បញ្ចូល សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម នៅទូទាំងវដ្ដនៃការស្រាវជ្រាវ។

ការពិភាក្សាគោលនយោបាយរបស់កម្ពុជា កាន់តែឆ្លុះបញ្ចាំងពីការទទួលស្គាល់តួនាទីរបស់ទិន្នន័យ និងការស្រាវជ្រាវ ក្នុងការធ្វើសេចក្ដីសម្រេចប្រកបដោយប្រសិទ្ធភាព។ សេចក្ដីថ្លែងការណ៍របស់រដ្ឋាភិបាល បានសង្កត់ធ្ងន់ម្ដងហើយម្ដងទៀតលើតម្រូវការទិន្នន័យ ដែលសុក្រឹតបែកចែកជាប្រភេទ និងនៅកម្រិតទ្រង់ទ្រាយតូច ដើម្បីធានាថាគោលនយោបាយឆ្លុះបញ្ចាំងពីតថភាពសេដ្ឋកិច្ច និងសង្គមជាក់ស្ដែងជាពិសេសសម្រាប់អាជីវកម្មខ្នាតតូច ប្រាក់ចំណូលគ្រួសារ និងទិន្នន័យប្រជាពលរដ្ឋងាយរងគ្រោះ។ ប្រមុខរាជរដ្ឋាភិបាលបានអំពាវនាវជាសាធារណៈឱ្យពង្រឹងការស្រាវជ្រាវផ្នែកសិក្សាធិការ និងការកែលម្អប្រព័ន្ធទិន្នន័យ ដើម្បីផ្ដល់ព័ត៌មានដល់យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដោយផ្សារភ្ជាប់ទិន្នន័យដោយផ្ទាល់ទៅនឹងការកំណត់គោលដៅ និងការអនុវត្តគោលនយោបាយ។[៣២] ការសង្កត់ធ្ងន់បែបនេះ ត្រូវបានពង្រឹងបន្ថែមនៅក្នុងមតិយោបល់ផ្លូវការ ដែលគូសបញ្ជាក់ពីតួនាទីរបស់ស្ថាប័នស្រាវជ្រាវថ្នាក់ជាតិក្នុងនាមជាអ្នករួមចំណែកដ៏សំខាន់ដល់ការតាក់តែងគោលនយោបាយ ការប្រមូលទិន្នន័យ និងការជជែកដេញដោលជាសាធារណៈ។ សញ្ញាទាំងនេះរំលេចឱ្យឃើញទស្សនៈទូលំទូលាយរបស់រដ្ឋាភិបាលដែលយល់ថា ការតាក់តែងគោលនយោបាយផ្អែកលើទិន្នន័យ និងប្រកបដោយបរិយាបន្ន រួមទាំងការយកចិត្តទុកដាក់លើជាតុផ្សំនៃសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម អាស្រ័យលើការស្រាវជ្រាវដែលអាចទុកចិត្តបាន ស្ថាប័នស្រាវជ្រាវដ៏រឹងមាំ និងការចូលរួមប្រកបដោយនិរន្តរភាពរវាងអ្នកស្រាវជ្រាវ អ្នកតាក់តែងគោលនយោបាយ និងសហគមន៍។

[៣២] https://en.freshnewsasia.com/index.php/en/localnews/67129-2026-01-20-07-11-34.html; https://kiripost.com/stories/pm-calls-for-micro-business-data-to-align-with-economic-growth-reality; https://coc2025.cdri.org.kh/storage/uploads/programme/pdf/1741097582_en.pdf; https://www.khmertimeskh.com/501521408/raising-incomes-through-data-focus-of-world-population-day/; https://www.khmertimeskh.com/501596172/pm-urges-enhanced-academic-research/

## ៣.២.១. ទិដ្ឋភាពទូទៅនៃវិស័យស្រាវជ្រាវ

វិស័យស្រាវជ្រាវនៅកម្ពុជា ដែលត្រូវបានកំណត់ជាប្រព័ន្ធអេកូឡូស៊ីនៃស្ថាប័នដែលបង្កើត វិភាគ និងប្រើប្រាស់ការស្រាវជ្រាវ ដើម្បីផ្តល់ព័ត៌មានដល់គោលនយោបាយសាធារណៈ មានភាពរីកចម្រើនគួរឱ្យកត់សម្គាល់ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ។ វិស័យស្រាវជ្រាវនៅកម្ពុជារួមមានសាកលវិទ្យាល័យរដ្ឋ ស្ថាប័នthink thanks វិទ្យាស្ថានស្រាវជ្រាវ និងអង្គការសង្គមស៊ីវិល។ ការសិក្សាវិភាគរបស់កម្មវិធីពន្លកចំណេះ ឆ្នាំ២០២០ បានគូសបញ្ជាក់ថា ទោះបីជាប្រព័ន្ធអេកូឡូស៊ីនេះកំពុងធ្វើសកម្មភាពកាន់តែច្រើនក៏ដោយ ប៉ុន្តែសមត្ថភាព ការសម្របសម្រួល និងផលជះលើគោលនយោបាយ គឺមានកម្រិតខុសគ្នា។[៣៣]

ចំណុចស្នូលនៃការស្រាវជ្រាវផ្នែកសិក្សាធិការ គឺសាកលវិទ្យាល័យរដ្ឋ ដូចជា សាកលវិទ្យាល័យភូមិន្ទភ្នំពេញ[៣៤] ដែលរួមបញ្ចូលកម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រ និងក្រោយបរិញ្ញាបត្រដ៏ធំ ជាមួយនឹងការស្រាវជ្រាវ និងការផ្តល់សេវាដល់សង្គម ព្រមទាំងស្ថាប័នជាតិផ្សេងទៀតដូចជារាជបណ្ឌិត្យសភាកម្ពុជា[៣៥] ដែលដើរតួជាស្ថាប័នស្រាវជ្រាវ និងផ្តល់យោបល់ផ្សារភ្ជាប់នឹងរដ្ឋាភិបាល និងជាអ្នកអភិវឌ្ឍធនធានមនុស្សលើវិស័យជាច្រើន។ សាកលវិទ្យាល័យឯកជន បង្កើតឱ្យមានក្រុមប្រឹក្សា និងវិទ្យាស្ថានស្រាវជ្រាវ ដែលគាំទ្រដល់ការស្រាវជ្រាវរបស់មហាវិទ្យាល័យ និងនិស្សិត ក្នុង សង្គមកិច្ច សេដ្ឋកិច្ច និងវិទ្យាសាស្ត្រ។ ស្ថាប័នទាំងនេះមានគោលបំណងកសាងសមត្ថភាពស្រាវជ្រាវផ្ទៃក្នុង ផលិតឯកសារបោះពុម្ពផ្សាយ និងតភ្ជាប់បញ្ញវន្តកម្ពុជាទៅកាន់បណ្តាញថ្នាក់តំបន់ និងសកលលោក។[៣៦]

ទោះជាយ៉ាងណា ទិន្នន័យពីការសិក្សាវិភាគលើវិស័យស្រាវជ្រាវនៅកម្ពុជា បានគូសបញ្ជាក់ថា ខណៈពេលដែលសាកលវិទ្យាល័យជាសសរស្តម្ភដ៏សំខាន់សម្រាប់ប្រព័ន្ធអេកូឡូស៊ីនៃការស្រាវជ្រាវ មុខងារស្រាវជ្រាវរបស់សាកលវិទ្យាល័យនៅតែមានលក្ខណៈបន្ទាប់បន្សំបើធៀបនឹងការបង្រៀន។ ជារឿយៗ បុគ្គលិកសិក្សាប្រឈមនឹងបន្ទុកការបង្រៀនដ៏ធ្ងន់ លទ្ធភាពទទួលបានថវិកាស្រាវជ្រាវនៅមានកម្រិត និងកង្វះការលើកទឹកចិត្តដល់ការបោះពុម្ពផ្សាយ ដែលរឹតត្បិតសមត្ថភាពរបស់ពួកគេក្នុងការរក្សារបៀបវារៈការស្រាវជ្រាវរយៈពេលវែង។ ដូច្នេះហើយទើបជារឿយៗ ការស្រាវជ្រាវនៅក្នុងសាកលវិទ្យាល័យ ត្រូវបានធ្វើឡើងដាច់ដោយឡែកពីគ្នា និងពឹងផ្អែកលើគម្រោងដែលទទួលបានមូលនិធិពីខាងក្រៅ ជាជាងអាទិភាពដែលជំរុញដោយស្ថាប័នផ្ទាល់។[៣៧]

ក្រៅពីសាកលវិទ្យាល័យនានា វិស័យស្រាវជ្រាវរបស់កម្ពុជារួមបញ្ចូលពីក្រុមស្ថាប័នស្រាវជ្រាវឯកទេស និងស្ថាប័នស្រាវជ្រាវ និងផ្តល់យោបល់ដែលកំពុងមានសន្ទុះកើនឡើង និងដើរតួនាទីកាន់តែលេចធ្លោនៅក្នុងវិស័យស្រាវជ្រាវ និងការពិភាក្សាដែលផ្តោតលើគោលនយោបាយ។ ស្ថាប័នទាំងនោះមានដូចជា វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) មជ្ឈមណ្ឌលសិក្សាគោលនយោបាយ (CPS) មជ្ឈមណ្ឌលខេមរសិក្សា (CKS) និងវេទិកាអនាគត (FF) ធ្វើការស្រាវជ្រាវអនុវត្តន៍លើវិស័យអភិបាលកិច្ច ការអភិវឌ្ឍសេដ្ឋកិច្ច ការអប់រំ ការប្រែប្រួលអាកាសធាតុ និងធនធានធម្មជាតិ។ បើធៀបនឹងសាកលវិទ្យាល័យអង្គការទាំងនេះ ច្រើនតែចូលរួមកាន់តែផ្ទាល់ក្នុងដំណើរការគោលនយោបាយ ដោយបង្កើតជាសេចក្តីសង្ខេបគោលនយោបាយ ឯកសារការងារ និងការវិភាគ ដែលសម្របទៅតាមតម្រូវការរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍។ ជំហររបស់អង្គការទាំងនេះ អនុញ្ញាតឱ្យពួកគេដើរតួជាអន្តរការីរវាងការស្រាវជ្រាវ និងការតាក់តែងគោលនយោបាយ ដែលរួមចំណែកដល់ការពិភាក្សាផ្អែកលើទិន្នន័យ និងក្នុងករណីមួយចំនួន ដែលជះឥទ្ធិពលដល់ការតាក់តែងគោលនយោបាយ។

៣៣ Pak, K., Fathimath, I., and Pellini, A. ( 2020 ), Diagnostic Study on the Cambodian Knowledge Sector, Policy Pulse, https://policypulse.org/wp-content/uploads/2020/07/Diagnostic_Study_FINAL_English-3.pdf

៣៤ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

៣៥ https://www.rac.gov.kh/public/

៣៦ ស្ថាប័នដែលបានលើកឡើងខាងលើគ្រាន់តែជាឧទាហរណ៍ប៉ុណ្ណោះ មិនមែនមានន័យថារាប់បញ្ចូលទាំងអស់នោះទេ។ ស្ថាប័នទាំងនេះគូសបញ្ជាក់ពីបណ្តុំតូចមួយនៃតួអង្គលេចធ្លោនៅក្នុងវិស័យស្រាវជ្រាវផ្នែកសិក្សាធិការនៅកម្ពុជា។ បញ្ជីឈ្មោះពេញលេញ និងធ្វើបច្ចុប្បន្នភាពជាប្រចាំ នៃសាកលវិទ្យាល័យរដ្ឋ និងឯកជន មាននៅក្រសួងអប់រំ យុវជន និងកីឡា។

៣៧ Pak, K., Fathimath, I., and Pellini, A. ( 2020 ), Diagnostic Study on the Cambodian Knowledge Sector, Policy Pulse, https://policypulse.org/wp-content/uploads/2020/07/Diagnostic_Study_FINAL_English-3.pdf

ការសិក្សាវិភាគនេះបានកត់សម្គាល់បន្ថែមទៀតថា ការស្រាវជ្រាវភាគច្រើនដែលធ្វើឡើងដោយអង្គការទាំងនេះ រងឥទ្ធិពលពីការងារទីប្រឹក្សា បានត្រឹមរយៈពេលខ្លី ដែលទទួលបានមូលនិធិពីម្ចាស់ជំនួយ ជាជាងរបៀបវារៈស្រាវជ្រាវតាមកម្មវិធី និងប្រកបដោយនិរន្តរភាព។ ខណៈដែលការធ្វើបែបនេះជួយឱ្យមានការឆ្លើយតបទៅនឹងបញ្ហាគោលនយោបាយដែលកំពុងលេចឡើង វាក៏អាចកម្រិតដល់និរន្តរភាព ភាពស៊ីជម្រៅនៃការវិភាគ និងការអភិវឌ្ឍអាទិភាពស្រាវជ្រាវដោយឯករាជ្យ ព្រមទាំងរួមចំណែកធ្វើឱ្យប្រែប្រួលគុណភាពនៃការស្រាវជ្រាវ និងកម្រិតការវិនិយោគលើការកសាងសមត្ថភាពរយៈពេលវែង រួមទាំងការបង្កើតវិធីសាស្ត្រថ្មីៗ និងអភិក្រមអន្តរវិស័យផងដែរ។

ក្រៅពីស្ថាប័នស្នូលទាំងនេះ ប្រព័ន្ធអេកូឡូស៊ីដ៏ទូលំទូលាយនៃតួអង្គស្រាវជ្រាវ និងគោលនយោបាយ ក៏រួមចំណែកដល់ការបង្កើតចំណេះដឹង និងការពិភាក្សាផងដែរ។ នេះរាប់បញ្ចូលទាំងអង្គការដែលរួមបញ្ចូលការស្រាវជ្រាវជាមួយនឹងការតស៊ូមតិ និងការចូលរួមរបស់សហគមន៍ ដូចជា អង្គការសមាគមជាងត្នោត ព្រមទាំងវេទិកាដែលគាំទ្រដល់ការសម្របសម្រួល និងការអភិវឌ្ឍសមត្ថភាពនៅទូទាំងសង្គមស៊ីវិល ដូចជា គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា។ តួអង្គស្រាវជ្រាវថ្នាក់តំបន់ និងអន្តរជាតិ រួមទាំងវិទ្យាស្ថានកម្ពុជាសម្រាប់កិច្ចសហប្រតិបត្តិការ និងសន្តិភាព វិទ្យាស្ថានចក្ខុវិស័យអាស៊ី និងមូលនិធិ Konrad-Adenauer-Stiftung (KAS) ក៏រួមចំណែកដល់ការវិភាគគោលនយោបាយ និងការពិភាក្សាស្តីពីអភិបាលកិច្ច កិច្ចសហប្រតិបត្តិការតំបន់ និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមផងដែរ។

រួមគ្នា ស្ថាប័នទាំងនេះបង្កើតបានជាប្រព័ន្ធអេកូឡូស៊ីស្រាវជ្រាវដ៏ចម្រុះ និងកំពុងវិវឌ្ឍឈានឡើង ដែលមិនត្រឹមតែបង្កើតទិន្នន័យប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដើរតួជាវេទិកាសម្រាប់ការពិភាក្សា កិច្ចសហការ និងការអភិវឌ្ឍអ្នកស្រាវជ្រាវវ័យក្មេងផងដែរ។ ទោះជាយ៉ាងណាក៏ដោយ ដូចដែលបានស្វែងយល់នៅក្នុងផ្នែកខាងក្រោមរួចមកហើយ ការដាក់បញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ជាប្រព័ន្ធទៅក្នុងប្រព័ន្ធអេកូឡូស៊ីនេះទាំងមូល នៅតែមានកម្រិតមិនស្មើគ្នា។[៣៨ ៣៩]

ការដឹកនាំ និងការរៀបចំបុគ្គលិកនៅទូទាំងស្ថាប័នទាំងនេះ ឆ្លុះបញ្ចាំងពីអាណត្តិ និងទម្រង់ប្រតិបត្តិការខុសៗគ្នារបស់ពួកគេ។ តាមធម្មតា សាកលវិទ្យាល័យដឹកនាំដោយបញ្ញវន្តជាន់ខ្ពស់ និងរចនាសម្ព័ន្ធថ្នាក់ដឹកនាំមហាវិទ្យាល័យ ចំណែកឯស្ថាប័នthink tanks និងវិទ្យាស្ថានស្រាវជ្រាវ ដឹកនាំដោយនាយកប្រតិបត្តិ ឬក្រុមប្រឹក្សាភិបាលដែលមានជំនាញខាងគោលនយោបាយ និងវិស័យ។ នៅទូទាំងវិស័យនេះ ក្រុមស្រាវជ្រាវច្រើនតែរួមបញ្ចូលគ្នានូវអ្នកស្រាវជ្រាវជាជនជាតិខ្មែរ និងអ្នកស្រាវជ្រាវជាជនបរទេស ទោះបីជាតំណែងជាអ្នកស្រាវជ្រាវជាន់ខ្ពស់ និងការដឹកនាំ នៅតែប្រមូលផ្តុំក្នុងចំណោមអ្នកជំនាញមួយចំនួនតូចដែលមានបទពិសោធន៍ក៏ដោយ។ ការសិក្សាវិភាគនេះក៏បានគូសបញ្ជាក់ពីគម្លាតនៅក្នុងគន្លងអាជីពសម្រាប់អ្នកស្រាវជ្រាវផងដែរ ជាពិសេសសម្រាប់បញ្ញវន្តដែលទើបចាប់ផ្តើមអាជីព និងឱកាសមានកម្រិតក្នុងទទួលបានការបណ្តុះបណ្តាលកម្រិតខ្ពស់ និងការណែនាំនៅក្នុងប្រទេសកម្ពុជា។

ការស្រាវជ្រាវភាគច្រើនធ្វើឡើងដោយបញ្ញវន្ត បុគ្គលិកស្រាវជ្រាវ ឬទីប្រឹក្សា ដែលបំពេញការងារតាមរយៈមូលនិធិផ្អែកលើគម្រោង។ លទ្ធផលសម្រេច រួមមានឯកសារបោះពុម្ពផ្សាយដែលត្រួតពិនិត្យដោយអ្នកជំនាញដូចគ្នា សេចក្តីសង្ខេបគោលនយោបាយ ការវាយតម្លៃផ្នែកបច្ចេកទេស និងការវាយតម្លៃដែលផ្តោតគោលដៅលើក្រុមគោលដៅចម្រុះ រួមទាំងរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងសហគមន៍សិក្សាធិការ។ លទ្ធផលទាំងនេះរួមចំណែកដល់ការពិភាក្សាគោលនយោបាយ ផ្តល់ព័ត៌មានសម្រាប់ការរៀបចំ ការអនុវត្តកម្មវិធី និងជួយតម្រឹមតម្រង់ការជជែកដេញដោលជាសាធារណៈ។ ទោះជាយ៉ាងណា កម្រិតដែលការស្រាវជ្រាវផ្តល់ព័ត៌មានជាប្រព័ន្ធដល់ការធ្វើសេចក្តីសម្រេច អាស្រ័យលើកត្តាដូចជា ពេលវេលា ភាពពាក់ព័ន្ធ ការបង្កភាពងាយស្រួល និងភាពរឹងមាំនៃទំនាក់ទំនងរវាងអ្នកស្រាវជ្រាវ និងអ្នកតាក់តែងគោលនយោបាយ។

៣៨ Konrad-Adenauer-Stiftung Cambodia. (2025). *The evolving role of think tanks in Cambodia*: Special report. Konrad-Adenauer-Stiftung Cambodia.

៣៩ មិនមានបញ្ជីសារពើភណ្ឌជាសាធារណៈផ្លូវការណាមួយ រាយនាមអង្គការមិនមែនរដ្ឋាភិបាល ស្ថាប័នthink tanks វិទ្យាស្ថានស្រាវជ្រាវ និងអង្គការសង្គមស៊ីវិលទាំងអស់ ដែលកំពុងធ្វើប្រតិបត្តិការនៅកម្ពុជាឱ្យបានគ្រប់ជ្រុងជ្រោយនោះទេ។ ព័ត៌មានអំពីតួអង្គទាំងនេះត្រូវបានចែកចាយនៅទូទាំងប្រព័ន្ធទិន្នន័យ និងបញ្ជីរាយនាមក្រៅផ្លូវការជាច្រើន ដែលគ្រប់គ្រងដោយបណ្តាញសង្គមស៊ីវិល ថ្នាលស្រាវជ្រាវ និងដៃគូអភិវឌ្ឍន៍។

សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម មានលេចឡើងនៅក្នុងរបៀបវារៈ និងដំណើរការស្រាវជ្រាវ ទោះបីជាក្នុងកម្រិតមិនស្មើគ្នាក៏ដោយ។ កម្មវិធីស្រាវជ្រាវមួយចំនួនបានដាក់បញ្ចូលទស្សនទាន សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ជាផ្លូវការ ជាពិសេសក្នុងករណីដែលការងារផ្តោតគោលដៅលើបរិយាបន្នក្នុងការអប់រំ អភិបាលកិច្ច សុខាភិបាល ឬជីវភាពរស់នៅ។ ការបណ្តុះបណ្តាល និងការណែនាំស្តីពីការអនុវត្តចក្ខុសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម នៅក្នុងការរៀបចំ និងការវិភាគការស្រាវជ្រាវ ត្រូវបានផ្តល់ជូនដោយគំនិតផ្តួចផ្តើមអន្តរជាតិមួយចំនួន ដែលជួយអ្នកស្រាវជ្រាវកសាងជំនាញក្នុងការកំណត់រក និងវាស់វែងវិសមភាព និងលទ្ធផលបរិយាបន្ន។ បណ្តាញ និងក្រុមអ្នកជំនាញផ្នែកសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ក៏បានផ្តល់ប្រឹក្សាលើការអនុវត្តការស្រាវជ្រាវប្រកបដោយបរិយាបន្ន ការចូលរួមជាមួយសហគមន៍ដែលត្រូវបានផាត់ចេញ និងការកសាងសមត្ថភាពសម្រាប់ការស្រាវជ្រាវគោលនយោបាយប្រកបដោយបរិយាបន្នផងដែរ។[៤០]

## ៣.២.២. ការអនុវត្តសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម នៅក្នុងស្ថាប័នស្រាវជ្រាវ

ស្ថាប័នស្រាវជ្រាវ និងអ្នកស្រាវជ្រាវ ដែលចូលរួមក្នុងការវិភាគនេះ បានបង្ហាញពីចំណាប់អារម្មណ៍យ៉ាងខ្លាំងចំពោះការស្រាវជ្រាវប្រកបដោយបរិយាបន្ន។ ទោះជាយ៉ាងណា ការដាក់បញ្ចូលគោលការណ៍សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ជាប្រព័ន្ធ និងប្រកបដោយនិរន្តរភាព នៅមានកម្រិតនៅឡើយ។ នៅក្នុងការអនុវត្តជាក់ស្តែង ស្ត្រី យុវជន ជនមានពិការភាព សហគមន៍ជនជាតិដើមភាគតិច ជនជាតិភាគតិច និងបុគ្គលដែលមានអត្តសញ្ញាណជាអន្តរប្រសព្វ ច្រើនតែត្រូវបានដាក់បញ្ចូល លុះត្រាតែពួកគេគឺជាចំណុចផ្តោតសំខាន់ផ្ទាល់នៃការសិក្សាតែប៉ុណ្ណោះ។ មានអង្គការតិចតួចណាស់ដែលអនុវត្តការគិតគូរពីសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ឱ្យបានជាប់លាប់នៅគ្រប់ដំណាក់កាលទាំងអស់ ទាំងនៅក្នុងការរៀបចំ ការវិភាគ ឬការផ្សព្វផ្សាយការស្រាវជ្រាវ។ ភាគច្រើននៃការងារមានស្រាប់ ដែលពាក់ព័ន្ធនឹងយេនឌ័រ ឬអត្តសញ្ញាណសង្គមផ្សេងទៀត ត្រូវបានជំរុញដោយអាទិភាពរបស់ម្ចាស់ជំនួយ ជាជាងជំរុញដោយគោលនយោបាយផ្ទៃក្នុង ក្របខណ្ឌ ឬការលើកទឹកចិត្តរបស់ស្ថាប័នផ្ទាល់។

នេះឆ្លុះបញ្ចាំងពីលំនាំទូលំទូលាយដែលបានរកឃើញនៅក្នុងការសិក្សាវិភាគលើវិស័យស្រាវជ្រាវនៅកម្ពុជា ដែលគូសបញ្ជាក់ថា ជារឿយៗរបៀបវារៈស្រាវជ្រាវត្រូវបានតម្រឹមតម្រង់ដោយគម្រោងរយៈពេលខ្លី ដែលទទួលបានមូលនិធិពីខាងក្រៅ ជាជាងអាទិភាពស្ថាប័នដែលប្រកបដោយនិរន្តរភាព។ ដូច្នេះហើយទើបបញ្ហាអន្តរវិស័យ ដូចជាសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ត្រូវបានគេចាត់ទុកថាជាលក្ខខណ្ឌតម្រូវតាមគម្រោង ជាជាងជាធាតុផ្សំស្នូលនៃគុណភាពការស្រាវជ្រាវ។

ជាទូទៅ ការយល់ដឹងអំពីទស្សនទានសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម នៅមានកម្រិតទាប ដោយអង្គការភាគច្រើនផ្តោតជាចម្បងលើយេនឌ័រ និងខ្វះអាណត្តិការងារច្បាស់លាស់ ឬការណែនាំជាក់ស្តែងសម្រាប់បរិយាបន្ន។ បទសម្ភាសន៍ និងការពិភាក្សាបានបង្ហាញថា ខណៈដែលជាទូទៅ អ្នកស្រាវជ្រាវបានលើកឡើងពីបញ្ហាកង្វះថវិកា និងសមត្ថភាពបុគ្គលិក និងអ្នកគ្រប់គ្រង ហាក់ដូចជាមិនសូវចង់ដោះស្រាយគម្លាតទាំងនេះភ្លាមៗទេ។ ដោយសារការស្រាវជ្រាវភាគច្រើនទទួលបានមូលនិធិពីម្ចាស់ជំនួយ កង្វះការលើកទឹកចិត្ត ឬ ការរំពឹងទុកខ្លាំងពីម្ចាស់ជំនួយ ច្រើនតែមិនសូវជំរុញឱ្យមានការដាក់បញ្ចូល សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ជាប្រព័ន្ធ។ បញ្ហាប្រឈមមួយទៀតគឺកង្វះការយល់ដឹងជារួមអំពីសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម។ ក្នុងចំណោមដៃគូរបស់កម្មវិធីពន្លកចំណេះ ដំណាក់កាលទី២ មិនមានការកំណត់ជារួមមួយ និងស៊ីសង្វាក់គ្នា ដើម្បីណែនាំដល់ការអនុវត្តនោះទេ។ ខណៈដែលគំនិតផ្តួចផ្តើមភាគច្រើនរួមបញ្ចូលការផ្តោតសំខាន់ខ្លះៗទៅលើស្ត្រី និងកត្តាផ្សេងទៀតដូចជា ពិការភាព ជាតិពន្ធុ ឬអត្តសញ្ញាណជាជនជាតិដើមភាគតិច ច្រើនតែត្រូវបានដោះស្រាយដាច់ដោយឡែកពីគ្នា ជាជាងតាមរយៈចក្ខុនៃភាពអន្តរប្រសព្វ។ ទោះបីជាទស្សនទាននៃភាពអន្តរប្រសព្វ ត្រូវបានលើកឡើងកាន់តែច្រើននៅក្នុងយុទ្ធសាស្ត្រ និងការពិភាក្សាក៏ដោយ ប៉ុន្តែវាកម្រត្រូវបានប្រែក្លាយទៅជាការរៀបចំការស្រាវជ្រាវ វិធីសាស្ត្រ ឬការវិភាគជាក់ស្តែងណាស់។

ប្រអប់ទី ១០

## របៀបដែលកម្មវិធីពន្លកចំណេះដំណាក់កាលទី២ បញ្ជ្រាបសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ទៅក្នុងការផ្សារភ្ជាប់ការស្រាវជ្រាវជាមួយនឹងគោលនយោបាយ

កម្មវិធីពន្លកចំណេះដំណាក់កាលទី២ បានចាត់វិធានការនានាដើម្បីធ្វើជាគំរូនៃការបញ្ជ្រាបសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ដែលកម្មវិធីបានលើកទឹកចិត្តឱ្យអនុវត្តនៅទូទាំងក្នុងវិស័យនេះ។ នេះរួមបញ្ចូលទាំងការច្របាច់បញ្ចូលគ្នានូវរចនាសម្ព័ន្ធស្ថាប័ន ការគាំទ្រផ្នែកបច្ចេកទេស និងការអនុវត្តនៅក្នុងកម្មវិធីទាំងមូល។
នៅកម្រិតស្ថាប័ន កម្មវិធីបានបង្កើតយន្តការសំខាន់ៗចំនួនបី៖

១. ក្រុមអ្នកជំនាញផ្នែកសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម រួមមានអង្គការជនពិការកម្ពុជា (CDPO) អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា (GADC) និងអង្គការនារីដើម្បីសន្តិភាព (WPM) ដែលជាអង្គការក្នុងមូលដ្ឋាន ដែលមានជំនាញឯកទេសស៊ីជម្រៅលើសមភាពយេនឌ័រ បរិយាបន្នពិការភាព និងបរិយាបន្នសង្គម។
២. បណ្ដាញស្ត្រីក្នុងវិស័យស្រាវជ្រាវSheThinks គឺជាបណ្ដាញស្ត្រីនៅក្នុងវិស័យស្រាវជ្រាវកម្រិតជាតិដំបូងគេ និងកំពុងលេចរូបរាងឡើងសម្រាប់តែស្ត្រីនៅកម្ពុជា ដែលគាំទ្រដល់អ្នកស្រាវជ្រាវជាស្ត្រីតាមរយៈការតម្រង់ទិស ការកសាងសមត្ថភាព និងការចូលរួមជាសមូហភាព។
៣ មន្ត្រីបង្គោលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម នៅក្នុងអង្គការដៃគូ ដែលដើរតួជាអ្នកគាំទ្រ និងជំរុញផ្ទៃក្នុងដើម្បីលើកកម្ពស់ការដាក់បញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ទៅក្នុងការរៀបចំការស្រាវជ្រាវ ការអនុវត្តគម្រោង និងការអនុវត្តការងារនៅស្ថាប័ន។

តាមរយៈក្រុមអ្នកជំនាញផ្នែកសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម កម្មវិធីពន្លកចំណេះដំណាក់កាលទី ២ បានផ្ដល់ការគាំទ្រផ្នែកបច្ចេកទេសដោយផ្ទាល់ដល់ដៃគូស្រាវជ្រាវ។ ការងារនេះរួមមានការផ្ដល់ការបណ្ដុះបណ្ដាលស្ដីពី សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម និងការសិក្សាស្រាវជ្រាវបែបចូលរួមផ្អែកលើគោលការណ៍ហ្វេមីនីស្ត (FPAR) ការភ្ជាប់ទំនាក់ទំនងអ្នកស្រាវជ្រាវជាមួយសហគមន៍ដែលត្រូវបានផាត់ចេញ ការរួមចំណែកដល់ដំណើរការការពិភាក្សាគោលនយោបាយ និងការគាំទ្រដល់ការអភិវឌ្ឍ និងការអនុវត្តគោលការណ៍ណែនាំស្ដីពីការស្រាវជ្រាវ។

ក្រៅពីរចនាសម្ព័ន្ធទាំងនេះ សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ត្រូវបានដាក់បញ្ចូលនៅទូទាំងវដ្ដនៃការស្រាវជ្រាវ និងគោលនយោបាយ រួមទាំងនៅក្នុងការរៀបចំការស្រាវជ្រាវ តាមរយៈស្តង់ដារគុណភាពនៃការស្រាវជ្រាវ គោលការណ៍ណែនាំសម្រាប់ការពិភាក្សាប្រកបដោយបរិយាបន្ន និងយន្តការចូលរួមក្នុងគោលនយោបាយ មានជាអាទិ៍មូលនិធិគាំទ្រការចូលរួមក្នុងគោលនយោបាយ (Policy Engagement Fund)។ សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ត្រូវបានគាំទ្របន្ថែមទៀតតាមរយៈការប្រាស្រ័យទាក់ទងដែលបង្កភាពងាយស្រួល និងត្រូវបានតាមដានតាមរយៈសូចនាករ MEL ស្ដីពីការស្រាវជ្រាវ ការពិភាក្សា និងការចូលរួមប្រកបដោយបរិយាបន្ន។

យន្តការទាំងនេះជួយដោះស្រាយគម្លាតដ៏សំខាន់មួយនៅទូទាំងវិស័យនេះ គឺកង្វះអ្នកជំនាញផ្នែកសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម នៅក្នុងស្ថាប័នស្រាវជ្រាវ។ តាមរយៈការច្របាច់បញ្ចូលគ្នានូវការគាំទ្រផ្នែកបច្ចេកទេសជាមួយបណ្ដាញដៃគូ និងវេទិកា/ថ្នាលសម្រាប់ការចូលរួម កម្មវិធីពន្លកចំណេះដំណាក់កាលទី២ បាន និងកំពុងរួមចំណែកដល់ការបង្កើតប្រព័ន្ធអេកូឡូស៊ីនៃការស្រាវជ្រាវមួយ ដែលប្រកបដោយបរិយាបន្ន និងការតភ្ជាប់ទំនាក់ទំនងគ្នាកាន់តែប្រសើរ។

## ភាពខុសគ្នានៅតាមទម្រង់អង្គការ

ក្នុងចំណោមអង្គការដែលត្រូវបានសម្ភាសន៍ មានចេតនាច្បាស់លាស់ក្នុងការដាក់បញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ទៅក្នុងការស្រាវជ្រាវ ប៉ុន្តែការអនុវត្តនៅមានកម្រិតមិនស្មើគ្នា និងពឹងផ្អែកខ្លាំងលើអាណត្តិការងាររបស់អង្គការ ការដឹកនាំរបស់អង្គការនីមួយៗ និងការគាំទ្រដែលមាន។ មជ្ឈមណ្ឌលសិក្សាគោលនយោបាយ បង្ហាញពីការអនុវត្តល្អបំផុតនៃការស្រាវជ្រាវដែលគិតគូរពីសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម និងផ្តោតលើគោលនយោបាយ ជាពិសេសតាមរយៈការសិក្សាអំពីជីវភាពរស់នៅក្នុងជនបទដោយប្រើប្រាស់វិធីសាស្រ្តចម្រុះ ដែលធ្វើឡើងរួមគ្នាជាមួយភាគីរាជរដ្ឋាភិបាលដូចជា ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ការសិក្សាទាំងនេះតែងតែបែកចែកទិន្នន័យតាមយេនឌ័រ និងរួមបញ្ចូលជនជាតិដើមភាគតិច និងជនមានពិការភាព ហើយលទ្ធផលត្រូវបានផ្តល់ឱ្យសម្រាប់បញ្ចូលដោយផ្ទាល់ទៅក្នុងការតាក់តែងគោលនយោបាយជាតិ និងការពិភាក្សាគោលនយោបាយជាបន្តបន្ទាប់។ ទន្ទឹមនឹងនេះ មជ្ឈមណ្ឌលសិក្សាគោលនយោបាយ បានគូសបញ្ជាក់ពីបញ្ហាផ្នែកប្រតិបត្តិការដែលនៅតែបន្តកើតមាន រួមទាំងឧបសគ្គផ្នែកភាសា និងវប្បធម៌ នៅពេលប្រាស្រ័យទាក់ទងជាមួយស្ត្រីជនជាតិដើមភាគតិច កង្វះការបង្កភាពងាយស្រួលសម្រាប់ជនមានពិការភាព ទាំងក្នុងដំណើរការស្រាវជ្រាវ និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងការគ្មានស្តង់ដារបទប្បញ្ញត្តិច្បាស់លាស់សម្រាប់ការរៀបចំប្រកបដោយបរិយាបន្នពិការភាព។ ការដាក់បញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ក៏រងឥទ្ធិពលបន្ថែមទៀតដោយភាពបត់បែនរបស់ម្ចាស់ជំនួយផងដែរ ជាពិសេសក្រោមគម្រោងដែលគាំទ្រដោយ DFAT និងកម្មវិធីពន្លកចំណេះដំណាក់កាលទី២ ដែលអនុញ្ញាតឱ្យមានសំណួរស្រាវជ្រាវបន្ថែមទាក់ទងនឹងសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម។ ទោះជាយ៉ាងណា ការណែនាំអំពី សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ភាគច្រើនពឹងផ្អែកលើអ្នកជំនាញក្នុងស្ថាប័នផ្ទាល់ ជាជាងក្របខណ្ឌស្រាវជ្រាវស្តង់ដារ ដែលបណ្តាលឱ្យមានកម្រិតខុសគ្នានៃភាពស៊ីជម្រៅនៅក្នុងការវិភាគភាពអន្តរប្រសព្វ។

ផ្ទុយទៅវិញ មជ្ឈមណ្ឌលខេមរសិក្សា និងវេទិកាអនាគត អនុវត្តការងារជាចម្បងនៅក្នុងប្រព័ន្ធអេកូឡូស៊ីនៃការស្រាវជ្រាវផ្នែកសិក្សាធិការ និងអាហារូបករណ៍ ដែលការដាក់បញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ធ្វើឡើងទៅតាមបំណងប្រាថ្នា និងជំរុញដោយសមត្ថភាព ជាជាងធ្វើឡើងជាប្រព័ន្ធ។ មជ្ឈមណ្ឌលខេមរសិក្សា មិនមានក្របខណ្ឌស្រាវជ្រាវស្ថាប័នទេ ហើយដាក់ការទទួលខុសត្រូវលើសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ភាគច្រើនគឺស្តីពីជម្រើសប្រធានបទនីមួយៗរបស់និស្សិតអាហារូបករណ៍ ដោយមានការបណ្តុះបណ្តាលតិចតួច ស្តីពីរបៀបដាក់បញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ទៅក្នុងការរៀបចំការស្រាវជ្រាវ ឬវិធីសាស្រ្តសម្រាប់ការវិភាគ។ វេទិកាអនាគត បង្ហាញពីកិច្ចខិតខំប្រឹងប្រែងកាន់តែច្បាស់ក្នុងការដាក់បញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម តាមរយៈគោលនយោបាយរបស់ស្ថាប័នផ្ទាល់ ការរៀនសូត្របែបឆ្លុះបញ្ចាំង និងលទ្ធផលអនុវត្តន៍ជាក់ស្តែងដូចជា សេចក្តីសង្ខេបគោលនយោបាយ និងទស្សនទាននៃការរៀបចំទីក្រុង ដោយមានទិន្នន័យមួយចំនួននៃឥទ្ធិពលគោលនយោបាយនៅថ្នាក់ក្រុង និងថ្នាក់ជាតិ។ ទោះបីជាយ៉ាងណា ស្ថាប័នទាំងពីរបានលើកឡើងពីកង្វះអ្នកជំនាញឯកទេសផ្នែកសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ការគាំទ្រក្នុងផ្នែកបង្វឹកបង្ហាត់ និងការកែសម្រួល ព្រមទាំងការណែនាំជាក់ស្តែងស្តីពីការប្រែក្លាយទស្សនទានសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ទៅជាការស្រាវជ្រាវ និងការសរសេររៀបរៀងយ៉ាងម៉ត់ចត់។ នៅទូទាំងស្ថាប័នទាំងបី លទ្ធផលបានចង្អុលបង្ហាញពីតម្រូវការក្របខណ្ឌសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ជាក់លាក់សម្រាប់ការស្រាវជ្រាវ ដែលមានរចនាសម្ព័ន្ធច្បាស់លាស់ជាងមុន ការគាំទ្រសមត្ថភាពឱ្យបានជាប់លាប់ និងតាមលំដាប់លំដោយល្អជាងមុន និងការសង្កត់ធ្ងន់ជាងមុនលើអន្តរប្រសព្វ ដើម្បីឈានហួសពីយេនឌ័រ ជាពិសេសបរិយាបន្នពិការភាព និងបរិយាបន្នជនជាតិដើមភាគតិច។

នៅឆ្នាំ២០២៤ មជ្ឈមណ្ឌលខេមរសិក្សា តាមរយៈកម្មវិធីពន្លកចំណេះដំណាក់កាលទី២ បានធ្វើការសិក្សាមួយ ដើម្បីវាយតម្លៃស្ថានភាពនៃសមត្ថភាពស្រាវជ្រាវនៅកម្ពុជា ដោយផ្តោតទាំងលើជំនាញបុគ្គល និងបរិយាកាសស្ថាប័ន ដែលទ្រទ្រង់ជំនាញទាំងនោះ។ លទ្ធផលបង្ហាញពីមូលដ្ឋានសមត្ថភាពដែលកំពុងរីកធំ ប៉ុន្តែក្នុងកម្រិតមិនស្មើគ្នា។ អ្នកស្រាវជ្រាវជាជនជាតិខ្មែរ ជាពិសេសអ្នកដែលមានទំនាក់ទំនងជាមួយសាកលវិទ្យាល័យ ស្ថាប័នthink tanks និងវិទ្យាស្ថានស្រាវជ្រាវ បង្ហាញពីចំណុចខ្លាំងក្នុងការពិនិត្យឯកសារ ការរៀបចំការស្រាវជ្រាវ ការប្រមូលទិន្នន័យ និងការរៀបរៀងសំណេរផ្នែកសិក្សាធិការ។ អ្នកឆ្លើយតបភាគច្រើនបានវាយតម្លៃខ្លួនឯងក្នុងកម្រិតមូលដ្ឋានដល់កម្រិតល្អ នៅទូទាំងសមត្ថភាពទាំងនេះ ដែលឆ្លុះបញ្ចាំងពីវឌ្ឍនភាពឈានឡើងជាលំដាប់។ មានការចូលរួមជាហូរហែក្នុងការបណ្តុះបណ្តាលការស្រាវជ្រាវ ដែលជំរុញដោយសាកលវិទ្យាល័យ វិទ្យាស្ថានស្រាវជ្រាវ និងកម្មវិធីដែលទទួលបានការគាំទ្រពីម្ចាស់ជំនួយ។ លំនាំបែបនេះជួយកសាងមូលដ្ឋានសម្រាប់ការអនុវត្តការស្រាវជ្រាវក្នុងចំណោមបញ្ញវន្តដែលទើបចាប់ផ្តើមចូលប្រឡូក និងបញ្ញវន្តដែលឈានដល់ពាក់កណ្តាលអាជីព។

[៤១] បទសម្ភាសន៍ជាមួយក្រុមការងារនៅ CPS, CKS, FF, CDPO និងស្ថាប័នផ្សេងទៀត។
[៤២] ផ្អែកលើបទសម្ភាសន៍ជាមួយអ្នកស្រាវជ្រាវមកពីអង្គការដៃគូរបស់កម្មវិធីពន្លកចំណេះ។

## *តួនាទីរបស់កម្មវិធីពន្លកចំណេះដំណាក់កាលទី២ ក្នុងការគាំទ្រការដាក់បញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម*

កម្មវិធីពន្លកចំណេះដំណាក់កាលទី២ បានដាក់ចេញនូវយន្តការមួយចំនួនដើម្បីគាំទ្រ និងណែនាំពីរបៀបដែលបរិយាបន្នគួរត្រូវបានឆ្លុះបញ្ចាំងនៅក្នុងការស្រាវជ្រាវ ជាចម្បងតាមរយៈ**សៀវភៅណែនាំស្តីពីការស្រាវជ្រាវប្រកបដោយគុណភាព**។ គោលការណ៍ណែនាំទាំងនេះកំណត់ស្តង់ដារអប្បបរមា សម្រាប់ការស្រាវជ្រាវដែលគួរឱ្យជឿទុកចិត្ត មានក្រមសីលធម៌ និងពាក់ព័ន្ធនឹងគោលនយោបាយ ហើយតម្រូវយ៉ាងច្បាស់លាស់ឱ្យដាក់បញ្ចូលការពិចារណាលើសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ក្នុងវដ្តនៃការស្រាវជ្រាវទាំងមូល។ សៀវភៅណែនាំនេះផ្តល់ទិសដៅជាក់ស្តែងស្តីពីការកំណត់សំណួរស្រាវជ្រាវដែលឆ្លើយតបនឹងសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ការអនុវត្តវិធីសាស្ត្រដែលគិតគូរពីវប្បធម៌ និងយេនឌ័រ ការធានាឱ្យមានការចូលរួមពីក្រុមដែលត្រូវបានផាត់ចេញ និងការប្រកាន់ខ្ជាប់គោលការណ៍ 'មិនបង្កគ្រោះថ្នាក់' ដ៏តឹងរ៉ឹង។ សៀវភៅណែនាំនេះក៏សង្កត់ធ្ងន់លើការវិភាគទិន្នន័យដែលបែកចែកជាប្រភេទ ការឆ្លុះបញ្ចាំងពីវិសមភាពនៃអន្តរប្រសព្វ និងការផ្សព្វផ្សាយប្រកបដោយបរិយាបន្ន ដែលផ្សារភ្ជាប់ទៅនឹងការផ្លាស់ប្តូរគោលនយោបាយ។

ប៉ុន្តែនៅក្នុងការអនុវត្តជាក់ស្តែង ការយល់ដឹង និងការទទួលយកគោលការណ៍ណែនាំទាំងនេះ នៅតែមានកម្រិតមិនស្មើគ្នា ជាពិសេសចំពោះដៃគូដែលមិនទទួលបានការគាំទ្រពីកម្មវិធីពន្លកចំណេះ។ ខណៈដែលក្របខណ្ឌនេះឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តដ៏មុតមាំរបស់ស្ថាប័ន ក្នុងការអនុវត្តការស្រាវជ្រាវដែលគិតគូរពីសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ប្រសិទ្ធភាពរបស់ក្របខណ្ឌនេះពឹងផ្អែកខ្លាំងទៅលើសមត្ថភាពរបស់អ្នកស្រាវជ្រាវ ក្នុងការឈានហួសពីអភិក្រមដែលផ្តោតតែលើយេនឌ័រ និងអនុវត្តការគិតគូរពីសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម កាន់តែទូលំទូលាយឱ្យបានជាប់លាប់នៅក្នុងវិធីសាស្ត្រ ការវិភាគ និងការចូលរួមរបស់អ្នកពាក់ព័ន្ធ។ ក្នុងន័យនេះ ការយកគោលការណ៍សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ទៅប្រតិបត្តិក្នុងការអនុវត្តការស្រាវជ្រាវប្រចាំថ្ងៃ មិនទាន់លេចចេញជាដុំកំភួនអ្វីឡើយ ហើយក៏មិនសូវមានសង្គតិភាពនៅក្នុងវិស័យស្រាវជ្រាវទាំងមូលដែរ។

## ៣.២.៣. សមភាពយេនឌ័រនៅក្នុងអាជីពស្រាវជ្រាវ ការដឹកនាំ និងការបង្កើតចំណេះដឹង

នៅទូទាំងប្រព័ន្ធអេកូឡូស៊ីនៃការស្រាវជ្រាវរបស់កម្ពុជា មានលើកឡើងយ៉ាងទូលំទូលាយអំពីការប្តេជ្ញាចិត្តចំពោះសមភាពយេនឌ័រ ប៉ុន្តែនេះមិនទាន់ត្រូវបានប្រែក្លាយទៅជាគន្លងអាជីពប្រកបដោយសមធម៌ ការបង្ហាញភាពជាអ្នកដឹកនាំ ឬឥទ្ធិពលលើការបង្កើតចំណេះដឹងនៅឡើយទេ។ បទសម្ភាសន៍កន្លងមកបានចង្អុលបង្ហាញពីឧបសគ្គផ្នែករចនាសម្ព័ន្ធ និងរបាំងមិនផ្លូវការនៅតែបន្តកើតមាន ដែលរបាំងកំណត់ថាតើនរណាខ្លះអាចចូលបម្រើការងារក្នុងអាជីពស្រាវជ្រាវ នរណាខ្លះអាចរីកចម្រើនទៅមុខ ជំនាញរបស់នរណាខ្លះត្រូវបានទទួលស្គាល់ និងថាតើចំណេះដឹងរបស់នរណាខ្លះអាចត្រូវបានយកទៅប្រើប្រាស់ក្នុងការតាក់តែងគោលនយោបាយ។ របាំងទាំងនេះមានផលជះខ្លាំងដល់ស្ត្រី និងមានផលជះកាន់តែច្រើនដល់ជនមានពិការភាព អ្នកស្រាវជ្រាវជាជនជាតិដើមភាគតិច និងអ្នកដែលមកពីតំបន់ជនបទ ឬមកពីមជ្ឈដ្ឋានមិនមែនវណ្ណៈអភិជន។

### *គន្លងការងារ និងអាជីពដែលមានលក្ខណៈផ្អែកតាមយេនឌ័រ*

បើគិតចេញពីជ្រុងធនធានមនុស្ស អ្នកស្រាវជ្រាវជាស្ត្រីប្រឈមមុខនឹងរបាំងអន្តរប្រសព្វក្នុងការជ្រើសរើសឱ្យចូលធ្វើការ ការរក្សាទុកឱ្យនៅបម្រើការងារ និងការតម្លើងឋានៈតួនាទី។ ការរំពឹងទុកមិនផ្លូវការជុំវិញការទទួលខុសត្រូវចំពោះគ្រួសារ និងការថែទាំ បានរឹតត្បិតសមត្ថភាពរបស់ស្ត្រីក្នុងការស្រាវជ្រាវ ដែលទាមទារការចុះមូលដ្ឋានច្រើន ការធ្វើដំណើរផ្លូវឆ្ងាយ ឬការចូលរួមកសាងបណ្តាញទំនាក់ទំនងដែលមិនទទួលបានប្រាក់កម្រៃ សកម្មភាពទាំងអស់នេះច្រើនតែត្រូវបានគេចាត់ទុកថាជាសូចនាករវាស់វែងពីការប្តេជ្ញាចិត្ត និងការត្រៀមខ្លួនជាស្រេចសម្រាប់ការឡើងតំណែង។ អ្នកចូលរួមបានពន្យល់ថា៖

[៤៣] សៀវភៅណែនាំស្តីការស្រាវជ្រាវប្រកបដោយគុណភាព របស់កម្មវិធីពន្លកចំណេះបង្កើតនៅឆ្នាំ២០២៥ នៅភ្នំពេញ៖ https://policypulse.org/publications/references/research-quality-standards/#:~:text=High%20quality%20research%20is%20crucial,A%20Guidebook%20on%20Quality%20Research!

> “ វាមិនត្រូវបានសរសេរនៅកន្លែងណានោះទេ ប៉ុន្តែប្រសិនបើអ្នកមិនអាចធ្វើដំណើរ ឬស្នាក់នៅរហូតដល់យប់ជ្រៅ ឬយល់ព្រមគ្រប់ពេលទេនោះ អ្នកនឹងត្រូវបានគេមើលឃើញថាមិនសូវយកចិត្តទុកដាក់នឹងការងារឡើយ។ ”

ការទទួលបានឱកាសចូលរួមក្នុងបណ្តាញវិជ្ជាជីវៈ ការផ្តល់ប្រឹក្សាតម្រង់ទិស និងមូលធនសង្គមនៅតែមានភាពមិនស្មើគ្នា ដែលធ្វើឱ្យឋានានុក្រមបែងចែកយេនឌ័រនៅក្នុងស្ថាប័នស្រាវជ្រាវរ។ បើពិនិត្យលើទិដ្ឋភាពផ្លូវការ គឺអង្គការជាច្រើនខ្វះលក្ខណៈវិនិច្ឆ័យការតម្លើងឋានៈតួនាទីដែលប្រកបដោយតម្លាភាព ឈានទៅការទទួលបានអាណត្តិការងារអចិន្ត្រៃយ៍ ឬប្រព័ន្ធទទួលស្គាល់ ដែលឱ្យតម្លៃលើការស្រាវជ្រាវបែបសហការ ការស្រាវជ្រាវអនុវត្តន៍ ឬការស្រាវជ្រាវផ្អែកលើសហគមន៍ ដែលវិស័យទាំងនេះស្ត្រីមានវត្តមានច្រើន។ ការឡើងតំណែងនៅតែពឹងផ្អែកខ្លាំងលើបណ្តាញទំនាក់ទំនងមិនផ្លូវការ ការគាំទ្រពីថ្នាក់លើ និងភាពលេចធ្លោនៅក្នុងមជ្ឈដ្ឋានគោលនយោបាយកម្រិតខ្ពស់ ដែលពង្រឹងបន្ថែមដល់ឋានានុក្រមដែលផ្អែកតាមយេនឌ័រស្រាប់ ។

---

## គម្លាតក្នុងការដឹកនាំ និងការប្រមូលផ្តុំអ្នកជំនាញ

បុរសនៅតែមានតំណាងច្រើនលើសលប់ ក្នុងចំណោមអ្នកស្រាវជ្រាវជាន់ខ្ពស់ ថ្នាក់ដឹកនាំស្ថាប័ន និង **"អ្នកជំនាញដែលត្រូវបានទទួលស្គាល់"**។ អ្នកផ្តល់បទសម្ភាសន៍តែងតែភ្ជាប់បញ្ហានេះទៅនឹងវិសមភាពក្នុងការទទួលបានការបណ្តុះបណ្តាលថ្នាក់បណ្ឌិត ការចូលរួមក្នុងកម្មវិធីអន្តរជាតិ និងឱកាសទទួលបានថវិកាស្រាវជ្រាវ។ ខណៈដែលទិន្នន័យថ្នាក់ជាតិនៅមានកម្រិត អ្នកចូលរួមបានកត់សម្គាល់ថា អ្នកមានសញ្ញាបត្របណ្ឌិតភាគច្រើនលើសលប់នៅតែជាបុរស ជាពិសេសក្នុងវិស័យសេដ្ឋកិច្ច វិទ្យាសាស្ត្រអាកាសធាតុ ការគ្រប់គ្រងធនធានធម្មជាតិ និងវិស័យបច្ចេកទេសផ្សេងទៀត។ អ្នកស្រាវជ្រាវម្នាក់បានបញ្ជាក់ថា៖

> “ នៅពេលដែលក្រសួងត្រូវការអ្នកជំនាញ ពួកគេបានគិតឃើញរួចទៅហើយ ហើយភាគច្រើនគឺបុរសដែលបានសិក្សានៅបរទេស។ ”

ការប្រមូលផ្តុំគុណវុឌ្ឍិបែបនេះ បានកំណត់ថាតើនរណាខ្លះដែលត្រូវបានអញ្ជើញឱ្យចូលរួមក្នុងការពិភាក្សាគោលនយោបាយ ការវិភាគរបស់នរណាខ្លះដែលត្រូវបានបន្លឺសំឡេង និងថាតើទស្សនៈរបស់នរណាខ្លះដែលកំណត់ទម្រង់នៃការជជែកដេញដោលថ្នាក់ជាតិ។

## ភាពលំអៀងយេនឌ័រនៅក្នុងរបៀបវារៈការស្រាវជ្រាវ និងការបង្កើតចំណេះដឹង

ភាពលំអៀងយេនឌ័រ ក៏ជះឥទ្ធិពលផងដែរលើប្រភេទនៃការស្រាវជ្រាវ និងរបៀបដែលចំណេះដឹងត្រូវបានបង្កើតឡើង។ ខណៈដែល ទិន្នន័យបែកចែកតាមយេនឌ័រកំពុងប្រើប្រាស់កាន់តែទូទៅ ជារឿយៗ យេនឌ័រត្រូវបានចាត់ទុកជាអថេរពណ៌នាមួយប៉ុណ្ណោះ ជាជាងកញ្ចក់ឆ្លុះបញ្ចាំងនៅក្នុងការវិភាគ។ សំណួរស្រាវជ្រាវ កម្រចោទសួរពីបទដ្ឋានយេនឌ័រ ទំនាក់ទំនងអំណាច ឬចនាសម្ព័ន្ធនៃការធ្វើសេចក្ដីសម្រេច ហើយការវិភាគយេនឌ័រច្រើនតែកំណត់ត្រឹមតែផ្នែកព័ត៌មានប៉ុណ្ណោះ ជាជាងកំណត់ជាផលជះដល់លទ្ធផល ឬអនុសាសន៍។

អ្នកផ្តល់បទសម្ភាសន៍ជាច្រើនបានគូសបញ្ជាក់ថា នេះមិនមែនគ្រាន់តែជាបញ្ហាបច្ចេកទេសប៉ុណ្ណោះទេ។ រយៈពេលខ្លីនៃគម្រោង ពេលវេលាមានកំណត់ ថវិកាមានមានកម្រិត និងសំណួរស្រាវជ្រាវដែលកំណត់ដោយម្ចាស់ជំនួយ បានរឹតត្បិតសមត្ថភាពក្នុងការរៀបចំការសិក្សាដែលមានការចូលរួម ប្រកបដោយបរិយាបន្ន។ ជាពិសេស អ្នកស្រាវជ្រាវដែលទើបចាប់ផ្តើមចូលប្រឡូកក្នុងអាជីព បានរាយការណ៍អំពីកង្វះការបណ្តុះបណ្តាលជាក់ស្តែងស្តីពីវិធីសាស្ត្រ ដែលគិតគូរពីយេនឌ័រ ហើយនិងប្រកបដោយបរិយាបន្ន។ អ្នកស្រាវជ្រាវម្នាក់បានកត់សម្គាល់ថា៖

> “ យើងត្រូវបានគេប្រាប់ថា យេនឌ័រមានសារៈសំខាន់ ប៉ុន្តែយើងមិនត្រូវបានផ្តល់ពេលវេលា ឬឧបករណ៍ ដើម្បីធ្វើវាឱ្យបានត្រឹមត្រូវនោះទេ។ ”

វិសមភាពក្នុងការទទួលបានបច្ចេកវិទ្យា ប្រព័ន្ធទិន្នន័យ និងឧបករណ៍ជំនួយ កាន់តែធ្វើឱ្យអ្នកស្រាវជ្រាវដែលមានពិការភាព និងអ្នកដែលមានមូលដ្ឋាននៅក្រៅរាជធានីភ្នំពេញ ជួបការលំបាកថែមទៀត ហើយនេះបានធ្វើឱ្យការបង្កើតចំណេះដឹងកាន់តែរេងសម្អាធពីវិសមភាពភូមិសាស្ត្រ និងសង្គម។

---

## បរិយាកាសការងារ សុវត្ថិភាព និងការរក្សាទុកឱ្យនៅបម្រើការងារ

បណ្តាញវិជ្ជាជីវៈមិនផ្លូវការនៅតែគ្របដណ្តប់ភាគច្រើនដោយបុរស ហើយវាបានជះឥទ្ធិពលលើលទ្ធភាពទទួលបានការណែនាំ ព័ត៌មាន និងឱកាសការងារ។ អ្នកស្រាវជ្រាវជាស្ត្រីបានរាយការណ៍អំពីការពិនិត្យពិច័យកាន់តែតឹងរ៉ឹងលើសមត្ថភាពរបស់ពួកគេ ជាពិសេសនៅក្នុងតួនាទីជាអ្នកដឹកនាំ ឬជំនាញបច្ចេកទេស។ ការងារចុះមូលដ្ឋាន ត្រូវបានលើកឡើងដដែលៗថាជាកន្លែងដែលមានហានិភ័យ ហើយមានគោលការណ៍ស្ថាប័នតិចតួចណាស់ ដែលដោះស្រាយបញ្ហាសុវត្ថិភាព ការបៀតបៀន ឬកាតព្វកិច្ចថែទាំ។ អ្នកស្រាវជ្រាវជាស្ត្រីម្នាក់បាននិយាយថា៖

> “ ប្រសិនបើមានរឿងអ្វីកើតឡើងនៅមូលដ្ឋាន វាត្រូវបានគេចាត់ទុកថាជាបញ្ហាផ្ទាល់ខ្លួន មិនមែនជាការទទួលខុសត្រូវរបស់ស្ថាប័ននោះទេ។ ”

ឥទ្ធិពលទាំងនេះ រួមចំណែកដល់ការបោះបង់ការងារកាន់តែច្រើនក្នុងចំណោមអ្នកស្រាវជ្រាវជាស្ត្រី ដែលទើបចាប់ផ្តើមចូលប្រឡូក ឬឈានដល់ពាក់កណ្តាលអាជីព ដែលធ្វើឱ្យខ្សែបណ្តាញអ្នកដឹកនាំចុះខ្សោយ និងកាត់បន្ថយនិរន្តរភាពនៅក្នុងស្ថាប័ន។

ប្រអប់ទី ១១

## បញ្ហាប្រឈមរបស់អ្នកស្រាវជ្រាវជាស្ត្រី

អ្នកស្រាវជ្រាវម្នាក់មកពីបណ្តាញ SheThinks បានពណ៌នាអំពីឧបសគ្គដែលគាត់បានជួបប្រទះ នៅពេលចាប់ផ្តើមអាជីពដំបូង។ ក្នុងនាមជាស្ត្រីវ័យក្មេងដែលកាន់តួនាទីគ្រប់គ្រង ភាពគួរឱ្យជឿទុកចិត្តរបស់គាត់តែងត្រូវបានគេចោទសួរ ទាំងនៅមូលដ្ឋាន និងនៅក្នុងអង្គការរបស់គាត់។ គាត់បានរកឃើញថា សហការី និងអ្នកគ្រប់គ្រង មិនសូវយកចិត្តទុកដាក់ចំពោះគំនិតរបស់គាត់ទេ ហើយគាត់ត្រូវខិតខំប្រឹងប្រែងធ្វើការជាងមិត្តរួមការងារជាបុរស ដើម្បីបញ្ជាក់ថាគាត់អាចដឹកនាំបាន។ ការគ្រប់គ្រងបុគ្គលិកជាបុរស នាំឱ្យមានការពិនិត្យពិច័យកាន់តែខ្លាំង ហើយការគោរពចំពោះគាត់ គឺមិនមានជាប់លាប់នោះទេ។

គាត់ក៏ប្រឈមមុខនឹងការរំពឹងទុកក្នុងសង្គមផងដែរ ដូចជា ការជួបជុំគ្នាផឹកស៊ី ដែលធ្វើឱ្យគាត់កាន់តែពិបាកក្នុងការកសាងទំនាក់ទំនងវិជ្ជាជីវៈដោយស្មើភាពគ្នា។ ការងារចុះមូលដ្ឋានក៏មានហានិភ័យផ្ទាល់ខ្លួនផងដែរ។ គាត់នឹកឃើញការធ្វើដំណើរតែម្នាក់ឯងជាមួយមន្ត្រីឧទ្យានុរក្ស និងសមាជិកសហគមន៍ និងត្រូវធ្វើអន្តរាគមន៍ នៅពេលសត្វស្វាដែលជិតផុតពូជមួយក្បាល ត្រូវគេចាប់បាន ដោយគាត់ត្រូវថ្លឹងថ្លែងរវាងពិធីការ និងសុវត្ថិភាពផ្ទាល់ខ្លួន។

យូរៗទៅ គាត់បានរៀនពីវិធីស្វែងរកផ្លូវឆ្លងកាត់សម្ពាធទាំងនេះ ហើយគាត់ទទួលបានការគាំទ្រពីអ្នកគ្រប់គ្រងមួយចំនួន ប៉ុន្តែបទពិសោធន៍របស់គាត់ឆ្លុះបញ្ចាំងពីឧបសគ្គបន្ថែមទៀត ដែលអ្នកស្រាវជ្រាវជាស្ត្រីជាច្រើនប្រឈមមុខ និងគុណតម្លៃនៃបណ្តាញដូចជា SheThinks ក្នុងការបង្កើតមជ្ឈដ្ឋានវិជ្ជាជីវៈ ដែលកាន់តែមានសុវត្ថិភាព និងការគាំទ្រ។

វត្តមាននៃបណ្តាញ SheThinks គឺដើម្បីការឆ្លើយតបទៅនឹងបញ្ហាប្រឈមទាំងនេះ និងគម្លាតកាន់តែធំនៅក្នុងប្រព័ន្ធអេកូឡូស៊ីស្រាវជ្រាវ។ បង្កើតឡើងក្នុងឆ្នាំ ២០២២-២០២៣ បណ្តាញនេះរីកធំឡើងចេញពីការទទួលស្គាល់ជារួមថា អ្នកស្រាវជ្រាវជាស្ត្រីនៅកម្ពុជាមានវត្តមាននៅតាមស្ថាប័ននានា និងជារឿយៗ ខ្វះការណែនាំ ការគាំទ្រពីដៃគូការងារ និងបណ្តាញវិជ្ជាជីវៈ។ ស្ត្រីជាច្រើនដែលទើបចាប់ផ្តើមអាជីព បានរៀបរាប់ពីអារម្មណ៍ឯកកោ ឬត្រូវបានគេផាត់ចេញ នៅក្នុងបរិយាកាសស្រាវជ្រាវ ដែលសំបូរដោយបុរស។

គម្លាតនេះបានរំលេចឱ្យឃើញច្បាស់តាមរយៈការចូលរួម និងការពិគ្រោះយោបល់របស់កម្មវិធីពន្លកចំណេះដំណាក់កាលទី២ ដែលតែងតែគូសបញ្ជាក់ពីតម្រូវការវេទិកាជាក់លាក់មួយ ដើម្បីគាំទ្រដល់ភាពជាអ្នកដឹកនាំរបស់ស្ត្រីនៅក្នុងវិស័យស្រាវជ្រាវ។ ជាការឆ្លើយតប កម្មវិធីពន្លកចំណេះបានរៀបចំសិក្ខាសាលាកំណត់ទិសដៅ ពីរលើក នៅក្នុងខែឧសភា ឆ្នាំ២០២៣ ដើម្បីវាយតម្លៃតម្រូវការនេះ។ លទ្ធផលគឺច្បាស់លាស់៖ អ្នកស្រាវជ្រាវជាស្ត្រីចង់បានចន្លោះ/វេទិកាផ្ទាល់ខ្លួន។

ក្នុងអំឡុងឆ្នាំ២០២៣-២០២៤ ក្រុមការងារដំបូងបានផ្លាស់ប្តូរពីការមានត្រឹមតែជាគំនិត ទៅជារចនាសម្ព័ន្ធពេញលេញមួយ។ សមាជិកបានរួមគ្នាអភិវឌ្ឍចក្ខុវិស័យ បេសកកម្ម និងគុណតម្លៃស្នូល ហើយក្រោយមកបានព្រាងធម្មនុញ្ញផ្លូវការមួយ ដែលបច្ចុប្បន្ន គឺជាត្រីវិស័យសម្រាប់អភិបាលកិច្ច និងប្រតិបត្តិការរបស់បណ្តាញ។ សិក្ខាសាលាជាយុទ្ធសាស្ត្រកាលពីខែមីនា ឆ្នាំ២០២៤ បានសម្រួចចំណុចផ្តោតរបស់កម្មវិធី និងទិសដៅរយៈពេលវែង។  ការជ្រើសរើសថ្នាក់ដឹកនាំដំបូងនៅពាក់កណ្តាលឆ្នាំ២០២៤ បានផ្តល់បង្អែកដ៏រឹងមាំដល់បណ្តាញនេះ។ ក្នុងដំណើរការនេះទាំងមូល កម្មវិធីពន្លកចំណេះដំណាក់កាលទី២ បានផ្តល់ការណែនាំផ្នែកបច្ចេកទេសលើទស្សនទាន សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម និងបានជួយពង្រឹងការគិតរបស់បណ្តាញនេះអំពីការអនុវត្តការស្រាវជ្រាវប្រកបដោយបរិយាបន្ន។ គោលការណ៍នេះបានជួយឱ្យបណ្តាញ SheThinks កំណត់លក្ខណៈខ្លួនឯងមិនត្រឹមតែជាក្រុមអ្នកជំនាញប៉ុណ្ណោះទេ ប៉ុន្តែក៏ជាសហគមន៍ដែលផ្តោតសំខាន់លើសមធម៌ និងការបង្កភាពងាយស្រួលផងដែរ។

បច្ចុប្បន្ន SheThinks គឺជាបណ្តាញស្ត្រីនៅក្នុងវិស័យស្រាវជ្រាវកម្រិតជាតិ ដែលមានកម្មវិធីច្បាស់លាស់ផ្តោតលើការចូលរួមរបស់សមាជិក ការកសាងសមត្ថភាព ការណែនាំ ការកៀរគរចំណេះដឹង និងការផ្សព្វផ្សាយជាសាធារណៈ។ ផែនការការងារឆ្នាំ២០២៤-២០២៨ រួមមានការបណ្តុះបណ្តាលស្តីពីវិធីសាស្ត្រស្រាវជ្រាវ និងការដាក់បញ្ចូលគោលការណ៍ សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ការគាំទ្រដល់ការសរសេរ និងការបោះពុម្ពផ្សាយ គម្រោងស្រាវជ្រាវរួមគ្នា ការរៀបចំសំណើសុំគម្រោងថវិកា និងបង្កើតវេទិកា/ថ្នាលសម្រាប់ធ្វើបទបង្ហាញការសិក្សាស្រាវជ្រាវ។ បណ្តាញនេះក៏កំពុងកសាងយន្តការសម្រាប់លទ្ធផលស្រាវជ្រាវរួមគ្នា ដោយកំណត់ជំហររបស់ស្ត្រីថាមិនមែនត្រឹមតែជាអ្នកចូលរួមប៉ុណ្ណោះទេ ប៉ុន្តែក៏ជាអ្នកបង្កើតទិន្នន័យដោយផ្ទាល់ផងដែរ។

នៅក្នុងវិស័យមួយដែលស្ថាប័ននានាមានភាពយឺតយ៉ាវក្នុងការកសាងក្របខណ្ឌ សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គមផ្ទាល់ខ្លួន បណ្តាញ SheThinks បានបំពេញនូវចន្លោះប្រហោងជាក់ស្តែងនេះ។ បណ្តាញនេះផ្តល់ការគាំទ្រពីដៃគូ ការកសាងទំនុកចិត្ត និងមូលដ្ឋានបច្ចេកទេស ដែលតាមការលើកឡើងដោយអ្នកស្រាវជ្រាវជាស្ត្រីជាច្រើន គឺពួកគេខ្វះខាតត្រង់ចំណុចនេះនៅក្នុងបរិយាកាសការងាររបស់ពួកគេ។ បណ្តាញនេះក៏ឆ្លុះបញ្ចាំងពីអ្វីដែលកម្មវិធីពន្លកចំណេះ ដំណាក់កាលទី២ មានបំណងលើកកម្ពស់នៅក្នុងប្រព័ន្ធអេកូឡូស៊ីដ៏ទូលំទូលាយផងដែរ៖ មជ្ឈដ្ឋានស្រាវជ្រាវប្រកបដោយបរិយាបន្ន ការចូលរួមយ៉ាងសកម្មពីក្រុមដែលមិនសូវមានតំណាង និងសហគមន៍អនុវត្តន៍ ដែលជួយពង្រឹងសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គមចាប់ពីមូលដ្ឋានឡើងទៅ។

## ៣.២.៤. បរិយាបន្នពិការភាពនៅក្នុងការស្រាវជ្រាវ និងការអនុវត្តរបស់ស្ថាប័ន

បរិយាបន្នពិការភាព កំពុងត្រូវបានទទួលស្គាល់កាន់តែច្រើនឡើងនៅក្នុងវិស័យស្រាវជ្រាវរបស់កម្ពុជា ដោយមានគំនិតផ្តួចផ្តើមមួយចំនួនតូចបានបង្ហាញពីការយល់ដឹងថ្មីៗ។ ស្ថាប័នស្រាវជ្រាវរបស់រដ្ឋាភិបាលដូចជា វិទ្យាស្ថានជាតិសង្គមកិច្ច បានធ្វើការសិក្សាស្តីពីកុមារ និងចាស់ជរាមានពិការភាព និងបានសហការជាមួយដៃគូនានាក្នុងការស្រាវជ្រាវទាក់ទងនឹងការឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងប្រជាពលរដ្ឋដែលងាយរងគ្រោះដោយអាកាសធាតុ។ កម្មវិធីមួយចំនួនដែលពាក់ព័ន្ធនឹងអាកាសធាតុ និងរបរចិញ្ចឹមជីវិតនៅជនបទ ក៏បានសាកល្បងការចូលរួមជាមួយជនមានពិការភាពផងដែរ រួមទាំងគំនិតផ្តួចផ្តើមគាំទ្រដល់កសិករមានពិការភាពឱ្យសម្របខ្លួនទៅនឹងហានិភ័យអាកាសធាតុ។ ឧទាហរណ៍ទាំងនេះបង្ហាញពីការទទួលស្គាល់កាន់តែខ្លាំងឡើងថា ពិការភាពគឺជាបញ្ហាមួយសម្រាប់ការអភិវឌ្ឍ  ហើយវាក៏បង្ហាញពីចំណុចអនុវត្តន៍ជាក់ស្តែងមួយចំនួនតូច  នៅក្នុងបរិបទរួមមួយដែលមិនទាន់មានភាពស៊ីសង្វាក់គ្នានៅឡើយ។

ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងទាំងនេះក៏ដោយ បរិយាបន្នពិការភាពនៅតែជាទិដ្ឋភាពមួយក្នុងចំណោមទិដ្ឋភាពដែលខ្សោយជាងគេ និងត្រូវបានបញ្ជ្រាបតិចតួចបំផុតទៅក្នុងការស្រាវជ្រាវ និងការអនុវត្តរបស់ស្ថាប័ន។ ដៃគូនានាតែងតែលើកឡើងថា បរិយាបន្នពិការភាពគឺជា "ផ្នែកដែលពិបាកបំផុត" នៃគោលការណ៍សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ក្នុងការយកទៅអនុវត្តជាក់ស្តែង។ បញ្ហាមិនមែននៅត្រង់កង្វះការយល់ដឹងទេ ប៉ុន្តែគឺឧបសគ្គជាប្រព័ន្ធដែលហួសពីស្ថាប័នស្រាវជ្រាវទៅទៀត។ បញ្ហាទាំងនេះផ្តើមចេញពីដំណាក់កាលដំបូងៗ រួមទាំងវិសមភាពក្នុងការទទួលបានការអប់រំប្រកបដោយបរិយាបន្ន កង្វះឱកាសក្នុងការឈានទៅបន្តការអប់រំឧត្តមសិក្សា និងអាជីពស្រាវជ្រាវ ព្រមទាំងការរើសអើងក្នុងសង្គមដែលនៅតែបន្តកើតមាន។ នៅក្នុងស្ថាប័នស្រាវជ្រាវ បញ្ហាប្រឈមទាំងនេះកាន់តែធ្ងន់ធ្ងរថែមទៀតដោយសារឧបសគ្គក្នុងការជ្រើសរើសបុគ្គលិក ការបង្កភាពងាយស្រួលនៅកន្លែងធ្វើការ វិធីសាស្ត្រស្រាវជ្រាវ ការផ្តល់មូលនិធិ និងអាកប្បកិរិយា។ ដូច្នេះហើយទើបជនមានពិការភាពនៅតែមានតំណាងតិចតួច ទាំងក្នុងនាមជាអ្នកចូលរួមក្នុងការស្រាវជ្រាវ និងក្នុងនាមជាអ្នកស្រាវជ្រាវ និងអ្នកបង្កើតចំណេះដឹង។

## ឧបសគ្គផ្នែកស្ថាប័ន និងប្រតិបត្តិការ

ឆ្លងកាត់បទសម្ភាសន៍នានា បរិយាបន្នពិការភាពត្រូវបានពណ៌នាជារឿយៗថា ជាធាតុផ្សំនៃសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ដែលទទួលបានជនជានតិចតួចបំផុត និងត្រូវបានបញ្ជ្រាបតិចតួចបំផុតទៅក្នុងស្ថាប័ន។ ខណៈដែលអ្នកស្រាវជ្រាវជាច្រើនបានរាយការណ៍ពីការយល់ដឹង ជាមូលដ្ឋានអំពីទស្សនទានបរិយាបន្នពិការភាព មានអ្នកស្រាវជ្រាវតិចតួចណាស់ដែលយល់ថា ពួកគេមានសមត្ថភាពគ្រប់គ្រាន់ដើម្បីយកទស្សនទាននេះទៅអនុវត្តជាក់ស្តែង។

ឧបសគ្គទាំងនេះស្តែងឡើងយ៉ាងច្បាស់នៅក្នុងប្រព័ន្ធជ្រើសរើសបុគ្គលិក និងកន្លែងធ្វើការ។ មានស្ថាប័នស្រាវជ្រាវតិចតួចណាស់ ដែលមានគោលនយោបាយធនធានមនុស្សប្រកបដោយបរិយាបន្នពិការភាព ឬមាននីតិវិធីច្បាស់លាស់សម្រាប់ផាសុកសមរម្យ។ ដៃគូមួយចំនួនបានរាយការណ៍ថា ពួកគេមិនដែលបានជួលបុគ្គលិកមានពិការភាពទាល់តែសោះ។ នេះមិនមែនដោយសារតែការផាត់ចេញដោយចេតនានោះទេ ប៉ុន្តែគឺដោយសារតែតម្រូវការការងារ បរិយាកាសកន្លែងធ្វើការ និងការរំពឹងទុក មិនត្រូវបានរៀបចំឡើងដើម្បីបង្កភាពងាយស្រួល។ ដូចដែលដៃគូម្នាក់បានលើកឡើងថា៖

> “ យើងមិនបដិសេធជនមានពិការភាពទេ ប៉ុន្តែប្រព័ន្ធខ្លួនឯងមិនទាន់ត្រៀមខ្លួនរួចរាល់សម្រាប់ពួកគេឡើយ។ ”

ឧបសគ្គផ្នែករចនាសម្ព័ន្ធទាំងនេះ ក៏ស្តែងឱ្យឃើញនៅក្នុងការជ្រើសរើស និងការចូលរួមក្នុងឱកាសដែលពាក់ព័ន្ធនឹងការស្រាវជ្រាវផងដែរ។ ដៃគូមួយចំនួនរួមមាន វេទិកាអនាគត និងមជ្ឈមណ្ឌលខេមរសិក្សា បានលើកឡើងថា នៅពេលដែលឱកាសអាហារូបករណ៍ស្រាវជ្រាវត្រូវបានបើកចំហសម្រាប់ជនមានពិការភាព ចំនួនបេក្ខជនដាក់ពាក្យគឺតិចណាស់។ ជារឿយៗ បេក្ខជនដែលបានដាក់ពាក្យ ប្រឈមនឹងការលំបាកក្នុងការបំពេញតាមលក្ខខណ្ឌតម្រូវស្តង់ដារ ឬរក្សាការចូលរួមឱ្យបានជាប់លាប់ ដោយអ្នកខ្លះបានបោះបង់ពាក់កណ្តាលទី។

ឧបសគ្គទាំងនេះមិនបានឆ្លុះបញ្ចាំងពីកង្វះការចាប់អារម្មណ៍ ឬសមត្ថភាពនោះទេ ប៉ុន្តែរំលេចឱ្យឃើញផលវិបាកបន្តបន្ទាប់គ្នានៃវិសមភាពក្នុងការទទួលបានការអប់រំ ការបណ្តុះបណ្តាល និងឱកាសអភិវឌ្ឍន៍វិជ្ជាជីវៈ។ បើគ្មានការគាំទ្រចំគោលដៅ ការប្រឹក្សានិងតម្រង់ទិស និងការផ្តល់ជម្រើសចូលបម្រើការងារ ដែលមានភាពបត់បែនជាងមុនទេ ជនមានពិការភាពនឹងនៅតែជួបការលំបាកក្នុងការទទួលបាន និងរក្សាតួនាទីនៅក្នុងវិស័យស្រាវជ្រាវ។

នៅកន្លែងដែលមានការជួលជនមានពិការភាពឱ្យធ្វើការ ជារឿយៗ ការគាំទ្រគឺមានមិនពេញលេញឡើយ និងធ្វើឡើងតាមតម្រូវការជាក់ស្តែងដោយផ្អែកលើធនធានដែលមាន ជាជាងផ្អែកលើស្តង់ដាររបស់ស្ថាប័ន។ ការរៀបចំការងារដ៏តឹងតែង ការសន្មតអំពីផលិតភាព និងលទ្ធភាពមានកម្រិតក្នុងការទទួលបានផាសុកសមរម្យ នៅតែបន្តរឹតត្បិតដល់ការចូលរួម និងការរីកចម្រើនក្នុងអាជីព។ កម្សោយក្នុងការអនុវត្តគោលនយោបាយស្តីពីការអប់រំបរិយាបន្ន រឹតតែរាំងដល់ការអភិវឌ្ឍសមត្ថភាពរបស់អ្នកស្រាវជ្រាវដែលមានពិការភាព ដែលនេះបានជំរុញធ្វើឱ្យវត្តមានរបស់ពួកគេនៅមានកម្រិត ក្នុងនាមជាអ្នកបង្កើតចំណេះដឹង និងជាតួអង្គក្នុងវិស័យគោលនយោបាយ។

គណនេយ្យភាពស្ថាប័ននៅមានកម្រិតខ្សោយ។ មានអង្គការ-ស្ថាប័នតិចតួចណាស់ ដែលមានគោលនយោបាយច្បាស់លាស់ស្តីពីបរិយាបន្នពិការភាព ឬរចនាសម្ព័ន្ធគណនេយ្យភាពច្បាស់លាស់។ តួនាទីជាមន្ត្រីបង្គោលពិការភាព ទោះមានក៏ដោយ ក៏ជារឿយៗ មានលក្ខណៈមិនផ្លូវការ ខ្វះធនធាន និងត្រូវបានបន្ថែមពីលើបន្ទុកការងារដែលមានស្រាប់។ ដូច្នេះហើយទើបការទទួលខុសត្រូវលើបរិយាបន្ន មានលក្ខណៈរប៉ាត់រប៉ាយ ជាជាងត្រូវបានធ្វើស្ថាប័នូបនីយកម្ម ហើយវឌ្ឍនភាពគឺអាស្រ័យលើគំនិតផ្តួចផ្តើមរបស់បុគ្គលម្នាក់ៗ ជាជាងប្រព័ន្ធការងាររបស់ស្ថាប័ន។

ក្នុងករណីដែលមានឯកសារណែនាំ វាច្រើនតែមានលក្ខណៈទូទៅ និងពិបាកយកទៅអនុវត្តជាក់ស្តែង។ ដូចដែលអ្នកផ្តល់បទសម្ភាសន៍ម្នាក់បានកត់សម្គាល់ថា **"យើងមិនត្រូវការទស្សនទានបន្ថែមទៀតទេ។ យើងត្រូវការដឹងឱ្យបានច្បាស់ថាតើត្រូវផ្លាស់ប្តូរអ្វីខ្លះនៅក្នុងការិយាល័យ ការជ្រើសរើសបុគ្គលិក និងវិធីសាស្ត្រស្រាវជ្រាវរបស់យើង។"** គម្លាតរវាងគោលការណ៍ និងឧបករណ៍អនុវត្តន៍ បានកម្រិតសមត្ថភាពរបស់ស្ថាប័នក្នុងការប្រែក្លាយការប្តេជ្ញាចិត្តទៅជាការអនុវត្តប្រចាំថ្ងៃ។

ឧបសគ្គផ្នែករចនាសម្ព័ន្ធទាំងនេះ បានរំលេចឱ្យឃើញនៅក្នុងបទពិសោធន៍ជីវិតជាក់ស្តែងរបស់អ្នកស្រាវជ្រាវដែលមានពិការភាព។ ជនមានពិការភាព ដែលបានចូលរួមក្នុងការវិភាគនេះ បានពណ៌នាអំពីទម្រង់នៃការផាត់ចេញ ទាំងទម្រង់ជាក់ស្តែង និងទម្រង់ដែលមិនស្តែងឱ្យឃើញ ជាពិសេសនៅក្នុងស្ថាប័នសិក្សាធិការ និងស្ថាប័នស្រាវជ្រាវ។ កង្វះការបង្កភាពងាយស្រួលផ្នែករូបវន្តនៅតាមបរិវេណសាលា និងការិយាល័យ កង្វះផាសុកសមរម្យ ការរៀបចំការងារដ៏តឹងតែង និងការសន្មតអំពីផលិតភាព នៅតែបន្តរឹតត្បិតការចូលរួម។ អ្នកចូលរួមម្នាក់ដែលមានពិការភាព បានលើកឡើងថា៖

> “បញ្ហាមិនមែននៅត្រង់សមត្ថភាពរបស់ខ្ញុំទេ ប៉ុន្តែគឺបរិយាកាស
> និងឥរិយាបថដែលសន្មតថា ខ្ញុំមិនអាចធ្វើការងារបានទៅវិញទេ។”

## ឧបសគ្គការរៀបចំ និងការចូលរួមក្នុងការស្រាវជ្រាវ

បរិយាបន្នពិការភាព មានភាពអន់ថយខ្លាំងនៅកម្រិតនៃការរៀបចំ និងការអនុវត្តការស្រាវជ្រាវ។ មធ្យោបាយដែលបង្កភាពងាយស្រួលមាន ដូចជា ឧបករណ៍ជំនួយដល់ស្រាវជ្រាវ ការបកប្រែភាសាសញ្ញា ទម្រង់ឯកសារសម្រួលសម្រួលនានា ឬការពន្យាពេលវេលាសម្រាប់ការចូលរួម កម្រត្រូវបានរៀបចំផែនការ ឬកំណត់ថវិកាណាស់។ ផ្ទុយទៅវិញ គេច្រើនតែចាត់ទុកមធ្យោបាយទាំងនេះថាជាធាតុផ្សំបន្ថែមទៅតាមជម្រើស ឬត្រូវបានបដិសេធចោលក្រោមហេតុផលថវិកាមានកម្រិត។ ដូចដែលដៃគូម្នាក់បានលើកឡើងថា៖ **"ការដាក់បញ្ចូលជនមានពិការភាពតែងតែមានន័យថា គេត្រូវការពេលវេលាបន្ថែម អ្នកបកប្រែ ការធ្វើដំណើរ និងថវិកា ហើយកិច្ចការទាំងនេះកម្រត្រូវបានរៀបចំផែនការទុកណាស់។"** ដូច្នេះហើយទើបជនមានពិការភាពកម្រត្រូវបានដាក់បញ្ចូលទៅក្នុងការពិគ្រោះយោបល់ សិក្ខាសាលាផ្ទៀងផ្ទាត់ ឬដំណើរការផ្សព្វផ្សាយ សូម្បីតែនៅពេលដែលលទ្ធផលនៃការស្រាវជ្រាវ ពាក់ព័ន្ធដោយផ្ទាល់នឹងពួកគេក៏ដោយ។

ការស្រាវជ្រាវដែលផ្តោតលើពិការភាព ហាក់ធ្វើឡើងតែតម្រូវលក្ខខណ្ឌពីម្ចាស់ជំនួយប៉ុណ្ណោះ ហើយការធ្វើដូច្នេះបង្កើតអភិក្រមអនុលោមភាពជាជាងការរៀបចំជាលក្ខណៈប្រព័ន្ធ។ យន្តការនេះបានកម្រិតដល់ការរៀនសូត្រ ធ្វើឱ្យគុណភាពទិន្នន័យធ្លាក់ចុះ និងបង្ហាញសញ្ញាថា បរិយាបន្នពិការភាពគឺជាលក្ខខណ្ឌតម្រូវ ជាជាងជាមូលដ្ឋានគ្រឹះសម្រាប់ការអនុវត្តការស្រាវជ្រាវប្រកបដោយភាពជឿជាក់។

អ្នកស្រាវជ្រាវជួបប្រទះបញ្ហាប្រឈមជាក់ស្តែងក្នុងការកំណត់អត្តសញ្ញាណ និងអញ្ជើញអ្នកចូលរួម រួមទាំងកង្វះទិន្នន័យបែកចែកជាប្រភេទ កិច្ចសហការមានកម្រិតខ្សោយជាមួយអង្គការតំណាងជនមានពិការភាព និងការចំណាយបន្ថែម ដែលពាក់ព័ន្ធនឹងវិធីសាស្ត្រស្រាវជ្រាវប្រកបដោយបរិយាបន្ន។

ការទាក់ទាញការចូលរួមរបស់ជនមានពិការភាពផ្សេងៗ ទាមទារអភិក្រមដែលសម្របតាមតម្រូវការជាក់លាក់។ ឧទាហរណ៍ការធ្វើការជាមួយអ្នកចូលរួមដែលមានពិការភាពគ-ថ្លង់ ទាមទារអ្នកបកប្រែភាសាសញ្ញា ចំណែកការទាក់ទាញការចូលរួមរបស់ជនមានពិការភាពផ្នែកបញ្ញាស្មារតី ឬផ្នែកចិត្តសង្គម អាចទាមទារឧបករណ៍សម្រប សម្រួល ការប្រាស្រ័យទាក់ទងដោយប្រើភាសាសាមញ្ញ និងពេលវេលាចូលរួមយូរជាងមុន។ ទោះជាយ៉ាងណា ក្របខណ្ឌពេលវេលានៃការស្រាវជ្រាវ និងថវិកា កម្រត្រូវបានរៀបចំឡើង ដើម្បីបំពេញតាមតម្រូវការទាំងនេះណាស់។ ដូច្នេះហើយទើបបរិយាបន្នពិការភាពច្រើនតែត្រូវបានគេមិនគិតគូរ ឬធ្វើឱ្យសាមញ្ញ ដោយសារវាត្រូវបានគេមើលឃើញថា **"ស្មុគស្មាញពេក"** ឬ **"ប្រើប្រាស់ធនធានច្រើនពេក"**។

បញ្ហាប្រឈមទាំងនេះ  កាន់តែស្មុគស្មាញដោយសារគម្លាតនៅក្នុងប្រព័ន្ធទិន្នន័យដែលពាក់ព័ន្ធនឹងពិការភាព។ ទិន្នន័យថ្មីៗពីអង្គការទិន្នន័យអំពីការអភិវឌ្ឍ[៩៤] បានគូសបញ្ជាក់ថា ទិន្នន័យពិការភាពនៅកម្ពុជាត្រូវបានប្រមូលនៅទូទាំងប្រព័ន្ធជាច្រើន រួមមានជំរឿនថ្នាក់ជាតិ មូលដ្ឋានទិន្នន័យអត្តសញ្ញាណកម្មគ្រួសារក្រីក្រ  និងប្រព័ន្ធរដ្ឋបាលតាមវិស័យ ដែលគ្រប់គ្រងដោយក្រសួងនានាដូចជា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ ទោះជាយ៉ាងណា សំណុំទិន្នន័យទាំងនេះមានលក្ខណៈបែកខ្ញែក មិនអាចដំណើរការជាមួយគ្នាបាន និងច្រើនតែផ្អែកលើនិយមន័យ និងវិធីសាស្ត្រវាស់វែងខុសៗគ្នា រួមទាំងការប្រើប្រាស់ខុសគ្នានូវសំណួររបស់ក្រុមការងារវ៉ាស៊ីនតោន ស្តីពីពិការភាព (សំណុំសំណួរស្តង់ដារជាសកលស្តីពីពិការភាពសម្រាប់ប្រើប្រាស់ក្នុងអង្កេត និងជំរឿន)។[៩៥] នេះធ្វើឱ្យមានការលំបាកក្នុងការប្រៀបធៀប ការបូកសរុប និងការវិភាគយ៉ាងស៊ីសង្វាក់គ្នានៅក្នុងវិស័យនានា។

[៩៤] Open Development Cambodia (ODC) (2025). Policy Brief: Open Data for Disability Inclusion in Cambodia. Phnom Penh: Open Development Cambodia: https://policypulse.org/wp-content/uploads/2025/03/2025_policybrieft_opendata_disability.pdf

[៩៥] https://www.washingtongroup-disability.com/question-sets/

បន្ថែមលើនេះ ទិន្នន័យស្ដីពីពិការភាពដែលមានផាសុកវត្ថុដល់សាធារណជន គឺនៅមានកម្រិត។ ខណៈដែលគេអាចរកបានតួលេខសំខាន់ៗមួយចំនួន សំណុំទិន្នន័យលម្អិតកម្រត្រូវបានបើកទូលាយ ឬធ្វើបច្ចុប្បន្នភាពជាប្រចាំ ជាពិសេសនៅថ្នាក់ក្រោមជាតិ។ ទិន្នន័យដែលមានស្រាប់ច្រើនតែខ្វះភាពស៊ីជម្រៅ ដោយមិនសូវមានការបែកចែកតាមពិការភាព យេនឌ័រ អាយុ ទីតាំង ឬស្ថានភាពសេដ្ឋកិច្ចសង្គមនោះឡើយ។ ឧទាហរណ៍ ទិន្នន័យរដ្ឋបាល និងទិន្នន័យអង្កេត អាចកំណត់អត្តសញ្ញាណជនមានពិការភាព ប៉ុន្តែមិនអាចច្បាមយកឧបសគ្គរាំងពួកគេក្នុងការទទួលបានសេវា ជីវភាពរស់នៅ ឬការចូលរួមក្នុងជីវភាពសាធារណៈនោះឡើយ។ កត្តាទាំងនេះបានរឹតត្បិតសមត្ថភាពរបស់អ្នកស្រាវជ្រាវ ក្នុងការរៀបចំការសិក្សាចំគោលដៅ ឬធានាបាននូវការជ្រើសរើសសំណាកតំណាងយ៉ាងត្រឹមត្រូវ។

ហេតុនេះហើយ ការកំណត់អត្តសញ្ញាណ និងការស្វែងរកជនមានពិការភាពសម្រាប់ធ្វើការស្រាវជ្រាវ ជារឿយៗត្រូវចំណាយពេលច្រើន និងពឹងផ្អែកលើបណ្ដាញមិនផ្លូវការ ឬការចូលរួមតាមកាលៈទេសៈជាមួយអង្គការតំណាងជនមានពិការភាព។ សូម្បីតែក្នុងករណីមានទិន្នន័យក៏ដោយ ក៏ទិន្នន័យទាំងនោះមិនមានស្តង់ដារស៊ីសង្វាក់គ្នា ឬមិនងាយស្រួលទទួលបានដែរ ដែលបង្កការលំបាកដល់ការយកទៅប្រើប្រាស់សម្រាប់ការវិភាគយ៉ាងម៉ត់ចត់ ឬការស្រាវជ្រាវពាក់ព័ន្ធនឹងគោលនយោបាយ។ឧបសគ្គទាំងនេះកម្រិតទាំងការដាក់បញ្ចូលជនមានពិការភាពទៅក្នុងដំណើរការស្រាវជ្រាវ និងគុណភាពនៃទិន្នន័យដែលបានបង្កើតឡើង។ ពិការភាពនៅតែមិនសូវត្រូវបានលើកឡើងនៅក្នុងសំណុំទិន្នន័យ ដែលផ្ដល់ព័ត៌មានដល់ការសម្រេចចិត្តលើគោលនយោបាយ ហើយចំណុចនេះរឹតតែធ្វើឱ្យមានការផាត់ចេញពិការភាពពីការធ្វើផែនការផ្អែកលើទិន្នន័យ។

## ឧបសគ្គបរិស្ថានរូបវន្ត ហិរញ្ញវត្ថុ និងការប្រាស្រ័យទាក់ទង

សូម្បីតែក្នុងករណីដែលការរៀបចំការស្រាវជ្រាវ ព្យាយាមធ្វើឱ្យមានបរិយាបន្នក៏ដោយ ក៏ជារឿយៗ ការចូលរួមត្រូវបានរឹតត្បិតដោយឧបសគ្គបរិស្ថានរូបវន្ត ហិរញ្ញវត្ថុ និងការប្រាស្រ័យទាក់ទង។ ទីតាំងស្រាវជ្រាវ និងទីតាំងពិភាក្សាជាច្រើន ខ្វះការបង្កភាពងាយស្រួលជាចម្បង ដូចជាផ្លូវជម្រាល ជណ្ដើរយន្ត និងមធ្យោបាយធ្វើដំណើរដែលផ្ដល់ភាពងាយស្រួល។ ដៃគូនៅខេត្តបាត់ដំបង និងខេត្តកំពត បានរៀបរាប់ពីកិច្ចប្រជុំគោលនយោបាយ ដែលប្រារព្ធធ្វើឡើងនៅទីកន្លែងដែលគ្មានផ្លូវជម្រាល ជណ្ដើរយន្ត ឬមធ្យោបាយធ្វើដំណើរដែលផ្ដល់ភាពងាយស្រួល។ អ្នកចូលរួមម្នាក់បាននិយាយថា៖ **"សម្រាប់មនុស្សជាច្រើនដែលជិះរទេះរុញ ការចូលរួមត្រូវបានបញ្ចប់មុនពេលវាចាប់ផ្ដើមទៅទៀត។"** រាជធានីភ្នំពេញមានភាពប្រសើរជាងមុនបន្តិចបន្តួចប៉ុណ្ណោះ ដោយស្តង់ដារនៃការបង្កភាពងាយស្រួលត្រូវបានអនុវត្តក្នុងកម្រិតខុសៗគ្នា និងកម្រត្រូវបានត្រួតពិនិត្យ។ នៅកន្លែងដែលមានផ្លូវជម្រាល វាច្រើនតែត្រូវបានរៀបចំឡើងមិនបានល្អ ឬមិនអាចប្រើប្រាស់បាន។

អង្គការមួយបានពណ៌នាអំពីរបៀបដែល **"សូម្បីតែការព្យាយាមសាងសង់ផ្លូវជម្រាល ក៏ក្លាយជាការខិតខំយ៉ាងស្វិតស្វាញមួយផងដែរ"** ដោយសារតែស្តង់ដារមិនច្បាស់លាស់ ថវិកាមានកម្រិត និងកង្វះការណែនាំផ្នែកបច្ចេកទេស។ បញ្ហានេះរាប់បញ្ចូលអគារសាធារណៈ ដែលត្រូវបានប្រើប្រាស់សម្រាប់ការស្រាវជ្រាវ និងការពិគ្រោះយោបល់ រួមទាំងសាលាឃុំ មណ្ឌលសុខភាព និងសាកលវិទ្យាល័យ។

ឧបសគ្គផ្នែកហិរញ្ញវត្ថុ រឹតធ្វើឱ្យមានការផាត់ចេញកាន់តែខ្លាំង។ ការចំណាយលើការធ្វើដំណើរ ជំនួយការផ្ទាល់ខ្លួន និងឧបករណ៍ជំនួយ ធ្វើឱ្យការចូលរួមមានត្រូវចំណាយច្រើន ជាពិសេសសម្រាប់អ្នករស់នៅជនបទ។ ការមានប័ណ្ណសម្គាល់ជនមានពិការភាព និងសិទ្ធិស្របច្បាប់ កម្រនឹងត្រូវបំប្លែងទៅជាការគាំទ្រផ្នែកហិរញ្ញវត្ថុជាក់ស្តែងណាស់។ អ្នកចូលរួមម្នាក់បាននិយាយថា៖ **"ការចំណាយលើការធ្វើដំណើរទៅកាន់វេទិកាគោលនយោបាយ គឺហួសពីលទ្ធភាពដែលអាចទៅរួច។"** ការចំណាយទាំងនេះ កម្រត្រូវបានដាក់បញ្ចូលក្នុងថវិកាស្រាវជ្រាវណាស់ ដែលនេះធ្វើឱ្យមានការផាត់ចេញជនមានពិការភាពដោយស្វ័យប្រវត្តិ។

ឧបសគ្គការប្រាស្រ័យទាក់ទង ក៏រឹតត្បិតដល់ការចូលរួមប្រកបដោយអត្ថន័យផងដែរ។ កិច្ចប្រជុំដែលគ្មានការបកប្រែភាសាសញ្ញា ឯកសារដែលមិនមានផ្ដល់ក្នុងទម្រង់ជាជម្រើស និងព័ត៌មានដែលត្រូវបានចែករំលែកតាមបណ្ដាញដែលមិនអាចចូលប្រើបាន មានន័យថា សូម្បីតែនៅពេលដែលជនមានពិការភាពមានវត្តមានផ្ទាល់ក៏ដោយ ក៏ការចូលរួមប្រកបដោយអត្ថន័យនៅតែមានកម្រិត។ គម្លាតទាំងនេះកម្រត្រូវបានគេទទួលស្គាល់ថាជាបញ្ហាគុណភាពនៃការស្រាវជ្រាវណាស់ ប៉ុន្តែវាប៉ះពាល់ដោយផ្ទាល់ទៅលើថាតើចំណេះដឹងរបស់នរណាខ្លះដែលត្រូវបានកត់ត្រាទុក និងថាតើសំឡេងរបស់នរណាខ្លះដែលកំណត់លទ្ធផល។

## ការរើសអើងក្នុងសង្គម និងឧបសគ្គឥរិយាបថ

ក្រៅពីហេដ្ឋារចនាសម្ព័ន្ធ និងធនធាន ឧបសគ្គឥរិយាបថនៅតែចាក់ឫសយ៉ាងជ្រៅ។ តាមការលើកឡើង ការរើសអើង និងការសន្មត អំពីសមត្ថភាព កើតមានច្រើនទៅលើអ្នកដែលមានពិការភាពផ្នែកចិត្តសង្គម។ ការសន្មតអំពីផលិតភាព នៅតែបន្តរឹតត្បិតដល់ការចូលរួម។ អ្នកចូលរួមបានលើកឡើងថា

> “ បញ្ហាមិនស្ថិតលើសមត្ថភាពទេ ប៉ុន្តែស្ថិតលើបរិយាកាស និងឥរិយាបថដែលសន្មតថា ពួកគេមិនអាចធ្វើការងារបានទៅវិញទេ។ ”

ភាពភ័យខ្លាចក្នុងការលាតត្រដាង កង្វះវិធានការការពារ និងភាពមានកម្រិតនៃសមត្ថភាពផ្នែកក្រមសីលធម៌ក្នុងចំណោមអ្នកស្រាវជ្រាវ ច្រើនតែបណ្តាលឱ្យមានការផាត់ចេញដោយស្វ័យប្រវត្តិ។ ដៃគូមួយចំនួនបានកត់សម្គាល់ថា បុគ្គលម្នាក់ៗត្រូវបានបន្ទុចបង្អាក់មិនឱ្យចូលរួម មិនត្រឹមតែដោយស្ថាប័នប៉ុណ្ណោះទេ ប៉ុន្តែជួនកាលក៏ត្រូវបានបន្ទុចបង្អាក់ដោយក្រុមគ្រួសារ និងថ្នាក់ដឹកនាំសហគមន៍ផងដែរ។ ឥរិយាបថទាំងនេះធ្វើឱ្យប៉ះពាល់ដល់ទំនុកចិត្ត និងពង្រឹងគំនិតយល់ឃើញថា វេទិកាគោលនយោបាយគឺមិនមែនសម្រាប់ពួកគេឡើយ។

ចំណុចសំខាន់ គឺឧបសគ្គឥរិយាបថទាំងនេះកម្រត្រូវបានដោះស្រាយ តាមរយៈការបណ្តុះបណ្តាលស្ថាប័ន ឬគោលនយោបាយណាស់។ ដូច្នេះ បរិយាបន្នអាស្រ័យទៅលើការយល់ដឹងរបស់បុគ្គលម្នាក់ៗ ជាជាងវិធានការការពារជាប្រព័ន្ធ ដែលធ្វើឱ្យបរិយាបន្ន មានភាពមិនច្បាស់លាស់ និងផុយស្រួយ។

---

## សមត្ថភាពរបស់អង្គការតំណាងជនមានពិការភាព (OPDs) និងឥទ្ធិពលគោលនយោបាយមានកម្រិត

នៅកម្រិតប្រព័ន្ធ អង្គការតំណាងជនមានពិការភាព ដើរតួនាទីយ៉ាងសំខាន់ក្នុងការតំណាងឱ្យទស្សនៈរបស់ជនមានពិការភាព ក៏ប៉ុន្តែ សមត្ថភាពរបស់អង្គការទាំងនេះក្នុងការជះឥទ្ធិពលលើដំណើរការស្រាវជ្រាវ និងដំណើរការគោលនយោបាយ គឺនៅមានកម្រិត។ បើធៀបនឹង អង្គការសិទ្ធិស្ត្រី និងតួអង្គសង្គមស៊ីវិលធំៗ អង្គការតំណាងជនមានពិការភាពជាច្រើន ធ្វើប្រតិបត្តិការដោយមានប្រព័ន្ធអភិបាលកិច្ចខ្សោយ សមត្ថភាពវិភាគគោលនយោបាយមានកម្រិត និងការផ្តល់មូលនិធិផ្អែកលើគម្រោង ដែលមិនជាប់លាប់។ លទ្ធផលពីការវាយតម្លៃបង្ហាញថា ខណៈដែលជាទូទៅ គុណភាពនៃការស្រាវជ្រាវ និងបេសកកម្មរបស់អង្គការ មានភាពរឹងមាំក្នុងចំណោមដៃគូសង្គមស៊ីវិលក៏ដោយ ក៏អង្គការតំណាងជនមានពិការភាព នៅតែប្រឈមនឹងការលំបាកជាក់លាក់ក្នុងការប្រែក្លាយទិន្នន័យទៅជាធាតុចូលទាន់ពេលវេលា និងស្របនឹងតម្រូវការគោលនយោបាយ។ ឱកាសក្នុងការចូលរួមតាក់តែងគោលនយោបាយរយៈពេលខ្លី ច្រើនតែទាមទារការវិភាគឆាប់រហ័ស និងសមស្រប តាមតម្រូវការ ប៉ុន្តែការខ្វះបុគ្គលិកបច្ចេកទេស និងការគ្មានថវិកាស្នូល បានរឹតត្បិតសមត្ថភាពរបស់អង្គការតំណាងជនមានពិការភាព ឆ្លើយតបប្រកបដោយប្រសិទ្ធភាព។ ដូច្នេះហើយទើបការចូលរួមក្នុងការពិភាក្សាគោលនយោបាយបច្ចេកទេស ច្រើនតែមានកម្រិតមិនស្មើគ្នា ហើយឥទ្ធិពលនៅតែមានកម្រិតទាប។

គម្លាតសមត្ថភាពក៏បង្ហាញឱ្យឃើញច្បាស់ផងដែរនៅទូទាំងផ្នែកមូលបទ និងស្ថាប័ន។ ខណៈដែលដៃគូបង្ហាញពីការអនុវត្តការងារបានល្អប្រសើរជាងមុនលើផ្នែកសមភាពយេនឌ័រ ការអនុវត្តការងារពាក់ព័ន្ធនឹងបរិយាបន្នពិការភាពនៅតែអន់ថយ។ នេះឆ្លុះបញ្ចាំងពីភាពមានកម្រិតនៃជំនាញ ឧបករណ៍ និងប្រព័ន្ធផ្ទៃក្នុង ដើម្បីអនុវត្តបរិយាបន្នឱ្យខាងតែបាន។ អង្គការតំណាងជនមានពិការភាព ជាច្រើនពឹងផ្អែកលើការអនុវត្តក្រៅផ្លូវការ ជាជាងគោលនយោបាយ និងនីតិវិធីដែលបានចងក្រងជាឯកសារ ដែលនេះធ្វើឱ្យប៉ះពាល់ដល់គណនេយ្យភាព ការបណ្តុះបណ្តាលបុគ្គលិកថ្មី និងនិរន្តរភាពរបស់ស្ថាប័ន។តួនាទីជាមន្ត្រីបង្គោលពិការភាព ទោះមានក៏ដោយ ក៏ច្រើនតែមានលក្ខណៈមិនផ្លូវការ ខ្វះធនធាន និងត្រូវបានបន្ថែមពីលើបន្ទុកការងារដែលមានស្រាប់ ដែលធ្វើឱ្យវឌ្ឍនភាពត្រូវអាស្រ័យលើបុគ្គលឆ្នើមម្នាក់ៗ ជាជាងការប្តេជ្ញាចិត្តយូរអង្វែងរបស់អង្គការផ្ទាល់។ បញ្ហានេះកាន់តែធ្ងន់ធ្ងរថែមទៀត ដោយសារតែការវិនិយោគមានកម្រិតលើការត្រួតពិនិត្យ ការវាយតម្លៃ ការរៀនសូត្រ ការគ្រប់គ្រងទិន្នន័យ និងការប្រាស្រ័យទាក់ទង ដែលចំណុចទាំងអស់នេះសុទ្ធតែមានសារៈសំខាន់សម្រាប់បង្កើនការប្រើប្រាស់លទ្ធផលស្រាវជ្រាវ និងការជះឥទ្ធិពលលើគោលនយោបាយ។

ឧបសគ្គផ្នែកស្ថាប័នទាំងនេះ ត្រូវបានបន្ថែមបន្ទុកដោយបញ្ហាប្រឈមជាប្រព័ន្ធ។ ការសម្របសម្រួលដោយរដ្ឋាភិបាលនៅមានភាពរប៉ាត់រប៉ាយ និងអាណត្តិស្ថាប័នមិនច្បាស់លាស់ ជាពិសេសរវាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រុមប្រឹក្សាសកម្មភាពជនពិការ បានធ្វើឱ្យចុះខ្សោយដល់គណនេយ្យភាព និងការតាមដាន។ ទោះបីជាច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការរបស់កម្ពុជា បានចែងពីកាតព្វកិច្ចយ៉ាងច្បាស់លាស់ក៏ដោយ ក៏ការអនុវត្តច្បាប់នៅតែមានកម្រិត ដែលបណ្តាលឱ្យការមិនគោរពតាមច្បាប់ចេះតែបន្តកើតមាន ដោយមានការទទួលខុសត្រូវតិចតួចបំផុត។ ក្នុងបរិបទនេះ បរិយាបន្នច្រើនតែត្រូវបានគេចាត់ទុកថាជាជម្រើស ជាជាងកាតព្វកិច្ច ហើយអង្គការតំណាងជនមានពិការភាព ត្រូវបានគេទុកឱ្យធ្វើការតស៊ូមតិលើការអនុវត្តច្បាប់ដោយគ្មានការគាំទ្រពីស្ថាប័ន ទិន្នន័យ ឬធនធានដែលត្រូវការចាំបាច់ ដើម្បីរក្សាការចូលរួមប្រកបដោយអត្ថន័យនៅក្នុងដំណើរការគោលនយោបាយ។

---

## វឌ្ឍនភាពមិនពេញលេញ មិនមែនជាការផ្លាស់ប្តូរប្រព័ន្ធ

វឌ្ឍនភាពខ្លះៗឃើញកើតមាន។ អង្គការដូចជា អង្គការជនពិការកម្ពុជា កំពុងកសាងជំនាញតស៊ូមតិ និងជំនាញភាពជាអ្នកដឹកនាំក្នុងចំណោមជនមានពិការភាព។ ក្រសួង និងអាជ្ញាធរមូលដ្ឋានមួយចំនួន បានធ្វើឱ្យប្រសើរឡើងនូវភាពងាយស្រួល និងបានអញ្ជើញតំណាងមកពីអង្គការតំណាងជនមានពិការភាព ឱ្យចូលរួមក្នុងគណៈកម្មាធិការគោលនយោបាយ។ ម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល បានគាំទ្រដល់ការចំណាយលើការចូលរួម និងយុទ្ធនាការលើកកម្ពស់ការយល់ដឹង។ ទោះជាយ៉ាងណា កិច្ចខិតខំប្រឹងប្រែងទាំងនេះនៅតែមានលក្ខណៈរប៉ាត់រប៉ាយ និងផ្អែកលើគម្រោងនៅឡើយ។ ដូចដែលដៃគូម្នាក់បានលើកឡើងយ៉ាងខ្លីថា

> “ យើងត្រូវបានគេអញ្ជើញ ប៉ុន្តែមិនត្រូវបានផ្តល់លទ្ធភាពឱ្យចូលរួមនោះទេ។ ”

ដរាបណាការបង្កភាពងាយស្រួល ការផ្តល់ធនធាន ការអនុវត្តច្បាប់ និងភាពជាតំណាងមិនត្រូវបានចាត់ទុកជាធាតុផ្សំដែលមិនអាចខ្វះបាននៃដំណើរការស្រាវជ្រាវ និងដំណើរការគោលនយោបាយទេនោះ បរិយាបន្នពិការភាពនឹងនៅតែមានលក្ខណៈដោយផ្នែក និងមានកម្រិតមិនស្មើគ្នា។ ការចាត់ទុកពិការភាពជាបញ្ហាកង្វល់ដាច់ដោយឡែក នៅតែបន្តធ្វើឱ្យចុះខ្សោយដល់គុណភាពនៃទិន្នន័យ និងធ្វើឱ្យប៉ះពាល់ដល់ការតាក់តែងគោលនយោបាយប្រកបដោយបរិយាបន្ន។

ប្រអប់ទី ១២

## សេចក្តីសង្ខេបលទ្ធផលសំខាន់ៗពីកិច្ចប្រជុំសហការរៀបចំគោលការណ៍ណែនាំស្តីពីបរិយាបន្ន និងបុគ្គលផ្ទើមពិការភាពប្រចាំស្ថាប័ន

កិច្ចប្រជុំចាប់ផ្តើមការងារមួយ បានប្រមូលផ្តុំដៃគូរបស់អង្គការសកម្មភាពប្រជាជនដើម្បីការអភិវឌ្ឍបរិយាបន្ន (PAfID) អង្គការជនពិការ និងជនមានពិការភាព ដើម្បីកសាងការយល់ដឹងរួមគ្នាអំពីរបៀបដែលការស្រាវជ្រាវ និងការពិភាក្សាប្រកបដោយបរិយាបន្នពិការភាព គួរតែដំណើរការនៅក្នុងការអនុវត្តជាក់ស្តែង។ អ្នកចូលរួមបានឈានដល់ការព្រមព្រៀងយ៉ាងមោះមុតលើគោលការណ៍ស្នូលរួមទាំង "គ្មានអ្វីអំពីពួកយើង ដោយគ្មានការចូលរួមអំពីពួកយើងនោះទេ" ភាពចាំបាច់ក្នុងការលុបបំបាត់ឧបសគ្គជាក់ស្តែង និងឧបសគ្គឥរិយាបថ និងសារៈសំខាន់នៃការចូលរួមពេញលេញ និងប្រកបដោយអត្ថន័យរបស់ជនមានពិការភាព នៅគ្រប់ដំណាក់កាលនៃការស្រាវជ្រាវ និងការពិភាក្សា។ ការពិភាក្សាបានបង្ហាញពីគម្លាតច្បាស់លាស់នៅក្នុងការអនុវត្តបច្ចុប្បន្ន ជាពិសេសជុំវិញការបង្កភាពងាយស្រួល វិធីសាស្ត្រប្រាស្រ័យទាក់ទង សមត្ថភាពរបស់អ្នកស្រាវជ្រាវ ការបែងចែកថវិកា និងទំនុកចិត្តក្នុងការចូលរួមជាមួយអ្នកដែលមានពិការភាពប្រភេទផ្សេងៗគ្នា។ អ្វីដែលសំខាន់នោះគឺកិច្ចប្រជុំបានបញ្ជាក់ថា បញ្ហាប្រឈមទាំងនេះមានលក្ខណៈជាប្រព័ន្ធ ជាជាងជាបញ្ហាដាច់ដោយឡែក ដែលវាជះឥទ្ធិពលអន្តរវិស័យលើគោលនយោបាយស្ថាប័ន ការរៀបចំការស្រាវជ្រាវ និងការរៀបចំកម្មវិធីផ្សេងៗ។

កិច្ចប្រជុំនេះបានឈានដល់ជំហានជាក់ស្តែងបន្តបន្ទាប់សម្រាប់ការគាំទ្ររបស់ PAfID ក្រោមកិច្ចការនេះ។ ដៃគូបានគាំទ្រដល់ការរួមគ្នាបង្កើតគោលការណ៍ណែនាំជាក់ស្តែងស្តីពីការបង្កភាពងាយស្រួលសម្រាប់ការស្រាវជ្រាវ និងការពិភាក្សា ដែលគាំទ្រដោយឧបករណ៍ដូចជា បញ្ជីផ្ទៀងផ្ទាត់ ការណែនាំស្តីពីការរៀបចំថវិកា និងការពិចារណាអំពីក្រមសីលធម៌សម្រាប់ការចូលរួមជាមួយជនមានពិការភាព។ ពួកគេបានឯកភាពគ្នាបង្កើតក្រុមការងារស្ម័គ្រចិត្ត នៃមន្ត្រីបង្គោលពិការភាពប្រចាំស្ថាប័ន ដើម្បីធ្វើជាបុគ្គលផ្ទើមជំរុញការរៀនសូត្រ ការឆ្លុះបញ្ចាំង និងការអនុវត្តនៅក្នុងស្ថាប័នដៃគូ ហើយទន្ទឹមនឹងនោះទទួលស្គាល់នូវក្តីកង្វល់ចំពោះបន្ទុកការងារដែលទាមទារឱ្យមានការពិភាក្សាផ្ទៃក្នុង។ ធាតុចូលពីជនមានពិការភាព បានជួយកំណត់ដោយផ្ទាល់នូវវិស័យអាទិភាពសម្រាប់គោលការណ៍ណែនាំនេះ ដើម្បីធានាថា វាឆ្លើយតបទៅនឹងឧបសគ្គពិតប្រាកដ ជាជាងត្រឹមតែជាការប្តេជ្ញាចិត្ត។ ជារួម កិច្ចប្រជុំបានកសាងមូលដ្ឋានគ្រឹះ ដ៏រឹងមាំសម្រាប់អភិក្រមរួមគ្នាបង្កើត និងតម្រង់ទិសឆ្ពោះទៅរកការអនុវត្តជាក់ស្តែងសម្រាប់បរិយាបន្នពិការភាព ដែលដៃគូអាចយកទៅអនុវត្តបានយ៉ាងពិតប្រាកដនៅក្នុងការងារស្រាវជ្រាវ ការពិភាក្សា និងការចូលរួមក្នុងគោលនយោបាយរបស់ពួកគេ។

## ៣.២.៥. បរិយាបន្នសង្គម៖ ជាតិពន្ធុ អត្តសញ្ញាណជាជនជាតិដើមភាគតិច យុវជន ភូមិសាស្ត្រ ទំនោរផ្លូវភេទ និងវិសមភាពសេដ្ឋកិច្ចសង្គម

### *ការធ្វើស្ថាប័នូបនីយកម្ម និងការលើកទឹកចិត្តក្នុងកម្រិតមិនស្មើគ្នា*

នៅតាមស្ថាប័នស្រាវជ្រាវនានា បរិយាបន្នសង្គមក្រៅពីបញ្ហាយេនឌ័រ នៅមានកម្រិតមិនស្មើគ្នា មិនសូវមានការអភិវឌ្ឍ និងពឹងផ្អែកជាចម្បងលើចំណុចផ្តោតសំខាន់របស់គម្រោង ជាជាងស្តង់ដាររបស់ស្ថាប័ន។ ខណៈដែលសមភាពយេនឌ័រត្រូវបានគេយល់ច្បាស់គួរសម និងក្នុងករណីខ្លះ ត្រូវបានធ្វើស្ថាប័នូបនីយកម្ម ធាតុផ្សំផ្សេងទៀតនៃសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ជាពិសេសជាតិពន្ធុ អត្តសញ្ញាណជាជនជាតិដើមភាគតិច យុវជន ទំនោរផ្លូវភេទ ភូមិសាស្ត្រ និងវិសមភាពសេដ្ឋកិច្ចសង្គម ទទួលបានការយកចិត្តទុកដាក់ជាប្រព័ន្ធតិចតួចបំផុត។ នេះឆ្លុះបញ្ចាំងអំពីលទ្ធផលមុនៗនៅក្នុងការវិភាគដែលបង្ហាញថា សមភាពយេនឌ័រគឺជាធាតុផ្សំមួយ នៃសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ដែលបានចាក់ឫសជ្រៅជាងគេបំផុតនៅក្នុងប្រព័ន្ធរដ្ឋាភិបាល។ ឋានានុក្រមដូចគ្នានេះ ក៏អាចមើលឃើញយ៉ាងច្បាស់នៅក្នុងវិស័យស្រាវជ្រាវផងដែរ។

ការយល់ដឹងស៊ីជម្រៅពីវគ្គបណ្តុះបណ្តាលស្តីពី សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ដែលគាំទ្រដោយកម្មវិធីពន្លកចំណេះដំណាក់កាលទី២ ឆ្លុះបញ្ចាំងឱ្យឃើញកាន់តែច្បាស់អំពីគម្លាតនេះ។ អ្នកចូលរួមជាច្រើនបានទទួលស្គាល់ដោយបើកចំហថា ការយល់ដឹងរបស់ពួកគេអំពីបរិយាបន្នសង្គមនៅមានកម្រិត។ ខណៈដែលអ្នកស្រាវជ្រាវភាគច្រើនយល់ថា ពួកគេមានទំនុកចិត្តគួរសមក្នុងការដោះស្រាយបញ្ហាយេនឌ័រ មានអ្នកស្រាវជ្រាវតិចតួចណាស់ដែលយល់ថា ពួកគេមានសមត្ថភាពគ្រប់គ្រាន់ក្នុងការអនុវត្តទម្រង់ផ្សេងទៀតនៃការផាត់ចេញ ទៅក្នុងការរៀបចំការស្រាវជ្រាវ ការប្រមូលទិន្នន័យ ឬការវិភាគ។ ដូចដែលអ្នកស្រាវជ្រាវម្នាក់ដែលចូលរួមក្នុងការវិភាគនេះបានកត់សម្គាល់ថា៖ ***"យេនឌ័រ គឺជាអ្វីដែលយើងធ្លាប់តែគិតដល់ជារឿយៗ។ បរិយាបន្នសង្គមហាក់ទូលំទូលាយជាង និងលំបាកជាង ហើយយើងមិនសូវទំតែដឹងថាត្រូវចាប់ផ្តើមពីចំណុចណានោះទេ។"*** អ្នកស្រាវជ្រាវម្នាក់ទៀតបានគូសបញ្ជាក់ថា៖ ***"យើងនិយាយអំពីបរិយាបន្ន ប៉ុន្តែនៅពេលនិយាយដល់ជាតិពន្ធុ ឬទំនោរផ្លូវភេទ គេបារម្ភពីការបង្កើតកំហុស ដូច្នេះ គេក៏ចៀសវាងមិននិយាយចំណុចនេះតែម្តង។"***

ខណៈដែលស្ថាប័នស្រាវជ្រាវមួយចំនួន ជាពិសេសស្ថាប័នដែលមានមូលដ្ឋាននៅភ្នំពេញ ដូចជា CDRI, CKS និង CPS បានបង្កើតនូវការសិក្សាស្តីពីភាពក្រីក្រនៅជនបទ ភាពគ្មានដីធ្លី សហគមន៍ជនជាតិដើមភាគតិច និងភាពងាយរងគ្រោះផ្នែកជីវភាព កិច្ចខិតខំប្រឹងប្រែងទាំងនេះ ភាគច្រើននៅតែមានលក្ខណៈផ្អែកតាមមូលបទ។ បរិយាបន្នត្រូវបានអនុវត្ត នៅពេលដែលវាបន្សុីគ្នា នឹងគោលបំណងរបស់គម្រោង ឬអាទិភាពរបស់ម្ចាស់ជំនួយ ជាជាងត្រូវបានដាក់បញ្ចូលជាការរំពឹងទុកស្តង់ដារនៅទូទាំងកម្រងស្នាដៃស្រាវជ្រាវទាំងមូល។ មានអង្គការ-ស្ថាប័នតិចតួចណាស់ ដែលមានគោលការណ៍ណែនាំផ្ទៃក្នុង ដំណើរការត្រួតពិនិត្យ ឬការលើកទឹកចិត្ត ដែលតម្រូវឱ្យអ្នកស្រាវជ្រាវធ្វើការពិចារណាជាប្រព័ន្ធថា តើនរណាដែលអាចត្រូវបានផាត់ចេញ និងក្រោមមូលហេតុអ្វី។ ដូចដែលអ្នកផ្តល់បទសម្ភាសន៍ម្នាក់បានពន្យល់ថា៖ ***"ប្រសិនបើលក្ខខណ្ឌប្រតិបត្តិនៃការស្រាវជ្រាវ មិនបានលើកឡើងអំពីជនជាតិដើមភាគតិច ឬយុវជនទេនោះ ជាធម្មតាយើងមិនផ្តោតលើប្រធានបទនោះទេ។ វាមិនមែនជាអ្វីដែលអង្គការ-ស្ថាប័ន តម្រូវឱ្យយើងធ្វើជាប្រព័ន្ធនោះទេ។"***

នេះឆ្លុះបញ្ចាំងពីលំនាំទូលំទូលាយដែលបានរកឃើញនៅក្នុងវិស័យស្រាវជ្រាវរបស់កម្ពុជា ដែលរបៀបវារៈស្រាវជ្រាវជារឿយៗ ត្រូវបានកំណត់ដោយគម្រោងរយៈពេលខ្លីដែលទទួលបានមូលនិធិពីខាងក្រៅ ជាជាងអាទិភាពស្ថាប័នដែលប្រកបដោយនិរន្តរភាព។ ក្នុងលក្ខខណ្ឌទាំងនេះ បរិយាបន្នមិនត្រូវបានកំណត់ជាលក្ខខណ្ឌតម្រូវទេ ហើយអ្នកស្រាវជ្រាវមានការលើកទឹកចិត្ត ឬធនធានមានកម្រិត ក្នុងការធ្វើអ្វីដែលហួសពីវិសាលភាព ដែលកំណត់ដោយលក្ខខណ្ឌប្រតិបត្តិរបស់គម្រោង។[៤៦]

[៤៦] Pak, K., Fathimath, I., and Pellini, A. ( 2020 ), Diagnostic Study on the Cambodian Knowledge Sector, Policy Pulse, https://policypulse.org/wp-content/uploads/2020/07/Diagnostic_Study_FINAL_English-3.pdf

## ការធ្វើស្ថាប័ន្ទបនីយកម្ម និងការលើកទឹកចិត្តក្នុងកម្រិតមិនស្មើគ្នា

លទ្ធផលដែលលេចឡើងដដែលៗគឺ បរិយាបន្នសង្គមដែលច្រើនតែត្រូវបានចាត់ទុកជាផ្នែកបន្ថែម ជាជាងជាធាតុផ្សំស្នូលសម្រាប់គុណភាពនៃការស្រាវជ្រាវ។ ការសិក្សានានាកម្រដាក់បញ្ចូលជនជាតិដើមភាគតិច ជនជាតិភាគតិច ក្រុម LGBTQIA+ យុវជន និងក្រុមដែលត្រូវបានផាត់ចេញផ្សេងទៀតណាស់ លុះត្រាតែពួកគេគឺជាប្រធានបទជាក់លាក់នៃការសិក្សា ឬតម្រូវដោយម្ចាស់ជំនួយ។ ក្នុងករណីដែលគ្មានលក្ខខណ្ឌតម្រូវបែបនេះ ការស្រាវជ្រាវច្រើនតែងាកទៅរកប្រជាពលរដ្ឋដែលងាយមើលឃើញ ឬងាយស្រួលទាក់ទងបាន។
អ្នកស្រាវជ្រាវម្នាក់បានគូសបញ្ជាក់ថា៖

> “ ជាធម្មតា យើងគិតអំពីបរិយាបន្ន បន្ទាប់ពីសំណួរស្រាវជ្រាវត្រូវបានកំណត់រួចទៅហើយ។ ដូចនេះ យើងពិបាកផ្លាស់ប្តូរឡើងវិញ។" អ្នកស្រាវជ្រាវម្នាក់ទៀតបានកត់សម្គាល់ថា៖ "ជារឿយៗ បរិយាបន្នជាអ្វីដែលយើងបន្ថែមទៅក្នុងផ្នែកវិធីសាស្ត្រ ប៉ុន្តែវាមិនសូវមានឥទ្ធិពលលើការសិក្សាប៉ុន្មានទេ។ ”

អភិក្រមនេះ កម្រិតទាំងភាពជាតំណាង និងភាពស៊ីជម្រៅនៃការវិភាគក្នុងការស្រាវជ្រាវ ដោយសារការផាត់ចេញមិនត្រូវបានលើកមកពិចារណានៅក្នុងការកំណត់ទម្រង់បញ្ហា ការបកស្រាយទិន្នន័យ ឬការរៀបចំអនុសាសន៍។ អភិក្រមនេះក៏ឆ្លុះបញ្ចាំងពីឧបសគ្គផ្នែកពេលវេលា និងធនធាន ព្រមទាំងការគ្មានយន្តការត្រួតពិនិត្យរបស់ស្ថាប័ន ដែលតម្រូវឱ្យមានការដាក់បញ្ចូលបរិយាបន្នតាំងពីចាប់ផ្តើមដំបូងផងដែរ។

បញ្ហាប្រឈមទាំងនេះ កាន់តែធ្ងន់ធ្ងរឡើងដោយសារដែនកំណត់ផ្នែកវិធីសាស្ត្រ និងតថភាពនៃប្រតិបត្តិការ។ ការស្រាវជ្រាវតែងតែពឹងផ្អែកលើប្រភេទក្រុមគោលដៅទូលំទូលាយដូចជា **"គ្រួសារជនបទ" "គ្រួសារងាយរងគ្រោះ"** ឬ **"សហគមន៍"**។ ខណៈដែលវាមានភាពងាយស្រួលការដាក់ឈ្មោះជារួមបែបនេះ បានបិទបាំងភាពខុសគ្នាពាក់ព័ន្ធនឹងជាតិពន្ធុ ភាសា ស្ថានភាពទេសន្តរប្រវេសន៍ ការកាន់កាប់ដីធ្លី ភាពក្រីក្រ និងការផាត់ចេញពីសង្គម។ អ្នកចូលរួមមួយចំនួនបានទទួលស្គាល់ដែនកំណត់នេះ។ ដូចដែលអ្នកផ្តល់បទសម្ភាសន៍ម្នាក់បានលើកឡើងថា៖

> “ "យើងដឹងថាពាក្យ 'ជនបទ' មិនមានន័យដូចគ្នានៅគ្រប់ទីកន្លែងទេ ប៉ុន្តែយើងមិនសុទ្ធតែមានឧបករណ៍ ឬពេលវេលាដើម្បីបកស្រាយវាឱ្យបានច្បាស់លាស់នោះឡើយ។" គាត់បានបន្ថែមទៀតថា៖ "នៅពេលដែលអ្នកបែកចែកទិន្នន័យជាប្រភេទច្រើនពេក វានឹងកាន់តែស្មុគស្មាញក្នុងការវិភាគ និងពន្យល់ដូច្នេះ គេចូលចិត្តរក្សាទិន្នន័យឱ្យនៅផ្តុំដដែល។" ”

ឧបសគ្គផ្នែកភូមិសាស្ត្រ និងភស្តុភារ រឹតតែជះឥទ្ធិពលលើការអនុវត្តការស្រាវជ្រាវ។ ការចូលរួមជាមួយសហគមន៍ជនជាតិដើមភាគតិច និងសហគមន៍ងាយរងគ្រោះ ជារឿយៗ ត្រូវបានរឹតត្បិតដោយភាពខុសគ្នាផ្នែកភាសា ភាពដាច់ស្រយាល និងពេលវេលា និងថវិកាបន្ថែមដែលត្រូវការចាំបាច់ដើម្បីធ្វើឱ្យការងារចុះមូលដ្ឋានប្រកបដោយបរិយាបន្ន។ ជាទូទៅ សាកលវិទ្យាល័យ និងមជ្ឈមណ្ឌលស្រាវជ្រាវនៅក្រៅរាជធានីភ្នំពេញ មានហេដ្ឋារចនាសម្ព័ន្ធអន់ថយជាង និងមានបុគ្គលិកដែលទទួលបានការបណ្តុះបណ្តាលតិចជាង។ ដូច្នេះហើយទើបក្នុងការបង្កើតទិន្នន័យ គេច្រើនតែងាកទៅរកតំបន់ទីក្រុង។

ទោះបីបញ្ហាប្រឈមទាំងនេះពិតជាបានកើតឡើងក៏ដោយ ប៉ុន្តែបទសម្ភាសន៍បង្ហាញថា ភាពស៊ាំរបស់ស្ថាប័នជាមួយនឹងវិធីសាស្ត្រស្តង់ដារ ក៏ជាចំណែកមួយផងដែរ។ អ្នកចូលរួមម្នាក់បានលើកឡើងថា៖ ***"យើងមាននិន្នាការធ្វើការនៅក្នុងកន្លែងដែលយើងស្គាល់រួចទៅហើយ។ ការចុះទៅតំបន់ដាច់ស្រយាល មានន័យថា យើងត្រូវការពេលវេលា ការបកប្រែ និងការសម្របសម្រួលច្រើនជាងមុន ហើយរឿងនេះមិនសុទ្ធតែទទួលបានការគាំទ្រនោះទេ។"*** អ្នកចូលរួមម្នាក់ទៀតបានគូសបញ្ជាក់ថា៖ ***"ពេលខ្លះ វាងាយស្រួលជាងក្នុងការនិយាយថា វាពិបាកពេក ជាជាងការផ្លាស់ប្តូររបៀបដែលយើងធ្វើការ។"***

---

## ***ចំណុចខ្វះខាតដែលបន្តលេចឡើង និងជាតុផ្សំនៃបរិយាបន្ន***

ទំនោរផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រ នៅតែស្ថិតក្នុងចំណោមធាតុផ្សំនៃបរិយាបន្នសង្គម ដែលទទួលបានការយកចិត្តទុកដាក់តិចបំផុត។ ទោះបីជាបច្ចុប្បន្ន មានការយល់ដឹងកាន់តែច្រើនអំពីបញ្ហា LGBTQIA+ ក៏ដោយ ប៉ុន្តែអ្នកស្រាវជ្រាវច្រើនតែបង្ហាញនូវភាពមិនប្រាកដប្រជាអំពីក្រមសីលធម៌ ការការពារ និងការរក្សាការសម្ងាត់។ ភាពមិនប្រាកដប្រជានេះ ជារឿយៗនាំឱ្យមានការបញ្ចៀសឱ្យផុតតែម្តង។ អ្នកស្រាវជ្រាវម្នាក់បានពន្យល់ថា៖

> “ យើងបារម្ភពីការធ្វើឱ្យមនុស្សប្រឈមនឹងហានិភ័យ ឬបង្កគ្រោះថ្នាក់ ដូច្នេះ ជារឿយៗ យើងមិនដាក់បញ្ចូលសំណួរពាក់ព័ន្ធនឹងទំនោរផ្លូវភេទទេ។ ”

អ្នកស្រាវជ្រាវខ្លះទៀតបានកត់សម្គាល់ពីការគ្មានគោលការណ៍ណែនាំក្នុងស្ថាប័ន។ ***"ប្រសិនបើមានគោលការណ៍ណែនាំផ្នែកក្រមសីលធម៌ច្បាស់លាស់ យើងនឹងមានអារម្មណ៍ជឿជាក់ជាងមុន។ ឥឡូវនេះ វាអាស្រ័យលើការវាយតម្លៃរបស់បុគ្គលម្នាក់ៗប៉ុណ្ណោះ"***។ ហេតុនេះ ទំនោរផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រ នៅតែមិនសូវត្រូវបានគេលើកឡើងនៅក្នុងលទ្ធផលនៃការស្រាវជ្រាវ ហើយវាបានកម្រិតទាំងការយល់ដឹង និងការឆ្លើយតបគោលនយោបាយ។

ដូចដែលអ្នកចូលរួមម្នាក់បានលើកឡើងយ៉ាងខ្លីថា៖ ***"បញ្ហាយេនឌ័រមានក្របខណ្ឌ ឧបករណ៍ និងការបណ្តុះបណ្តាល ចំណែកបរិយាបន្នសង្គម នៅតែជាប្រធានបទមិនច្បាស់លាស់សម្រាប់ពួកយើងភាគច្រើន។"*** បើគ្មានការកសាងសមត្ថភាពចំគោលដៅ ការណែនាំផ្នែកវិធីសាស្ត្រច្បាស់លាស់ជាងមុន និងការរំពឹងទុកច្បាស់លាស់ពីស្ថាប័ននោះទេ ការងារបរិយាបន្នសង្គមនឹងនៅតែដើរយឺតជាងការងារយេនឌ័រ ហើយវានឹងកម្រិតដល់ភាពពាក់ព័ន្ធ ភាពគួរឱ្យជឿទុកចិត្ត និងផលជះរបស់ការស្រាវជ្រាវលើគោលនយោបាយ។

## ៣.២.៦. អន្តរប្រសព្វ៖ ការយល់ដឹងអំពីឧបសគ្គត្រួតគ្នា និងអត្តសញ្ញាណត្រួតគ្នា

### ***ការលើកទឹកចិត្ត និងគណនេយ្យភាពស្ថាប័នមានកម្រិតខ្សោយ***

ឆ្លងកាត់បទសម្ភាសន៍នានា ប្រធានបទដែលលេចឡើងដដែលៗ គឺគ្មានការរំពឹងទុកច្បាស់លាស់ពីស្ថាប័ន ឬម្ចាស់ជំនួយជុំវិញការវិភាគអន្តរប្រសព្វ។ ខណៈដែលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ច្រើនតែត្រូវបានលើកឡើងនៅក្នុងសំណើគម្រោង អន្តរប្រសព្វកម្រត្រូវបានកំណត់ជាលក្ខខណ្ឌតម្រូវវាយតម្លៃ ឬត្រួតពិនិត្យប្រកបដោយអត្ថន័យណាស់។ អ្នកស្រាវជ្រាវជាន់ខ្ពស់ម្នាក់បានលើកឡើងថា៖ ***"ប្រសិនបើម្ចាស់ជំនួយមិនទាមទារ ហើយថ្នាក់ដឹកនាំមិនតម្រូវទេ នោះវានៅត្រឹមតែជាគំនិតល្អមួយ ជាជាងលក្ខខណ្ឌតម្រូវដែលត្រូវអនុវត្ត។"***

បើគ្មានការលើកទឹកចិត្ត យន្តការគណនេយ្យភាព ឬការផ្តល់សញ្ញាពីថ្នាក់ដឹកនាំឱ្យបានច្បាស់លាស់ជាងមុនទេ អន្តរប្រសព្វនៅតែជាជម្រើស និងត្រូវបានអនុវត្តក្នុងកម្រិតមិនស្មើគ្នានៅក្នុងវដ្តនៃការស្រាវជ្រាវទាំងមូល។ នេះឆ្លុះបញ្ចាំងពីលំនាំទូលំទូលាយនៅក្នុងវិស័យស្រាវជ្រាវរបស់កម្ពុជា ដែលការស្រាវជ្រាវជារឿយៗ ត្រូវបានតម្រឹមតម្រង់ដោយគម្រោងរយៈពេលខ្លីដែលទទួលបានមូលនិធិពីខាងក្រៅ ដូច្នេះហើយទើបមិនសូវមានការជំរុញលើកទឹកចិត្តឱ្យវិនិយោគ លើវិធីសាស្ត្រដែលស្មុគស្មាញ និងទាមទារធនធានច្រើនដូចជា ការវិភាគអន្តរប្រសព្វ។

នៅទូទាំងប្រព័ន្ធអេកូឡូស៊ីនៃការស្រាវជ្រាវ អន្តរប្រសព្វត្រូវបានគេទទួលស្គាល់កាន់តែច្រើនឡើងថា មានភាពពាក់ព័ន្ធទៅនឹងការយល់ដឹងអំពីបទពិសោធន៍ជីវិតជាក់ស្តែងនៅកម្ពុជា។ ការផ្លាស់ប្តូរបែបនេះ មួយផ្នែកត្រូវបានជំរុញដោយការបណ្តុះបណ្តាលស្តីពី សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ដែលគាំទ្រដោយកម្មវិធីពន្លកចំណេះដំណាក់កាលទី២ និងមួយផ្នែកទៀតត្រូវបានជំរុញដោយគំនិតផ្តួចផ្តើមដែលទទួលបានមូលនិធិពីម្ចាស់ជំនួយ ដែលលើកទឹកចិត្តអ្នកស្រាវជ្រាវឱ្យសម្លឹងមើលហួសពីបញ្ហាយេនឌ័រតែមួយមុខ។ វិទ្យាស្ថានមួយចំនួនបានចាប់ផ្តើមទទួលស្គាល់ថាតើយេនឌ័រមានអន្តរកម្មដូចម្តេចជាមួយពិការភាព ជាតិពន្ធុ អាយុ ទំនោរផ្លូវភេទ និងភូមិសាស្ត្រ ដើម្បីជះឥទ្ធិពលផ្សេងគ្នាហានិភ័យលទ្ធភាពទទួលបាន និងលទ្ធផល។ ចំណុចនេះអាចមើលឃើញច្បាស់បំផុតនៅក្នុងវិស័យដូចជា ការប្រែប្រួលអាកាសធាតុ និងជីវភាពរស់នៅជនបទ ដែលភាពងាយរងគ្រោះខុសៗគ្នាពិបាកនឹងត្រូវមើលរំលង។ ទោះជាយ៉ាងណា ខណៈដែលភាសានៃអន្តរប្រសព្វកាន់តែមានភាពសុំា ការបកស្រាយទស្សនទាននេះ សម្រាប់ការអនុវត្តការស្រាវជ្រាវ នៅតែមានកម្រិតមិនស្មើគ្នា និងមានតិចតួចនៅឡើយ។

---

## ឧបសគ្គក្នុងការរៀបចំការស្រាវជ្រាវ និងវិធីសាស្ត្រស្រាវជ្រាវ

កម្សោយក្នុងការដាក់បញ្ចូលអន្តរប្រសព្វគឺអាចមើលឃើញច្បាស់បំផុតនៅកម្រិតវិធីសាស្ត្រ។ មានការសិក្សាតិចតួចណាស់ ដែលរួមបញ្ចូលយុទ្ធសាស្ត្រជ្រើសរើសសំណាកបែបអន្តរប្រសព្វ ឧបករណ៍ប្រមូលទិន្នន័យដែលបានកែសម្រួល ឬផែនការវិភាគច្បាស់លាស់ដែលគិតគូរពីអត្តសញ្ញាណត្រួតគ្នា។ ទន្ទឹមនឹងនេះ វិធីសាស្ត្រផ្សព្វផ្សាយ ហាក់ដូចជាសន្មតថាក្រុមគោលដៅមានលក្ខណៈស្រដៀងគ្នា ដោយមើលរំលងភាពខុសគ្នាផ្នែកភាសា អក្ខរកម្ម ការបង្កភាពងាយស្រួល និងលទ្ធភាពប្រើប្រាស់បច្ចេកវិទ្យាឌីជីថល។

អ្នកស្រាវជ្រាវផ្នែកអភិវឌ្ឍន៍ជនបទម្នាក់ បានរៀបរាប់អំពីបញ្ហាប្រឈមក្នុងការជំរុញការចូលរួមរបស់ស្ត្រីជនជាតិដើមភាគតិចឱ្យចូលរួម៖

> “ឧបសគ្គផ្នែកភាសា កម្រិតវប្បធម៌ បទដ្ឋានវប្បធម៌ ហាក់ស្មុគស្មាញខ្លាំងណាស់ ដូច្នេះ ពេលខ្លះយើងបញ្ចៀសការដាក់បញ្ចូលចំណុចទាំងនេះដោយផ្ទាល់តែម្តង។”

មានការលើកឡើងពីលំនាំស្រដៀងគ្នានេះទាក់ទងនឹងបរិយាបន្នពិការភាពផងដែរ។ ការគ្មានអ្នកបកប្រែភាសាសញ្ញា ឬទម្រង់ឯកសារដែលបង្កភាពងាយស្រួល ជារឿយៗត្រូវបានលើកឡើងថាជាហេតុផលនៃការផាត់ចេញជនមានពិការភាពពីការពិគ្រោះយោបល់ ឬការពិភាក្សាគោលនយោបាយ ជាជាងចាត់ទុកជាចំណុចខ្វះខាតដែលទាមទារឱ្យមានការកែសម្រួល។

ការសម្រេចចិត្តទាំងនេះ ទោះត្រូវបានចាត់ទុកថាជាការអនុវត្តជាក់ស្តែងក៏ដោយ ប៉ុន្តែវាបណ្តាលឱ្យមានការផាត់ចេញជាប្រព័ន្ធនូវអ្នកដែលរងផលប៉ះពាល់ខ្លាំងបំផុតដោយសេចក្តីសម្រេចគោលនយោបាយ។ ចំណុចនេះបានកម្រិត សមត្ថភាពនៃការស្រាវជ្រាវក្នុងការច្បាមយករបៀបដែលទម្រង់នៃការផាត់ចេញត្រួតគ្នា ជះឥទ្ធិពលលើបទពិសោធន៍ជីវិតជាក់ស្តែងដូច្នេះ វាបានកាត់បន្ថយភាពស៊ីជម្រៅ និងភាពពាក់ព័ន្ធនៃទិន្នន័យ ដែលគេប្រើប្រាស់នៅក្នុងដំណើរការគោលនយោបាយ។

## ការយល់ដឹងច្រើនជាងមុន ប៉ុន្តែការអនុវត្តមានកម្រិត

ជាទូទៅ អ្នកស្រាវជ្រាវ និងអ្នកគ្រប់គ្រងការស្រាវជ្រាវ បង្ហាញការយល់ដឹងអំពីទស្សនទាន "អន្តរប្រសព្វ" ដោយជារឿយៗ ពួកគេពណ៌នាថា វា "មានសារៈសំខាន់" ឬ "ចាំបាច់" សម្រាប់ការស្រាវជ្រាវប្រកបដោយបរិយាបន្ន។ ក៏ប៉ុន្តែសម្រាប់វិទ្យាស្ថានភាគច្រើន វានៅតែជាគំនិតថ្មី និងអរូបី ជាជាងជាអភិក្រមប្រតិបត្តិការ។

ឆ្លងកាត់ការពិភាក្សា អ្នកស្រាវជ្រាវដែលចូលរួមក្នុងការសិក្សានេះបានកត់សម្គាល់ថា៖ ***"យើងយល់ថា យេនឌ័រមិនមែនជាកត្តាតែមួយគត់ទៀតទេ។ ប៉ុន្តែនៅពេលឈានដល់ការរៀបចំការសិក្សាជាក់ស្តែង យើងពិតជាមិនដឹងពីរបៀបឆ្លុះបញ្ចាំងពីបញ្ហានោះទេ។"*** ក្នុងការអនុវត្តជាក់ស្តែង អន្តរប្រសព្វច្រើនតែត្រូវបានបន្ថយមកត្រឹមតែជាការដាក់បញ្ចូលអថេរប្រជាសាស្ត្រជាច្រើន ជាជាងការវិភាគអំពីរបៀបដែលអត្តសញ្ញាណមានអន្តរកម្មជាមួយគ្នា ដើម្បីកំណត់អំណាច ការផាត់ចេញ ឬឱកាស។ ចំណុចនេះបានរឹតត្បិតគុណតម្លៃបែបពន្យល់របស់ទស្សនទាននេះ និងអាចបង្កើតឡើងវិញនូវបរិយាបន្នត្រឹមតែជានិមិត្តរូប ដោយគ្មានការយល់ដឹងស៊ីជម្រៅ។

---

## ភាពមិនប្រាកដប្រជាផ្នែកក្រមសីលធម៌ និងការចៀសវាងក្រុមដែលត្រូវបានផាត់ចេញ

អ្នកផ្តល់ព័ត៌មានជាច្រើនបានគូសបញ្ជាក់ពីភាពមិន ស្រណុកចិត្ត និងភាពមិនប្រាកដប្រជាជុំវិញការចូលរួមជាមួយសហគមន៍ LGBTQIA+ ជនជាតិភាគតិច និងជនមានពិការភាព។ ខណៈដែលការចូលរួមបានកើនឡើងបន្តិចម្តងៗ អ្នកស្រាវជ្រាវជាច្រើននៅខ្វះទំនុកចិត្តផ្នែកក្រមសីលធម៌ និងការណែនាំជាក់ស្តែង។
អ្នកចូលរួមបានលើកឡើងថា

> “ យើងបារម្ភពីការបង្កគ្រោះថ្នាក់ ឬការសួរសំណួរខុស ប៉ុន្តែដោយសារយើងមិនដឹងពីរបៀបធ្វើវាឱ្យបានត្រឹមត្រូវ ទីបំផុតយើងក៏មិនធ្វើវាតែម្តង។ ”

លំនាំនេះបង្ហាញថា ការផាត់ចេញមិនមែនដោយសារតែភាពមិនអាចទៅរួចផ្នែកបច្ចេកទេសប៉ុន្មានទេ ប៉ុន្តែភាគច្រើនគឺដោយសារតែការបណ្តុះបណ្តាលមិនគ្រប់គ្រាន់ ការណែនាំមិនច្បាស់លាស់នៅក្នុងស្ថាប័ន និងក្របខណ្ឌក្រមសីលធម៌មានកម្រិត ដែលត្រូវបានរៀបចំឡើងសម្រាប់ការស្រាវជ្រាវអន្តរប្រសព្វ។

ក្នុងករណីខ្លះ ឧបសគ្គក៏ពាក់ព័ន្ធនឹងធនធាន ឬជំនាញមានកម្រិតផងដែរ។ ដូចដែលអ្នកចូលរួមម្នាក់បានកត់សម្គាល់ថា "យើងមិនមានធនធាន ឬជំនាញទេ ដូច្នេះ វាមានសុវត្ថិភាពជាងប្រសិនមិនដាក់បញ្ចូលពួកគេ។" ចំណុចនេះជំរុញឱ្យមានការបញ្ចៀស ជាជាងការកែសម្រួលវិធីសាស្ត្រស្រាវជ្រាវ។

ជារួមវិស័យស្រាវជ្រាវនៅកម្ពុជា បង្ហាញពីការចាប់អារម្មណ៍យ៉ាងខ្លាំង ប៉ុន្តែស្ថាប័នមិនបានត្រៀមខ្លួនឱ្យបានគ្រប់គ្រាន់ ក្នុងការដាក់បញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ប្រកបដោយអត្ថន័យនោះទេ។ យេនឌ័រត្រូវបានគេទទួលស្គាល់ បរិយាបន្នពិការភាពមានសភាពដាច់ដោយដុំៗ ចំណែកឯបរិយាបន្នសង្គម និងអន្តរប្រសព្វ នៅតែមិនទាន់មានភាពស៊ីសង្វាក់គ្នា និងមិនសូវមានការអភិវឌ្ឍគ្រាប់គ្រាន់នៅឡើយ។ វឌ្ឍនភាពភាគច្រើនកើតមានក្នុងការស្រាវជ្រាវដែលជំរុញដោយម្ចាស់ជំនួយ ជាជាងក្របខណ្ឌរបស់អង្គការ-ស្ថាប័នផ្ទាល់។ ក្រោមការគាំទ្រប្រកបដោយនិរន្តរភាព ជាពិសេសការគាំទ្រពីកម្មវិធីពន្លកចំណេះដំណាក់កាលទី២ ស្ថាប័នស្រាវជ្រាវអាចឈានហួសពីការយល់ដឹងផ្នែកទស្សនទាន និងកសាងជំនាញជាក់ស្តែង ការលើកទឹកចិត្តស្ថាប័ន និងរចនាសម្ព័ន្ធធនធាន ដែលត្រូវការចាំបាច់ដើម្បីបង្កើតទិន្នន័យដែលកាន់តែប្រកបដោយបរិយាបន្ន ភាពពាក់ព័ន្ធ និងគុណភាពខ្ពស់។

## ៣.២.៧. បញ្ហាប្រឈម៖ ការប្តេជ្ញាចិត្ត ជាមួយនឹងតថភាពជាក់ស្តែងដ៏លំបាក និងអត្តសញ្ញាណត្រួតគ្នា

នៅក្នុងប្រព័ន្ធអេកូឡូស៊ីនៃចំណេះដឹង និងគោលនយោបាយរបស់កម្ពុជា មានការប្តេជ្ញាចិត្តកាន់តែច្រើន និងច្បាស់លាស់ចំពោះការជំរុញសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម។ ទោះជាយ៉ាងណា ការប្រែក្លាយចេតនានេះទៅជាការអនុវត្តឱ្យបានជាប់លាប់ នៅតែជាការលំបាក។ បញ្ហាប្រឈមមិនត្រឹមតែមានក្នុងផ្នែកបច្ចេកទេសប៉ុណ្ណោះទេ ប៉ុន្តែក៏ពាក់ព័ន្ធនឹងរចនាសម្ព័ន្ធ ស្ថាប័ន និងនយោបាយផងដែរ ហើយវាបានកំណត់ទាំងរបៀបបង្កើតការស្រាវជ្រាវ និងរបៀបដែលទិន្នន័យមានផលជះលើគោលនយោបាយ។

### *ឧបសគ្គរាំងឥទ្ធិពលរបស់សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម នៅក្នុងដំណើរការគោលនយោបាយ*

អង្គការសង្គមស៊ីវិល ដើរតួនាទីយ៉ាងសំខាន់នៅក្នុងដំណើរការគោលនយោបាយស្តីពីសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម នៅកម្ពុជា ដោយធ្វើប្រតិបត្តិការនៅចំណុចប្រសព្វរវាងបទពិសោធន៍ជីវិតជាក់ស្តែង និងការធ្វើសេចក្តីសម្រេចជាផ្លូវការ។ ទោះជាយ៉ាងណា ឥទ្ធិពលរបស់អង្គការទាំងនេះមិនមានលក្ខណៈត្រង់ទៅមុខ និងមិនមានការធានាឡើយ។ ខណៈដែលអង្គការសង្គមស៊ីវិលត្រូវបានអញ្ជើញជាប្រចាំឱ្យចូលរួមក្នុងការពិគ្រោះយោបល់ លទ្ធភាពចូលរួមមិនសុទ្ធតែមានន័យថាជាការមានឥទ្ធិពលលើលទ្ធផលគោលនយោបាយចុងក្រោយនោះទេ។ ផលជះមិនសូវអាស្រ័យលើការដាក់បញ្ចូលជាផ្លូវការនោះទេ ប៉ុន្តែពឹងផ្អែកខ្លាំងលើទំនាក់ទំនង ការកំណត់គោលជំហរជាយុទ្ធសាស្ត្រ និងសមត្ថភាពក្នុងការបំប្លែងតថភាព របស់សហគមន៍ ទៅជាទិន្នន័យដែលពាក់ព័ន្ធ នឹងគោលនយោបាយ។

បទសម្ភាសន៍ជាមួយសមាជិកក្រុមអ្នកជំនាញផ្នែកសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ចង្អុលបង្ហាញពីវឌ្ឍនភាពពិតប្រាកដ ប៉ុន្តែមានកម្រិតមិនស្មើគ្នា។ អង្គការជាច្រើនបានពណ៌នាអំពីស្ថានភាព ដែលធាតុចូលសំខាន់ៗរបស់អង្គការសង្គមស៊ីវិលត្រូវបានឆ្លុះបញ្ចាំងនៅក្នុងសេចក្តីព្រាងគោលនយោបាយដំបូង ប៉ុន្តែធាតុចូលទាំងនោះត្រូវបានកាត់បន្ថយ ឬដកចេញនៅដំណាក់កាលក្រោយៗ។ ចំណុចនេះច្រើនតែកើតឡើងក្នុងអំឡុងពេលចរចានយោបាយ ការផ្លាស់ប្តូរថ្នាក់ដឹកនាំ ភាពតានតឹងរវាងតួអង្គផ្នែកបច្ចេកទេស និងតួអង្គនយោបាយ ឬការកែសម្រួលនៅដំណាក់កាលចុងក្រោយ ដែលធ្វើឡើងដោយគ្មានការពិគ្រោះយោបល់បន្ថែម។ លំនាំទាំងនេះធ្វើឱ្យបាត់បង់ទំនុកចិត្តលើដំណើរការចូលរួម និងរំលេចឱ្យឃើញគម្លាតដែលនៅតែបន្តកើតមាន រវាងការពិគ្រោះយោបល់ និងសិទ្ធិអំណាចធ្វើសេចក្តីសម្រេច។

ឥទ្ធិពលមានកម្រិតរបស់សង្គមស៊ីវិលលើលទ្ធផលគោលនយោបាយស្តីពី សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម កើតចេញពីឧបសគ្គផ្នែករចនាសម្ព័ន្ធ និងឧបសគ្គផ្នែកនយោបាយ។ ជាទូទៅ ការទទួលខុសត្រូវលើសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ត្រូវបានផ្ទេរទៅឱ្យអង្គភាពបច្ចេកទេស ឬមន្ត្រីបង្គោលដែលមិនសូវមានសិទ្ធិអំណាច ខណៈដែលការសម្រេចចិត្តចុងក្រោយស្ថិតលើតួអង្គនយោបាយ ដែលសម្រាប់ពួកគេ ដែលបរិយាបន្នជារឿយៗគឺជារឿងដែលអាចចរចាបាន។ ដូច្នេះហើយទើបការគាំទ្រពីថ្នាក់ដឹកនាំមិនមានជាប់លាប់ និងពឹងផ្អែកលើបុគ្គលឆ្នើមម្នាក់ៗ ជាជាងការប្តេជ្ញាចិត្តដែលចាក់ឫសជ្រៅក្នុងស្ថាប័ន ដែលធ្វើឱ្យវឌ្ឍនភាពងាយនឹងរង្គោះរង្គើ ហើយងាយដើរថយក្រោយ។

យើងក៏មើលឃើញភស្តុតាងនៃការសម្រាំងយកទស្សនទានសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គមផងដែរ។ ទោះបីជាក្របខណ្ឌកម្រិតសកលទទួលបានគាំទ្រជាផ្លូវការក៏ដោយ ប៉ុន្តែជារឿយៗ ក្របខណ្ឌទាំងនេះត្រូវបានចាត់ទុកថាជាគំនិតផ្តួចផ្តើមពីខាងក្រៅ ឬមិនស្របនឹងអាទិភាពនយោបាយក្នុងស្រុក ដែលនាំឱ្យមានការសម្រាំងយក ឬកាត់បន្ថយសារៈសំខាន់ ក្នុងអំឡុងពេលចរចាគោលនយោបាយ។ ដំណើរការពិគ្រោះយោបល់រឹតតែធ្វើឱ្យឥទ្ធិពលចុះខ្សោយ៖ ជារឿយៗ ការពិគ្រោះយោបល់ធ្វើឡើងយ៉ាងប្រញាប់ប្រញាល់ ខ្វះធនធាន និងរៀបចំឡើងក្នុងទម្រង់មួយដែលផ្តល់អត្ថប្រយោជន៍ដល់តួអង្គ ដែលមានបណ្តាញទំនាក់ទំនងល្អ ច្រើនជាងអង្គការថ្នាក់មូលដ្ឋាន

សហគមន៍ជនជាតិដើមភាគតិច និងជនមានពិការភាព។ ឧបសគ្គផ្នែកភាសា លក្ខខណ្ឌតម្រូវផ្នែកការិយាធិបតេយ្យ និងការទទួលស្គាល់មានកម្រិតលើចំណេះដឹងតាមសហគមន៍ និងចំណេះដឹងជនជាតិដើមភាគតិច បានជំរុញឱ្យមានការផាត់ចេញកាន់តែខ្លាំង ដែលធ្វើឱ្យថយចុះភាពពាក់ព័ន្ធគ្នារវាងបទពិសោធន៍ជីវិតជាក់ស្តែង និងការសម្រេចចិត្តលើគោលនយោបាយ។ ក្នុងបរិបទនេះ សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ច្រើនតែត្រូវបានគេចាត់ទុកថាជារឿងដែលអាចបត់បែនបាន ជាជាងជាមូលដ្ឋានគ្រឹះ។ ការយល់បែបនេះបានរឹតត្បិតទំហំនៃការធ្វើស្ថាប័នូបនីយកម្មអភិក្រមបែបបរិយាបន្ន នៅក្នុងដំណើរការគោលនយោបាយ។

បទពិសោធន៍ពីកម្មវិធីពន្លកចំណេះបង្ហាញថា ខណៈដែលយន្តការនានា ដូចជា មូលនិធិគាំទ្រការចូលរួមក្នុងគោលនយោបាយ បានបង្កើតចំណុចចូលរួមផ្ទាល់កាន់តែច្រើន សម្រាប់ការចូលរួមផ្អែកលើទិន្នន័យជាមួយភាគីរដ្ឋាភិបាល ឥទ្ធិពលយូរអង្វែង នៅតែពឹងផ្អែកលើពេលវេលា ទំនាក់ទំនង និងការតម្រឹមតាមអាទិភាពរដ្ឋាភិបាល។ នេះគូសបញ្ជាក់ថា ការកែលម្អលទ្ធផលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម មិនត្រឹមតែទាមទារឱ្យមានទិន្នន័យល្អប្រសើរជាងមុនប៉ុណ្ណោះទេ ប៉ុន្តែក៏ទាមទារឱ្យមានការយកចិត្តទុកដាក់ខ្លាំងជាងមុនលើរបៀបដែលដំណើរការគោលនយោបាយ ស្តែងឡើងនៅក្នុងការអនុវត្តជាក់ស្តែងផងដែរ។

## ឧបសគ្គរារាំងការដាក់បញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ទៅក្នុងការស្រាវជ្រាវ

នៅក្នុងប្រព័ន្ធអេកូឡូស៊ីនៃចំណេះដឹង និងគោលនយោបាយរបស់កម្ពុជា ការដាក់បញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម នៅតែមានកម្រិតមិនស្មើគ្នា និងភាគច្រើនពឹងផ្អែកលើលក្ខខណ្ឌតម្រូវរបស់គម្រោង ជាជាងស្តង់ដារស្ថាប័ន។ របៀបវារៈស្រាវជ្រាវ នៅតែត្រូវបានកំណត់ជាចម្បងដោយគម្រោងរយៈពេលខ្លីដែលទទួលបានមូលនិធិពីខាងក្រៅ ដែលផ្តោតអាទិភាពលើការឆ្លើយតប ច្រើនជាងនិរន្តរភាព។ ក្នុងលក្ខខណ្ឌទាំងនេះ សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ច្រើនតែត្រូវបានគេចាត់ទុកថាជាលក្ខខណ្ឌតម្រូវរបស់គម្រោង ជាជាងជាធាតុផ្សំស្នូលសម្រាប់គុណភាពនៃការស្រាវជ្រាវ។ មានអង្គការ-ស្ថាប័នតិចតួចណាស់ ដែលមានគោលនយោបាយផ្ទៃក្នុង ការលើកទឹកចិត្ត ឬយន្តការគណនេយ្យភាព ដែលតម្រូវឱ្យមានការដាក់បញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ជាប្រព័ន្ធ។ ចំណុចនេះបណ្តាលឱ្យមានភាពខុសគ្នាយ៉ាងខ្លាំងនៅក្នុងការអនុវត្តជាក់ស្តែង។ សូម្បីតែនៅកន្លែងដែលមានចំណាប់អារម្មណ៍ខ្លាំងលើសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ក៏ការយកទៅអនុវត្តជាក់ស្តែងនៅមានកម្រិតនៅឡើយ។ ជាទូទៅ អ្នកស្រាវជ្រាវបង្ហាញការយល់ដឹងគ្រប់គ្រាន់អំពីយេនឌ័រ ប៉ុន្តែធាតុផ្សំផ្សេងទៀតដូចជា ពិការភាព ជាតិពន្ធុ ទំនោរផ្លូវភេទ និងអន្តរប្រសព្វ មិនសូវត្រូវបានគេយល់ដឹង និងយកទៅអនុវត្តឱ្យបានខ្ជាប់ខ្ជួននោះទេ។ ឆ្លងកាត់បទសម្ភាសន៍នានា លំនាំរួមមួយបានលេចឡើង គឺការយល់ដឹងផ្នែកទស្សនទាន មានភាពជឿនលឿនជាងសមត្ថភាពផ្នែកវិធីសាស្ត្រ។ បរិយាបន្នច្រើនតែត្រូវបានគេលើកមកពិចារណានៅដំណាក់កាលចុងក្រោយនៃដំណើរការស្រាវជ្រាវ ហើយនេះបានកម្រិតឥទ្ធិពលរបស់បរិយាបន្នទៅលើការរៀបចំការសិក្សា ការប្រមូលទិន្នន័យ និងការវិភាគ។ ដូច្នេះហើយទើបសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ច្រើនតែត្រូវបានឆ្លុះបញ្ចាំងនៅក្នុងទិន្នន័យបែបពណ៌នា ជាជាងជួយតម្រឹមតម្រង់របកគំហើញសំខាន់ៗ ឬអនុសាសន៍គោលនយោបាយ។

ឧបសគ្គរារាំងការចូលរួម កាន់តែរឹតត្បិតដល់បរិយាបន្ន។ អង្គការ-ស្ថាប័ន ដូចជា វេទិកាអនាគត និងមជ្ឈមណ្ឌលខេមរសិក្សា បានរាយការណ៍ថាមានជនមានពិការភាពតិចតួច ដែលបានដាក់ពាក្យចូលរួមក្នុងកម្មវិធីអាហារូបករណ៍ និងស្រាវជ្រាវ និងបានលើកឡើងពីបញ្ហាប្រឈមទាក់ទងនឹងការបន្តចូលរួម និងការបញ្ចប់ការសិក្សា។ លំនាំទាំងនេះឆ្លុះបញ្ចាំងពីឧបសគ្គជាប្រព័ន្ធកាន់តែទូលំទូលាយ រួមទាំងវិសមភាពក្នុងការទទួលបានការអប់រំ ការទទួលបានឱកាសតិចតួចក្នុងអាជីពស្រាវជ្រាវ និងបរិយាកាសដែលមិនត្រូវបានរៀបចំឡើង ដើម្បីគាំទ្រដល់តម្រូវការចម្រុះ។ ចំណុចនេះធ្វើឱ្យជនមានពិការភាព និងក្រុមងាយរងគ្រោះផ្សេងទៀត មិនសូវចូលរួមក្នុងសហគមន៍ស្រាវជ្រាវ ដែលជះឥទ្ធិពលលើថា តើទស្សនៈរបស់នរណាខ្លះដែលត្រូវបានឆ្លុះបញ្ចាំងក្នុងការបង្កើតទិន្នន័យ។

ឧបសគ្គផ្នែកប្រតិបត្តិការ ក៏ដើរតួនាទីយ៉ាងសំខាន់ផងដែរ។ ការស្រាវជ្រាវប្រកបដោយបរិយាបន្ន ទាមទារពេលវេលា ធនធាន និងការរៀបចំផែនការបន្ថែម រួមទាំងការប្រើប្រាស់ឧបករណ៍ដែលជួយសម្រួល ការបកប្រែភាសាសញ្ញា ទម្រង់ឯកសារដែលបង្កភាពងាយស្រួល និងដំណើរការចូលរួមដែលផ្ដល់ពេលវេលាយូរ។ ទោះជាយ៉ាងណា វិធានការទាំងនេះកម្រត្រូវបានបញ្ចូលទៅក្នុងការរៀបចំ ឬថវិកាស្រាវជ្រាវណាស់ ហើយជារឿយៗ ត្រូវបានគេចាត់ទុកថាជាផ្នែកបន្ថែមដែលមានក៏បាន អត់ក៏បាន។ ដូចដែលដៃគូម្នាក់បានកត់សម្គាល់ថា

> “ការដាក់បញ្ចូលជនមានពិការភាព មានន័យថា យើងត្រូវការពេលវេលាបន្ថែម អ្នកបកប្រែ ការធ្វើដំណើរ និងថវិកា ហើយកិច្ចការទាំងនេះកម្រត្រូវបានរៀបចំផែនការទុកណាស់។”

ដូចដែលបានពិភាក្សានៅក្នុងផ្នែកមុនៗ ឧបសគ្គទាំងនេះរួមចំណែកដល់ការផាត់ចេញជនមានពិការភាពពីការពិគ្រោះយោបល់ ដំណើរការផ្ទៀងផ្ទាត់ និងសកម្មភាពផ្សព្វផ្សាយ សូម្បីតែនៅពេលដែលលទ្ធផលពីការស្រាវជ្រាវពាក់ព័ន្ធដោយផ្ទាល់នឹងពួកគេក៏ដោយ។

បញ្ហាប្រឈមទាំងនេះ កាន់តែស្មុគស្មាញដោយសារគម្លាតក្នុងប្រព័ន្ធទិន្នន័យពាក់ព័ន្ធនឹងពិការភាព និងប្រព័ន្ធទិន្នន័យដែលបំបែកជាប្រភេទ។ ទិន្នន័យស្ដីពីជនមានពិការភាពនៅមានកម្រិត មិនពេញលេញ និងជារឿយៗ មិនអាចចូលមើលបានជាសាធារណៈ។ ប្រភពទិន្នន័យដែលមានស្រាប់ ដូចជា ជំរឿនថ្នាក់ជាតិ មូលដ្ឋានទិន្នន័យអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងប្រព័ន្ធរដ្ឋបាល មិនមានភាពស៊ីសង្វាក់គ្នា និងជារឿយៗប្រើប្រាស់និយមន័យ ឬវិធីសាស្ត្រវាស់វែងខុសៗគ្នា។ ទិន្នន័យកម្រត្រូវបានបំបែកហួសពីប្រភេទមូលដ្ឋានណាស់ និងខ្វះព័ត៌មានលម្អិតស្ដីពីពិការភាព ទីតាំងភូមិសាស្ត្រ និងស្ថានភាពសេដ្ឋកិច្ចសង្គម។ ចំណុចនេះធ្វើឱ្យអ្នកស្រាវជ្រាវជួបការលំបាកក្នុងការកំណត់អត្តសញ្ញាណអ្នកចូលរួម ការរៀបចំវិធីសាស្ត្រប្រកបដោយបរិយាបន្ន ឬការអនុវត្តការវិភាគឱ្យបានគ្រប់ជ្រុងជ្រោយ ដែលរឹតតែធ្វើឱ្យមានការលើកឡើងតិចតួចអំពីពិការភាពនៅក្នុងទិន្នន័យស្រាវជ្រាវ និងគោលនយោបាយ។

## ៣.២.៨. អនុសាសន៍៖ ទស្សនៈរបស់ស្ថាប័នស្រាវជ្រាវចំពោះការគាំទ្រដល់ការដាក់បញ្ចូល សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម

លទ្ធផលបង្ហាញថា ការដាក់បញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ទៅក្នុងវិស័យស្រាវជ្រាវរបស់កម្ពុជា ពឹងផ្អែកលើការគាំទ្រជាក់ស្ដែង និងការមានធនធានគ្រប់គ្រាន់ មិនមែនគ្រាន់តែជាការប្ដេជ្ញាចិត្តនោះទេ។ អ្នកស្រាវជ្រាវ និងអ្នកគ្រប់គ្រងការស្រាវជ្រាវតែងតែសង្កត់ធ្ងន់ថា បរិយាបន្នអាចក្លាយជាការពិតទៅបាន លុះត្រាតែវាត្រូវបានគាំទ្រដោយការណែនាំច្បាស់លាស់ មូលនិធិដែលងាយស្រួលទទួលបាន ការលើកទឹកចិត្តពីស្ថាប័ន និងការគាំទ្រផ្ទាល់។ ក៏ប៉ុន្តែនៅពេលដែលក្របខណ្ឌសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គមពេញលេញត្រូវបានយកទៅអនុវត្ត វាស្ដែងឱ្យឃើញច្បាស់ថា ការដាក់បញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ប្រកបដោយអត្ថន័យ គឺលើសពីអ្វីដែលកម្មវិធីពន្លកចំណេះដំណាក់កាលទី២ អាចធ្វើបានតែម្នាក់ឯង។ ឧបសគ្គជាច្រើនមានលក្ខណៈជាប្រព័ន្ធ និងស្ថិតនៅក្រៅវិសាលភាពផ្ទាល់របស់ស្ថាប័នស្រាវជ្រាវ ជាពិសេសនៅពេលនិយាយដល់ភាពអាចរកបាន និងការត្រៀមខ្លួនរួចរាល់របស់និស្សិតបញ្ចប់ការសិក្សា ដែលមកពីក្រុមដែលត្រូវបានផាត់ចេញ។

ទោះបីជាមានឧបសគ្គជាប្រព័ន្ធក៏ដោយ ប៉ុន្តែស្ថាប័នស្រាវជ្រាវនៅអាចចាត់វិធានការប្រកបដោយអត្ថន័យនៅកម្រិតកម្មវិធី និងកម្រិតស្ថាប័ន។ សកម្មភាពទាំងនេះមិនតម្រូវឱ្យរង់ចាំកំណែទម្រង់ថ្នាក់ជាតិទេ ប៉ុន្តែតម្រូវឱ្យមានការរៀបចំផែនការ ការវិនិយោគ និងភាពជាដៃគូច្បាស់លាស់។

## ចំណុចចាប់ផ្តើមដែលប្រាកដប្រជា និងមានឥទ្ធិពលបំផុត រួមមាន៖

### ១ ការជំរុញសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ឱ្យហួសពីការអនុវត្តត្រឹមតែបំពេញកាតព្វកិច្ចតាមគម្រោង

ការដាក់បញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ចាំបាច់ត្រូវផ្លាស់ប្តូរពីលក្ខខណ្ឌតម្រូវរបស់គម្រោង ទៅជាស្តង់ដារស្នូលនៃគុណភាពការស្រាវជ្រាវ។ ស្ថាប័នស្រាវជ្រាវគួរតែបញ្ជ្រាបសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គមទៅក្នុងវដ្តស្រាវជ្រាវទាំងមូល ចាប់ពីការកំណត់របៀបវារៈ និងការរៀបចំរហូតដល់ការវិភាគ និងការផ្សព្វផ្សាយ។ ការណ៍នេះទាមទារឱ្យមានការឈានហួស ពីវិធីសាស្ត្របំពេញបញ្ជីត្រួតពិនិត្យ និងធានាថា បរិយាបន្នជះឥទ្ធិពលលើសំណួរស្រាវជ្រាវ វិធីសាស្ត្រ និងលទ្ធផលប្រកបដោយអត្ថន័យ។ ម្ចាស់ជំនួយ និងអ្នកដឹកនាំការស្រាវជ្រាវ អាចគាំទ្រដល់ការផ្លាស់ប្តូរនេះ ដោយវាយតម្លៃមិនត្រឹមតែថាតើ សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ត្រូវបានដាក់បញ្ចូល ឬអត់នោះទេ ប៉ុន្តែក៏វាយតម្លៃផងដែរថាតើវាជះឥទ្ធិពលដូចម្តេចដល់លទ្ធផលស្រាវជ្រាវ និងភាពពាក់ព័ន្ធនៃគោលនយោបាយ។

### ២ ការពង្រីកការអនុវត្ត សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ជាក់ស្តែងនៅក្នុងវិធីសាស្ត្រស្រាវជ្រាវ

ខណៈដែលការយល់ដឹងផ្នែកទស្សនទានអំពី សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម មានភាពប្រសើរឡើង អ្នកស្រាវជ្រាវជាច្រើននៅខ្វះឧបករណ៍ និងទំនុកចិត្តក្នុងការអនុវត្តជាក់ស្តែង។ ចាំបាច់ត្រូវមានការគាំទ្រចំគោលដៅដើម្បីពង្រឹងការរៀបចំការស្រាវជ្រាវប្រកបដោយបរិយាបន្ន រួមទាំងយុទ្ធសាស្ត្រជ្រើសរើសសំណាក វិធីសាស្ត្រប្រមូលទិន្នន័យ និងការវិភាគ ដែលឆ្លុះបញ្ចាំងពីបទពិសោធន៍ចម្រុះ និងត្រួតគ្នា។ ការណែនាំជាក់ស្តែង ការបង្វឹកបង្ហាត់ និងឧទាហរណ៍នៃវិធីសាស្ត្រអនុវត្តន៍ជាក់ស្តែង អាចជួយអ្នកស្រាវជ្រាវផ្លាស់ប្តូរពីការយល់ដឹងទៅជាការអនុវត្ត ជាពិសេសនៅក្នុងវិស័យដូចជា បរិយាបន្នពិការភាព និងអន្តរប្រសព្វ។

### ៣ ការពង្រឹងការចូលរួម និងគន្លងឆ្ពោះទៅរកការស្រាវជ្រាវ

ការពង្រីកសមាសភាពអ្នកចូលរួមក្នុងការស្រាវជ្រាវ គឺជារឿងចាំបាច់សម្រាប់ការបង្កើនបរិយាបន្ននៃទិន្នន័យ។ ស្ថាប័នស្រាវជ្រាវអាចពង្រីកការចូលរួម ដោយបង្កើតតួនាទីនៅទូទាំងដំណើរការស្រាវជ្រាវ រួមមានការប្រមូលទិន្នន័យ ការសរសេរកូដ ការធ្វើប្រតិចារិក ការប្រាស្រ័យទាក់ទង និងកិច្ចការរដ្ឋបាល។

- ស្ថាប័នស្រាវជ្រាវអាចចាប់ដៃគូសហការជាមួយអង្គការតំណាងជនមានពិការភាព សាកលវិទ្យាល័យ និងស្ថាប័នផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីអភិវឌ្ឍកម្មវិធីកម្មសិក្សា និងមុខតំណែងកម្រិតចាប់ផ្តើមដំបូង ដែលកសាងជំនាញគាំទ្រដល់ការស្រាវជ្រាវ ជំនាញគ្រប់គ្រងទិន្នន័យ និងជំនាញប្រាស្រ័យទាក់ទង។ គន្លងបែបនេះអាចលុបបំបាត់គម្លាតរវាងគុណវុឌ្ឍិផ្លូវការដែលនៅមានកម្រិត និងសមត្ថភាពជាក់ស្តែង។ ដៃគូម្នាក់បានកត់សម្គាល់ថា៖ "ជនមានពិការភាពអាចរួមចំណែកតាមវិធីជាច្រើន ប៉ុន្តែយើងមិនមានមធ្យោបាយច្បាស់លាស់ ដើម្បីដាក់បញ្ចូលពួកគេនោះទេ។"

- ទន្ទឹមនឹងនេះ ភាពជាដៃគូជាមួយសាកលវិទ្យាល័យ អង្គការតំណាងជនមានពិការភាប និងស្ថាប័នផ្តល់ការបណ្តុះបណ្តាល អាចគាំទ្រដល់កម្មវិធីកម្មសិក្សា អាហារូបករណ៍ និងឱកាសការងារកម្រិតចាប់ផ្តើមដំបូង ដែលជួយកសាងជំនាញពាក់ព័ន្ធ។ អភិក្រមទាំងនេះជួយដោះស្រាយឧបសគ្គផ្នែករចនាសម្ព័ន្ធ ដែលកម្រិតការចូលរួមរបស់ជនមានពិការភាព និងក្រុមដែលត្រូវបានផាត់ចេញពីសង្គមផ្សេងទៀត នៅក្នុងការស្រាវជ្រាវ។

## ៤ ការពង្រឹងការជ្រើសរើសបុគ្គលិក ការរក្សាទុកបុគ្គលិក និងប្រព័ន្ធកន្លែងធ្វើការដែលប្រកបដោយបរិយាបន្ន

ការចូលរួមប្រកបដោយបរិយាបន្ន ទាមទារលើសពីការជ្រើសរើសបុគ្គលិកទៅទៀត។ ស្ថាប័នស្រាវជ្រាវគួរតែពង្រឹងប្រព័ន្ធកន្លែងធ្វើការ ដើម្បីគាំទ្រដល់ការរក្សាទុកបុគ្គលិក និងការរីកចម្រើន រួមទាំងផាសុកសមរម្យ ការរៀបចំការងារដែលមានភាពបត់បែន និងបរិយាកាសកន្លែងធ្វើការដែលបង្កភាពងាយស្រួល។ ភាពជាដៃគូជាមួយអង្គការ-ស្ថាប័នជំនាញឯកទេសអាចផ្តល់ការគាំទ្រផ្នែកបច្ចេកទេសលើការបង្កភាពងាយស្រួលនៅកន្លែងធ្វើការ និងការអភិវឌ្ឍបុគ្គលិក។ បើគ្មានប្រព័ន្ធទាំងនេះទេ កិច្ចខិតខំប្រឹងប្រែងផ្នែកបរិយាបន្ន ទំនងជានឹងនៅតែជាការដោះស្រាយតាមកាលៈទេសៈ និងមិនមាននិរន្តរភាពឡើយ។

## ៥ ការទទួលស្គាល់ និងការផ្តល់ធនធានសម្រាប់ការចំណាយលើការងារបរិយាបន្ន

ការស្រាវជ្រាវប្រកបដោយបរិយាបន្ន ទាមទារធនធានជាក់លាក់ រួមមានការធ្វើដំណើរ ការបកប្រែ ទម្រង់ឯកសារដែលបង្កភាពស្រួល និងពេលវេលាចូលរួមកាន់តែយូរ។ ការចំណាយទាំងនេះ គួរត្រូវបានចាត់ទុកជាសមាសធាតុស្តង់ដារនៃការរៀបចំការស្រាវជ្រាវ និងការរៀបចំថវិកា ជាជាងជាការបន្ថែមទៅតាមជម្រើស។ អ្នកឆ្លើយតបម្នាក់បាននិយាយថា៖ **"ជានិច្ចជាកាល ការដាក់បញ្ចូលជនមានពិការភាពមានន័យថា យើងត្រូវការពេលវេលាបន្ថែម អ្នកបកប្រែ ការធ្វើដំណើរ និងថវិកា ហើយកិច្ចការទាំងនេះកម្រត្រូវបានរៀបចំផែនការទុកណាស់។"** ទាំងស្ថាប័នស្រាវជ្រាវ និងអ្នកផ្តល់មូលនិធិ សុទ្ធតែដើរតួនាទីសំខាន់ក្នុងការធានាថា ការបង្កភាពងាយស្រួល និងបរិយាបន្ន ទទួលបានធនធានគ្រប់គ្រាន់តាំងពីដំបូង ដើម្បីកាត់បន្ថយទំនោរផាត់ចេញអ្នកចូលរួម ដោយសារឧបសគ្គនៃការចំណាយ។

## ៦ ការពង្រឹងការលើកទឹកចិត្ត និងគណនេយ្យភាពស្ថាប័ន

ការដាក់បញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ប្រកបដោយនិរន្តរភាព អាស្រ័យលើការរំពឹងទុករបស់ស្ថាប័ន និងយន្តការគណនេយ្យភាពច្បាស់លាស់។ នេះអាចរួមបញ្ចូលការដាក់បញ្ចូលលក្ខណៈវិនិច្ឆ័យសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ទៅក្នុងដំណើរការអនុម័តការស្រាវជ្រាវ ការផ្សារភ្ជាប់សូចនាករប្រតិបត្តិការការងារទៅនឹងការអនុវត្តការស្រាវជ្រាវប្រកបដោយបរិយាបន្ន ការតម្រូវឱ្យមានការបែងចែកថវិកាសម្រាប់ការបង្កភាពងាយស្រួល និងការបង្កើតប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលវាយតម្លៃបរិយាបន្ននៅក្នុងវដ្តស្រាវជ្រាវទាំងមូល។ បើគ្មានយន្តការបែបនេះទេ ការដាក់បញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ប្រហែលជានៅតែធ្វើឡើងក្នុងកម្រិតមិនស្មើគ្នា និងពឹងផ្អែកលើគំនិតផ្តួចផ្តើមរបស់បុគ្គលម្នាក់ៗ។ សម្រាប់អង្គការ-ស្ថាប័នជាច្រើន បរិយាបន្ននៅតែត្រូវបានគេចាត់ទុកថាជា **"រឿងដែលល្អបើមាន"** ដោយសារតែវាមិនត្រូវបានផ្សារភ្ជាប់ទៅនឹងការផ្តល់មូលនិធិ ការទទួលស្គាល់គុណភាព ឬឥទ្ធិពលគោលនយោបាយនោះទេ។ ដូច្នេះ គេនៅតែចាត់ទុក សមភាពយេនឌ័រពិការភាព និងបរិយាបន្នសង្គម ថាជាផ្នែកបន្ថែម ជាជាងជាលក្ខខណ្ឌតម្រូវស្នូលសម្រាប់ការស្រាវជ្រាវដែលគួរឱ្យជឿទុកចិត្តនិងពាក់ព័ន្ធនឹងគោលនយោបាយ។

## ៣.៣ សមាជិកសហគមន៍

**សំណួរស្រាវជ្រាវទី ៣**

តើមានឧបសគ្គ ឱកាស អាទិភាព និងតម្រូវការជាក់លាក់អ្វីខ្លះសម្រាប់ស្ត្រី ជនមានពិការភាព ក្រុមស្រលាញ់ភេទដូចគ្នា និងក្រុមជួបការលំបាកផ្សេងទៀតនៅក្នុងសង្គម ក្នុងការចូលរួមក្នុងវិស័យស្រាវជ្រាវ និងដំណើរការគោលនយោបាយ?

### តើធ្វើដូចម្តេចទើបអាចកាត់បន្ថយឧបសគ្គ និងទាញប្រយោជន៍ពីឱកាស ដើម្បីធ្វើឱ្យប្រសើរឡើងដល់ការចូលរួមរបស់ក្រុមជួបការលំបាក នៅក្នុងវិស័យស្រាវជ្រាវ និងដំណើរការគោលនយោបាយ ដែលអាចឱ្យពួកគេទទួលបានការគាំទ្រកាន់តែប្រសើរ?

ផ្នែកនេះបង្ហាញពីលទ្ធផលទាក់ទងនឹងរបៀបដែលស្ត្រី ជនមានពិការភាព ក្រុមស្រលាញ់ភេទដូចគ្នា និងក្រុមងាយរងគ្រោះផ្សេងទៀតនៅក្នុងសង្គម ឆ្លងកាត់បទពិសោធន៍ និងស្វែងរកវិធីចូលរួមក្នុងវិស័យស្រាវជ្រាវ និងដំណើរការគោលនយោបាយ។ ផ្នែកនេះពិនិត្យមើលឧបសគ្គដែលរឹតត្បិតការចូលរួមរបស់ពួកគេ ទន្ទឹមនឹងឱកាស អាទិភាព និងតម្រូវការជាក់លាក់ដែលកំណត់ដោយសមាជិកសហគមន៍ផ្ទាល់។

ជំនួសឱ្យការវាយតម្លៃក្របខណ្ឌស្ថាប័ន ផ្នែកនេះផ្តោតសំខាន់ទៅលើទិដ្ឋភាពនៃការចូលរួមវិញ។ ផ្នែកនេះពិនិត្យមើលថាតើឧបសគ្គលេចឡើងនៅទីណា និងដោយរបៀបណា នៅទូទាំងដំណើរការស្រាវជ្រាវ និងដំណើរការគោលនយោបាយ ចាប់ពីលទ្ធភាពចូលរួម រហូតដល់សមត្ថភាពក្នុងការរួមចំណែកប្រកបដោយអត្ថន័យ និងថាតើសំឡេងរបស់ពួកគេត្រូវបានឆ្លុះបញ្ចាំងនៅក្នុងការសម្រេចចិត្តដែរ ឬទេ។ ផ្នែកនេះក៏ពិចារណាផងដែរអំពីរបៀបដែលឧបសគ្គទាំងនេះមានភាពខុសគ្នាពីក្រុមមួយទៅក្រុមមួយ និងកាន់តែស្មុគស្មាញដោយសារអត្តសញ្ញាណអន្តរប្រសព្វ។ ផ្នែកនេះសង្កត់ធ្ងន់លើការកំណត់ចំណុចចាប់ផ្តើមជាក់ស្តែង ដើម្បីផ្លាស់ប្តូរពីការចូលរួមតាមកាលៈទេសៈ ឬជានិមិត្តរូបទៅជាការចូលរួមប្រកបដោយបរិយាបន្នដែលកាន់តែស៊ីសង្វាក់គ្នា និងមានអត្ថន័យ។

## ៣.៣.១. បរិបទដែលជះឥទ្ធិពលលើការចូលរួម

គម្លាតរវាងតំបន់ទីក្រុង និងតំបន់ជនបទនៅកម្ពុជា កំណត់ថាតើក្រុមសហគមន៍ឆ្លងកាត់បទពិសោធន៍ពាក់ព័ន្ធនឹងគោលនយោបាយ ដំណើរការស្រាវជ្រាវ និងសេវាសាធារណៈយ៉ាងដូចម្ដេច និងជះឥទ្ធិពលលើសមត្ថភាពរបស់ពួកគេក្នុងការចូលរួមក្នុងដំណើរការទាំងនេះ។ តំបន់ជនបទនៅតែសំបូរប្រជាជនក្រីក្រ ជាទីដែលលទ្ធភាពទទួលបានសេវាថែទាំសុខភាព ការអប់រំ ហេដ្ឋារចនាសម្ព័ន្ធ និងការគាំពារសង្គមនៅមានកម្រិត។ យោងតាមអង្កេតវង្វាស់កម្រិតជីវភាពរស់នៅរបស់ធនាគារពិភពលោក ដែលជាការអង្កេតគ្រួសារផ្លូវការ ដែលប្រើប្រាស់ដោយវិទ្យាស្ថានជាតិស្ថិតិ ភាពក្រីក្រនៅជនបទក្នុងឆ្នាំ២០២៣ ត្រូវបានប៉ាន់ប្រមាណថាមានចំនួន ២២,៨ ភាគរយ ធៀបនឹង ៤,២ ភាគរយនៅរាជធានីភ្នំពេញ និង ១២,៦ ភាគរយនៅតំបន់ប្រជុំជនផ្សេងទៀត។ វិសមភាពទាំងនេះកំណត់ពីរបៀបដែលក្រុមគោលដៅសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ឆ្លងកាត់បទពិសោធន៍ ឆ្លើយតបទៅនឹងគោលនយោបាយ និងកំណែទម្រង់ថ្នាក់ជាតិ។[៤៧]

ប្រាក់ចំណូលគ្រួសារ និងលទ្ធភាពទទួលបានសេវាជាមូលដ្ឋាន នៅតែមានកម្រិតមិនស្មើគ្នាខ្លាំង ហើយបញ្ហានេះរងឥទ្ធិពលពីវិសាលភាពនៃការផ្ដល់សេវារបស់រដ្ឋាភិបាលដែលមិនទាន់បានទូលំទូលាយ។ ខណៈដែលការកែលម្អហេដ្ឋារចនាសម្ព័ន្ធ ដូចជា លទ្ធភាពទទួលបានទឹកស្អាត ត្រូវបានពង្រីកតាមរយៈកម្មវិធីរដ្ឋាភិបាល និងជំនួយសហគមន៍ជនបទនៅតែបន្តប្រឈមនឹងគម្លាតសេវាដ៏ធំ។ សេវាថែទាំសុខភាពមានកម្រិត សាលារៀនខ្វះធនធាន ផ្លូវថ្នល់ជាច្រើនមិនទាន់បានឈូសឆាយចាក់ក្រាល និងតំបន់ជាច្រើនខ្វះអគ្គិសនីប្រើប្រាស់ជាប្រចាំ។ ចន្លោះប្រហោងនេះបានរំលេចឱ្យឃើញ នៅក្នុងរបាយអ្នកជំនាញថែទាំសុខភាព៖ គ្រូពេទ្យប្រហែល ៤០ ភាគរយ និងគ្រូពេទ្យឯកទេសប្រហែល ៧៤ ភាគរយមានមូលដ្ឋាននៅរាជធានីភ្នំពេញ ដើម្បីផ្ដល់សេវាដល់ប្រជាពលរដ្ឋវណ្ណៈកណ្ដាល និងវណ្ណៈខាងលើ ដែលកំពុងកើនឡើង ខណៈដែលប្រជាពលរដ្ឋក្រីក្រប្រហែល ៩០ ភាគរយរស់នៅតំបន់ជនបទ ជាទីដែលពួកគេមិនសូវមានលទ្ធភាពទទួលបានសេវាថែទាំ។

ក្នុងបរិបទនេះ វាមិនជារឿងគួរឱ្យភ្ញាក់ផ្អើលទេដែលមូលបទសំខាន់មួយពីការចុះស្រាវជ្រាវនៅមូលដ្ឋាន គឺគម្លាតដ៏ធំរវាងការផ្ដល់សច្ចាប័នលើគោលនយោបាយថ្នាក់ជាតិ និងការផ្ដល់សេវាជាក់ស្ដែងនៅមូលដ្ឋាន។ ស្ថាប័នផ្ដល់សេវានៅថ្នាក់ក្រោមជាតិ (គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ក្រុង ស្រុក ខណ្ឌ និងគណកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមារខេត្ត) បានលើកឡើងពីគោលនយោបាយ និងកម្មវិធីជាច្រើនដែលសំដៅដល់សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម រួមមានតួនាទីរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ របបគាំពារសង្គម ការឧបត្ថម្ភសាច់ប្រាក់ និងកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ។ ប៉ុន្តែក្រុមគោលដៅសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គមផ្ទាល់ ជាពិសេសជនមានពិការភាព កសិករខ្នាតតូច ជនជាតិដើមភាគតិច ជនចំណាកស្រុក និងជនក្រីក្រនៅទីក្រុង បានលើកឡើងថា ពួកគេមិនទទួលបានអត្ថប្រយោជន៍ស្មើៗគ្នាពីសេវាទាំងនេះទេ។

ការវិភាគរួមគ្នារបស់ DFAT-សហភាពអឺរ៉ុប-ធនាគារពិភពលោក ក្នុងឆ្នាំ២០២១[៤៨] បានគូសបញ្ជាក់ពីភាពចាំបាច់នៃការផ្លាស់ប្ដូរនិម្មាបនកម្មសារពើពន្ធអន្តររដ្ឋាភិបាលរបស់កម្ពុជា ដើម្បីកែលម្អការផ្ដល់សេវាសាធារណៈ។ ចំណុចនេះនៅតែស្ដែងឱ្យឃើញរហូតមកដល់សព្វថ្ងៃនេះ។ ការស្រាវជ្រាវកម្រិតសហគមន៍បង្ហាញថា ចន្លោះប្រហោងក្នុងការអនុវត្ត ការផ្ដល់ធនធានតិចតួច និងគណនេយ្យភាពមានកម្រិត នៅតែធ្វើឱ្យប៉ះពាល់ដល់គោលបំណងនៃគោលនយោបាយ។

[៤៧] World Bank LSMS 2023, National Institute of Statistics ( NIS ), Ministry of Planning

[៤៨] World Bank Cambodia – *Intergovernmental Fiscal Architecture Study:* https://documents.worldbank.org/curated/en/099440003152223052/pdf/P168407082902104a0b28a0d00b4ec6625f.pdf. ។ ការសិក្សានេះពិនិត្យមើលក្របខណ្ឌសារពើពន្ធអន្តររដ្ឋាភិបាលរបស់កម្ពុជា និងគូសបញ្ជាក់ពីបញ្ហាប្រឈមដែលនៅបន្តកើតមាន នៅក្នុងការកំណត់ការទទួលខុសត្រូវលើការចំណាយ ប្រភពហិរញ្ញប្បទាន និងការពង្រឹងការផ្ដល់សេវាតាមរយៈរដ្ឋបាលថ្នាក់ក្រោមជាតិ។ ការសិក្សានេះចង្អុលបង្ហាញពីគម្លាតក្នុងការរចនាប្រព័ន្ធ និងការបែងចែកធនធាន ដែលរឹតត្បិតដល់ការផ្ដល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាព។

ភាពមិនស៊ីសង្វាក់គ្នារវាងគោលនយោបាយ និងបទពិសោធន៍ជីវិតជាក់ស្តែងបែបនេះ លាតសន្ធឹងហួសពីការផ្តល់សេវា និងគ្របដណ្តប់ដល់ការចូលរួមក្នុងដំណើរការស្រាវជ្រាវ និងដំណើរការគោលនយោបាយផ្ទាល់តែម្តង។ នៅក្នុងការអនុវត្តជាក់ស្តែង ក្រុមគោលដៅសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម កម្រចូលរួមដោយផ្ទាល់នៅក្នុងដំណើរការគោលនយោបាយណាស់ ហើយទស្សនៈរបស់ពួកគេច្រើនតែត្រូវបានបញ្ជូនបន្តតាមរយៈតួអង្គអន្តរការី។ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ និងអង្គការមិនមែនរដ្ឋាភិបាលថ្នាក់មូលដ្ឋាន ដើរតួនាទីជាអន្តរការីដ៏សំខាន់ក្នុងការបញ្ជូនទស្សនៈរបស់ក្រុមគោលដៅសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ជាពិសេសនៅកន្លែងដែលទីភ្នាក់ងាររដ្ឋាភិបាល និងស្ថាប័នស្រាវជ្រាវ មិនបានចូលរួមដោយផ្ទាល់ជាមួយសហគមន៍។ ការចូលរួមនេះ ជារឿយៗមានលក្ខណៈអសកម្ម ដោយធ្វើឡើងដើម្បីឆ្លើយតបទៅនឹងសំណើពីរដ្ឋាភិបាល ឬអ្នកស្រាវជ្រាវ ជាជាងជាផ្នែកមួយនៃការចូលរួមទៅវិញទៅមក និងជាប់លាប់។ ខណៈដែលព័ត៌មានត្រូវបានប្រមូលតាមរយៈបណ្តាញទាំងនេះ ក្រុមគោលដៅសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម តែងតែលើកឡើងថា ធាតុចូលរបស់ពួកគេមិនសូវត្រូវបានឆ្លុះបញ្ចាំងនៅក្នុងការសម្រេចចិត្តលើគោលនយោបាយ ឬប្រែក្លាយទៅជាការកែលម្អសេវានោះទេ។ ដូច្នេះ តម្រូវការជាច្រើននៅតែមិនទាន់ត្រូវបានដោះស្រាយ ឬទទួលបានការឆ្លើយតបត្រឹមតែមួយផ្នែកប៉ុណ្ណោះ។ គម្លាតទាំងនេះត្រូវបានពង្រឹងបន្ថែមដោយកង្វះធនធាននៅទូទាំងប្រព័ន្ធទាំងមូល។ ការពិភាក្សាជាមួយក្រសួង សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងកិច្ចការនារី បានគូសបញ្ជាក់ពីការខ្វះខាតធនធានហិរញ្ញវត្ថុ និងធនធានមនុស្ស ដើម្បីគាំទ្រដល់អន្តរាគមន៍ដែលផ្តោតលើសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ជាពិសេសសម្រាប់ជនមានពិការភាព។ ឧបសគ្គស្រដៀងគ្នានេះក៏ត្រូវបានលើកឡើងដោយអ្នកផ្តល់សេវានៅមូលដ្ឋានផងដែរ ដែលពួកគេបានរៀបរាប់ពីការលំបាកក្នុងការផ្តល់ការគាំទ្រឱ្យបានគ្រប់គ្រាន់ និងប្រកបដោយនិរន្តរភាពនៅកម្រិតសហគមន៍ សូម្បីតែនៅកន្លែងដែលមានការប្តេជ្ញាចិត្តផ្នែកគោលនយោបាយក៏ដោយ។

ការងារស្រាវជ្រាវចុះមូលដ្ឋានកម្រិតសហគមន៍ កាន់តែរំលេចឱ្យឃើញបញ្ហាប្រឈមទាំងនេះ។ ការស្រាវជ្រាវបឋមជាមួយក្រុមគោលដៅសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ដែលបំពេញបន្ថែមដោយទស្សនៈពីតួអង្គរដ្ឋបាលថ្នាក់ក្រោមជាតិ បានបង្ហាញពីឧបសគ្គផ្សេងៗគ្នាដែលពាក់ព័ន្ធនឹងយេនឌ័រ ពិការភាព អត្តសញ្ញាណជាជនជាតិដើមភាគតិច ជាតិពន្ធុ និងភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ចសង្គម។ ជារួម លទ្ធផលទាំងនេះចង្អុលបង្ហាញពីតម្រូវការអភិក្រមដែលកាន់តែមានគោលដៅច្បាស់លាស់ ប្រកបដោយបរិយាបន្ន និងមានធនធានគ្រប់គ្រាន់ សម្រាប់ការចូលរួម ការបង្កើតជាទិន្នន័យ និងការផ្តល់សេវា។ បើគ្មានការដោះស្រាយឧបសគ្គជាក់លាក់របស់ក្រុមនីមួយៗទេនោះ កិច្ចខិតខំប្រឹងប្រែងដើម្បីដាក់បញ្ចូល សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ទៅក្នុងដំណើរការស្រាវជ្រាវ និងដំណើរការគោលនយោបាយ នឹងនៅតែមិនអាចសម្រេចបានបរិយាបន្នប្រកបដោយអត្ថន័យ។

ការសង្កេតទាំងអស់នៅក្នុងផ្នែកបន្តបន្ទាប់ ឆ្លុះបញ្ចាំងពីបទពិសោធន៍ជីវិតជាក់ស្តែង និងទស្សនៈដែលត្រូវបានចែករំលែកដោយផ្ទាល់ដោយសមាជិកសហគមន៍ក្នុងអំឡុងពេលនៃការចុះស្រាវជ្រាវនៅមូលដ្ឋាន។

## ៣.៣.២. សមភាពយេនឌ័រ៖ ឧបសគ្គ និងអាទិភាពសម្រាប់ការចូលរួមរបស់ស្ត្រី

នៅតាមបណ្តាខេត្តនានា ស្ត្រីប្រឈមនឹងឧបសគ្គជាប្រព័ន្ធ និងជាហូរហែ ដែលរឹតត្បិតការចូលរួមរបស់ពួកគេក្នុងដំណើរការស្រាវជ្រាវ និងគោលនយោបាយ។ ឧបសគ្គទាំងនេះលេចឡើងនៅគ្រប់ដំណាក់កាលនៃការចូលរួម ចាប់ពីលទ្ធភាពចូលរួមក្នុងការពិគ្រោះយោបល់ សមត្ថភាពរួមចំណែកប្រកបដោយអត្ថន័យ រហូតដល់ថាតើទស្សនៈរបស់ពួកគេមានឥទ្ធិពលលើការសម្រេចចិត្តដែរ ឬទេ។ ទិន្នន័យពីការងារចុះស្រាវជ្រាវនៅកម្រិតសហគមន៍បង្ហាញថា ខណៈដែលស្ត្រីតែងតែមានវត្តមានក្នុងការពិគ្រោះយោបល់ ការចូលរួមរបស់ពួកគេមិនសូវតែមានផលជះ ឬចេញជាលទ្ធផលដែលប្រសើរឡើងនោះទេ។

## ឧបសគ្គផ្នែករចនាសម្ព័ន្ធ៖ ការអនុវត្តក្នុងស្ថាប័ន និងសេដ្ឋកិច្ចនៃការថែទាំ

ឧបសគ្គផ្នែករចនាសម្ព័ន្ធ នៅតែជាដែនកំណត់ចម្បងចំពោះការចូលរួមរបស់ស្ត្រី ជាពិសេសនៅត្រង់លទ្ធភាពចូលរួម។ នៅតំបន់ជនបទ ដូចជា ខេត្តបាត់ដំបង និងខេត្តកំពត ពេលវេលារបស់ស្ត្រីត្រូវបានរឹតត្បិតដោយការទទួលខុសត្រូវលើកិច្ចការថែទាំដែលមិនទទួលបានប្រាក់កម្រៃ ការងារផ្ទះ និងសកម្មភាពស្វែងរកប្រាក់ចំណូល។ អ្នកចូលរួមជាច្រើនបានលើកឡើងថា ពួកគេផ្តោតអាទិភាពលើការចិញ្ចឹមជីវិតប្រចាំថ្ងៃ និងការងារស្វែងរកប្រាក់ចំណូល ជាជាងការចូលរួមក្នុងការពិគ្រោះយោបល់ ជាពិសេសក្នុងបរិបទនៃអស្ថិរភាពសេដ្ឋកិច្ច។

ការប្រែប្រួលអាកាសធាតុ បានពង្រីកឧបសគ្គទាំងនេះបន្ថែមទៀត។ នៅខេត្តបាត់ដំបង ស្ត្រីបានរាយការណ៍ថា ជាញឹកញាប់ គ្រោះទឹកជំនន់បានរំខានដល់ការធ្វើកសិកម្ម និងកាត់បន្ថយប្រាក់ចំណូលគ្រួសារ ដែលបង្ខំឱ្យពួកគេត្រូវផ្តោតអាទិភាពលើតម្រូវការជីវភាពចំពោះមុខ ជាជាងការចូលរួមក្នុងកិច្ចប្រជុំ ឬការពិគ្រោះយោបល់។

អ្នកចូលរួមក៏បានចង្អុលបង្ហាញពីឧបសគ្គផ្នែកស្ថាប័នផងដែរ។ អង្គការដែលផ្តោតការយកចិត្តទុកដាក់លើស្ត្រី បានរៀបរាប់ពីការខ្វះខាតថវិកា និងសមត្ថភាពបច្ចេកទេស ដើម្បីអនុវត្តការស្រាវជ្រាវដោយឯករាជ្យ។ ជារឿយៗ ពួកគេត្រូវពឹងផ្អែកលើទីប្រឹក្សាខាងក្រៅ និងគម្រោងរយៈពេលខ្លី។

នៅក្នុងប្រព័ន្ធរដ្ឋាភិបាល អ្នកចូលរួមបានគូសបញ្ជាក់ពីឋានានុក្រមអំណាចផ្ទៃក្នុង និងការជំទាស់នឹងធាតុចូលដែលឆ្លើយតបនឹងយេនឌ័រ។ ស្ត្រីមួយចំនួននៅខេត្តកំពតបានរាយការណ៍ថា មតិត្រឡប់លើបញ្ហាសុខភាព និងអនាម័យត្រូវបានប្រមូលជាច្រើនលើកច្រើនសារ ប៉ុន្តែ "មិនដែលត្រូវបានឆ្លុះបញ្ចាំងនៅក្នុងការសម្រេចចិត្តចុងក្រោយឡើយ"។

## ឧបសគ្គផ្នែកបទដ្ឋាន និងឥរិយាបថ

ធាតុចូលរបស់អ្នកចូលរួមគូសបញ្ជាក់ពីរបៀបដែលបទដ្ឋានយេនឌ័រ នៅតែបន្តកំណត់ថាតើជំនាញរបស់នរណាត្រូវបានចាត់ទុកថាត្រឹមត្រូវ និងស្របច្បាប់។ ស្ត្រីនៅខេត្តបាត់ដំបង និងខេត្តកំពត បានរៀបរាប់ពីអារម្មណ៍មិនសូវមានទំនុកចិត្តក្នុងការប្រាស្រ័យទាក់ទងជាមួយអ្នកស្រាវជ្រាវ ឬមន្ត្រី ជាពិសេសលើប្រធានបទដូចជា ដីធ្លី ធនធានធម្មជាតិ ហិរញ្ញវត្ថុ ឬការធ្វើចំណាកស្រុក ដែលភាគច្រើនគេយល់ថាជាវិស័យរបស់បុរស។ អ្នកខ្លះបាននិយាយថា ពួកគេទុកឱ្យស្វាមី ឬសាច់ញាតិជាបុរសជាអ្នកនិយាយក្នុងការពិភាក្សាសាធារណៈ ព្រោះពួកគេយល់ថាទស្សនៈរបស់ពួកគេមិនសូវមានឥទ្ធិពល។

ស្ត្រីក៏បានលើកឡើងផងដែរថា ការអញ្ជើញឱ្យចូលរួមក្នុងការពិគ្រោះយោបល់ ជារឿយៗផ្តោតលើបុរសជាជម្រើសដំបូង សូម្បីតែនៅពេលដែលការពិភាក្សាទាំងនោះទាក់ទងនឹងកម្មវិធី ដែលជះឥទ្ធិពលផ្ទាល់លើស្ត្រីក៏ដោយ រួមទាំងសេវាសុខាភិបាល កិច្ចគាំពារសង្គម និងទេសន្តរប្រវេសន៍ការងារ។ ផ្អែកលើការឆ្លុះបញ្ចាំងទាំងនេះ ស្ត្រីច្រើនតែត្រូវបានគេចាត់ទុកជាអ្នកទទួលផល ជាជាងជាអ្នករួមចំណែកដល់ចំណេះដឹង និងគោលនយោបាយ។ ការយល់ឃើញបែបនេះធ្វើឱ្យទស្សនៈដែលប្រមូលបានមានភាពចង្អៀត។

សូម្បីតែនៅពេលចូលរួមក៏ដោយ ក៏អំណាចគ្របដណ្តប់ផ្ទៃក្នុងនៅតាមស្ថាប័នថ្នាក់ឃុំ និងស្រុក ត្រូវបានគេមើលឃើញថារឹតត្បិតដល់ឥទ្ធិពលនៃធាតុចូលរបស់ស្ត្រី នៅក្នុងដំណើរការធ្វើសេចក្តីសម្រេច។ នៅតំបន់ជនបទ លទ្ធភាពមានកម្រិតក្នុងការទទួលបានការអប់រំ រឹតតែធ្វើឱ្យប៉ះពាល់ដល់សមត្ថភាពរបស់ស្ត្រីក្នុងការចូលរួមប្រកបដោយប្រសិទ្ធភាព។ អ្នកចូលរួមមួយចំនួនបានកត់សម្គាល់ថា ខណៈដែលស្ត្រីចូលរួមក្នុងការពិភាក្សាជាក្រុមផ្សេងៗ ពួកគេអាចជួបការលំបាកក្នុងការបញ្ចេញមតិផ្ទាល់ខ្លួនឱ្យបានច្បាស់លាស់ ជាពិសេសនៅក្នុងការពិភាក្សាផ្លូវការ ឬការពិភាក្សាផ្នែកបច្ចេកទេស។

## ឧបសគ្គផ្នែកដំណើរការ៖ ការរៀបចំការស្រាវជ្រាវ និងការរៀបចំការពិភាក្សា

ផ្អែកលើបទពិសោធន៍របស់អ្នកចូលរួម ការរៀបចំ និងការអនុវត្តការស្រាវជ្រាវ និងការពិគ្រោះយោបល់ កាន់តែរឹតត្បិតឥទ្ធិពលរបស់ស្ត្រី។ ស្ត្រីតែងតែពណ៌នាអំពីការចូលរួមថាជាការទាញយកប្រយោជន៍៖ ស្ត្រីត្រូវបានគេពិគ្រោះយោបល់ ប៉ុន្តែធាតុចូលរបស់ពួកគេមិនត្រូវបានដាក់បញ្ចូលទៅក្នុងគោលនយោបាយនៅពេលធ្វើការសម្រេចចិត្តចុងក្រោយឡើយ។ ចំណុចនេះបានញ៉ាំងឱ្យស្ត្រីមិនចង់ចូលរួមក្នុងការពិគ្រោះយោបល់ ជាពិសេសក្នុងចំណោមស្ត្រីមានប្រាក់ចំណូលទាប ដែលភាគច្រើនបាននិយាយថា ពួកគេចូលរួមលុះត្រាតែពួកគេមើលឃើញអត្ថប្រយោជន៍ច្បាស់លាស់ និងជាក់ស្តែងប៉ុណ្ណោះ។

> “យើងត្រូវបានគេសួរជាច្រើនដងអំពីបញ្ហាសុខភាព និងអនាម័យ ប៉ុន្តែគ្មានអ្វីផ្លាស់ប្តូរទេ។ យើងមិនឃើញគំនិតរបស់យើងនៅក្នុងការសម្រេចចិត្តចុងក្រោយឡើយ។" – អ្នកចូលរួមជាស្ត្រីនៅខេត្តកំពត ”

ការចូលរួមក៏ច្រើនតែត្រូវបានសម្របសម្រួលតាមរយៈតួអង្គអន្តរការី ដូចជា គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ និងអង្គការមិនមែនរដ្ឋាភិបាល ជាជាងតាមរយៈការចូលរួមដោយផ្ទាល់។  ខណៈដែលតួអង្គទាំងនេះដើរតួនាទីយ៉ាងសំខាន់ក្នុងការពាំនាំទស្សនៈរបស់សហគមន៍ គំរូប្រយោលនេះអាចធ្វើឱ្យចុះខ្សោយសំឡេងរបស់ស្ត្រី និងកាត់បន្ថយគណនេយ្យភាពចំពោះរបៀបដែលធាតុចូលទាំងនោះត្រូវបានយកទៅប្រើប្រាស់។

ទន្ទឹមនឹងនេះ អ្នកចូលរួមបានកំណត់លក្ខខណ្ឌដែលធ្វើឱ្យការចូលរួមមានភាពប្រសើរឡើង។ ស្ត្រីបានលើកឡើង អំពីការចូលរួមប្រកបដោយអត្ថន័យជាងមុន នៅពេលដែលអ្នកសម្ភាសន៍គឺជាស្ត្រី នៅពេលដែលការពិភាក្សាត្រូវបានធ្វើឡើងក្នុងលក្ខណៈដែលងាយស្រួលយល់ និងសមស្របតាមវប្បធម៌ និងនៅពេលដែលអ្នកស្រាវជ្រាវបានពន្យល់យ៉ាងច្បាស់អំពីគោលបំណង និងការប្រើប្រាស់ដែលរំពឹងទុកពីការស្រាវជ្រាវ។ លទ្ធផលទាំងនេះគូសបញ្ជាក់ពីសារៈសំខាន់នៃទំនុកចិត្ត តម្លាភាព និងភាពជាតំណាង ក្នុងការតម្រឹមតម្រង់លទ្ធផលនៃការចូលរួម។

## ឧបសគ្គពាក់ព័ន្ធនឹងសុវត្ថិភាព និងការបង្កភាពងាយស្រួល

ជាតុចូលរបស់អ្នកចូលរួមបានគូសបញ្ជាក់ពីបញ្ហាសុវត្ថិភាព និងការធ្វើដំណើរថាជាឧបសគ្គដ៏សំខាន់ ជាពិសេសសម្រាប់ស្ត្រីដែលមានប្រាក់ចំណូលទាប។ នៅរាជធានីភ្នំពេញ ស្ត្រីមកពីសង្កាត់ក្រីក្របានលើកឡើងពីការចៀសវាងការចូលរួមប្រជុំនៅពេលល្ងាច ដោយសារតែខ្វះភ្លើងបំភ្លឺផ្លូវ ការធ្វើដំណើរមិនមានសុវត្ថិភាព និងការភ័យខ្លាចការបៀតបៀន។ នៅតំបន់ជនបទ ផ្លូវឆ្ងាយ និងកង្វះមធ្យោបាយធ្វើដំណើរដែលមានតម្លៃសមរម្យ រឹតតែកាត់បន្ថយការចូលរួម ជាពិសេសនៅពេលដែលការប្រជុំធ្វើឡើងនៅឆ្ងាយពីភូមិ ឬនៅម៉ោងដែលមេឃចាប់ងងឹត។ ឧបសគ្គផ្នែករចនាសម្ព័ន្ធទាំងនេះ កាន់តែស្មុគស្មាញដោយសារកត្តាស្ថានភាពជាក់ស្តែង។ ក្នុងអំឡុងពេលចុះមូលដ្ឋាន ភ្លៀងធ្លាក់ខ្លាំង និងចរាចរណ៍មិនជាប់លាប់នៃមធ្យោបាយធ្វើដំណើរ រឹតតែកាត់បន្ថយសមត្ថភាពរបស់ស្ត្រីក្នុងការចូលរួមប្រជុំ ជាពិសេសនៅតំបន់ដែលមានហេដ្ឋារចនាសម្ព័ន្ធអន់ថយ។

ការពិចារណាជាក់ស្តែងបែបនេះ កម្រត្រូវបានលើកមកពិចារណានៅក្នុងការរៀបចំការស្រាវជ្រាវ និងការពិគ្រោះយោបល់ណាស់។ ដូច្នេះ ដំណើរការនៃការចូលរួមហាក់ផ្តល់អត្ថប្រយោជន៍ដល់បុរស និងក្រុមដែលមានស្ថិរភាពសេដ្ឋកិច្ចជាង ដែលប្រឈមមុខនឹងឧបសគ្គផ្នែកចល័តភាព និងសុវត្ថិភាពតិចជាង។ កត្តាអន្តរប្រសព្វ រួមមានអាយុ ភាពក្រីក្រ និងស្ថានភាពគ្រួសារ បានពង្រីកឧបសគ្គទាំងនេះថែមទៀត ជាពិសេសសម្រាប់ស្ត្រីវ័យក្មេង និងគ្រួសារដែលមានស្ត្រីជាមេគ្រួសារ។

### ៣.៣.៣. បរិយាបន្នពិការភាព៖ ឧបសគ្គ និងអាទិភាពសម្រាប់ជនមានពិការភាព

ផ្អែកលើការឆ្លុះបញ្ចាំង និងធាតុចូលពីអ្នកចូលរួម ជនមានពិការភាពបានរៀបរាប់ពីភាពប្រសើរឡើងមួយចំនួននៅក្នុងការផ្តល់សេវា និងកិច្ចខិតខំប្រឹងប្រែងលើកកម្ពស់បរិយាបន្ន ដូចជា ការស្តារនីតិសម្បទាតាមសហគមន៍ គំនិតផ្តួចផ្តើមការអប់រំបរិយាបន្ន និងកម្មវិធីលើកកម្ពស់ការយល់ដឹង ដែលគាំទ្រដោយអង្គការតំណាងជនមានពិការភាព និងអង្គការមិនមែនរដ្ឋាភិបាល។ ប័ណ្ណសម្គាល់ជនមានពិការភាពក៏ត្រូវបានកត់សម្គាល់ថាជាឧបករណ៍ដ៏មានប្រយោជន៍ផងដែរ សម្រាប់ការទទួលបានអត្ថប្រយោជន៍គាំពារសង្គមមួយចំនួន។ ទោះជាយ៉ាងណា ការផ្លាស់ប្តូរទាំងនេះមិនមានកម្រិតស្មើគ្នាទេ ហើយការគ្របដណ្តប់ច្រើនតែនៅមានកម្រិត។ អ្នកចូលរួមម្នាក់បានកត់សម្គាល់ថា៖

> “ ប័ណ្ណសម្គាល់ជនមានពិការភាព មានពិតមែន ប៉ុន្តែវាមិនសូវផ្លាស់ប្តូរអ្វីច្រើនទេ នៅក្នុងជីវិតប្រចាំថ្ងៃរបស់យើង។ ”

ឧបសគ្គទាំងនេះមានទំនាក់ទំនងគ្នាទៅវិញទៅមក ហើយកើតឡើងនៅគ្រប់ដំណាក់កាលនៃការចូលរួម ដែលមិនត្រឹមតែរឹតត្បិតលទ្ធភាពចូលរួមក្នុងការពិគ្រោះយោបល់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងរឹតត្បិតសមត្ថភាពរបស់ជនមានពិការភាពក្នុងការរួមចំណែកប្រកបដោយអត្ថន័យ និងជះឥទ្ធិពលដល់លទ្ធផលគោលនយោបាយផងដែរ។

---

## *ឧបសគ្គពាក់ព័ន្ធនឹងការបង្កភាពងាយស្រួល៖ ឧបសគ្គបរិស្ថានរូបវន្ត ហិរញ្ញវត្ថុ និងការប្រាស្រ័យទាក់ទង*

លទ្ធភាពចូលរួមក្នុងដំណើរការស្រាវជ្រាវ និងដំណើរការគោលនយោបាយ ត្រូវបានរឹតត្បិតដោយបណ្តុំនៃឧបសគ្គបរិស្ថានរូបវន្ត ហិរញ្ញវត្ថុ និងការប្រាស្រ័យទាក់ទង។

អ្នកចូលរួមតែងបានលើកឡើងថា ការធ្វើដំណើរគឺជាឧបសគ្គចម្បងចំពោះការចូលរួមក្នុងដំណើរការស្រាវជ្រាវ និងដំណើរការគោលនយោបាយ។ កង្វះមធ្យោបាយធ្វើដំណើរដែលបង្កភាពងាយស្រួល ផ្លូវជម្រាល និងទីកន្លែងជួបជុំដែលងាយស្រួលចេញចូល បានរារាំងមិនឱ្យជនមានពិការភាពជាច្រើនចូលរួមក្នុងការប្រជុំ និងការពិគ្រោះយោបល់។ នៅខេត្តបាត់ដំបង អ្នកចូលរួមបានគូសបញ្ជាក់ពីការគ្មានផ្លូវជម្រាល និងមធ្យោបាយធ្វើដំណើរសាធារណៈដែលងាយស្រួលប្រើប្រាស់ ថាជាឧបសគ្គចម្បងមួយ។ អ្នកចូលរួមបាននិយាយថា៖ *"ទោះបីជាយើងចង់ចូលរួមក៏ដោយ ក៏យើងមិនអាចដែរ ព្រោះយើងមិនអាចទៅដល់ទីកន្លែងនោះ។"*

ឧបសគ្គផ្នែកហិរញ្ញវត្ថុកាន់តែរឹតត្បិតដល់ការចូលរួម។ អ្នកចូលរួមបានពន្យល់ថា ការស្រាវជ្រាវដែលពាក់ព័ន្ធនឹងជនមានពិការភាព ទាមទារឱ្យមានធនធានបន្ថែមសម្រាប់ការធ្វើដំណើរ ការស្នាក់នៅ និងឧបករណ៍ប្រាស្រ័យទាក់ទងដែលបង្កភាពងាយស្រួល ប៉ុន្តែការចំណាយបែបនេះកម្រត្រូវបានរៀបចំផែនការថវិកាណាស់។ នៅរាជធានីភ្នំពេញ ជនមានពិការភាពបានកត់សម្គាល់ថា ទោះបីជាមានសិទ្ធិទទួលបានអត្ថប្រយោជន៍ក្រោមច្បាប់ជាធរមានក៏ដោយ ប៉ុន្តែអត្ថប្រយោជន៍ទាំងនេះកម្រលេចចេញជារូបរាងយ៉ាងពិតប្រាកដណាស់។ អ្នកចូលរួមបានរៀបរាប់យ៉ាងច្បាស់អំពីគម្លាតនេះថា៖ *"ច្បាប់ចែងថា យើងគួរតែទទួលបានការគាំទ្រ ប៉ុន្តែតាមពិត យើងនៅតែត្រូវរ៉ាប់រងការចំណាយភាគច្រើនដោយខ្លួនឯងដដែល។"*

ឧបសគ្គក្នុងការប្រាស្រ័យទាក់ទង ក៏ដើរតួនាទីយ៉ាងសំខាន់ផងដែរ។ ទម្រង់ឯកសារដែលបង្កភាពងាយស្រួល រួមទាំងការបកប្រែភាសាសញ្ញា ឯកសារសរសេរជាអក្សរស្ទាប និងទម្រង់ជាជម្រើសផ្សេងទៀត កម្រត្រូវបានផ្តល់ជូនណាស់ នៅក្នុងការស្រាវជ្រាវ និងការពិគ្រោះយោបល់។ កង្វះអ្នកបកប្រែត្រូវបានលើកឡើងញឹកញាប់ថាជាបញ្ហាប្រឈមមួយ។ អ្នកចូលរួមក៏បានកត់សម្គាល់ផងដែរថា អ្នកប្រមូលទិន្នន័យមួយចំនួនខ្វះទំនុកចិត្ត ឬការបណ្តុះបណ្តាល ស្តីពីរបៀបប្រាស្រ័យទាក់ទងឱ្យមានប្រសិទ្ធភាព ហើយចំណុចនេះបានបណ្តាលឱ្យមានការផាត់ចេញដោយស្វ័យប្រវត្តិ។

## ឧបសគ្គផ្នែកសំឡេងតំណាង និងការចូលរួម៖ ការរើសអើង និងគម្លាតសមត្ថភាព

ការរើសអើងក្នុងសង្គម នៅតែជាឧបសគ្គចម្បងមួយ។ អ្នកចូលរួមបានរៀបរាប់ពីការណ៍ដែលពួកគេត្រូវបានផាត់ចេញពីការពិភាក្សាក្នុងសហគមន៍ ដោយទស្សនៈរបស់ពួកគេត្រូវបានបដិសេធ ឬមិនត្រូវបានគេយកចិត្តទុកដាក់។ នៅខេត្តកំពត ជនមានពិការភាពបានលើកឡើងថា ពួកគេតែងតែមិនទទួលបានការយកចិត្តទុកដាក់នៅក្នុងការពិភាក្សារបស់សហគមន៍ ដោយសំឡេងរបស់ពួកគេត្រូវបានបដិសេធ ឬមើលរំលង។ ពួកគេមានអារម្មណ៍ថា អ្នកផងប្រព្រឹត្តចំពោះពួកគេខុសពីមនុស្សធម្មតា ហាក់ដូចជាពួកគេមិនមែនជាផ្នែកមួយនៃសហគមន៍អញ្ចឹង។ ជាតុចូលរបស់ពួកគេមិនត្រូវបានគេយកចិត្តទុកដាក់ទេ។ រឿងនេះធ្វើឱ្យមនុស្សភាគច្រើនលែងចង់បញ្ចេញមតិ។

ឧបសគ្គរាំងការចូលរួម ក៏មានភាពខុសគ្នាផងដែរនៅតាមក្រុមផ្សេងៗគ្នា។ អ្នកចូលរួមដែលមានពិការភាពគ-ថ្លង់ បានគូសបញ្ជាក់ពីការផាត់ចេញ ដោយសារកង្វះការបកប្រែ ចំណែកជនមានកម្សោយគំហើញ បានលើកឡើងពីលទ្ធភាពមានកម្រិតក្នុងការទទួលបានបច្ចេកវិទ្យាជំនួយ និងឯកសារដែលបង្កភាពងាយស្រួល។ ការអប់រំ និងអក្ខរកម្មមានកម្រិត ជាពិសេសនៅតំបន់ជនបទ កាន់តែរឹតត្បិតលទ្ធភាពចូលរួមក្នុងការពិភាក្សាផ្នែកបច្ចេកទេស ឬការពិភាក្សាផ្លូវការ។

---

## ឧបសគ្គរាំងភាពជាតំណាង និងគណនេយ្យភាព

ភាពជាតំណាងនៅក្នុងវិស័យស្រាវជ្រាវ និងគោលនយោបាយ នៅមានកម្រិតនៅឡើយ។ អ្នកចូលរួមបានកត់សម្គាល់ថា ពួកគេកម្រឃើញជនមានពិការភាពចូលរួមក្នុងនាមជាអ្នកស្រាវជ្រាវ អ្នកសម្របសម្រួល ឬអ្នកធ្វើសេចក្ដីសម្រេចណាស់ ហើយចំណុចនេះបានជួយពង្រឹងការយល់ឃើញថា ទស្សនៈរបស់ពួកគេមិនសូវសំខាន់ មិនមែនជាចំណុចស្នូលនៃដំណើរការគោលនយោបាយ។

យន្តការគណនេយ្យភាពក៏អន់ខ្សោយផងដែរ។ អ្នកចូលរួមបានសម្ដែងភាពមិនច្បាស់ក្នុងចិត្តអំពីរបៀបដែលជនមានពិការភាពត្រូវបានពិគ្រោះយោបល់ នៅក្នុងដំណើរការគោលនយោបាយ រួមទាំងយុទ្ធសាស្ត្រថ្មីៗ ដូចជា ផែនការយុទ្ធសាស្ត្រជាតិស្ដីពីពិការភាពជាដើម។ អ្នកខ្លះបានកត់សម្គាល់ថា ការពិគ្រោះយោបល់ច្រើនតែធ្វើឡើងតាមរយៈអង្គការតំណាងជនមានពិការភាព ជាជាងជាការពិគ្រោះដោយផ្ទាល់ជាមួយបុគ្គលរងផលប៉ះពាល់។ អ្នកចូលរួមមានអារម្មណ៍ថា ការពិគ្រោះយោបល់ភាគច្រើនធ្វើឡើងជាមួយអង្គការតំណាង និងមិនមែនធ្វើឡើងដោយផ្ទាល់ជាមួយប្រជាពលរដ្ឋរងផលប៉ះពាល់នោះទេ។ ដូចដែលអ្នកចូលរួមម្នាក់បានកត់សម្គាល់ថា៖

> “យើងមិនដែលបានទទួលដំណឹងត្រឡប់មកវិញថាតើពួកគេយកជាតុចូលរបស់យើងទៅធ្វើអ្វីខ្លះនោះទេ។”

ការគ្មានព័ត៌មានត្រឡប់បែបនេះ បានកាត់បន្ថយទំនុកចិត្ត និងរួមចំណែកធ្វើឱ្យលែងសូវមានទឹកចិត្តចង់ចូលរួម។ ដូច្នេះ ជារឿយៗ ការចូលរួមគឺនៅត្រឹមតែជាការពិគ្រោះយោបល់ ជាជាងជាការជះឥទ្ធិពល។

## តួនាទីអន្តរការី៖ អាជ្ញាធរមូលដ្ឋាន និងអង្គការតំណាងជនមានពិការភាព

ក្នុងការអនុវត្តជាក់ស្តែង ការចូលរួមរបស់ជនមានពិការភាពកម្រធ្វើឡើងដោយផ្ទាល់ណាស់ ប៉ុន្តែត្រូវបានសម្របសម្រួលតាមរយៈអាជ្ញាធរមូលដ្ឋាន និងអង្គការតំណាងជនមានពិការភាព ទៅវិញ។ មេភូមិ និងមេឃុំ-ចៅសង្កាត់តែងតែត្រូវបានកំណត់ថាជាអន្តរការីដ៏សំខាន់រវាងក្រុមស្រាវជ្រាវ និងជនមានពិការភាព។ នៅកន្លែងដែលអាជ្ញាធរមូលដ្ឋានទទួលបានព័ត៌មាន និងមានភាពសកម្ម ពួកគេបានជួយសម្របសម្រួលការចូលរួម។ នៅកន្លែងដែលអាជ្ញាធរមូលដ្ឋានមានភាពសកម្ម ពួកគាត់នឹងធានាថា អ្នកចូលរួមត្រូវបានដាក់បញ្ចូលទៅក្នុងកិច្ចប្រជុំទាំងនោះ។

អង្គការតំណាងជនមានពិការភាព ក៏ត្រូវបានពណ៌នាថាជាអន្តរការីដ៏សំខាន់ផងដែរ។ អង្គការទាំងនេះជួយតភ្ជាប់ក្រុមស្រាវជ្រាវជាមួយសហគមន៍ ពន្យល់ពីដំណើរការស្រាវជ្រាវ និងកសាងទំនុកចិត្តក្នុងចំណោមអ្នកចូលរួម។ តួនាទីនេះមានសារៈសំខាន់ជាពិសេសចំពោះការគ្របដណ្តប់ដល់ជនមានពិការភាព ដែលអាចនៅតែត្រូវបានគេផាត់ចេញ ប្រសិនបើគ្មានអង្គការទាំងនេះ។

ទោះជាយ៉ាងណា តួនាទីអន្តរការីទាំងនេះច្រើនតែមានលក្ខណៈមិនផ្លូវការ និងខ្វះធនធាន។ អង្គការតំណាងជនមានពិការភាព បានរាយការណ៍ថា ពួកគេមានថវិកាមិនគ្រប់គ្រាន់ ដើម្បីគាំទ្រដល់ការចូលរួមប្រកបដោយនិរន្តរភាព ខណៈដែលអាជ្ញាធរមូលដ្ឋានអាចខ្វះការបណ្តុះបណ្តាល ឬការលើកទឹកចិត្តឱ្យផ្តោតអាទិភាពលើការចូលរួមប្រកបដោយបរិយាបន្ន។ ខណៈដែលការធ្វើដូចនេះអាចធ្វើឱ្យប្រសើរឡើងដល់លទ្ធភាពចូលរួម វាក៏អាចកំណត់របៀបនៃការចូលរួមផងដែរ។ ការពិគ្រោះយោបល់ដែលធ្វើឡើងជាចម្បងតាមរយៈអង្គការជាជាងបុគ្គលផ្ទាល់ អាចនឹងកម្រិត ភាពចម្រុះនៃបទពិសោធន៍ជីវិតជាក់ស្តែង ដែលត្រូវបានច្បាមយក។

---

## ឧបសគ្គកម្រិតប្រព័ន្ធ៖ ការអនុវត្តគោលនយោបាយ គម្លាតទិន្នន័យ និងទំនុកចិត្ត

នៅកម្រិតប្រព័ន្ធ ឧបសគ្គរចនាសម្ព័ន្ធកាន់តែទូលំទូលាយ រឹតតែកម្រិតការចូលរួមប្រកបដោយអត្ថន័យ។ អ្នកចូលរួមបានរៀបរាប់ពីគម្លាតរវាងការប្តេជ្ញាចិត្តក្នុងគោលនយោបាយ និងការអនុវត្តជាក់ស្តែង។ កម្ពុជាមានក្របខណ្ឌគតិយុត្ត និងឧបករណ៍ ដូចជា ប័ណ្ណសម្គាល់ជនមានពិការភាព ប៉ុន្តែតម្លៃជាក់ស្តែងរបស់ពួកវាត្រូវបានកម្រិតដោយការផ្តល់សេវាមិនបានល្អ ការអនុវត្តមិនស៊ីសង្វាក់គ្នា និងការយល់ដឹងតិច។ ជាលទ្ធផល គោលនយោបាយច្រើនតែត្រូវបានគេមើលឃើញថាមានតែនៅលើក្រដាស ជាជាងស្តែងឡើងក្នុងការអនុវត្ត។

គម្លាតក្នុងប្រព័ន្ធទិន្នន័យ បានធ្វើឱ្យរាំងស្ទះបន្ថែមទៀតដល់បរិយាបន្ន។ ជារឿយៗ ស្ថានភាពពិការភាពត្រូវបានគេចាត់ថ្នាក់ខុស ឬមិនត្រូវបានច្បាមយកនៅក្នុងអង្កេតនានា ដែលជះឥទ្ធិពលដល់សិទ្ធិទទួលបានសេវា និងរឹតត្បិតសមត្ថភាពក្នុងការបង្កើតទិន្នន័យដែលសុក្រឹត និងបែកចែកជាប្រភេទ។ អ្នកចូលរួមមួយចំនួនបានលើកឡើងថា ពួកគេត្រូវបានកត់ត្រាថា "មិនមានពិការភាព" ដោយសារតែអ្នកប្រមូលទិន្នន័យ ខ្វះការយល់ដឹង។

ទិន្នន័យមិនពេញលេញបែបនេះ ធ្វើឱ្យអន់ថយទាំងគុណភាពនៃការស្រាវជ្រាវ និងទំនុកចិត្ត។ នៅពេលដែលទិន្នន័យមិនបានឆ្លុះបញ្ចាំងត្រឹមត្រូវអំពីបទពិសោធន៍ជីវិតជាក់ស្តែង វាបានញ៉ាំងឱ្យមានគម្លាតរវាងការបង្កើតទិន្នន័យ និងការរៀបចំគោលនយោបាយ ដែលជួយពង្រឹងដល់ការយល់ឃើញថា ការចូលរួមមិនបាននាំឱ្យមានការផ្លាស់ប្តូរប្រកបដោយអត្ថន័យនោះទេ។

ប្រអប់ទី ១៣

## ឧបសគ្គធំៗដែលរារាំងការចូលរួម និងអាទិភាពសម្រាប់ជនមានពិការភាពនៅក្នុងដំណើរការស្រាវជ្រាវ និងដំណើរការរបស់សហគមន៍៖ សេចក្តីសង្ខេបលទ្ធផលពីការពិភាក្សាក្រុមគោលដៅ

នៅទូទាំងខេត្តបាត់ដំបង ខេត្តកំពត និងរាជធានីភ្នំពេញ អ្នកចូលរួមបានរៀបរាប់ពីឧបសគ្គស្រដៀងៗគ្នា ដែលរឹតត្បិតដល់ការចូលរួមប្រកបដោយអត្ថន័យរបស់ជនមានពិការភាព ក្នុងដំណើរការស្រាវជ្រាវ និងដំណើរការគោលនយោបាយ។

អាទិភាព និងអនុសាសន៍សំខាន់ៗដែលត្រូវបានកំណត់ក្នុងអំឡុងការពិភាក្សាក្រុមគោលដៅ៖

- **ភាពងាយស្រួលផ្នែកបរិស្ថានរូបវន្ត នៅតែជាឧបសគ្គចម្បងមួយ។** ទីកន្លែងប្រជុំ សាលារៀន និងសាលាឃុំជាច្រើន មិនបង្កភាពងាយស្រួលសម្រាប់អ្នកជិះរទេះរុញ ឬអ្នកដែលលំបាកធ្វើដំណើរ។ កង្វះផ្លូវជម្រាល កន្លែងអង្គុយដែលងាយស្រួលចេញចូល និងមធ្យោបាយធ្វើដំណើរដែលអាចទុកចិត្តបាន នៅតែបន្តរារាំងការចូលរួម ជាពិសេសនៅតំបន់ជនបទ។

- **ជារឿយៗ ការប្រាស្រ័យទាក់ទង និងឧបករណ៍ស្រាវជ្រាវ ផាត់ចេញជនមានពិការភាព។** ការបកប្រែភាសាសញ្ញាកម្រមានផ្តល់ជូន កម្រងសំណួរមិនត្រូវបានកែសម្រួល ហើយទម្រង់ប្រាស្រ័យទាក់ទងជាជម្រើសផ្សេងទៀតកម្រត្រូវបានប្រើប្រាស់ណាស់។ ក្នុងករណីខ្លះ គ្រួសារមួយចំនួនត្រូវបានគេរំលងចោលទាំងស្រុង ដោយសារអ្នកប្រមូលទិន្នន័យសន្មតថាការចូលរួមនឹងចំណាយពេលយូរ ឬស្មុគស្មាញពេក។

- **ឧបសគ្គផ្នែកហិរញ្ញវត្ថុ កាន់តែរឹតត្បិតការចូលរួម។** ការចំណាយលើការធ្វើដំណើរ ការខាតបង់ពេលវេលាធ្វើការ និងតម្រូវការជំនួយការផ្ទាល់ខ្លួន កម្រទទួលបានការប៉ះប៉ូវសងណាស់ ដែលធ្វើឱ្យជនមានពិការភាពជួបការលំបាកក្នុងការចូលរួមក្នុងការពិគ្រោះយោបល់ ឬការសម្ភាសន៍។

- **កម្សោយក្នុងការអនុវត្តគោលនយោបាយស្តីពីពិការភាព កាត់បន្ថយផលជះជាក់ស្តែង។** កម្ពុជាមានយន្តការ ដូចជាប័ណ្ណសម្គាល់ជនមានពិការភាព ប៉ុន្តែអ្នកចូលរួមបានលើកឡើងថា អត្ថប្រយោជន៍នៅមានកម្រិត ដោយសារការផ្តល់សេវាមិនជាប់លាប់ ការអនុវត្តច្បាប់នៅទន់ខ្សោយ និងគម្លាតរវាងបទប្បញ្ញត្តិច្បាប់ និងការគាំទ្រជាក់ស្តែង។

- **ការរើសអើងសង្គម និងកង្វះភាពជាតំណាង ធ្វើឱ្យមានការផាត់ចេញកាន់តែខ្លាំង។** អ្នកចូលរួមបានរៀបរាប់ពីការណ៍ដែលពួកគេត្រូវបានរារាំងមិនឱ្យនិយាយក្នុងការពិភាក្សាសហគមន៍ ហើយកម្រឃើញជនមានពិការភាព មានតំណាងនៅក្នុងក្រុមស្រាវជ្រាវ គណៈកម្មាធិការមូលដ្ឋាន ឬមជ្ឈដ្ឋានធ្វើសេចក្តីសម្រេចណាស់។ បញ្ហានេះបានញ៉ាំងឱ្យបាត់បង់ទំនុកចិត្ត និងជួយពង្រឹងដល់ការយល់ឃើញថា ទស្សនៈរបស់ពួកគេគឺមិនសូវសំខាន់។

- **ឧបសគ្គខុសៗគ្នា ទៅតាមប្រភេទពិការភាព និងបរិបទ។** អ្នកចូលរួមដែលមានពិការភាពគ-ថ្លង់ បានគូសបញ្ជាក់ពីការផាត់ចេញជាបន្តបន្ទាប់ពីសេវាសាធារណៈ មូលដ្ឋានសុខាភិបាល ការអប់រំ និងដំណើរការផ្តល់អាជ្ញាប័ណ្ណ/លិខិតអនុញ្ញាត ដោយសារឧបសគ្គក្នុងការប្រាស្រ័យទាក់ទង។ អ្នកចូលរួមដែលមានកម្សោយគំហើញ បានលើកឡើងពីគម្លាតពាក់ព័ន្ធនឹងបច្ចេកវិទ្យាជំនួយ ការយល់ដឹងមានកម្រិតនៅក្នុងស្ថាប័ន និងផលប៉ះពាល់ផ្នែកចិត្តសង្គម ដូចជា កង្វះទំនុកចិត្ត និងភាពថប់បារម្ភ។ អក្ខរកម្ម និងការអប់រំមានកម្រិត ជាពិសេសក្នុងចំណោមអ្នកចូលរួមដែលមានពិការភាពគ-ថ្លង់ និងជនមានពិការភាពនៅតំបន់ជនបទ កាន់តែរឹតត្បិតដល់ការចូលរួមប្រកបដោយអត្ថន័យ នៅក្នុងការស្រាវជ្រាវដ៏ស្មុគស្មាញ ឬការពិភាក្សាគោលនយោបាយ។

- **ការពិគ្រោះយោបល់ដែលគ្មានការតាមដានបន្ត ធ្វើឱ្យបាត់ទំនុកចិត្ត និងការចូលរួម។** ឆ្លងកាត់ការពិភាក្សាជាមួយអង្គការរបស់ជនមានពិការភាព និងអង្គការបម្រើផលប្រយោជន៍ជនមានពិការភាព អ្នកចូលរួមបានរាយការណ៍ថា ពួកគេត្រូវបានគេពិគ្រោះយោបល់ម្តងហើយម្តងទៀត តាមរយៈសិក្ខាសាលា និងការស្រាវជ្រាវ ប៉ុន្តែឃើញមានទិន្នន័យតិចតួចណាស់ដែលបញ្ជាក់ថា ធាតុចូលរបស់ពួកគេបាននាំទៅរកសកម្មភាពជាក់ស្តែង ឬការផ្លាស់ប្តូរគោលនយោបាយ។ យន្តការទទួលមតិត្រឡប់អន់ខ្សោយ គួបផ្សំនឹងភាពខ្វះចន្លោះជាបន្តបន្ទាប់ក្នុងការបង្កភាពងាយស្រួល បានញ៉ាំងឱ្យមានភាពនឿយណាយ និងអារម្មណ៍លែងសូវចង់ចូលរួម។

## អ្នកចូលរួមបានផ្តល់អនុសាសន៍ច្បាស់លាស់ និងជាក់ស្តែង ដើម្បីដោះស្រាយគម្លាត/ភាពចន្លោះទាំងនេះ។

អ្នកចូលរួមតែងតែសង្កត់ធ្ងន់ថា ការបង្កើនការចូលរួមទាមទារឱ្យមានលើសពីការអញ្ជើញ គឺត្រូវឈានដល់បរិយាបន្ន និងឥទ្ធិពលប្រកបដោយអត្ថន័យ។ ពោលគឺត្រូវធានាថា ជនមានពិការភាពមិនត្រឹមតែមានវត្តមានប៉ុណ្ណោះទេ ប៉ុន្តែក៏អាចចូលរួមប្រកបដោយប្រសិទ្ធភាព និងជះឥទ្ធិពលលើលទ្ធផលផងដែរ។

- ធានាឱ្យមានផាសុកសមរម្យនៅគ្រប់ដំណើរការនៃការចូលរួម រួមទាំងការផ្តល់អ្នកបកប្រែភាសាសញ្ញា ដែលឈរនៅទីតាំងត្រឹមត្រូវ និងទទួលបានការគាំទ្រ ការផ្តល់ឯកសារដែលបង្កភាពងាយស្រួលជាមុន ជំនួយការផ្ទាល់ខ្លួន ការសម្រាកឱ្យបានគ្រប់គ្រាន់ និងការឧបត្ថម្ភគាំទ្រដល់ការធ្វើដំណើរជាក់ស្តែង។
- កែលម្អវិធីសាស្ត្រប្រាស្រ័យទាក់ទង ដោយប្រើប្រាស់ទម្រង់ដែលបង្កភាពងាយស្រួល ដូចជា វីដេអូភាសាសញ្ញាដែលមានអក្សររត់ពីក្រោម មាតិកាសំឡេង អត្ថបទសាមញ្ញ និងវេទិកាឌីជីថល ដូចជា Facebook និង Telegram ដើម្បីទៅកាន់ដល់ក្រុមចម្រុះ។
- ពង្រឹងការចូលរួមតាមរយៈអង្គការតំណាងជនមានពិការភាព និងអភិក្រមផ្អែកលើសហគមន៍ ហើយទន្ទឹមនឹងនោះ ត្រូវបើកឱកាសឱ្យមានការចូលរួមដោយផ្ទាល់កាន់តែច្រើនពីសំណាក់ជនមានពិការភាព នៅក្នុងដំណើរការស្រាវជ្រាវ និងការពិភាក្សា ជាពិសេសនៅតំបន់ក្រៅពីរាជធានីភ្នំពេញ។
- ដាក់បញ្ចូលជនមានពិការភាពដោយផ្ទាល់ទៅក្នុងការរៀបចំ និងការអនុវត្តការស្រាវជ្រាវ រួមទាំងក្នុងនាមជាអ្នកប្រមូលទិន្នន័យ និងអ្នកសម្របសម្រួល ដើម្បីបង្កើនទំនុកចិត្ត ភាពពាក់ព័ន្ធ និងគុណភាពនៃទិន្នន័យ។
- កែសម្រួលវិធីសាស្ត្រស្រាវជ្រាវ ដោយប្រើប្រាស់វិធីសាស្ត្របែបរៀបរាប់ សន្ទនា និងបរិយាបន្នច្រើនជាងមុន ជាជាងវិធីសាស្ត្រដែលមានលក្ខណៈបច្ចេកទេសខ្លាំង ដើម្បីផ្តល់ការគាំទ្រកាន់តែប្រសើរដល់ការចូលរួមប្រកបដោយអត្ថន័យ។ ងាកចេញពីអភិក្រមផ្អែកលើភាពសប្បុរស ដោយផ្តោតអាទិភាពលើការអភិវឌ្ឍជំនាញ កម្មសិក្សា និងការកសាងសមត្ថភាព
- ទន្ទឹមនឹងការចូលរួមជាប់លាប់ជាមួយរដ្ឋាភិបាល ដើម្បីប្រែក្លាយទិន្នន័យទៅជាសកម្មភាពជាក់ស្តែង និងគាំទ្រដល់បរិយាបន្នរយៈពេលវែង។

## ៣.៣.៤. បរិយាបន្នសង្គម (ជាតិពន្ធុ អត្តសញ្ញាណជាជនជាតិដើមភាគតិច យេនឌ័រ ទំនោរផ្លូវភេទ ភូមិសាស្ត្រ ស្ថានភាពសេដ្ឋកិច្ចសង្គម អាយុ)

ជាតិពន្ធុ អត្តសញ្ញាណជាជនជាតិដើមភាគតិច យេនឌ័រ ទំនោរផ្លូវភេទ ភូមិសាស្ត្រ អាយុ និងស្ថានភាពសេដ្ឋកិច្ចសង្គម សុទ្ធសឹងជាកត្តាដែលញ៉ាំងឱ្យមានការផាត់ចេញពីដំណើរការស្រាវជ្រាវ និងដំណើរការគោលនយោបាយនៅកម្ពុជា។ ការផាត់ចេញនេះស្ដែងឡើងតាមរយៈយន្តការស្ថាប័ន សង្គម និងសេដ្ឋកិច្ចដែលកើតឡើងដដែលៗ និងកំណត់ថាតើនរណាអាចចូលរួមបាន ថាតើចំណេះដឹងរបស់នរណាត្រូវបានទទួលស្គាល់ និងថាតើតថភាពរបស់នរណាដែលត្រូវបានឆ្លុះបញ្ចាំងជាចុងក្រោយនៅក្នុងគោលនយោបាយ។ យន្តការទាំងនេះតែងតែផ្ដោតអាទិភាពលើប្រជាជនដែលនិយាយភាសាខ្មែរ រស់នៅទីប្រជុំជន និងទទួលបានការទទួលស្គាល់ជាផ្លូវការ ប៉ុន្តែក្នុងពេលជាមួយគ្នានោះផាត់ចេញក្រុមផ្សេងទៀត ដែលបណ្ដាលឱ្យមានគម្លាតទិន្នន័យ និងចំណុចខ្វះខាតក្នុងការតាក់តែងគោលនយោបាយជាបន្តបន្ទាប់ ។

### *ឧបសគ្គកម្រិតប្រព័ន្ធ៖ ការអនុវត្តគោលនយោបាយ គម្លាតទិន្នន័យ និងទំនុកចិត្ត*

ភាសា និងការរៀបចំការពិគ្រោះយោបល់ គឺជាកត្តាមួយដែលតែងជំរុញឱ្យមានការផាត់ចេញ។ ឧបករណ៍ស្រាវជ្រាវ និងការពិគ្រោះយោបល់លើគោលនយោបាយ ធ្វើឡើងជាភាសាខ្មែរ[៤៩] និងពឹងផ្អែកលើទម្រង់កិច្ចប្រជុំផ្លូវការ ដែលសន្មតថា អ្នកចូលរួមចេះអាន និងសរសេរ មានទំនុកចិត្តក្នុងការនិយាយជាសាធារណៈ និងស៊ាំនឹងនីតិវិធីរដ្ឋបាល។ សហគមន៍ជនជាតិដើមភាគតិចនៅខេត្តមណ្ឌលគិរី និងរតនគិរី ព្រមទាំងក្រុមជនជាតិភាគតិចនៅខេត្តបាត់ដំបង និងរាជធានីភ្នំពេញ បានរៀបរាប់ថា ពួកគេមានវត្តមាននៅក្នុងការពិគ្រោះយោបល់ ប៉ុន្តែមិនអាចចូលរួមប្រកបដោយអត្ថន័យបានទេ៖ *"យើងចូលរួមកិច្ចប្រជុំ ប៉ុន្តែយើងមិនសូវយល់ពីអ្វីដែលគេកំពុងពិភាក្សានោះទេ។ ដល់ពេលយើងតាមទាន់ការពិភាក្សាបានរំលងហួសបាត់ទៅហើយ។"*

អ្នកចូលរួមក៏បានចែករំលែកផងដែរថា ពួកគេត្រូវបានសួរថាតើពួកគេយល់ព្រមចំពោះបញ្ហា ឬអនុសាសន៍ជាក់លាក់ណាមួយដែរ ឬទេ ប៉ុន្តែពួកគេមិនសូវយល់ថាតើការយល់ព្រមនោះមានន័យយ៉ាងណាសម្រាប់ពួកគេ ឬថាតើវានឹងត្រូវប្រែក្លាយទៅជាអ្វីនៅពេលអនុវត្តជាក់ស្ដែងនោះទេ។ ចំណុចនេះបណ្ដាលឱ្យមានការចូលរួមដោយគ្មានការយល់ដឹង ដែលរឹតត្បិតលទ្ធភាពចូលរួមប្រកបដោយអត្ថន័យ ឬឥទ្ធិពលលើលទ្ធផល។

ប្រព័ន្ធរដ្ឋបាល និងភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ច រឹតតែបង្កើតឱ្យមានការផាត់ចេញបន្ថែមទៀត។ សហគមន៍ជនជាតិវៀតណាមបានរៀបរាប់ពីរបៀបដែលការខ្វះខាតឯកសារអត្រានុកូលដ្ឋាន បានរឹតត្បិតមិនត្រឹមតែលទ្ធភាពទទួលបានសេវាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងរឹតត្បិតដំណើរការស្រាវជ្រាវ និងការពិគ្រោះយោបល់ដែលពឹងផ្អែកលើឯកសារកំណត់ត្រាផ្លូវការផងដែរ។ អ្នកចូលរួមម្នាក់បានពន្យល់ថា៖ *"ប្រសិនបើឈ្មោះរបស់អ្នកមិនមាននៅក្នុងប្រព័ន្ធទេ អ្នកនឹងមិនត្រូវបានគេអញ្ជើញឡើយ។ វាហាក់ដូចជាអ្នកមិនមានវត្តមាននៅលើលោកនេះអញ្ចឹង។"* បញ្ហានេះបណ្ដាលឱ្យមានការផាត់ចេញពីឱកាសចូលរួម និងការផាត់ចេញពីសំណុំទិន្នន័យ ដែលផ្ដល់មូលដ្ឋានព័ត៌មានដល់តាក់តែងគោលនយោបាយ។

ភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ច និងឧបសគ្គផ្នែកភូមិសាស្ត្រ ក៏បានរឹតត្បិតការចូលរួមផងដែរ។ គ្រួសារនៅជនបទ និងគ្រួសារមានប្រាក់ចំណូលទាប តែងតែគូសបញ្ជាក់ពីការចំណាយលើការចូលរួម។ ការចំណាយលើការធ្វើដំណើរ ការបាត់បង់ប្រាក់ឈ្នួលប្រចាំថ្ងៃ និងលទ្ធភាពមានកម្រិតក្នុងការប្រើប្រាស់អ៊ីនធឺណិត បានកាត់បន្ថយលទ្ធភាពរបស់ពួកគេក្នុងការចូលរួមក្នុងការពិគ្រោះយោបល់ ឬសហការជាមួយអ្នកប្រមូលទិន្នន័យ។ អ្នកឆ្លើយសំណួរម្នាក់ដែលរស់នៅជនបទបានកត់សម្គាល់ថា៖

> “ប្រសិនបើខ្ញុំទៅប្រជុំនៅថ្នាក់ស្រុក ខ្ញុំនឹងបាត់បង់ចំណូលពេញមួយថ្ងៃ។
> គ្មាននរណាម្នាក់ផ្ដល់សំណងសម្រាប់រឿងនេះទេ ដូច្នេះហើយទើបខ្ញុំឈប់ទៅ។”

[៤៩] ជនជាតិភាគតិច និងជនជាតិដើមភាគតិចនៅកម្ពុជា និយាយភាសាចម្រុះផ្សេងៗ ក្រៅពីភាសាខ្មែរ។ ការពិគ្រោះយោបល់ និងឧបករណ៍ស្រាវជ្រាវដែលប្រើប្រាស់តែភាសាខ្មែរ បានរឹតត្បិតការចូលរួមប្រកបដោយអត្ថន័យសម្រាប់អ្នកដែលមិនសូវមានចំណេះដឹងភាសាខ្មែរ ជាពិសេសស្ត្រី យុវជន និងចាស់ជរា។

ឧបសគ្គទាំងនេះកម្រត្រូវបានគេគិតគូរនៅក្នុងការរៀបចំការស្រាវជ្រាវណាស់ ហើយវាបានបណ្តាលឱ្យមានទិន្នន័យដែលភាគច្រើនតំណាងលើសលុបតែប្រជាជនដែលមានលំនឹងសេដ្ឋកិច្ច រស់នៅទីប្រជុំជន និងត្រូវបានទទួលស្គាល់ជាផ្លូវការប៉ុណ្ណោះ។ នៅកន្លែងដែលមានការចុះប្រមូលទិន្នន័យដល់មូលដ្ឋាន ឬមានការផ្តល់សំណងសម្រាប់ការចំណាយពេលចូលរួម គ្រួសារក្រីក្រ និងគ្រួសារនៅតំបន់ដាច់ស្រយាលមានការចូលរួមកាន់តែច្រើន ដែលនេះបង្ហាញថា ការផាត់ចេញនៅទីនេះ មិនមែនបណ្តាលមកពីកង្វះចំណាប់អារម្មណ៍ទេ ប៉ុន្តែភាគច្រើនបណ្តាលមកពីកង្វះភាពអំណោយផលផ្នែករចនាសម្ព័ន្ធ។

នៅកន្លែងដែលកិច្ចខិតខំប្រឹងប្រែងផ្នែកបរិយាបន្នត្រូវបានកែសម្រួល ឧទាហរណ៍ តាមរយៈការធ្វើការជាមួយអ្នកដឹកនាំសហគមន៍ ឬការប្រើប្រាស់ភាសាក្នុងមូលដ្ឋាន នៅក្នុងកម្មវិធីអប់រំ កសិកម្ម ឬការគ្រប់គ្រងធនធានធម្មជាតិ ការចូលរួមមានភាពប្រសើរឡើង។ ទោះជាយ៉ាងណា ឧទាហរណ៍ទាំងនេះត្រូវបានពណ៌នាថាមានលក្ខណៈផ្អែកតាមគម្រោង ជាជាងការអនុវត្តជាស្តង់ដារទូទៅ។ មេរៀនដ៏សំខាន់នោះគឺបរិយាបន្នមានភាពប្រសើរឡើង នៅពេលដែលយន្តការនៃការចូលរួមត្រូវបានកែសម្រួលឱ្យស្របទៅនឹងសហគមន៍ ជាជាងការរំពឹងថាសហគមន៍ត្រូវសម្របខ្លួនទៅតាមទម្រង់ស្ថាប័នដ៏តឹងរ៉ឹង។

## ឧបសគ្គផ្នែកសំឡេងតំណាង និងការចូលរួម៖ បទដ្ឋាន សុវត្ថិភាព និងអត្តសញ្ញាណ

សូម្បីតែនៅពេលដែលក្រុមងាយរងគ្រោះមានវត្តមាន ក៏បទដ្ឋានសង្គម និងទំនាក់ទំនងអំណាច នៅតែជាកត្តា កំណត់ថាតើសំឡេងរបស់នរណាមានទម្ងន់/ឥទ្ធិពល។ យុវជននៅតាមបណ្តាខេត្តនានា បានសម្តែងឆន្ទៈចង់ចូលរួម ប៉ុន្តែក៏មានការខកចិត្តផងដែរ ដែលការរួមចំណែករបស់ពួកគេកម្រមានឥទ្ធិពលលើការសម្រេចចិត្ត។ អ្នកចូលរួមបានលើកឡើងជាច្រើនលើកច្រើនសាថា កិច្ចប្រជុំភូមិស្ថិតក្រោមការចាត់ចែង និងការសម្រេចដោយសមាជិកសហគមន៍ដែលមានវ័យចំណាស់ សូម្បីតែលើបញ្ហាដែលជះឥទ្ធិពលផ្ទាល់ដល់យុវជនក៏ដោយ។

អ្នកចូលរួមដែលជាក្រុមស្រលាញ់ភេទដូចគ្នា បានលើកឡើងអំពីទម្រង់នៃការផាត់ចេញដែលកាន់តែធ្ងន់ធ្ងរជាងនេះ។ អ្នកចូលរួមជាច្រើនបានរៀបរាប់ថា ពួកគេមិនត្រូវបានគេអញ្ជើញឱ្យចូលរួមក្នុងការពិគ្រោះយោបល់ទាល់តែសោះ ខណៈដែលអ្នកខ្លះទៀតបានលាក់បាំងអត្តសញ្ញាណរបស់ពួកគេ ដោយសារការភ័យខ្លាចការមាក់ងាយ ការបៀតបៀនដោយពាក្យសម្តី ឬការលោតត្រដាងជាសាធារណៈ។ នៅរាជធានីភ្នំពេញ អ្នកចូលរួមបាននិយាយអំពីការណ៍ដែលពួកគេត្រូវបានគេសើចចំអក ឬគ្មានអ្នកអើពើនៅក្នុងកិច្ចប្រជុំសហគមន៍។ នៅខេត្តកំពត ការគ្មានការការពារតាមផ្លូវច្បាប់ បានពង្រីកហានិភ័យទាំងនេះ។ ដូចដែលអ្នកចូលរួមម្នាក់បានពណ៌នាថា៖

> “ប្រសិនបើគេដឹងថា អ្នកជានរណា អ្នកគ្មានសុវត្ថិភាពទេ ដូច្នេះ អ្នកសុខចិត្តនៅស្ងៀម ឬមិនមកតែម្តង។”

នៅកន្លែងដែលការពិគ្រោះយោបល់ធានាបាននូវការរក្សាការសម្ងាត់ ការធ្វើការតាមរយៈអន្តរការីដែលគួរឱ្យទុកចិត្ត ឬការបង្កើតចន្លោះសុវត្ថិភាពដាច់ដោយឡែក អ្នកចូលរួមដែលជាក្រុមស្រលាញ់ភេទដូចគ្នា បានលើកឡើងអំពីការចូលរួមដែលបើកចំហជាងមុន និងការរួមចំណែកដែលកាន់តែមានភាពពាក់ព័ន្ធ។ ឧទាហរណ៍ទាំងនេះបង្ហាញថា ការចូលរួមគឺអាចធ្វើទៅបាន នៅពេលដែលគេបានទទួលស្គាល់ និងខិតខំកាត់បន្ថយហានិភ័យ ជាជាងទម្លាក់លើបុគ្គលផ្ទាល់។

## ឥទ្ធិពល និងភាពជាតំណាង៖ តើចំណេះដឹងរបស់នរណាដែលត្រូវបានយកជាការ

ការចូលរួមមិនប្រាកដថាប្រែក្លាយទៅជាឥទ្ធិពលរហូតនោះទេ។ នៅតាមក្រុមនានា អ្នកចូលរួមបានរៀបរាប់ថា ពួកគេមិនសូវមានសមត្ថភាពជះឥទ្ធិពលលើលទ្ធផលនៃការស្រាវជ្រាវ ឬការសម្រេចចិត្តលើគោលនយោបាយ។

ជារឿយៗ ក្រុមងាយរងគ្រោះមានតំណាងតិចតួចនៅក្នុងការធ្វើសេចក្តីសម្រេច ហើយចំណេះដឹងរបស់ពួកគេមិនសុទ្ធតែត្រូវបានទទួលស្គាល់ថាត្រឹមត្រូវ ឬសមស្របនោះទេ។ ដំណើរការពិគ្រោះយោបល់ អាចនឹងមានអ្នកចូលរួមចម្រុះ ប៉ុន្តែការធ្វើសេចក្តីសម្រេចភាគច្រើននៅតែអាស្រ័យលើតួអង្គដែលមានអំណាចជាង ឬត្រូវបានទទួលស្គាល់ជាផ្លូវការជាង។

អ្នកចូលរួមក៏បានគូសបញ្ជាក់ផងដែរថា សូម្បីតែនៅពេលដែលពួកគេត្រូវបានស្នើឱ្យផ្តល់ធាតុចូល ក៏ពួកគេមិនសុទ្ធតែដឹងថាតើការរួមចំណែករបស់ពួកគេត្រូវបានគេយកទៅប្រើប្រាស់ដូចម្តេច ឬថាតើវាមានឥទ្ធិពលដូចម្តេចលើការសម្រេចចិត្តចុងក្រោយនោះទេ។ ចំណុចនេះរឹតតែញ៉ាំងឱ្យមានការយល់ឃើញថា ការចូលរួមមានលក្ខណៈត្រឹមតែជានិមិត្តរូប ជាជាងជាការចូលរួមដែលនាំមកនូវលទ្ធផលជាក់ស្តែង។

---

## ផលវិបាកកម្រិតប្រព័ន្ធ៖ គម្លាតទិន្នន័យ និងចំណុចខ្វះខាតក្នុងគោលនយោបាយ

លំនាំនៃការផាត់ចេញទាំងនេះ ជះឥទ្ធិពលដោយផ្ទាល់លើអ្វីដែលគោលនយោបាយមើលឃើញ និងអ្វីដែលគោលនយោបាយមើលរំលង។ នៅពេលដែលសហគមន៍ជនជាតិដើមភាគតិចមិនអាចលើកឡើងពីអាទិភាពរបស់ពួកគេ គោលនយោបាយនៅថ្នាក់មូលដ្ឋាននឹងមើលរំលងការអនុវត្តកសិកម្មបែបប្រពៃណី ដូចដែលអ្នកចូលរួមនៅខេត្តកំពតបានលើកឡើង។ នៅពេលដែលសហគមន៍ដែលគ្មានឯកសារបញ្ជាក់អត្តសញ្ញាណ បាត់ឈ្មោះពីសំណុំទិន្នន័យ គម្លាតនៃសេវានឹងនៅតែមិនស្តែងឱ្យឃើញ។ នៅពេលដែលយុវជន ក្រុមស្រលាញ់ភេទដូចគ្នា និងជនជាតិភាគតិច រឹតត្បិតខ្លួនឯងមិនបញ្ចេញមតិ ឬត្រូវបានផាត់ចេញ ការជជែកដេញដោលលើគោលនយោបាយ នឹងងាកទៅរកទស្សនៈរបស់ក្រុមដែលមានឥទ្ធិពលជាងដោយស្វ័យប្រវត្តិ។
អ្នកចូលរួមម្នាក់បានឆ្លុះបញ្ចាំងថា៖

> “គេនិយាយថា គោលនយោបាយគឺសម្រាប់មនុស្សគ្រប់រូប ប៉ុន្តែមនុស្សដូចពួកយើងមិនដែលបានចូលរួមទេ នៅពេលមានការពិភាក្សាអំពីគោលនយោបាយ។”

ផលអវិជ្ជមានដែលទទួលបាន មិនមែនត្រឹមតែជាការចូលរួមមានកម្រិតប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាការបង្កើតឱ្យមានចំណុចខ្វះខាតបែបរចនាសម្ព័ន្ធក្នុងគោលនយោបាយ ដែលវាយតម្លៃទាបចំពោះភាពចម្រុះនៅក្នុងសហគមន៍ ផាត់ចេញប្រជាពលរដ្ឋសំខាន់ៗ និងធ្វើឱ្យថយចុះប្រសិទ្ធភាពគោលនយោបាយ។ ដូច្នេះ ការពង្រឹងបរិយាបន្នសង្គម ទាមទារលើសពីការពង្រីកការផ្សព្វផ្សាយទៅទៀត។ វាទាមទារឱ្យមានការផ្លាស់ប្តូរប្រកបដោយការគិតគូរច្បាស់លាស់ ទៅលើថាតើទិន្នន័យត្រូវបានបង្កើតឡើងយ៉ាងដូចម្តេច ថាតើចំណេះដឹងរបស់នរណាត្រូវបានចាត់ទុកថាត្រឹមត្រូវ និងសមស្រប និងថាតើដំណើរការចូលរួមត្រូវបានរៀបចំឡើងបែបណា ដើម្បីទប់ទល់នឹងហានិភ័យ ជាជាងទម្លាក់ទៅឱ្យអ្នកដែលកំពុងងាយរងគ្រោះស្រាប់។

## ៣.៣.៥. អន្តរប្រសព្វ៖ ឧបសគ្គត្រួតគ្នា និងតម្រូវការដែលមិនទាន់បានបំពេញ

សហគមន៍នៅទូទាំងប្រទេសកម្ពុជា ជួបប្រទះការផាត់ចេញ មិនមែនដោយសារកត្តាតែមួយនោះទេ ប៉ុន្តែគឺដោយសារគុណវិបត្តិត្រួតគ្នាយ៉ាងច្រើន។ យេនឌ័រ ពិការភាព ជាតិពន្ធុ ភូមិសាស្ត្រ និងភាពក្រីក្រ បានជះឥទ្ធិពលលើគ្នាទៅវិញទៅមកបង្កើតជាការផាត់ចេញជាច្រើនកម្រិត ដែលធ្វើឱ្យប៉ះពាល់ដល់លទ្ធភាពទទួលបានសេវា ការចូលរួមក្នុងការស្រាវជ្រាវ និងភាពជាតំណាងនៅក្នុងគោលនយោបាយ។ ឧបសគ្គត្រួតគ្នាទាំងនេះ កម្រត្រូវបានចាប់យកនៅក្នុងការប្រមូលទិន្នន័យបែបស្តង់ដារណាស់ ដែលធ្វើឱ្យគោលនយោបាយមិនអាចឆ្លើយតបទៅនឹងតថភាពជីវិតជាក់ស្តែងរបស់អ្នកដែលរងផលប៉ះពាល់ខ្លាំងបំផុត។

### *ឧបសគ្គត្រួតគ្នាដែលរារាំងដល់លទ្ធភាពទទួលបាន និងការចូលរួម*

ឧបសគ្គដែលមានទម្រង់ជាអន្តរប្រសព្វ បានរឹតត្បិតយ៉ាងខ្លាំងដល់ការចូលរួមនៅក្នុងវដ្តទាំងមូលនៃគោលនយោបាយ និងការស្រាវជ្រាវ។

ស្ត្រីមានពិការភាពនៅជនបទ ប្រឈមនឹងឧបសគ្គជាច្រើន។ ជារួម ឧបសគ្គក្នុងការធ្វើដំណើរ ការរើសអើងក្នុងសង្គម ការទទួលខុសត្រូវលើកិច្ចការថែទាំ និងលទ្ធភាពមានកម្រិតក្នុងការទទួលបានព័ត៌មាន បានរឹតត្បិតការចូលរួមរបស់ពួកគាត់ជាមួយសេវា និងដំណើរការគោលនយោបាយ។ អ្នកចូលរួមម្នាក់បានពន្យល់ថា៖

> “ ខ្ញុំមិនអាចធ្វើដំណើរទៅសាលាស្រុកតែម្នាក់ឯងបានទេ ហើយទោះបីជាខ្ញុំអាចទៅបានក៏ដោយ ក៏គេមិនយកមតិយោបល់របស់យើងជាការដែរ។ ”

ស្ត្រីជនជាតិដើមភាគតិច ជួបប្រទះការផាត់ចេញបន្ថែមមួយកម្រិតទៀត។ ឧបសគ្គផ្នែកភាសា ការមិនសូវចេះអក្សរ និងចម្ងាយផ្លូវឆ្ងាយពីកន្លែងអប់រំ ឬមូលដ្ឋានសុខាភិបាល ធ្វើឱ្យពួកគាត់ពិបាកចូលរួមក្នុងកម្មវិធីផ្សេងៗ។ ដូចដែលស្ត្រីជនជាតិដើមភាគតិចម្នាក់បានគូសបញ្ជាក់ថា៖

> “ សូម្បីតែនៅពេលមានកម្មវិធីក៏ដោយ ក៏សេចក្តីជូនដំណឹងសរសេរជាភាសាខ្មែរដែលខ្ញុំមិនយល់នោះទេ។ ពេលខ្លះ សាលារៀននៅឆ្ងាយពេក ដែលធ្វើឱ្យខ្ញុំមិនអាចចូលរួមជាមួយកូនៗបាន។ ”

យុវជនមកពីគ្រួសារមានប្រាក់ចំណូលទាប បានរៀបរាប់ពីអារម្មណ៍រងផលវិបាកទ្វេដង បើធៀបនឹងយុវជននៅទីក្រុង។ យុវជនម្នាក់បានលើកឡើងថា៖

> “ យើងចង់ចូលរួម ប៉ុន្តែយើងត្រូវធ្វើការដើម្បីរស់" ។ ”

ចំណុចនេះបានគូសបញ្ជាក់ពីរបៀបដែលការផាត់ចេញផ្នែកសេដ្ឋកិច្ច និងសង្គម ជួយពង្រឹងគ្នាទៅវិញទៅមក។ ឧទាហរណ៍ទាំងនេះបង្ហាញថា ឧបសគ្គមិនបានកើតឡើងដោយឯកឯងនោះទេ។ ផ្ទុយទៅវិញ ឧបសគ្គទាំងនោះជួយពង្រឹងគ្នាទៅវិញទៅមក ដែលកាត់បន្ថយទាំងលទ្ធភាពទទួលបានឱកាសចូលរួម និងសមត្ថភាពចូលរួមប្រកបដោយអត្ថន័យ។

## ចំណាកស្រុក បន្ទុកកិច្ចការថែទាំ និងការផ្លាស់ប្តូរការទទួលខុសត្រូវ

ការធ្វើចំណាកស្រុក បានបង្កើតភាពស្មុគស្មាញមួយកម្រិតទៀត។ ជារឿយៗ ស្ត្រីដែលរស់នៅឯស្រុកកំណើតត្រូវទទួលបន្ទុកថែទាំកុមារ ឬសាច់ញាតិចាស់ជរាកាន់តែច្រើន ខណៈដែលយុវជនអាចប្រឈមនឹងភាពងាយរងគ្រោះផ្នែកការងារ/កម្លាំងពលកម្ម ដោយសារគ្មានការគាំទ្រពីមនុស្សពេញវ័យ។ អ្នកចូលរួមម្នាក់ដែលជាចាស់ជរាបានឆ្លុះបញ្ចាំងថា៖

> “ កូនប្រសារស្រីរបស់យើងចេញទៅបាត់អស់ហើយ។ យើងត្រូវរ៉ាប់រងការងារស្រែចម្ការ និងមើលថែក្មេងៗដោយខ្លួនឯង។ យើងគ្មានពេលឯណាទៅចូលរួមប្រជុំ ឬសម្តែងក្តីកង្វល់របស់យើងទេ។" ”

សម្ពាធច្រើនកម្រិតទាំងនេះ បានរឹតត្បិតទាំងពេលវេលា និងសមត្ថភាពចូលរួមក្នុងដំណើរការស្រាវជ្រាវ ឬដំណើរការគោលនយោបាយ។ ការចូលរួម លែងសំខាន់ដូចការចិញ្ចឹមជីវិត និងទំនួលខុសត្រូវថែទាំគ្រួសារ។ ទោះបីជាវាមានសារៈសំខាន់យ៉ាងណាក៏ដោយ ក៏សក្តានុពលទាំងនេះកម្រត្រូវបានគេច្បាមយកនៅក្នុងការវិភាគការស្រាវជ្រាវ ឬការវិភាគគោលនយោបាយ ដែលច្រើនតែចាត់ទុកយេនឌ័រ អាយុ ឬស្ថានភាពទេសន្តរប្រវេសន៍ ជាអថេរដាច់ដោយឡែកពីគ្នា ជាជាងជាកត្តាដែលមានទំនាក់ទំនងលើគ្នាទៅវិញទៅមក។

---

## គម្លាតក្នុងការរៀបចំការស្រាវជ្រាវ និងប្រព័ន្ធទិន្នន័យ

ភាពមានកម្រិតនៃការដាក់បញ្ចូលអន្តរប្រសព្វ ស្តែងឱ្យឃើញច្បាស់បំផុតតាមរយៈរបៀបនៃការរៀបចំការស្រាវជ្រាវ និងរបៀបប្រមូលទិន្នន័យ។

សមាជិកសហគមន៍តែងលើកឡើងថា អង្កេត និងការពិគ្រោះយោបល់ មិនបានឆ្លុះបញ្ចាំងពីបញ្ហាប្រឈមរួមរបស់ពួកគេឡើយ។ សមាជិកសហគមន៍ម្នាក់បាននិយាយថា៖

> “ ពួកគេសួរសំណួរសាមញ្ញៗអំពីស្ត្រី ឬយុវជន ប៉ុន្តែមិនដែលសួរថាតើវាមានន័យយ៉ាងណាសម្រាប់យុវតីមានពិការភាពម្នាក់ ដែលរស់នៅឆ្ងាយពីតំបន់ផ្តល់សេវានោះទេ។ ”

ឧបករណ៍ស្រាវជ្រាវច្រើនតែសន្មតផ្តោតលើកត្តាអត្តសញ្ញាណតែមួយ ដោយមើលរំលងរបៀបដែលការទទួលរងការផាត់ចេញ កើនឡើងដោយសារកត្តាសង្គម សេដ្ឋកិច្ច និងភូមិសាស្ត្រ។ ចំណុចនេះធ្វើឱ្យគេទទួលបានទិន្នន័យតែមួយផ្នែក ឬមិនពេញលេញ ដែលមិនឆ្លុះបញ្ចាំងពីតថភាពជីវិតជាក់ស្តែង។

ផលវិបាកគឺច្បាស់លាស់៖ គុណវិបត្តិដែលត្រួតគ្នា ដូចជា អត្តសញ្ញាណជាក្មេងស្រីជនជាតិដើមភាគតិចដែលមានពិការភាព ឬស្ត្រីនៅជនបទដែលថែទាំសាច់ញាតិនៃគ្រួសារដែលធ្វើចំណាកស្រុក មិនត្រូវបានច្បាមយកជាប្រព័ន្ធទៅក្នុងសំណុំទិន្នន័យរបស់ក្រសួងឡើយ។ បើគ្មានព័ត៌មានទាំងនេះទេ គោលនយោបាយមិនអាចឆ្លើយតបបានសមស្របទៅនឹងឧបសគ្គជាក់ស្តែង និងហានិភ័យដែលប្រជាពលរដ្ឋទាំងនេះកំពុងប្រឈមមុខនោះទេ។

## ៣.៣.៦. អនុសាសន៍៖ ទស្សនៈរបស់សហគមន៍ស្តីពីការលុបបំបាត់ឧបសគ្គ និងការចាប់យកឱកាស

លទ្ធផលបង្ហាញថា ការបង្កើនការចូលរួមរបស់ស្ត្រី ជនមានពិការភាព ក្រុមស្រលាញ់ភេទដូចគ្នា និងក្រុមងាយរងគ្រោះផ្សេងទៀតនៅក្នុងសង្គម ទាមទារឱ្យមានការផ្លាស់ប្តូរជាក់ស្តែង និងមានធនធានគាំទ្រគ្រប់គ្រាន់ទៅលើរបៀបនៃការរៀបចំ និងអនុវត្តដំណើរការស្រាវជ្រាវ និងដំណើរការគោលនយោបាយ។ ការចូលរួមមិនត្រូវបានរឹតត្បិតដោយឆន្ទៈនោះទេ ប៉ុន្តែវាត្រូវបានរឹតត្បិតដោយឧបសគ្គផ្នែករចនាសម្ព័ន្ធ ឧបសគ្គផ្នែកនីតិវិធី និងឧបសគ្គក្នុងសង្គម ដែលលេចឡើងនៅគ្រប់ដំណាក់កាលនៃការចូលរួមចាប់ពីលទ្ធភាពទទួលបានរហូតដល់ឥទ្ធិពល។

ការដោះស្រាយឧបសគ្គទាំងនេះ ទាមទារឱ្យមានការផ្តោតលើសពីការពិគ្រោះយោបល់ដែលធ្វើឡើងតែមួយដង និងងាកទៅរកប្រព័ន្ធនៃការចូលរួមដែលកាន់តែប្រកបដោយបរិយាបន្ន និងមានការគិតគូរច្បាស់លាស់។ ខណៈដែលឧបសគ្គមួយចំនួនមានលក្ខណៈជាប្រព័ន្ធ (ឧ. ភាពក្រីក្រ បទដ្ឋានសង្គម និងគម្លាតពាក់ព័ន្ធនឹងឯកសារ) មានចំណុចចាប់ផ្តើមដ៏ច្បាស់លាស់ និងអាចអនុវត្តបាន នៅកម្រិតនៃការរៀបចំកម្មវិធី ការអនុវត្តការស្រាវជ្រាវ និងការចូលរួមពីស្ថាប័ន។

### ចំណុចចាប់ផ្តើមដែលមានសក្តានុពលបំផុត រួមមាន៖

#### ១ ការរៀបចំការចូលរួមដោយផ្អែកលើតថភាពជីវិតជាក់ស្តែង មិនមែនផ្អែកលើភាពងាយស្រួលរបស់ស្ថាប័នឡើយ

សមាជិកសហគមន៍នៅទូទាំងក្រុមទាំងអស់ បានសង្កត់ធ្ងន់ថា ការចូលរួមមានភាពប្រសើរឡើង នៅពេលដែលដំណើរការស្រាវជ្រាវ និងការចូលរួមក្នុងគោលនយោបាយ ផ្តោតលើឧបសគ្គជាក់ស្តែងរបស់ប្រជាពលរដ្ឋ ជាជាងភាពងាយស្រួលរបស់ស្ថាប័ន។ វិធីសាស្ត្របន្ទាន់បំផុតមួយដើម្បីកាត់បន្ថយឧបសគ្គ គឺការចូលរួមដែលកាន់តែមានភាពបត់បែន និងគិតគូរពីបរិបទ។ ការពិគ្រោះយោបល់ដែលធ្វើឡើងក្នុងអំឡុងម៉ោងរវល់ធ្វើកិច្ចការថៃទាំ ធ្វើកសិកម្ម ឬលក់ដូរនៅផ្សារ តែងតែផាត់ចេញស្ត្រី អ្នកស៊ីឈ្នួលប្រចាំថ្ងៃ និងអ្នកថែទាំ។ ការកែសម្រួលពេលវេលា ការផ្តល់វគ្គប្រជុំខ្លីៗ ឬបែងចែកពេលវេលាខុសៗគ្នា និងការអនុញ្ញាតឱ្យមានជម្រើសច្រើនសម្រាប់ការចូលរួម តែងត្រូវបានលើកឡើងថាជាកត្តាសម្រួលសមស្រប។

#### ២ ការកាត់បន្ថយការចំណាយផ្នែកសេដ្ឋកិច្ចលើការចូលរួម

ឧបសគ្គផ្នែកសេដ្ឋកិច្ចនៅតែជាកត្តាកំណត់ដ៏ចម្បងមួយ។ ការចំណាយលើការធ្វើដំណើរ ការបាត់បង់ប្រាក់ចំណូល និងការទទួលខុសត្រូវលើកិច្ចការថៃទាំកុមារ ប៉ះពាល់ដោយផ្ទាល់ថាតើមនុស្សអាចចូលរួមបាន ឬអត់។ អ្នកចូលរួមបានសង្កត់ធ្ងន់ថា ការចូលរួមច្រើនតែត្រូវបានគេចាត់ទុកថាជាការស្ម័គ្រចិត្ត ប៉ុន្តែការខាតបង់ឱកាសរកប្រាក់ចំណូលគឺមានទំហំធំធេង សម្រាប់គ្រួសារក្រីក្រ។ ការផ្តល់ប្រាក់ឧបត្ថម្ភការធ្វើដំណើរ ការផ្តល់ប្រាក់ឧបត្ថម្ភសម្រាប់ការចំណាយពេល ឬការដាក់បញ្ចូលការចូលរួមទៅក្នុងការជួបជុំសហគមន៍ដែលមានស្រាប់ ត្រូវបានគេមើលឃើញថាជាវិធានការត្រឹមត្រូវ សមស្រប និងចាំបាច់ ជាជាងគ្រាន់តែជាការលើកទឹកចិត្ត។ នៅកន្លែងដែលមានការគាំទ្របែបនេះ ការចូលរួមមានការកើនឡើង និងមានភាពចម្រុះជាងមុន។

#### ៣ ការដាក់បញ្ចូលការបង្កភាពងាយស្រួល និងការកែសម្រួលជាការអនុវត្តស្តង់ដារ

ការបង្កភាពងាយស្រួល និងការកែសម្រួលឧបករណ៍ បានក្លាយជាចំណុចដ៏សំខាន់សម្រាប់បរិយាបន្នប្រកបដោយអត្ថន័យ ជាពិសេសសម្រាប់ជនមានពិការភាព សហគមន៍ជនជាតិដើមភាគតិច និងអ្នកដែលមិនសូវចេះអក្សរ។ សហគមន៍បានគូសបញ្ជាក់ថា បរិយាបន្នមិនទាមទារដំណោះស្រាយស្មុគស្មាញនោះទេ ប៉ុន្តែវាទាមទារការរៀបចំផែនការ។ ការរៀបចំការពិគ្រោះយោបល់នៅទីកន្លែងដែលងាយស្រួលចេញចូល ការកែសម្រួលកម្រងសំណួរទៅជាទម្រង់ផ្ទាល់មាត់ ឬទម្រង់រូបភាព ការផ្តល់អ្នកបកប្រែភាសាសញ្ញា និងការប្រើប្រាស់ភាសាក្នុងមូលដ្ឋាន បានបង្កើនការចូលរួមយ៉ាងច្រើន។ ការគ្មានវិធានការទាំងនេះ អាចជាសញ្ញាបញ្ជាក់ថា គេមិនបានរំពឹងទុក ឬឱ្យតម្លៃលើការចូលរួមរបស់ក្រុមងាយរងគ្រោះឡើយ។

## ៤ ការពង្រឹងទំនុកចិត្តតាមរយៈភាពជាតំណាង និងអភិក្រមដែលផ្សារភ្ជាប់នឹងមូលដ្ឋាន

ទំនុកចិត្ត និងភាពជឿជាក់ ពាក់ព័ន្ធបំផុតទៅនឹងថាតើនរណាជាអ្នកធ្វើការស្រាវជ្រាវ និងដោយរបៀបណា។ អ្នកចូលរួមនៅតាមបណ្ដាខេត្តនានា បានលើកឡើងពីឆន្ទៈខ្ពស់ក្នុងការចូលរួម នៅពេលដែលអ្នកស្រាវជ្រាវឆ្លុះបញ្ចាំងពីអត្តសញ្ញាណរបស់ពួកគេ ឬបង្ហាញពីភាពស៊ាំទៅនឹងបរិបទក្នុងមូលដ្ឋាន។ ស្ត្រី ជនមានពិការភាព និងអ្នកចូលរួមដែលជាជនជាតិដើមភាគតិច បានឆ្លើយតបដោយបើកចំហជាងមុន នៅពេលដែលអ្នកប្រមូលទិន្នន័យគឺជាស្ត្រី ចេះនិយាយភាសាក្នុងមូលដ្ឋាន ឬត្រូវបានឧទ្ទេសនាមតាមរយៈរចនាសម្ព័ន្ធសហគមន៍ដែលគួរឱ្យទុកចិត្ត។ ចំណុចនេះបង្ហាញពីតម្លៃនៃការចូលរួមរបស់សហគមន៍ ក្នុងនាមជាអ្នកសម្របសម្រួលអ្នកស្រាវជ្រាវរួមគ្នា ឬអ្នកប្រមូលទិន្នន័យ ជាជាងការពឹងផ្អែកតែទៅលើក្រុមការងារខាងក្រៅ។

## ៥ ការពង្រឹងតម្លាភាព មតិត្រឡប់ និងគណនេយ្យភាពនៅក្នុងដំណើរការនៃការចូលរួម

សហគមន៍ក៏បានគូសបញ្ជាក់ពីសារៈសំខាន់នៃភាពច្បាស់លាស់ និងតម្លាភាពផងដែរ។ អ្នកចូលរួមជាច្រើនបានសម្ដែងភាពនឿយណាយ ចំពោះការពិគ្រោះយោបល់ដែលមិននាំឱ្យមានការផ្លាស់ប្ដូរជាក់ស្ដែង។ អ្នកចូលរួមមើលឃើញថា ការពន្យល់ច្បាស់លាស់អំពីមូលហេតុដែលព័ត៌មានត្រូវបានប្រមូល ថាតើវានឹងត្រូវបានប្រើប្រាស់យ៉ាងដូចម្ដេច និងថាតើមតិត្រឡប់អ្វីខ្លះដែលសហគមន៍អាចរំពឹងទុក មានសារៈសំខាន់សម្រាប់ការរក្សា ការចូលរួមជាប់លាប់។ នៅកន្លែងដែលមានយន្តការផ្ដល់មតិត្រឡប់ សូម្បីតែក្នុងទម្រង់ក្រៅផ្លូវការក៏ដោយ ទំនុកចិត្តលើដំណើរការស្រាវជ្រាវ និងដំណើរការគោលនយោបាយ មានភាពប្រសើរឡើង។

## ៦ ការបង្កើតចន្លោះសុវត្ថិភាព និងប្រកបដោយនិរន្តរភាពសម្រាប់ការចូលរួម

អ្នកចូលរួមបានសង្កត់ធ្ងន់ថា បរិយាបន្នត្រូវតែគ្របដណ្ដប់លើសពីការពិគ្រោះយោបល់ដែលធ្វើឡើងតែមួយដង។ អ្នកចូលរួមមើលឃើញថា ការចូលរួមជាច្រើនលើកច្រើនសារ និងប្រកបដោយការគោរព មានសារៈសំខាន់ចំពោះការកសាងទំនុកចិត្ត ជាពិសេសក្នុងចំណោមក្រុមដែលធ្លាប់ទទួលរងការរើសអើង ឬការផាត់ចេញ ដូចជា ជនមានពិការភាពផ្នែកចិត្តសង្គម ឬក្រុមស្រលាញ់ភេទដូចគ្នា ជាដើម។ ចន្លោះសុវត្ថិភាព ការការពារការរក្សាការសម្ងាត់ និងការចូលរួមជាប្រចាំ ត្រូវបានកំណត់ថាជាបុរេលក្ខខណ្ឌចាំបាច់សម្រាប់ការចូលរួមលើបញ្ហារសើប។

## ៧ ការទាញប្រយោជន៍ និងការពង្រឹងអង្គការ និងបណ្ដាញក្នុងមូលដ្ឋាន

អង្គការ និងបណ្ដាញក្នុងមូលដ្ឋានដែលមានស្រាប់ បង្ហាញពីឱកាសដែលមិនទាន់ប្រើប្រាស់ឱ្យអស់សក្ដានុពល។ អង្គការតំណាងជនមានពិការភាព ក្រុមស្ត្រី បណ្ដាញយុវជន រចនាសម្ព័ន្ធដឹកនាំជនជាតិដើមភាគតិច និងអង្គការសហគមន៍មូលដ្ឋាន សុទ្ធតែមានទំនាក់ទំនង និងភាពស្របច្បាប់នៅក្នុងសហគមន៍រួចជាស្រេច។ ទោះជាយ៉ាងណា អ្នកចូលរួមបានព្រមានថា ក្រុមទាំងនេះច្រើនតែត្រូវបានពិគ្រោះយោបល់ដោយគ្មានការផ្ដល់ធនធាន ឬឥទ្ធិពលគ្រប់គ្រាន់នោះទេ។ ការទាញប្រយោជន៍ពីតួនាទីរបស់ពួកគេឱ្យប្រកបដោយអត្ថន័យ ទាមទារការទទួលស្គាល់គម្លាតសមត្ថភាព ការគាំទ្រដល់ការសម្របសម្រួល និងការចៀសវាងការចូលរួមត្រឹមតែបង្គ្រប់កិច្ច។




# ០៤

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍



**ផ្នែកនេះបង្ហាញពីសេចក្តីសន្និដ្ឋាន និងអនុសាសន៍ដែលអាចអនុវត្តបាន ដោយផ្អែកលើការវិភាគអំពីឧបសគ្គ ឱកាស និងអាទិភាពសម្រាប់ក្រុមជនងាយរងគ្រោះក្នុងសង្គម នៅប្រទេសកម្ពុជា។**

## ៤.១. សេចក្តីសន្និដ្ឋាន

ការវិភាគនេះរកឃើញថា  កម្ពុជាសម្រេចបានវឌ្ឍនភាពយ៉ាងសំខាន់ក្នុងការទទួលស្គាល់តួនាទីនៃសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម នៅក្នុងប្រព័ន្ធគោលនយោបាយ និងការស្រាវជ្រាវ។ ក្នុងយុទ្ធសាស្ត្រជាតិ ផែនការតាមវិស័យ និងការពិភាក្សាកម្រិតស្ថាប័ន បច្ចុប្បន្នសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយថាជាគោលការណ៍ស្នូលនៃការអភិវឌ្ឍ។ ទោះជាយ៉ាងណា វឌ្ឍនភាពនេះនៅមានកម្រិតមិនស្មើគ្នា និងមិនទាន់ត្រូវបានប្រែក្លាយយ៉ាងរលូនឱ្យទៅជាប្រព័ន្ធ ការលើកទឹកចិត្ត និងការអនុវត្ត ដែលជំរុញឱ្យមានបរិយាបន្នប្រកបដោយអត្ថន័យនៅឡើយទេ។ លទ្ធផលទាំងនេះចង្អុលបង្ហាញពីការផ្លាស់ប្តូរការយល់ដឹងដ៏សំខាន់៖ បញ្ហាប្រឈមលែងស្ថិតនៅលើថាតើ សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ត្រូវបានទទួលស្គាល់ ឬអត់នោះទេ ប៉ុន្តែស្ថិតនៅលើថាតើវាត្រូវបានធ្វើស្ថាប័នូបនីយកម្ម និងដាក់ឱ្យអនុវត្តជាក់ស្តែងប្រកបដោយប្រសិទ្ធភាព នៅក្នុងវដ្តទាំងមូលនៃគោលនយោបាយ និងការស្រាវជ្រាវដែរ ឬទេ។

**សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម បានផ្លាស់ប្តូរពីការមិនទទួលបានការយកចិត្តទុកដាក់សោះ ទៅជាការទទួលស្គាល់ ប៉ុន្តែមិនទាន់ឈានដល់ការធ្វើស្ថាប័នូបនីយកម្មនៅឡើយទេ។** សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ត្រូវបានឆ្លុះបញ្ចាំងយ៉ាងច្បាស់នៅក្នុងក្របខណ្ឌគោលនយោបាយរបស់កម្ពុជា រួមមានយុទ្ធសាស្ត្របញ្ចកោណ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រតាមវិស័យស្តីពីយេនឌ័រ និងពិការភាព។ ក្រសួងនានាបានបញ្ជ្រាបបរិយាបន្នទៅក្នុងផែនការរបស់ខ្លួនកាន់តែច្រើន ហើយមានការបើកចំហកាន់តែខ្លាំងក្នុងការទាក់ទាញភាគីពាក់ព័ន្ធចម្រុះឱ្យចូលរួមក្នុងការពិភាក្សាគោលនយោបាយ។ ទោះជាយ៉ាងណា ការប្តេជ្ញាចិត្តទាំងនេះមិនទាន់ចាក់ឫសជ្រៅទៅក្នុងប្រព័ន្ធស្ថាប័ននៅឡើយ។ មានលក្ខខណ្ឌតម្រូវផ្លូវការ ការលើកទឹកចិត្ត ឬយន្តការគណនេយ្យភាពតិចតួចណាស់ ដើម្បីធានាថា ការស្រាវជ្រាវប្រកបដោយបរិយាបន្ន ដំណើរការពិភាក្សាបង្កភាពងាយស្រួល ឬទស្សនៈចម្រុះជួយតម្រឹមតម្រង់ការសម្រេចចិត្តលើគោលនយោបាយចុងក្រោយ។ ដូច្នេះ ការអនុវត្តនៅតែមានកម្រិតមិនស្មើគ្នា និងជារឿយៗ អាស្រ័យលើការដឹកនាំរបស់បុគ្គលម្នាក់ៗ ការគាំទ្រពីម្ចាស់ជំនួយ ឬគម្រោងជាក់លាក់។

**បើគ្មានការលើកទឹកចិត្ត និងការផ្តល់ធនធានច្បាស់លាស់ទេ ការអនុវត្ត សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម នៅតែមានកម្រិតមិនស្មើគ្នា និងអាស្រ័យលើការគាំទ្រពីខាងក្រៅ។** លទ្ធផលដែលតែងលេចឡើងនៅតាមស្ថាប័ននានា គឺកង្វះធនធាន និងការលើកទឹកចិត្តជាក់លាក់ ដើម្បីគាំទ្រដល់ការដាក់បញ្ចូល សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ។ ថវិការដ្ឋាភិបាលសម្រាប់បរិយាបន្ន និងការស្រាវជ្រាវ នៅមានកម្រិត ហើយការផ្តល់មូលនិធិសម្រាប់សកម្មភាពពាក់ព័ន្ធនឹង សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ច្រើនតែត្រូវបាន បញ្ចូលទៅក្នុងកម្មវិធីទូលំទូលាយ ជាជាងការបែងចែកថវិកាឱ្យបានច្បាស់លាស់។ ទន្ទឹមនឹងនេះ មិនសូវមានការលើកទឹកចិត្តស្ថាប័នឱ្យផ្តោតអាទិភាពលើការស្រាវជ្រាវ ឬការចូលរួមប្រកបដោយបរិយាបន្នដូចជា សូចនាករការអនុវត្តការងារ លក្ខខណ្ឌតម្រូវនៃជំនួយមូលនិធិ ឬស្តង់ដារផ្លូវការជាដើម។ ដូច្នេះ កិច្ចខិតខំប្រឹងប្រែងលើការងារ សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ច្រើនតែត្រូវបានជំរុញដោយការប្តេជ្ញាចិត្តរបស់បុគ្គល ជាជាងការរំពឹងទុកជាប្រព័ន្ធ។

**ការផាត់ចេញមានលក្ខណៈជាប្រព័ន្ធ  និងត្រូវបានបង្កើតឡើងវិញតាមរយៈការរៀបចំ  និងការអនុវត្តដំណើរការស្រាវជ្រាវ និងដំណើរការគោលនយោបាយ។** ឧបសគ្គរារាំងការចូលរួម មិនកំណត់ត្រឹមឧបសគ្គជាក់ស្តែង ដូចជា ពេលវេលា ការចំណាយ ឬការធ្វើដំណើរប៉ុណ្ណោះទេ ប៉ុន្តែវាបង្កប់នៅក្នុងការរៀបចំ និងដំណើរការនៃប្រព័ន្ធស្រាវជ្រាវ និងប្រព័ន្ធគោលនយោបាយផ្ទាល់តែម្តង។ ជារឿយៗ  ឧបករណ៍ និងវិធីសាស្ត្រស្រាវជ្រាវ មិនបានសម្របតាមកម្រិតខុសគ្នានៃសមត្ថភាព ភាសា និងអក្ខរកម្មនោះទេ។ ការអនុវត្តរបស់ស្ថាប័នកំណត់ថាតើនរណាត្រូវបានគេអញ្ជើញ ថាតើចំណេះដឹងរបស់នរណាត្រូវបានគេចាត់ទុកថាគួរឱ្យជឿទុកចិត្ត និងថាតើភស្តុតាងត្រូវបានបកស្រាយដោយរបៀបណា។ ដំណើរការគោលនយោបាយ ច្រើនតែផ្តោតអាទិភាពលើធាតុចូលបច្ចេកទេស ជាជាងបទពិសោធន៍ជីវិតជាក់ស្តែង ហើយនេះបានរឹតត្បិតឥទ្ធិពលនៃទស្សនៈរបស់សហគមន៍។

**ចាំបាច់ត្រូវតែរំលេចបរិយាបន្ននៅក្នុងដំណើរការទាំងមូលនៃការចូលរួម** ជាជាងត្រឹមតែចំណុចចូលរួមតែមួយ។ បញ្ហាប្រឈមពាក់ព័ន្ធនឹងបរិយាបន្ន អាចមើលឃើញយ៉ាងច្បាស់នៅទូទាំងដំណើរការនៃការចូលរួម ចាប់ពីការស្រាវជ្រាវ ដល់ការពិភាក្សា និងរហូតដល់ការយកទៅប្រើប្រាស់ក្នុងគោលនយោបាយ។ ភាពខ្វះចន្លោះទាំងនេះជួយពង្រឹងគ្នាទៅវិញទៅមកបង្កើតឱ្យមានប្រព័ន្ធមួយដែលបរិយាបន្នមានត្រឹមតែមួយផ្នែក និងមិនពេញលេញ។

- ក្នុងការស្រាវជ្រាវ មានគម្លាតក្នុងការប្រមូលទិន្នន័យដែលចម្រុះ និងជាតំណាង ជាពិសេសពីក្រុមដែលត្រូវបានផាត់ចេញ។
- ក្នុងការពិភាក្សា ការចូលរួមច្រើនតែមានកម្រិតមិនស្មើគ្នា ដោយមិនសូវមានចន្លោះ/ឱកាសសម្រាប់ការចូលរួមប្រកបដោយអត្ថន័យពីក្រុមដែលត្រូវបានផាត់ចេញ។
- ក្នុងដំណើរការគោលនយោបាយ ការប្រែក្លាយទិន្នន័យទៅជាសេចក្តីសម្រេច មិនបានឆ្លុះបញ្ចាំងពីធាតុចូលរបស់សហគមន៍ឱ្យបានជាប់លាប់នោះទេ។

**ហេតុផលទាំងនេះបានញុាំងឱ្យមានការចូលរួមកាន់តែច្រើន ប៉ុន្តែមិនសូវមានផលជះ។** ឆ្លងកាត់ក្រុមទាំងអស់ដែលត្រូវបានពិគ្រោះយោបល់ រួមទាំងស្ត្រី ជនមានពិការភាព សហគមន៍ជនជាតិដើមភាគតិច និងប្រជាជនងាយរងគ្រោះផ្សេងទៀត ការចូលរួមក្នុងការស្រាវជ្រាវ និងការពិគ្រោះយោបល់គោលនយោបាយ កំពុងកើនឡើងជាលំដាប់។ ទោះជាយ៉ាងណា ការចូលរួមបែបនេះច្រើនតែមិនសូវមានភាពស៊ីជម្រៅ និងឥទ្ធិពល។ អ្នកចូលរួមតែងតែរៀបរាប់ថា ដំណើរការពិគ្រោះយោបល់មានលក្ខណៈជាការទាញប្រយោជន៍។ ខណៈដែលពួកគេត្រូវបានអញ្ជើញឱ្យចែករំលែកធាតុចូល ធាតុចូលទាំងនេះមិនសុទ្ធតែត្រូវបានឆ្លុះបញ្ចាំងនៅក្នុងលទ្ធផលគោលនយោបាយនោះទេ ហើយក៏មិនមានយន្តការផ្តល់មតិត្រឡប់ ដើម្បីពន្យល់ថាតើការរួមចំណែកត្រូវបានយកទៅប្រើប្រាស់ដោយរបៀបណាដែរ។ ចំណុចនេះបាននាំឱ្យមានអារម្មណ៍នឿយណាយចំពោះការពិគ្រោះយោបល់ និងលែងសូវមានទំនុកចិត្តលើដំណើរការនៃការចូលរួម។

**តួអង្គអន្តរការីដើរតួនាទីចាំបាច់ ប៉ុន្តែមិនគ្រប់គ្រាន់ក្នុងការធានាបាននូវបរិយាបន្នប្រកបដោយអត្ថន័យ និងដោយផ្ទាល់នោះទេ។** តួអង្គអន្តរការី រួមទាំងរចនាសម្ព័ន្ធឃុំ-សង្កាត់ អង្គការតំណាងជនមានពិការភាព និងអង្គការសង្គមស៊ីវិល ដើរតួនាទីយ៉ាងសំខាន់ក្នុងការតភ្ជាប់សហគមន៍ជាមួយនឹងដំណើរការស្រាវជ្រាវ និងដំណើរការគោលនយោបាយ។ ពួកគេជួយសម្របសម្រួលការចូលរួម បកស្រាយព័ត៌មាន និងកសាងទំនុកចិត្ត។ ទោះជាយ៉ាងណា ការពឹងផ្អែកលើអន្តរការីក៏ជះឥទ្ធិពលលើរបៀបដែលការចូលរួមកើតឡើងផងដែរ។ ជារឿយៗ ការចូលរួមមានលក្ខណៈប្រយោល ហើយទស្សនៈអាចនឹងត្រូវបានសម្រាំងយក ឬបូកសរុបបញ្ចូលគ្នា។ ក្នុងពេលជាមួយគ្នានេះ អង្គការជាច្រើនក្នុងចំណោមនេះ ធ្វើប្រតិបត្តិការដោយមានធនធាន និងឥទ្ធិពលតិចតួច។

**ប្រព័ន្ធទិន្នន័យបច្ចុប្បន្ន មិនទាន់មានលទ្ធភាពច្បាមយកភាពងាយរងគ្រោះដែលមានលក្ខណៈត្រួតគ្នាទេ ដែលធ្វើឱ្យមានចំណុចខ្វះខាតក្នុងគោលនយោបាយជាបន្តបន្ទាប់។** ខណៈដែលយេនឌ័រ និងពិការភាព កាន់តែត្រូវបានរំលេចឱ្យឃើញនៅក្នុងគោលនយោបាយ និងការរៀបចំកម្មវិធី ភាពប្រទាក់ក្រឡានៅតែមិនសូវត្រូវបានគេលើកឡើង។ អ្នកដែលជួបប្រទះទម្រង់នៃភាពងាយរងគ្រោះច្រើនបែប និងត្រួតគ្នា ដូចជាស្ត្រីមានពិការភាពរស់នៅជនបទ ឬយុវជនជាជនជាតិដើមភាគតិចមកពីគ្រួសារមានប្រាក់ចំណូលទាប មិនត្រូវបានច្បាមយកទៅបញ្ចូលក្នុងទិន្នន័យ ឬឆ្លុះបញ្ចាំងក្នុងការរៀបចំគោលនយោបាយឱ្យបានគ្រប់គ្រាន់ឡើយ។ ប្រព័ន្ធស្រាវជ្រាវ និងប្រព័ន្ធរដ្ឋបាលភាគច្រើន ចាត់ថ្នាក់បុគ្គលទៅតាមកត្តាតែមួយ ដែលធ្វើឱ្យប្រព័ន្ធទាំងនោះមិនសូវមានសមត្ថភាពយល់ដឹងថាតើទម្រង់នៃការផាត់ចេញផ្សេងៗជះឥទ្ធិពលលើគ្នាយ៉ាងដូចម្តេច។

**ទំនុកចិត្តគឺជាបុរេលក្ខខណ្ឌសម្រាប់ការចូលរួមប្រកបដោយប្រសិទ្ធភាព។** ទំនុកចិត្តបានលេចឡើងជាកត្តាសំខាន់ដែលកំណត់ថាតើសហគមន៍ចូលរួម ឬអត់ និងចូលរួមដោយរបៀបណា។ អ្នកចូលរួមមានឆន្ទៈរួមចំណែកកាន់តែច្រើន នៅពេលដែលដំណើរការស្រាវជ្រាវមានតម្លាភាព នៅពេលដែលអ្នកស្រាវជ្រាវយល់ពីបរិបទមូលដ្ឋាន និងនៅពេលដែលមានការផ្តល់មតិត្រឡប់។ ផ្ទុយទៅវិញ ការពិគ្រោះយោបល់ដែលធ្វើឡើងដដែលៗ ដោយគ្មានលទ្ធផលជាក់ស្តែង បានកាត់បន្ថយទំនុកចិត្ត និងទឹកចិត្តចូលរួម។ ដូច្នេះ ទំនុកចិត្តមិនមែនគ្រាន់តែជាលទ្ធផលនៃការចូលរួមនោះទេ ប៉ុន្តែជាលក្ខខណ្ឌមួយ ដែលជំរុញឱ្យមានការចូលរួមប្រកបដោយអត្ថន័យ។

**បរិយាបន្នទាមទារនូវជម្រើសនៃការរៀបចំ ដែលមានការគិតគូរច្បាស់លាស់ និងស៊ីសង្វាក់គ្នា។** ការដោះស្រាយឧបសគ្គជាច្រើនដែលបានកំណត់ អាចធ្វើឡើងតាមរយៈការកែសម្រួលជាក់ស្តែង ដូចជា ការកំណត់ពេលវេលាឱ្យបានសមស្រប ការឧបត្ថម្ភគាំទ្រដល់ការធ្វើដំណើរ ទម្រង់ឯកសារដែលបង្កភាពងាយស្រួល និងការប្រើប្រាស់ភាសាក្នុងមូលដ្ឋាន។ ការកែសម្រួលទាំងនេះអាចបង្កើនការចូលរួមបានយ៉ាងច្រើន។ ទោះជាយ៉ាងណា វិធានការទាំងនេះមិនត្រូវបានអនុវត្តឱ្យបានជាប់លាប់នោះទេ។ ចំណុចនេះមិនឆ្លុះបញ្ចាំងពីកង្វះដំណោះស្រាយផ្នែកបច្ចេកទេសនោះទេ ប៉ុន្តែវាឆ្លុះបញ្ចាំងពីកង្វះការរៀបចំប្រកបដោយគោលបំណងច្បាស់លាស់ ដើម្បីធានាឱ្យមានបរិយាបន្ន។

**កម្ពុជាស្ថិតនៅចំណុចអន្តរកាលមួយ ដែលបរិយាបន្នអាចផ្លាស់ប្តូរពីការអនុវត្តតាមកាលៈទេសៈ ទៅជាការផ្លាស់ប្តូរកម្រិតប្រព័ន្ធ។** លទ្ធផលទាំងនេះ ក៏ចង្អុលបង្ហាញពីឱកាសជាច្រើនដែលកំពុងលេចឡើងផងដែរ។ កម្ពុជាមានក្របខណ្ឌគោលនយោបាយរឹងមាំ តម្រូវការទិន្នន័យកាន់តែច្រើន និងការចូលរួមកាន់តែច្រើនរវាងរដ្ឋាភិបាល ស្ថាប័នស្រាវជ្រាវ និងសង្គមស៊ីវិល។ កម្មវិធីដូចជាកម្មវិធីពន្លកចំណេះ ដំណាក់កាលទី២ បង្ហាញថា គេពិតជាអាចពង្រឹងការអនុវត្តការស្រាវជ្រាវ និងការពិភាក្សាប្រកបដោយបរិយាបន្ន។ បច្ចុប្បន្ន មានឱកាសមួយដើម្បីឈានហួសពីគំនិតផ្តួចផ្តើមដាច់ដោយឡែកពីគ្នា និងដាក់បញ្ចូលអភិក្រមទាំងនេះឱ្យកាន់តែមានលក្ខណៈជាប្រព័ន្ធទៅក្នុងស្ថាប័ននានា។

## ៤.២. អនុសាសន៍ពាក់ព័ន្ធនឹង សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម

អនុសាសន៍ទាំងនេះត្រូវបានរៀបចំឡើងទៅតាមតួអង្គចម្បងរួមមាន៖ ក្រសួងស្ថាប័នរដ្ឋាភិបាល និងអាជ្ញាធរថ្នាក់ក្រោមជាតិ ស្ថាប័នស្រាវជ្រាវ និងសាកលវិទ្យាល័យ ព្រមទាំងសហគមន៍ និងសង្គមស៊ីវិល។ អនុសាសន៍ទាំងនេះផ្តោតលើការលុបបំបាត់ឧបសគ្គផ្នែករចនាសម្ព័ន្ធ ឧបសគ្គផ្នែកស្ថាប័ន និងឧបសគ្គផ្នែកនីតិវិធី ដែលរារាំងការចូលរួមក្នុងដំណើរការស្រាវជ្រាវ និងដំណើរការគោលនយោបាយដើម្បីធានាថា ក្រុមងាយរងគ្រោះ រួមមានស្ត្រី ជនមានពិការភាព ក្រុមស្រលាញ់ភេទដូចគ្នា ជនជាតិដើមភាគតិច និងជនជាតិភាគតិច យុវជន និងប្រជាពលរដ្ឋដែលនៅតំបន់ដាច់ស្រយាល អាចរួមចំណែកប្រកបដោយអត្ថន័យ។

### *ក្រសួងស្ថាប័នរដ្ឋាភិបាល និងអាជ្ញាធរថ្នាក់ក្រោមជាតិ*

ក្រសួងស្ថាប័នរដ្ឋាភិបាល និងអាជ្ញាធរថ្នាក់ក្រោមជាតិ ដើរតួនាទីយ៉ាងសំខាន់ក្នុងការកំណត់ថាតើនរណាត្រូវបានគេមើលឃើញ ត្រូវបានស្តាប់ និងត្រូវបានផ្តល់អាទិភាពនៅក្នុងប្រព័ន្ធគោលនយោបាយ និងប្រព័ន្ធស្រាវជ្រាវ។ កម្ពុជាមានក្របខណ្ឌគោលនយោបាយ សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម រួចហើយ ប៉ុន្តែការអនុវត្តនៅមានកម្រិតមិនស្មើគ្នា និងទើបតែចាប់ផ្តើមឡើង។ ជារឿយៗ បរិយាបន្នត្រូវបានគេចាត់ទុកថាជាលក្ខខណ្ឌតម្រូវផ្នែកនីតិវិធី ជាជាងដាក់បញ្ចូលទៅក្នុងប្រព័ន្ធធ្វើសេចក្តីសម្រេច ដោយមានគណនេយ្យភាពតិចតួច ទិន្នន័យមិនពេញលេញ និងដំណើរការពិគ្រោះយោបល់ដែលមិនជំរុញការចូលរួមប្រកបដោយអត្ថន័យឱ្យបានជាប់លាប់។

ការពង្រឹងការដាក់បញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ទៅក្នុងប្រព័ន្ធរដ្ឋាភិបាល ទាមទារឱ្យមានការផ្លាស់ប្តូរពីការប្តេជ្ញាចិត្តផ្នែកគោលនយោបាយ ទៅជាការអនុវត្តក្នុងស្ថាប័នផ្ទាល់។ នេះរួមបញ្ចូលទាំងការដាក់បញ្ចូលបរិយាបន្នទៅក្នុងប្រព័ន្ធ ផែនការប្រព័ន្ធ រៀបចំថវិកា និងប្រព័ន្ធអនុវត្តន៍ការងារ ការធ្វើស្តង់ដារនីយកម្មលើដំណើរការពិគ្រោះយោបល់ដែលបង្កភាពងាយស្រួល និងប្រកបដោយបរិយាបន្ន ការពង្រឹងប្រព័ន្ធទិន្នន័យដើម្បីច្បាមយកភាពងាយរងគ្រោះច្រើនកម្រិត និងការកែលម្អការអនុវត្តនៅថ្នាក់ក្រោមជាតិ។

| ឧបសគ្គ និងហេតុផលបញ្ជាក់ | អនុសាសន៍ |
|---|---|
| សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ត្រូវបានគេចាត់ទុកត្រឹមតែជាការអនុលោមតាមកាតព្វកិច្ចជាជាងដាក់បញ្ចូលទៅក្នុងការធ្វើសេចក្តីសម្រេច ហើយនេះបានរឹតត្បិតឥទ្ធិពលរបស់ សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម លើអាទិភាពគោលនយោបាយ និងការបែងចែកធនធាន។ | • កំណត់ជាផ្លូវការនូវតួនាទីរបស់ក្រុមការងារបញ្ជ្រាបយេនឌ័រ និងមន្ត្រីបង្គោលពិការភាព ដោយមានអាណត្តិ ថវិកា និងប្រព័ន្ធរាយការណ៍ច្បាស់លាស់។<br>• ប្រគល់ការទទួលខុសត្រូវលើគណនេយ្យភាព សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ដល់ថ្នាក់ដឹកនាំជាន់ខ្ពស់ តាមរយៈដំណើរការរៀបចំផែនការ និងដំណើរការវាយតម្លៃការអនុវត្តការងារ។<br>• តម្រូវឱ្យមានការវិភាគយេនឌ័រ និងពិការភាពនៅក្នុងសេចក្តីសង្ខេបគោលនយោបាយ និងគំរូឯកសារប្រគល់ភារកិច្ចស្រាវជ្រាវ។ |
| ការពិគ្រោះយោបល់មិនត្រូវបានធ្វើឱ្យមានភាពងាយស្រួល និងមានបរិយាបន្ន ដែលបណ្តាលឱ្យមានការចូលរួមមិនស្មើគ្នា និងឥទ្ធិពលតិចតួចពីក្រុមដែលត្រូវបានផាត់ចេញ។ | • ដាក់ចេញស្តង់ដារអប្បបរមានៃការបង្កភាពងាយស្រួលសម្រាប់ការពិគ្រោះយោបល់សាធារណៈ រួមទាំងការបង្កភាពងាយស្រួលផ្នែករូបវន្ត ការដាក់អក្សររត់ពីក្រោម ការបកប្រែ ឯកសារដែលបង្កភាពងាយស្រួល និងការបែងចែកថវិកាសម្រាប់ការសម្របសម្រួល។<br>• សាកល្បងដំណើរការ (តាមរយៈកម្មវិធីដូចជា កម្មវិធីដែលគាំទ្រដោយពន្លកចំណេះ)មុននឹងពង្រីកវិសាលភាពអនុវត្តន៍។<br>• បង្កើតគោលការណ៍ណែនាំ ស្តីពីការសម្របសម្រួលប្រកបដោយបរិយាបន្ន និងការចូលរួមប្រកបដោយសុវត្ថិភាព។ |
| ទិន្នន័យ មិនត្រូវបានបែកចែកជាប្រភេទឱ្យបានគ្រប់គ្រាន់ និងកម្រមានលក្ខណៈប្រទាក់ក្រឡា ដែលរឹតត្បិតសមត្ថភាពក្នុងការកំណត់អត្តសញ្ញាណ និងឆ្លើយតបទៅនឹងភាពងាយរងគ្រោះដែលត្រួតគ្នា។ | • ពង្រឹងការបែកចែកទិន្នន័យជាប្រភេទ (ពិការភាព ភេទ អាយុ ជាតិពន្ធុ ទីតាំង)។<br>• សាកល្បងអនុវត្តការវិភាគអន្តរប្រសព្វ នៅក្នុងសំណុំទិន្នន័យអាទិភាព។<br>• បង្កើនការផ្សារភ្ជាប់ទិន្នន័យដោយផ្ទាល់ទៅនឹងការរៀបចំផែនការ និងការរៀបចំថវិកា។ |

| ឧបសគ្គ និងហេតុផលបញ្ជាក់ | អនុសាសន៍ |
| --- | --- |
| ប្រព័ន្ធទិន្នន័យដែលហួសសម័យ / លែងមានសុពលភាព កាត់បន្ថយភាពទាន់ពេលវេលា គុណភាព និងលទ្ធភាពប្រើប្រាស់ទិន្នន័យ សម្រាប់ការធ្វើសេចក្តីសម្រេច។ | • ប្រើប្រាស់ប្រព័ន្ធទិន្នន័យឌីជីថល ដែលអាចដំណើរការជាមួយគ្នាបាន រួមជាមួយនឹងផ្ទាំងបង្ហាញទិន្នន័យដែលបែកចែកជាប្រភេទ ការបញ្ចូលទិន្នន័យតាមទូរសព្ទដៃ/ថេប្លេតនៅថ្នាក់ឃុំ-សង្កាត់ និងការវិភាគដោយប្រើប្រាស់បញ្ញាសិប្បនិម្មិត ដើម្បីកំណត់រកភាពងាយរងគ្រោះដែលត្រួតគ្នា។<br>• ប្រើប្រាស់ការបញ្ចូលទិន្នន័យតាមទូរសព្ទចល័តនៅថ្នាក់ឃុំ-សង្កាត់ ។<br>• សាកល្បងប្រព័ន្ធវិភាគកម្រិតខ្ពស់ និងថ្នាលឌីជីថលដែលបង្ក ភាពងាយស្រួល។ |
| យេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ត្រូវបានដោះស្រាយដាច់ដោយឡែកពីគ្នា ដែលរឹតត្បិតការយល់ដឹងអំពីការផាត់ចេញដែលត្រួតគ្នា។ | • បង្កើតក្រុមការងារទទួលបន្ទុកអន្តរប្រសព្វនៅក្នុងក្រសួងនានា និងដាក់ចេញនូវឧបករណ៍សាមញ្ញៗ ដូចជា ការវិភាគផ្អែកលើលក្ខណៈបុគ្គល និងការគូសផែនទីភាគីពាក់ព័ន្ធ តាមកម្រិត។<br>• ប្រើប្រាស់ឧបករណ៍ដូចជា ការគូសផែនទីភាគីពាក់ព័ន្ធ និងការវិភាគលក្ខណៈបុគ្គល។<br>• អនុវត្ត សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ក្នុងវិស័យគោលនយោបាយអន្តរវិស័យ។ |
| កង្វះសមត្ថភាព និងការណែនាំនៅថ្នាក់ក្រោមជាតិ រឹតត្បិតការប្រែក្លាយការប្តេជ្ញាចិត្ត ក្នុងគោលនយោបាយ ទៅជាការអនុវត្តជាក់ស្តែង។ | • ផ្តល់ការកសាងសមត្ថភាព និងឧបករណ៍ចំគោលដៅ។<br>• បញ្ជ្រាបសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ទៅក្នុងដំណើរការរៀបចំផែនការនៅមូលដ្ឋាន។<br>• ពង្រឹងយន្តការផ្តល់មតិត្រឡប់រវាងសហគមន៍ និងរដ្ឋាភិបាល។ |

## ស្ថាប័នវិស័យស្រាវជ្រាវ

ស្ថាប័នក្នុងវិស័យស្រាវជ្រាវ ដើរតួនាទីយ៉ាងសំខាន់ក្នុងការកំណត់ថាតើទិន្នន័យអ្វីខ្លះត្រូវបានបង្កើតឡើង ចំណេះដឹងរបស់នរណាត្រូវបានទទួលស្គាល់ និងថាតើបញ្ហាគោលនយោបាយត្រូវបានកំណត់យ៉ាងដូចម្តេច។ ខណៈដែលមានការបើកចំហកាន់តែច្រើនចំពោះ សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ការអនុវត្តបច្ចុប្បន្ននៅមានកម្រិតមិនស្មើគ្នា និងជារឿយៗ ជំរុញដោយលក្ខខណ្ឌតម្រូវរបស់គម្រោង ជាជាងស្តង់ដារស្ថាប័ន។ ដូច្នេះ បរិយាបន្នមិនត្រូវបានអនុវត្តឱ្យបានជាប់លាប់នៅទូទាំងវដ្តនៃការស្រាវជ្រាវឡើយ ដែលនេះបានកម្រិតទាំងភាពចម្រុះនៃទិន្នន័យ និងភាពពាក់ព័ន្ធរបស់ទិន្នន័យទាំងនោះសម្រាប់គោលនយោបាយ។

ការពង្រឹងសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម នៅក្នុងវិស័យស្រាវជ្រាវ ទាមទារឱ្យមានការផ្លាស់ប្តូរពីអភិក្រមផ្អែកលើការអនុលោមតាមកាតព្វកិច្ច ទៅជាប្រព័ន្ធស្រាវជ្រាវដែលត្រូវបានធ្វើស្ថាប័នូបនីយកម្ម មានគណនេយ្យភាព និងប្រកបដោយបរិយាបន្ន។ នេះរួមបញ្ចូលទាំងការដាក់បញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ជាស្តង់ដារគុណភាពចម្បង ការកែលម្អការរៀបចំការស្រាវជ្រាវឱ្យប្រកបដោយបរិយាបន្ន និងបង្កភាពងាយស្រួល ការពង្រឹងសមត្ថភាពរបស់អ្នកស្រាវជ្រាវ និងការដោះស្រាយឧបសគ្គផ្នែករចនាសម្ព័ន្ធដែលកំណត់ថាតើនរណាជាអ្នកបង្កើតចំណេះដឹង និងថាតើទស្សនៈរបស់នរណាដែលត្រូវបានលើកជាតំណាង។

| ឧបសគ្គ និងហេតុផលបញ្ជាក់ | អនុសាសន៍ |
|---|---|
| សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ត្រូវបានចាត់ទុកថាជាលក្ខខណ្ឌតម្រូវកម្រិតគម្រោង ដែលជំរុញដោយម្ចាស់ជំនួយ ជាជាងជាស្តង់ដារគុណភាពចម្បង នៃការស្រាវជ្រាវ ដែលធ្វើឱ្យរឹតត្បិតដល់ភាពជាម្ចាស់របស់ស្ថាប័ននិងការអនុវត្តយ៉ាងរលូន។ | • ផ្លាស់ប្តូរសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ពីការត្រឹមតែបំពេញតាមកាតព្វកិច្ច ទៅជាស្តង់ដារគុណភាពចម្បងនៃការស្រាវជ្រាវ ដោយផ្សារភ្ជាប់ការផ្តល់មូលនិធិ ការជ្រើសរើសដៃគូ និងការបន្តផ្តល់ការគាំទ្រ ទៅនឹងការអនុវត្តប្រកបដោយបរិយាបន្ន ដែលបានបង្ហាញឱ្យឃើញ។<br>• អភិវឌ្ឍគោលនយោបាយ សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ផ្ទៃក្នុង ដែលសម្របតាមទំហំ និងអាណត្តិរបស់ស្ថាប័ន។<br>• បញ្ជ្រាបគណនេយ្យភាព សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ទៅក្នុងរចនាសម្ព័ន្ធអភិបាលកិច្ច ការអនុវត្តការងាររបស់ថ្នាក់ដឹកនាំ និងការសម្រេចចិត្តលើភាពជាដៃគូ។ |
| កម្សោយនៃភាពជាម្ចាស់របស់ថ្នាក់ដឹកនាំ មានន័យថា ការអនុវត្តការស្រាវជ្រាវប្រកបដោយបរិយាបន្នមានកម្រិតមិនស្មើគ្នា ខ្វះខាតធនធាន និងមិនត្រូវបានស្ថាប័នកំណត់យកជាអាទិភាព។ | • តម្រូវឱ្យថ្នាក់ដឹកនាំជាន់ខ្ពស់  បង្ហាញពីការប្តេជ្ញាចិត្តរបស់ស្ថាប័នចំពោះ សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម រួមទាំងការផ្តល់ធនធាន និងការអភិវឌ្ឍបុគ្គលិក។<br>• បញ្ជ្រាបសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ទៅក្នុងយុទ្ធសាស្ត្ររបស់ស្ថាប័ន ការគ្រប់គ្រងការអនុវត្តការងារ និងប្រព័ន្ធអភិបាលកិច្ចនៃការស្រាវជ្រាវ។ |
| អភិក្រមបែបបរិយាបន្ន និងអន្តរប្រសព្វ ត្រូវបានអនុវត្តនៅដំណាក់កាលចុងក្រោយ នៃវដ្តស្រាវជ្រាវ ដែលរឹតត្បិតថាតើនរណាអាចចូលរួមបាន និងថាតើចំណេះដឹងរបស់នរណាដែលត្រូវបានឆ្លុះបញ្ចាំង។ | • ដាក់បញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ក្នុងវដ្តស្រាវជ្រាវទាំងមូល (តាំងពីការរៀបចំរហូតដល់ការផ្សព្វផ្សាយ)។<br>• កសាងភាពជាដៃគូ ជាមួយអង្គការតំណាងជនមានពិការភាព និងអង្គការថ្នាក់មូលដ្ឋាន  ដើម្បីសហការរៀបចំរបៀបវារៈស្រាវជ្រាវ។<br>• កែសម្រួលវិធីសាស្ត្រស្រាវជ្រាវ ឱ្យមានការចូលរួមកាន់តែច្រើន និងឆ្លើយតបទៅនឹងបរិបទ។ |

| ឧបសគ្គ និងហេតុផលបញ្ជាក់ | អនុសាសន៍ |
|---|---|
| អ្នកស្រាវជ្រាវខ្វះជំនាញជាក់ស្តែង ក្នុងការអនុវត្តវិធីសាស្ត្រ បែបបរិយាបន្ន និងអន្តរប្រសព្វ ជាពិសេសសម្រាប់បរិយាបន្នពិការភាព។ | • ផ្តល់ការបណ្តុះបណ្តាលតម្រង់ទិសការអនុវត្តជាក់ស្តែង លើបទដ្ឋានយេនឌ័រ បរិយាបន្នពិការភាព និងការចូលរួមប្រកបដោយសុវត្ថិភាព ជាមួយសហគមន៍ជនជាតិដើមភាគតិច និងសហគមន៍ស្រលាញ់ភេទដូចគ្នា ។<br>• គាំទ្រដល់ការណែនាំ ការរៀនសូត្រពីគ្នាទៅវិញទៅមក និងអភិក្រមនៃការបណ្តុះបណ្តាលដែលយកទៅអនុវត្តផ្ទាល់។ |
| ឧបករណ៍ វិធីសាស្ត្រ និងទម្រង់នៃការផ្សព្វផ្សាយការស្រាវជ្រាវ ជារឿយៗមិនបង្កភាពងាយស្រួលក្នុងការប្រើប្រាស់ ដែលធ្វើឱ្យរឹតត្បិតដល់ការចូលរួម និងការប្រើប្រាស់ដោយជនមានពិការភាព និងក្រុមងាយរងគ្រោះ។ | • ធានាថា ឧបករណ៍ និងលទ្ធផលសម្រេចបាន បង្កភាពងាយស្រួលក្នុងការប្រើប្រាស់ (ភាសាសាមញ្ញ ទម្រង់សំឡេង/រូបភាព ឯកសារដែលបានកែសម្រួល)។<br>• អភិវឌ្ឍឃ្លាំងផ្ទុកទិន្នន័យបើកទូលាយ (open-access repositories) សម្រាប់លទ្ធផលស្រាវជ្រាវដែលគិតគូរពីសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ក្នុងទម្រង់ដែលងាយស្រួលអាន ឬប្រើប្រាស់។ |
| អ្នកស្រាវជ្រាវជាស្ត្រី និងអ្នកស្រាវជ្រាវដែលមានអត្តសញ្ញាណយេនឌ័រចម្រុះ ប្រឈមនឹងឧបសគ្គផ្នែករចនាសម្ព័ន្ធ ក្នុងការឈានទៅកាន់តួនាទីជាអ្នកដឹកនាំ។ ចំណុចនេះកំណត់ថាតើទស្សនៈរបស់នរណាមានឥទ្ធិពលលើរបៀបវារៈស្រាវជ្រាវ។ | • កំណត់គោលដៅស្ថាប័នសម្រាប់ការចូលរួមរបស់ស្ត្រី ក្នុងតួនាទីដឹកនាំ និងតួនាទីបច្ចេកទេស។<br>• ផ្តល់កម្មវិធីណែនាំ អាហារូបករណ៍ និងគន្លងអភិវឌ្ឍន៍អាជីព។<br>• តាមដានការតម្លើងឋានៈ ការដឹកនាំ និងការបែងចែកបន្ទុកការងារ ដើម្បីដោះស្រាយបញ្ហាពាក់ព័ន្ធនឹងភាពលំអៀង។ |
| ការស្រាវជ្រាវនៅតែប្រមូលផ្តុំតាមទីក្រុង ដែលធ្វើឱ្យរឹតត្បិតដល់ការតំណាង ឱ្យសហគមន៍ជនបទ សហគមន៍ជនជាតិដើមភាគតិច និងសហគមន៍ងាយរងគ្រោះ។ | • ផ្តល់មូលនិធិខ្នាតតូច និងការគាំទ្រផ្នែកបច្ចេកទេសសម្រាប់ការស្រាវជ្រាវនៅតំបន់ដាច់ស្រយាល។<br>• ចាប់ដៃគូសហការជាមួយស្ថាប័នក្នុងមូលដ្ឋាន និងអង្គការសហគមន៍មូលដ្ឋាន។<br>• ប្រើប្រាស់ឧបករណ៍ចល័ត និងឌីជីថល ដើម្បីអោយទៅដល់ប្រជាជនដែលទទួលបានសេវានៅមានកម្រិត |
| ការប្រើប្រាស់ឧបករណ៍ឌីជីថល នៅមានកម្រិត ដែលធ្វើឱ្យរឹតត្បិតដល់វិសាលភាព និងបរិយាបន្ននៃដំណើរការស្រាវជ្រាវ។ | • ប្រើប្រាស់ឧបករណ៍ប្រមូលទិន្នន័យតាមទូរសព្ទចល័ត និងថ្នាលអេឡិចត្រូនិក ដើម្បីពង្រីកការចូលរួម។<br>• បង្កើតកម្មវិធីណែនាំតាមប្រព័ន្ធអនឡាញ និងថ្នាក់សិក្សាតាមប្រព័ន្ធអេឡិចត្រូនិកសម្រាប់អ្នកស្រាវជ្រាវ។ |

## សហគមន៍ និងសង្គមស៊ីវិល

សហគមន៍ និងតួអង្គសង្គមស៊ីវិល គឺជាស្នូលនៃការបង្កើតទិន្នន័យ និងភាពពាក់ព័ន្ធនៃគោលនយោបាយ ប៉ុន្តែនៅតែជាក្រុមដែលទទួលបានសិទ្ធិអំណាចតិចតួចបំផុតនៅក្នុងដំណើរការស្រាវជ្រាវ និងដំណើរការគោលនយោបាយ។ ទោះបីជាមានបទពិសោធន៍ជីវិតជាក់ស្តែងដ៏សម្បូរបែបក៏ដោយ ប៉ុន្តែការចូលរួមរបស់ពួកគេជារឿយៗត្រូវបានរឹតត្បិតដោយឧបសគ្គជាក់ស្តែង សមត្ថភាពមានកម្រិត និងដំណើរការដែលមិនប្រែក្លាយការចូលរួមទៅជាឥទ្ធិពលជាក់ស្តែង។ ដូច្នេះហើយទើបការចូលរួមច្រើនតែមានលក្ខណៈជាការទាញប្រយោជន៍ ដោយមានយន្តការផ្តល់មតិត្រឡប់អន់ខ្សោយ និងឥទ្ធិពលតិចតួចលើការសម្រេចចិត្ត។

ការពង្រឹងតួនាទីរបស់សហគមន៍ និងសង្គមស៊ីវិល ទាមទារឱ្យមានការផ្លាស់ប្តូរពីការត្រឹមតែពិគ្រោះយោបល់ ទៅជាការចូលរួមប្រកបដោយអត្ថន័យ និងភាពជាម្ចាស់រួមគ្នា។ នេះរួមបញ្ចូលទាំងការកាត់បន្ថយឧបសគ្គជាក់ស្តែងដែលរារាំងដល់ការចូលរួម ការវិនិយោគលើសមត្ថភាពរបស់អង្គការតំណាងជនមានពិការភាព និងអង្គការសហគមន៍មូលដ្ឋាន ព្រមទាំងការបង្កើតប្រព័ន្ធដែលធានាថា ធាតុចូលរបស់សហគមន៍ជះឥទ្ធិពលលើរបៀបវារៈស្រាវជ្រាវ ផ្តល់ព័ត៌មានដល់ការសម្រេចចិត្តលើគោលនយោបាយ ហើយយូរទៅ ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងលទ្ធផលចុងក្រោយ។

| ឧបសគ្គ និងហេតុផលបញ្ជាក់ | អនុសាសន៍ |
|---|---|
| សហគមន៍ រួមទាំងអង្គការតំណាងជនមានពិការភាព មានឥទ្ធិពលតិចតួចលើរបៀបវារៈស្រាវជ្រាវ និងដំណើរការគោលនយោបាយ ដែលធ្វើឱ្យការចូលរួម មិនអាចប្រែក្លាយទៅជាអំណាចធ្វើសេចក្តីសម្រេច។ | • បញ្ជ្រាបភាពតំណាងឱ្យសហគមន៍ និងអង្គការតំណាងជនមានពិការភាព នៅក្នុងរចនាសម្ព័ន្ធអភិបាលកិច្ច។<br>• កំណត់ជាផ្លូវការនូវដំណើរការសហការរៀបចំនៅទូទាំងវដ្តនៃការស្រាវជ្រាវ (ការកំណត់របៀបវារៈ ការប្រមូលទិន្នន័យ ការបកស្រាយទិន្នន័យ)។<br>• ដាក់បញ្ចូលការចូលរួមប្រកបដោយអត្ថន័យ ទៅក្នុងការលើកទឹកចិត្តរបស់ស្ថាប័ន ដើម្បីធានាឱ្យមានឥទ្ធិពលយូរអង្វែង។ |
| ឧបសគ្គជាក់ស្តែង ដូចជា ការចំណាយលើការធ្វើដំណើរ ភាសា ការបង្កភាពងាយស្រួល និងសុវត្ថិភាព បានរឹតត្បិតការចូលរួម ជាពិសេសសម្រាប់ក្រុមដែលត្រូវបានផាត់ចេញ។ | • ផ្តល់ការឧបត្ថម្ភគាំទ្រដល់ការធ្វើដំណើរ ការបកប្រែ ការបកប្រែភាសាសញ្ញា និងឯកសារដែលងាយស្រួលប្រើប្រាស់។<br>• ប្រើប្រាស់វិទ្យុសហគមន៍ អង្កេតតាមទូរសព្ទចល័ត និងឧបករណ៍ជាភាសាក្នុងមូលដ្ឋាន ដើម្បីពង្រីកការចូលរួម។ |
| អង្គការតំណាងជនមានពិការភាព និងអង្គការថ្នាក់មូលដ្ឋាន មានសមត្ថភាពមិនស្មើគ្នាក្នុងការចូលរួមជាមួយដំណើរការស្រាវជ្រាវ និងដំណើរការគោលនយោបាយ ដែលធ្វើឱ្យពួកគេមិនសូវមានលទ្ធភាពជះឥទ្ធិពលដល់លទ្ធផល។ | • វិនិយោគលើការកសាងសមត្ថភាព សម្រាប់អង្គការតំណាងជនមានពិការភាព និងអ្នកដឹកនាំសហគមន៍ លើការបកស្រាយទិន្នន័យ ការចូលរួមក្នុងគោលនយោបាយ និងការតស៊ូមតិដោយសុវត្ថិភាព។<br>• ផ្សារភ្ជាប់ការកសាងសមត្ថភាពទៅនឹងវេទិកាពិភាក្សាដែលកំពុងដំណើរការ របស់កម្មវិធីពន្លកចំណេះ ដំណាក់កាលទី២។ |

| ឧបសគ្គ និងហេតុផលបញ្ជាក់ | អនុសាសន៍ |
|---|---|
| ការចូលរួម ច្រើនតែមានលក្ខណៈជាការទាញប្រយោជន៍ ដោយមានយន្តការផ្ដល់មតិត្រឡប់មានលក្ខណៈអន់ខ្សោយ និងខ្វះការអនុវត្តបន្តរហូតដល់ចប់សព្វគ្រប់ ដែលធ្វើឱ្យថយចុះទំនុកចិត្ត និងឆន្ទៈក្នុងការចូលរួម។ | • បង្កើតយន្តការច្បាស់លាស់សម្រាប់ការផ្ដល់មតិត្រឡប់ ដោយបង្ហាញពីរបៀបដែលធាតុចូលសហគមន៍មានឥទ្ធិពលលើការសម្រេចចិត្ត។<br>• គាំទ្រដល់ការចូលរួមជាប់លាប់ តាមរយៈការពិភាក្សាថ្នាក់ខេត្ត ដែលសហការសម្របសម្រួលដោយកម្មវិធីពន្លកចំណេះ ដំណាក់កាលទី ២ អាជ្ញាធរមូលដ្ឋាន និងតំណាងសហគមន៍។ |
| ការមិនសូវទទួលស្គាល់បទពិសោធន៍ជីវិតជាក់ស្ដែង និងការពឹងផ្អែកលើដំណើរការដែលជំរុញពីខាងក្រៅ កម្រិតភាពពាក់ព័ន្ធ និងភាពសមស្របនៃទិន្នន័យ។ | • ពង្រឹងអភិក្រមបង្កើតទិន្នន័យ ដែលដឹកនាំដោយសហគមន៍។<br>• គាំទ្រវេទិកាចូលរួមរយៈពេលវែង ដែលអនុញ្ញាតឱ្យសហគមន៍កំណត់សំណួរស្រាវជ្រាវ វិធីសាស្ត្រ និងការបកស្រាយលទ្ធផល។ |

## ៤.៣. ឱកាសសម្រាប់កម្មវិធីពន្លកចំណេះ

លទ្ធផលទាំងនេះបង្ហាញពីនិន្នាការស្របគ្នាមួយ គឺការប្ដេជ្ញាចិត្តចំពោះ សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ពិតជាមានមែន ប៉ុន្តែប្រព័ន្ធដែលត្រូវការចាំបាច់ដើម្បីអនុវត្តការប្ដេជ្ញាចិត្តនោះនៅមានលក្ខណៈអន់ថយ ខ្វះចន្លោះ និងមានការបែងចែកធនធានមិនស្មើគ្នា។ គម្លាតជាច្រើនដែលបានកំណត់ឃើញ មិនតម្រូវឱ្យមានគោលនយោបាយថ្មីនោះទេ ប៉ុន្តែវាទាមទារឱ្យមានការណែនាំច្បាស់លាស់ជាងមុន ការសម្របសម្រួលប្រសើរជាងមុន និងការផ្លាស់ប្ដូរតិចតួច ប៉ុន្តែមានការគិតគូរច្បាស់លាស់ ទៅលើរបៀបដាក់បញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ទៅក្នុងការរៀបចំផែនការ និងការស្រាវជ្រាវ។ ចំណុចនេះបង្កើតឱ្យមានឱកាសដ៏ជាក់ស្ដែងមួយសម្រាប់ឱ្យកម្មវិធីពន្លកចំណេះ ដំណាក់កាលទី២ ឈានហួសពីបរិយាបន្នកម្រិតគម្រោង ហើយដើរតួជាអ្នកជំរុញប្រព័ន្ធនៅទូទាំងរដ្ឋាភិបាល ប្រព័ន្ធអេកូឡូស៊ីនៃការស្រាវជ្រាវ និងតួអង្គសហគមន៍។ ឧត្តមភាពប្រៀបធៀបរបស់កម្មវិធីពន្លកចំណេះ ដំណាក់កាលទី២ ស្ថិតនៅលើតួនាទីក្នុងការកៀរគរ ភាពគួរឱ្យជឿទុកចិត្តរបស់កម្មវិធីនេះចំពោះរដ្ឋាភិបាល និងស្ថាប័នស្រាវជ្រាវ និងសមត្ថភាពផ្សារភ្ជាប់ការបង្កើតទិន្នន័យទៅនឹងឥទ្ធិពលលើគោលនយោបាយ។

**១ ការប្រែក្លាយការប្ដេជ្ញាចិត្តចំពោះ សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ទៅជាប្រព័ន្ធរដ្ឋាភិបាលដែលអាចប្រើប្រាស់បាន។ កម្មវិធីពន្លកចំណេះ មានតួនាទីដ៏ស័ក្តិសមក្នុងការជួយឱ្យក្រសួងនានាប្រែក្លាយឆន្ទៈគោលនយោបាយទៅជាការអនុវត្តប្រចាំថ្ងៃ។**

- ជាជាងដាក់បញ្ចូលក្របខណ្ឌថ្មីៗ កម្មវិធីពន្លកចំណេះ ដំណាក់កាលទី២ អាចផ្ដោតលើការធ្វើឱ្យការប្ដេជ្ញាចិត្តចំពោះ សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ដែលមានស្រាប់ អាចប្រើប្រាស់បានដោយមន្ត្រី ដែលបច្ចុប្បន្ននៅខ្វះឧបករណ៍ ទំនុកចិត្ត និងការលើកទឹកចិត្ត។ នេះរួមបញ្ចូលទាំងការគាំទ្រដល់ការធ្វើស្ថាប័នូបនីយកម្ម និងការផ្ដល់ធនធានដល់ក្រុមការងារបញ្ជ្រាបយេនឌ័រ (GMAGs) និងមន្ត្រីបង្គោលពិការភាព ការកំណត់លក្ខខណ្ឌតម្រូវសាមញ្ញៗសម្រាប់ការវិភាគយេនឌ័រ និងពិការភាពនៅក្នុងទម្រង់គំរូគោលនយោបាយ និងការស្រាវជ្រាវ និងការសាកល្បងស្តង់ដារអប្បបរមានៃការបង្កភាពងាយស្រួល នៅក្នុងដំណើរការពិគ្រោះយោបល់ដែលបានជ្រើសរើស។
- តាមរយៈការធ្វើការជាមួយក្រសួងពាក់ព័ន្ធ កម្មវិធីអាចបង្ហាញថាតើការចូលរួមក្នុងដំណើរការគោលនយោបាយដែលបង្កភាពងាយស្រួល និងប្រកបដោយបរិយាបន្ន មានលក្ខណៈដូចម្ដេចនៅក្នុងការអនុវត្តជាក់ស្ដែង និងបង្កើតជាម៉ូឌែលដែលអាចយកទៅអនុវត្តកាន់តែទូលំទូលាយ។

## ២ ការពង្រឹងបរិយាបន្នពិការភាព ឱ្យក្លាយជាធាតុផ្សំស្នូលនៃទិន្នន័យ និងគោលនយោបាយ។

**បរិយាបន្នពិការភាព នៅតែជាធាតុផ្សំមួយនៃសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ដែលសភាពខ្សោយជាងគេ ទាំងនៅក្នុងគោលនយោបាយ និងការស្រាវជ្រាវ។ កម្មវិធីពន្លកចំណេះ ដំណាក់កាលទី២ មានឱកាសជាក់ស្តែងក្នុងការផ្លាស់ប្តូរស្ថានភាពនេះ ដោយចាត់ទុកសមធម៌ពិការភាពជាមូលដ្ឋានគ្រឹះ ជាជាងជាជម្រើស។**

- កម្មវិធីអាចគាំទ្រដល់ក្រសួងនានា ក្នុងការពង្រឹងមន្ត្រីបង្គោលពិការភាព តាមរយៈការបណ្តុះបណ្តាលចំគោលដៅ ដែលផ្សារភ្ជាប់ទៅនឹងចំណុចអាទិភាពនៃផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ការកែលម្អការប្រមូលទិន្នន័យឱ្យប្រកបដោយបរិយាបន្នពិការភាព និងការទទួលស្គាល់អង្គការតំណាងជនមានពិការភាព ក្នុងនាមជាដៃគូគោលនយោបាយ ជាជាងត្រឹមតែជាអ្នកចូលរួមពិគ្រោះយោបល់។
- នៅក្នុងវិស័យស្រាវជ្រាវ កម្មវិធីពន្លកចំណេះ ដំណាក់កាលទី២ អាចតម្រូវឱ្យមានការរៀបចំ និងការផ្សព្វផ្សាយការស្រាវជ្រាវដែលបង្កភាពងាយស្រួល ជាលក្ខខណ្ឌស្តង់ដារនៃការផ្តល់មូលនិធិ គាំទ្រដល់ការសហការរៀបចំការស្រាវជ្រាវជាមួយអង្គការតំណាងជនមានពិការភាព និងធានាថា ការចំណាយលើការបង្កភាពងាយស្រួល ត្រូវបានបញ្ចូលទៅក្នុងថវិកា។

## ៣ ការផ្លាស់ប្តូរពីការជំរុញការចូលរួមដើម្បីទាញប្រយោជន៍ ទៅជាទិន្នន័យដែលដឹកនាំដោយសហគមន៍។

**សហគមន៍តែងតែសម្តែងឆន្ទៈចង់ចូលរួម ប៉ុន្តែមានការខកចិត្តចំពោះដំណើរការដែលមិនបង្កភាពងាយស្រួល មានលក្ខណៈទាញប្រយោជន៍ និងមិនឆ្លើយតបនឹងតម្រូវការ។ កម្មវិធីពន្លកចំណេះ មានឱកាសដ៏ល្អក្នុងការផ្លាស់ប្តូរហេតុផលនេះ តាមរយៈការវិនិយោគលើការបង្កើតទិន្នន័យដែលដឹកនាំដោយសហគមន៍ និងនៅថ្នាក់ក្រោមជាតិ។**

- មូលនិធិគាំទ្រការស្រាវជ្រាវដែលដឹកនាំដោយសហគមន៍ ការពិភាក្សាគោលនយោបាយថ្នាក់ខេត្ត និងការបណ្តុះបណ្តាលកម្រិតមូលដ្ឋានស្តីពីការបកស្រាយទិន្នន័យ អាចពង្រឹងតួនាទីរបស់សហគមន៍ អង្គការតំណាងជនមានពិការភាព  និងសង្គមស៊ីវិល ក្នុងនាមជាអ្នកផលិត និងអ្នកបកស្រាយចំណេះដឹង។
- ការគាំទ្រដល់កត្តាជំរុញជាក់ស្តែងដូចជា ការធ្វើដំណើរ ការបកប្រែ ការបកប្រែភាសាសញ្ញា និងការសម្របសម្រួលនៅមូលដ្ឋាន ជួយដោះស្រាយដោយផ្ទាល់នូវចំណុចខ្វះខាតក្នុងការរៀបចំ ដែលបានកត់សម្គាល់នៅក្នុងលទ្ធផលនានា។ ការវិនិយោគទាំងនេះជួយធានាថា ការចូលរួមធ្វើឡើងប្រកបដោយអត្ថន័យ ហើយធាតុចូលរបស់សហគមន៍ត្រូវបានបញ្ចូលទៅក្នុងការសម្រេចចិត្ត ជាជាងបញ្ចូលទៅក្នុងរបាយការណ៍។

## ៤ ការប្រើប្រាស់អំណាចកៀគររបស់កម្មវិធីពន្លកចំណេះ ដំណាក់កាលទី២ ដើម្បីកសាងគណនេយ្យភាព និងការរៀនសូត្រ។

កម្មវិធីអាចប្រើប្រាស់ឋានៈរបស់ខ្លួន ដើម្បីតភ្ជាប់តួអង្គដែលកម្រៀនសូត្រពីគ្នាទៅវិញទៅមក។ ក្រុមការងារអន្តរក្រសួង និងការពិភាក្សារវាងសហគមន៍ និងរដ្ឋាភិបាល បង្កើតជាឱកាសសម្រាប់សាកល្បងអភិក្រមបែបបរិយាបន្ន  ឆ្លុះបញ្ចាំងពីអ្វីដែលដំណើរការបានល្អ    និងកែសម្រួលទិសដៅ។ តាមរយៈការចងក្រងជាឯកសារ និងចែករំលែកមេរៀនពីការអនុវត្តសាកល្បង កម្មវិធីអាចជួយផ្លាស់ប្តូរ សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ពីសកម្មភាពដែលធ្វើឡើងតាមកាលៈទេសៈ និងជំរុញដោយម្ចាស់ជំនួយ ទៅជាការអនុវត្តដែលកាន់តែស៊ីសង្វាក់គ្នា និងមានគណនេយ្យភាព។ ចំណុចនេះបន្សុីគ្នានឹងទ្រឹស្តីនៃការផ្លាស់ប្តូរ របស់កម្មវិធីពន្លកចំណេះ ដំណាក់កាលទី២ តាមរយៈការពង្រឹងយន្តការផ្តល់មតិត្រឡប់រវាងទិន្នន័យ ការចូលរួម និងសកម្មភាពគោលនយោបាយ។

# ឯកសារយោង

## ក. ក្របខណ្ឌ និងអនុសញ្ញាអន្តរជាតិ

១. United Nations (២០១៨). Turning Promises into Action: Gender Equality in the ២០៣០ Agenda for Sustainable Development. New York: UN Women.
២. United Nations (២០១៥). Transforming Our World: The ២០៣០ Agenda for Sustainable Development. New York: United Nations Department of Economic and Social Affairs. Available at: sustainabledevelopment.un.org
៣. ILO (២០០២). Convention No. ១៦៩ on Indigenous and Tribal Peoples. Geneva: International Labour Organization.

## ខ. ឯកសាររបស់ក្រសួងការបរទេស និងពាណិជ្ជកម្ម (DFAT) និងរដ្ឋាភិបាលអូស្ត្រាលី

៤. DFAT (២០២៣). Gender Equality, Disability, and Social Inclusion Analysis: Good Practice Note. Canberra: Australian Government Department of Foreign Affairs and Trade.
៥. DFAT (២០២៥). Child Protection Policy ២០២៥. Canberra: Australian Government Department of Foreign Affairs and Trade. Available at: www.dfat.gov.au
៦. DFAT (២០២១). Independent Strategic Review: DFAT Support to the Identification of Poor Households (IDPoor) in Cambodia Phase ៣. Canberra: Australian Government.
៧. DFAT / EU / World Bank (២០២១). Analysis of Cambodia's Intergovernmental Fiscal Architecture.
៨. Gender at Work Collaborative. Gender at Work Framework.

## គ. រាជរដ្ឋាភិបាលកម្ពុជា៖ ច្បាប់ គោលនយោបាយ និងយុទ្ធសាស្ត្រ

៩. យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១៖ ការរក្សាសន្តិភាព ការជំរុញកំណើនសេដ្ឋកិច្ច និងការលើកកម្ពស់ សមធម៌ និងចីរភាព របស់រាជរដ្ឋាភិបាល (២០២៣)។
១០. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ របស់ក្រសួងផែនការ (ធ្វើបច្ចុប្បន្នភាព ឆ្នាំ២០២៤)។
១១. នារីរតនៈទី៦៖ ផែនការយុទ្ធសាស្ត្ររយៈពេល៥ឆ្នាំសម្រាប់សមភាពយេនឌ័រ ២០២៤-២០២៨ របស់ក្រសួងកិច្ចការនារី (ប្រកាសប្រើប្រាស់ថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤)។
១២. នារីរតនៈទី៥៖ ផែនការយុទ្ធសាស្ត្ររយៈពេល៥ឆ្នាំសម្រាប់សមភាពយេនឌ័រ ២០១៩-២០២៣ របស់ក្រសួងកិច្ចការនារី (២០១៩)។
១៣. ផែនការសកម្មភាពបញ្ជ្រាបយេនឌ័រ ២០១៩-២០២៣ របស់ក្រសួងកិច្ចការនារី (២០១៩)។
១៤. ផែនការមេស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ ២០១៨-២០៣០ របស់ក្រសួងកិច្ចការនារី/ក្រសួងបរិស្ថាន (២០១៨)។

១៥. ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ ២០២៤-២០២៨ របស់ក្រុមប្រឹក្សាសកម្មភាពជនពិការ នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (២០២៤)។
១៦. ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ ២០១៩-២០២៣ របស់ក្រុមប្រឹក្សាសកម្មភាពជនពិការ នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (២០១៩)។
១៧. ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ របស់រាជរដ្ឋាភិបាលកម្ពុជា (២០១៦)។
១៨. ច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ (២០០៩)។
១៩. អនុក្រឹត្យលេខ ៣៧២ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២៣ ស្តីពីការអនុវត្តកម្មវិធីជាតិជំនួយសង្គមក្នុង កញ្ចប់គ្រួសារ មូលនិធិជាតិជំនួយសង្គម (២០២៣)។
២០. ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ (១៩៩៦)។
២១. ក្រមបរិស្ថាន និងធនធានធម្មជាតិ (២០២៣)។
២២. យុទ្ធសាស្ត្រវេជបូកជាតិ ២០១៧-២០២៦ របស់ក្រសួងបរិស្ថាន (២០១៧)។
២៣. ផែនការជាតិរួមចំណែកឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា ជំណាក់កាលទី៣ (NDC ៣.0) របស់ក្រសួងបរិស្ថាន (២០២២)។
២៤. កម្រងលិខិតបទដ្ឋានគតិយុត្តគន្លះៗស្តីពី កំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (២០១៦) ប្រភព៖ ncdd.gov.kh
២៥. សៀវភៅណែនាំសម្រាប់គណៈកម្មាធិការទទួលបន្ទុកកិច្ចការស្ត្រី និងកុមារឃុំ សង្កាត់ (គ.ក.ស.ក) របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។


## ឃ. ស្ថិតិជាតិ និងប្រភពទិន្នន័យ


២៦. ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ២០២១-២០២២ របស់វិទ្យាស្ថានជាតិស្ថិតិ ក្រសួងសុខាភិបាល/ ICF (២០២៣)។
២៧. របាយការណ៍អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា ឆ្នាំ២០២២ របស់វិទ្យាស្ថានជាតិស្ថិតិ (២០២៣) នៃក្រសួងផែនការ។
២៨. World Bank / National Institute of Statistics (2023). Living Standards Measurement Survey (LSMS) Cambodia.
២៩. National Institute of Statistics / CAMSTAT. Cambodia Statistics Portal.

## ង. ស្នាដៃក្នុងផ្នែកសិក្សាធិការ និងវិភាគ

៣០. Crenshaw, K. (1989). ពាក្យ 'អន្តរប្រសព្វ' ដែលត្រូវបានបង្កើតឡើង ដើម្បីពណ៌នាអំពីរបៀបដែលទម្រង់ផ្សេងៗគ្នានៃការរើសអើង អំណាច និងឯកសិទ្ធិ ធ្វើអន្តរកម្មជាមួយគ្នានៅក្នុងជីវិតរស់នៅរបស់ស្ត្រីស្បែកខ្មៅ ក្នុងលក្ខណៈដែលត្រូវបានគេផាត់ចោល នៅពេលដែលការរើសអើងយេនឌ័រ និងការរើសអើងពូជសាសន៍ ត្រូវបានចាត់ទុកថាជារឿងដាច់ដោយឡែកពីគ្នា។ ចាប់តាំងពីពេលនោះមក ពាក្យនេះត្រូវបានពង្រីកបន្ថែម ដើម្បីពណ៌នាអំពីទម្រង់ត្រួតគ្នានៃការជិះជាន់ និងវិសមភាព ដែលកើតចេញពីគុណសម្បត្តិ និងគុណវិបត្តិផ្នែករចនាសម្ព័ន្ធ ដែលជះឥទ្ធិពលលើបទពិសោធន៍ និងឱកាសសង្គមរបស់បុគ្គល ឬក្រុមណាមួយ។ ពាក្យនេះពណ៌នាអំពីប្រព័ន្ធនៃការរើសអើង ដែលត្រួតគ្នា ឬពឹងផ្អែកលើគ្នាទៅវិញទៅមក ទាក់ទងនឹងអាយុ ពិការភាព ជាតិពន្ធុ យេនឌ័រ ទីតាំងភូមិសាស្ត្រ ភេទ ស្ថានភាពសេដ្ឋកិច្ចសង្គម ទំនោរផ្លូវភេទ។

៣១. Open Data Watch (2025). Guide: Integrating Intersectionality in Data Systems. Published in partnership with Data2X. Available at: opendatawatch.com/wp-content/uploads/2025/publications/Guide_Integrating-Intersectionality-in-Data-Systems.pdf

៣២. Konrad-Adenauer-Stiftung Cambodia (2025). The Evolving Role of Think Tanks in Cambodia: Special Report. Phnom Penh: KAS Cambodia.

៣៣. World Bank (2021). Cambodia: Intergovernmental Fiscal Architecture Study. Washington, DC: World Bank. Available at: documents.worldbank.org/curated/en/099440003152223052

៣៤. Open Development Cambodia (ODC) (2025). Policy Brief: Open Data for Disability Inclusion in Cambodia. Phnom Penh: Open Development Cambodia: https://policypulse.org/wpcontent/uploads/2025/03/2025_policybrieft_opendata_disability.pdf

## ច. ឯកសារកម្មវិធី និងស្ថាប័ន

៣៥. ACCESS 2 Program (n.d.). Australia-Cambodia Cooperation for Equitable Sustainable Services - Phase 2 (ACCESS 2). Program overview. Available at: access2cambodia.org/access-2-program/

៣៦. Ponlok Chomnes II (n.d.). Guidelines for Research Process and Quality Research. Phnom Penh: The Asia Foundation / Ponlok Chomnes II.

៣៧. Ponlok Chomnes II (n.d.). GEDSI and Disability-Inclusive Research Design Guidelines. Phnom Penh: The Asia Foundation / Ponlok Chomnes II.

៣៨. Pak, K., Fathimath, I., and Pellini, A. (2020), Diagnostic Study on the Cambodian Knowledge Sector, Policy Pulse, https://policypulse.org/wp-content/uploads/2020/07/Diagnostic_Study_FINAL_English-3.pdf

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ ១. សទ្ទានុក្រម ទស្សនទានស្នូលនៃសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម

**ការបង្កភាពងាយស្រួល (Accessibility)**
លក្ខណៈនៃការងាយស្រួលប្រើប្រាស់ ងាយស្រួលចូល ឬងាយស្រួលទៅដល់ដោយជនមានពិការភាព ដែលសំដៅលើការរចនាផលិតផល ឧបករណ៍ សេវា កម្មវិធីសិក្សា ឬបរិស្ថាន។

---

**ឧបសគ្គរារាំងលទ្ធភាពទទួលបាន (Access barriers)**
ឧបសគ្គដែលរារាំងមិនឱ្យជនមានពិការភាព ប្រើប្រាស់សម្ភាររូបវន្ត ឧបករណ៍ និងធនធានស្តង់ដារ។

---

**ពិការភាព (Disability)**
**អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនពិការ** (មាត្រា ១) ឱ្យនិយមន័យពិការភាពថាជា "ភាពអន់ខ្សោយរយៈពេលយូរផ្នែកកាយសម្បទា ប្រាជ្ញា ឬវិញ្ញាណ ដែលនៅពេលជួបប្រទះជាមួយឧបសគ្គនានា អាចរារាំងពួកគេមិនឱ្យមានការចូលរួមយ៉ាងពេញលេញ និងមានប្រសិទ្ធភាពក្នុងសង្គម ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ។" និយមន័យនេះសង្កត់ធ្ងន់ថា ពិការភាពមិនមែនស្ថិតតែលើបុគ្គលម្នាក់ៗប៉ុណ្ណោះទេ ប៉ុន្តែវាត្រូវបានបង្កើតឡើងតាមរយៈអន្តរកម្មរវាងការចុះខ្សោយ និងឧបសគ្គផ្នែកបរិស្ថាន សង្គម និងស្ថាប័ន។

---

**បរិយាបន្នពិការភាព (Disability inclusion)**
ដំណើរការនៃការធានាថា ជនមានពិការភាពអាចចូលរួមបានពេញលេញ និងដោយស្មើភាព ក្នុងគ្រប់ទិដ្ឋភាពទាំងអស់របស់សង្គម រួមទាំងការស្រាវជ្រាវ គោលនយោបាយ និងការធ្វើសេចក្តីសម្រេចចិត្ត។

---

**ភាពចម្រុះ (Diversity)**
ការឆ្លុះបញ្ចាំងពីសហគមន៍ទូលំទូលាយ។ ការមានសហគមន៍ចម្រុះ ដោយមានមនុស្សមកពីសាវតារចម្រុះ ដែលមានតំណាងនៅក្នុងគ្រប់វិស័យ និងគ្រប់កម្រិត។

**សមភាពយេនឌ័រ (Gender equality)**
អង្គការ UN Women, **ការិយាល័យទីប្រឹក្សាពិសេសទទួលបន្ទុកបញ្ហាយេនឌ័រ និងការលើកកម្ពស់ស្ត្រី (OSAGI) ការបញ្ជ្រាបយេនឌ័រ - ទស្សនទាន និងនិយមន័យ** បានឱ្យនិយមន័យសមភាពយេនឌ័រថាជា 'សិទ្ធិ ការទទួលខុសត្រូវ និងឱកាសស្មើគ្នារបស់ស្ត្រី និងបុរស និងក្មេងស្រី និងក្មេងប្រុស។ សមភាពមិនមានន័យថា ស្ត្រី និងបុរសនឹងក្លាយទៅជាអ្វីដែលដូចគ្នានោះទេ ប៉ុន្តែមានន័យថា សិទ្ធិ ការទទួលខុសត្រូវ និងឱកាសរបស់ស្ត្រី និងបុរស នឹងមិនអាស្រ័យលើថាពួកគេកើតមកជាមនុស្សស្រី ឬមនុស្សប្រុសឡើយ។ សមភាពយេនឌ័របង្កប់ន័យថា ផលប្រយោជន៍ តម្រូវការ និងអាទិភាពរបស់ស្ត្រី និងបុរស ត្រូវបានយកមកពិចារណា ដោយទទួលស្គាល់នូវភាពចម្រុះរបស់ក្រុមស្ត្រី និងបុរសផ្សេងៗគ្នា។'

---

**ការបញ្ជ្រាបយេនឌ័រ (Gender mainstreaming)**
អង្គការ UN Women, **ការិយាល័យ OSAGI ការបញ្ជ្រាបយេនឌ័រ - ទស្សនទាន និងនិយមន័យ** បានឱ្យនិយមន័យការបញ្ជ្រាបយេនឌ័រថាជាការធានាថា 'ទស្សនៈយេនឌ័រ និងការយកចិត្តទុកដាក់ចំពោះគោលដៅសមភាពយេនឌ័រ គឺជាចំណុចស្នូលនៃរាល់សកម្មភាព ការអភិវឌ្ឍគោលនយោបាយ ការស្រាវជ្រាវ ការតស៊ូមតិ/ការពិភាក្សា នីតិកម្ម ការបែងចែកធនធាន និងការធ្វើផែនការ ការអនុវត្ត និងការតាមដានត្រួតពិនិត្យកម្មវិធី និងគម្រោង។'

---

**សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម (GEDSI)**
Gender Equality, Disability and Social Inclusion
គឺជាពាក្យដែលបង្កើតឡើងដោយក្រសួងការបរទេស និងពាណិជ្ជកម្ម (DFAT) អូស្ត្រាលី ដើម្បីធានាថា 'គ្មាននរណាម្នាក់ត្រូវបានទុកចោល។' សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ដាក់បញ្ចូលទស្សនទាននៃការផាត់ចេញពីសង្គម និងបរិយាបន្នសង្គម ដោយធានាថា កត្តាទាំងនេះត្រូវ

បានដោះស្រាយរួមគ្នា ជាជាងដោះស្រាយ ដាច់ដោយឡែកពីគ្នា។ អភិក្រមរបស់ DFAT ក្នុងការវិភាគសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម 'កំណត់ថាតើមនុស្សទទួលបានបទពិសោធន៍បែបណាពីបទដ្ឋានសង្គម ទំនាក់ទំនង និងឌីណាមិកអំណាច ដោយសារតែអត្តសញ្ញាណរបស់ពួកគេ រួមទាំងយេនឌ័រ អាយុ ពិការភាព ប្រាក់ចំណូល ការអប់រំ ជំនឿ ពូជសាសន៍ ជាតិពន្ធុ ទំនោរផ្លូវភេទ និងស្ថានភាពទេសន្តរប្រវេសន៍។'

## ការវិភាគសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម (GEDSI Analysis)

កំណត់ត្រានៃការអនុវត្តល្អពាក់ព័ន្ធនឹងការវិភាគសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម របស់ DFAT ទទួលស្គាល់ថា មានក្រុមមនុស្សជាក់លាក់ដែលជួបប្រទះការផាត់ចេញ និងការមិនទទួលបានការយកចិត្តទុកដាក់ ទោះជាស្ថិតក្នុងយេនឌ័រណាក៏ដោយ។ អភិក្រមរបស់ DFAT ចំពោះការវិភាគសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម 'កំណត់ថាតើមនុស្សទទួលបានបទពិសោធន៍បែបណាពីបទដ្ឋានសង្គម ទំនាក់ទំនង និងអំណាចគ្របដណ្តប់ ដោយសារតែអត្តសញ្ញាណរបស់ពួកគេ។ អភិក្រមនេះទទួលស្គាល់ថា អន្តរកម្មរវាងការចុះខ្សោយ (កាយសម្បទា វិញ្ញាណ ចិត្តសង្គម ប្រាជ្ញា) និងឧបសគ្គ (បរិស្ថានរូបវន្ត សង្គម ការប្រាស្រ័យទាក់ទង និងស្ថាប័ន) មានផលប៉ះពាល់យ៉ាងទូលំទូលាយ និងស្វែងយល់ពីរបៀបដែលធាតុផ្សំទាំងនេះត្រួតគ្នាបង្កើតជាបទពិសោធន៍ចម្រុះនៃការផាត់ចេញ និងការមិនទទួលបានការយកចិត្តទុកដាក់។'

## ការបញ្ជ្រាបសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម តាមរយៈអភិក្រមពីរផ្លូវ (GEDSI Mainstreaming with a Twin-Track Approach)៖

អភិក្រមពីរផ្លូវ សំដៅលើការអនុវត្តទាំងការដាក់បញ្ចូល និងការផ្តោតគោលដៅលើក្រុម សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម នៅក្នុងសកម្មភាព ឬកម្មវិធីមួយ។ អភិក្រមនេះមានគោលបំណងធានាថា ស្ត្រី ជនមានពិការភាព និងក្រុមងាយរងគ្រោះផ្សេងទៀត អាចត្រូវបានដាក់បញ្ចូលទៅក្នុងការងារទាំងមូល ហើយទន្ទឹមនឹងនោះ អនុវត្តគំនិតផ្តួចផ្តើមចំគោលដៅ ទៅតាមការចាំបាច់។

- **ឧទាហរណ៍នៃការដាក់បញ្ចូល៖**
  ការដាក់បញ្ចូលមានន័យថា គ្រប់អភិក្រម និងសកម្មភាពទាំងអស់ត្រូវពិចារណាពីស្ថានភាពខុសគ្នារបស់ស្ត្រី និងបុរស។ ឧទាហរណ៍ ដើម្បីឱ្យលទ្ធផលនៃការស្រាវជ្រាវគោលនយោបាយ ត្រូវបានផ្សព្វផ្សាយដោយប្រសិទ្ធភាពទៅកាន់ភាគីពាក់ព័ន្ធចម្រុះ ការសំខាន់គឺត្រូវផ្សព្វផ្សាយលទ្ធផលទៅកាន់ភាគីពាក់ព័ន្ធទាំងស្ត្រី និងបុរស ព្រមទាំងជនមានពិការភាព (ឧ. តាមរយៈអង្គការតំណាងជនមានពិការភាព) និងក្រុមជនជាតិដើមភាគតិច (ឧ. ជាភាសាក្នុងមូលដ្ឋាន) ជាដើម ដោយប្រើប្រាស់វិធីសាស្ត្រដែលបង្ហាញពីការគោរព និងបំពេញតម្រូវការរបស់គ្រប់ភាគី។

- **ឧទាហរណ៍នៃការផ្តោតចំគោលដៅ៖**
  ការផ្តោតចំគោលដៅ សំដៅជាពិសេសទៅលើក្រុមគោលដៅតែមួយ និងស្ថានភាពរបស់ពួកគេ។ ឧទាហរណ៍ ការស្រាវជ្រាវដែលផ្តោតចំគោលដៅ អាចពាក់ព័ន្ធនឹងការស្វែងយល់ឱ្យបានស៊ីជម្រៅទៅលើបញ្ហាជាក់លាក់របស់ក្រុមតែមួយដូចជា ស្ត្រី និងការងារថែទាំ លទ្ធភាពទទួលបានជាសកល និងផាសុកសមរម្យសម្រាប់ជនមានពិការភាព ឬការរើសអើង និងការបៀតបៀនដោយបើកចំហរទៅលើក្រុមស្រលាញ់ភេទដូចគ្នា ដើម្បីធានាបាននូវការដាក់បញ្ចូលបញ្ហារបស់ក្រុមនោះ។ ការងារនេះក៏អាចពាក់ព័ន្ធនឹងការផ្តោតគោលដៅលើអត្តសញ្ញាណត្រួតគ្នាផងដែរ ដូចជា ស្ត្រីមានពិការភាព ដែលមានប្រាក់ចំណូលទាប យុវជនជាជនជាតិដើមភាគតិចមកពីសហគមន៍ដាច់ស្រយាល។

**ជនជាតិដើមភាគតិច (Indigenous People)**
ធនាគារពិភពលោកបញ្ជាក់ថា ជនជាតិដើមភាគតិច គឺជា 'សង្គម និងសហគមន៍ដែលមានភាពខុសគ្នាខាងវប្បធម៌ ដែលមានចំណងទាក់ទងជាសមូហភាពតាំងពីដូនតាទៅនឹង ដីធ្លី និងធនធានធម្មជាតិ ដែលពួកគេរស់នៅ កាន់កាប់ ឬដែលពួកគេត្រូវបានបណ្តេញចេញ។' ទោះបីជាជនជាតិដើមភាគតិច មានចំនួនប្រមាណ ៦ ភាគរយនៃចំនួនប្រជាជនពិភពលោកក៏ដោយ ប៉ុន្តែពួកគេមានចំនួនប្រហែល ១៩ ភាគរយនៃចំនួនប្រជាជនក្រីក្របំផុត។" [និយមន័យនេះត្រូវបានគាំទ្រដោយ អង្គការជនជាតិដើមភាគតិចកម្ពុជា (CIPO)។]

**អន្តរប្រសព្វ (Intersectionality)**
បង្កើតឡើងដោយបញ្ញវន្តច្បាប់ លោកស្រី Kimberlé Crenshaw ក្នុងឆ្នាំ១៩៨៩ អន្តរប្រសព្វពណ៌នាអំពីរបៀបដែលទម្រង់នៃការរើសអើង អំណាច និងឯកសិទ្ធិជាច្រើន ជួបប្រសព្វគ្នាដើម្បីជះឥទ្ធិពលលើបទពិសោធន៍ និងឱកាសសង្គមរបស់បុគ្គល ឬក្រុម។ ពាក្យនេះពណ៌នាអំពី 'ប្រព័ន្ធនៃការរើសអើងដែលត្រួតគ្នា ឬអាស្រ័យលើគ្នាទៅវិញទៅមក ទាក់ទងនឹងអាយុ ពិការភាព ជាតិពន្ធុ យេនឌ័រ ទីតាំងភូមិសាស្ត្រ ភេទ ស្ថានភាពសេដ្ឋកិច្ចសង្គម ទំនោរផ្លូវភេទ' និងអត្តសញ្ញាណផ្សេងៗទៀត។ ក្នុងការងារសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម អន្តរប្រសព្វមានន័យថា ការវិភាគពីរបៀបដែលអត្តសញ្ញាណត្រួតគ្នាទាំងនេះ មានឥទ្ធិពលលើបទពិសោធន៍ជីវិតជាក់ស្តែង និងការជានាថា កម្មវិធីឆ្លើយតបទៅនឹងតថភាពជាក់ស្តែងដែលមានច្រើនកម្រិត ជាជាងការសន្មតថា ដំណោះស្រាយមួយអាចប្រើបានសម្រាប់មនុស្សគ្រប់គ្នា។ ឯកសារណែនាំ និងឧបករណ៍ស្តីពីអន្តរប្រសព្វរបស់អង្គការ UN Women បានគូសបញ្ជាក់អំពី 'សក្តានុពលប្រកបដោយការ ផ្លាស់ប្តូរនៃអន្តរប្រសព្វ ដែលលាតសន្ធឹងហួសពីការពឹងផ្អែកតែលើផលជះនៃអត្តសញ្ញាណប្រទាក់ក្រឡាគ្នា។' យោងតាម DFAT "[ការវិភាគសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម] គិតគូរពីភាពប្រទាក់ក្រឡា និងពិចារណាលើអត្តសញ្ញាណចម្រុះរបស់មនុស្ស និងរបៀបដែលកត្តាទាំងនេះជះឥទ្ធិពលលើបទពិសោធន៍ ក្តីកង្វល់ តម្រូវការ និងសមត្ថភាពផ្សេងៗគ្នារបស់ពួកគេ" ហើយ "ការវិភាគសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ប្រកបដោយគុណភាពប្រើប្រាស់អភិក្រមបែបអន្តរប្រសព្វ។ ការវិភាគ សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ដែលទទួលស្គាល់បទពិសោធន៍ និងលទ្ធភាពទទួលបានអំណាចខុសៗគ្នារបស់មនុស្ស ជួយឱ្យការរៀបចំកម្មវិធីកាន់តែចំគោលដៅ និងមានប្រសិទ្ធភាពជាងមុន។"

**ក្រុមស្រលាញ់ភេទដូចគ្នា (LGBTQIA+)**
ស្រីស្រឡាញ់ស្រី ប្រុសស្រឡាញ់ប្រុស ទ្វេភេទ អ្នកប្តូរយេនឌ័រ អ្នកមានអត្តសញ្ញាណយេនឌ័រមិនច្បាស់លាស់ អ្នកមានលក្ខណៈជីវសាស្ត្រទាំងពីរភេទ អ្នកគ្មានចំណង់ផ្លូវភេទ/មនោសញ្ចេតនា និងអត្តសញ្ញាណយេនឌ័រ ឬចំណង់ផ្លូវភេទចម្រុះផ្សេងទៀត។

**ការមិនទទួលបានការយកចិត្តទុកដាក់ (Marginalisation)**
ដំណើរការដែលបុគ្គល ឬក្រុមនានា ត្រូវបានរុញច្រានទៅជាយសង្គម និងត្រូវបានផាត់ចេញពីលទ្ធភាពទទួលបានសិទ្ធិ ធនធាន ឱកាស និងការធ្វើសេចក្តីសម្រេច។ ការមិនទទួលបានការយកចិត្តទុកដាក់ ស្តែងឡើងតាមរយៈយន្តការត្រួតគ្នាជាច្រើន រួមមានសង្គម សេដ្ឋកិច្ច ភូមិសាស្ត្រ ស្ថាប័ន និងនយោបាយ ហើយជារឿយៗ កាន់តែធ្ងន់ធ្ងរនៅពេលដែលបុគ្គលម្នាក់ៗមានអត្តសញ្ញាណច្រើន ដែលមិនទទួលបានការយកចិត្តទុកដាក់។

### ក្រុមងាយរងគ្រោះ ឬក្រុមត្រូវបានផាត់ចេញពីសង្គម (Marginalised groups)

ក្រុមងាយរងគ្រោះ ឬក្រុមត្រូវបានផាត់ចេញពីសង្គម គឺជាប្រភេទក្រុមមនុស្សក្នុងសង្គមដែលប្រឈមមុខនឹងគុណវិបត្តិផ្នែកសង្គម សេដ្ឋកិច្ច នយោបាយ ឬវប្បធម៌ ហើយត្រូវបានរុញច្រានឱ្យចាកឆ្ងាយផុតពីប្រជាជនទូទៅ។ ក្រុមងាយរងគ្រោះ ឬត្រូវបានផាត់ចេញពីសង្គម រួមបញ្ចូលក្រុមដែលជួបប្រទះការផាត់ចេញផ្នែករចនាសម្ព័ន្ធ រួមមានស្ត្រី ជនមានពិការភាព ជនជាតិដើមភាគតិច ក្រុមស្រលាញ់ភេទដូចគ្នា ប្រជាជនដែលមានប្រាក់ចំណូលទាប ជនជាតិភាគតិច ជនក្រីក្រ និងក្រុមប្រតិបត្តិសាសនាភាគតិច។

---

### ផាសុកសមរម្យ (Reasonable accommodation)

ការកែសម្រួល ឬការផ្លាស់ប្តូរបរិយាកាស ដែលសម្រួលដល់ជនមានពិការភាព ឧទាហរណ៍ អាចដាក់ពាក្យសុំចូលធ្វើការ បំពេញមុខងារចាំបាច់ក្នុងការងារ ឬទទួលបានអត្ថប្រយោជន៍ស្មើគ្នានឹងអត្ថប្រយោជន៍ ដែលផ្តល់ជូនបុគ្គលិកដែលមិនមានពិការភាព។

---

### ការផាត់ចេញពីសង្គម (Social exclusion)

ផ្អែកលើនិយមន័យនានា ដូចជា ការកំណត់អត្តសញ្ញាណបរិយាបន្ន និងការផាត់ចេញពីសង្គមរបស់អង្គការសហប្រជាជាតិ ការផាត់ចេញពីសង្គម សំដៅលើ 'ច្បាប់ គោលនយោបាយ សេចក្តីសម្រេច អាកប្បកិរិយារបស់ស្ថាប័ន និងរចនាសម្ព័ន្ធដែលផាត់ចេញសហគមន៍ទាំងមូល ឬក្រុមមនុស្សជាប្រព័ន្ធពីសិទ្ធិ ឱកាស និងធនធាន ដែលមនុស្សភាគច្រើននៅក្នុងសង្គមទទួលបាន។' ការមានជីវភាពក្រីក្រអាចនាំឱ្យមានការផាត់ចេញ ប៉ុន្តែការផាត់ចេញពីសង្គមមានវិសាលភាពធំទូលាយជាងភាពក្រីក្រ គឺវាគ្របដណ្តប់លើទិដ្ឋភាពនយោបាយ ភូមិសាស្ត្រ សង្គម និងសេដ្ឋកិច្ច។

---

### បរិយាបន្នសង្គម (Social inclusion)

បរិយាបន្នសង្គម សំដៅលើដំណើរការនៃការដោះស្រាយឧបសគ្គផ្នែករចនាសម្ព័ន្ធ និងអតុល្យភាពអំណាច ដើម្បីឱ្យមនុស្សគ្រប់រូប ជាពិសេសអ្នកដែលត្រូវបានគេផាត់ចេញដោយសារអត្តសញ្ញាណត្រួតគ្នា អាចចូលរួមដោយស្មើភាពនៅក្នុងសង្គម ទទួលបានឱកាស និងធនធាន និងទទួលបានអត្ថប្រយោជន៍ពីលទ្ធផលនៃការអភិវឌ្ឍ។

---

## ទស្សនទានទាក់ទងនឹងវិស័យស្រាវជ្រាវ និងគោលនយោបាយ

### ការពិភាក្សា (Dialogue)

ការផ្លាស់ប្តូរព័ត៌មាន គំនិត ឬមតិ រវាងភាគីនានាតាមរយៈពាក្យសម្តី ឬសំណេរ។ គោលដៅនៃការពិភាក្សាអាចមានចាប់ពីការយល់ដឹងពីគ្នាទៅវិញទៅមក រហូតដល់ការស្វែងយល់ពីប្រធានបទនានា។ ការពិភាក្សាមានភាពបត់បែន និងមានប្រយោជន៍សម្រាប់ភាពច្បាស់លាស់ ការរៀនសូត្រ ឬការកសាងទំនាក់ទំនង។ ក្នុងបរិបទគោលនយោបាយ ការពិភាក្សាសំដៅលើការសន្ទនា ឬកិច្ចពិភាក្សាដែលមានការរៀបចំ និងគោលបំណងច្បាស់លាស់ ក្នុងចំណោមភាគីពាក់ព័ន្ធចម្រុះ រួមមានមន្ត្រីរដ្ឋាភិបាល អ្នកជំនាញ អ្នកស្រាវជ្រាវ អង្គការសង្គមស៊ីវិល និងសាធារណជន ក្នុងគោលបំណងចែករំលែកចំណេះដឹង កំណត់មធ្យោបាយដោះស្រាយបញ្ហា ឬឱកាសគោលនយោបាយជាក់លាក់ និងជាទីបំផុត ផ្តល់ព័ត៌មានសម្រាប់ការអភិវឌ្ឍ ការអនុវត្ត ឬការកែសម្រួលគោលនយោបាយ និងគំនិតផ្តួចផ្តើមនានា។

---

### ទិន្នន័យ (Evidence)

សំដៅលើព័ត៌មានជាក់ស្តែង តួលេខ លទ្ធផលនៃការស្រាវជ្រាវ ឬចំណេះដឹង ដែលត្រូវបានប្រើប្រាស់ដើម្បីផ្តល់ព័ត៌មានសម្រាប់គោលបំណងផ្សេងៗ រួមទាំងការអភិវឌ្ឍគោលនយោបាយ ការវិភាគ និងដំណើរការធ្វើសេចក្តីសម្រេច។ ខណៈដែល "ទិន្នន័យចម្រុះ" សង្កត់ធ្ងន់លើភាពចម្រុះនៃប្រភព និងវិធីសាស្ត្រ "ទិន្នន័យប្រកបដោយបរិយាបន្ន" សង្កត់ធ្ងន់លើការតំណាង ជាពិសេសសំឡេងដែលជារឿយៗត្រូវបានគេផាត់ចេញ។

### ការតាក់តែងគោលនយោបាយផ្អែកលើទិន្នន័យ ( Evidence based policymaking )

'គោលនយោបាយផ្អែកលើទិន្នន័យ' គឺជាអភិក្រមមួយសម្រាប់ការសម្រេចចិត្តលើគោលនយោបាយ ដែលផ្ដោតអាទិភាពលើការប្រើប្រាស់ការស្រាវជ្រាវ និងទិន្នន័យដែលល្អិតល្អន់ និងមានគុណភាពខ្ពស់ ជាមូលដ្ឋានចម្បងសម្រាប់ការរៀបចំ ការអនុវត្ត និងការវាយតម្លៃគោលនយោបាយ។

---

### ការតាក់តែងគោលនយោបាយដោយទទួលបានធាតុចូលពីទិន្នន័យ ( Evidence-informed policymaking )

ការអនុវត្តការធ្វើសេចក្ដីសម្រេចលើគោលនយោបាយ ដោយផ្អែកលើទិន្នន័យ និងព័ត៌មានដែលអាចជឿទុកចិត្តបាន និងពាក់ព័ន្ធ។ ក្នុងបរិបទនៃការពិភាក្សាអំពីការប្រើប្រាស់ទិន្នន័យនៅក្នុងវិស័យផ្សេងៗ មានការទទួលស្គាល់កាន់តែច្រើនឡើងថា ទិន្នន័យគ្រាន់តែជាកត្តាសំខាន់មួយក្នុងចំណោមកត្តាសំខាន់ៗជាច្រើន ដែលជះឥទ្ធិពលលើការតាក់តែងគោលនយោបាយ។ កន្សោមពាក្យ 'គោលនយោបាយដែលទទួលបានធាតុចូលពីទិន្នន័យ' បានគិតគូរអំពីចំណុចនេះ។ ពាក្យនេះក៏ចង្អុលបង្ហាញពីទិដ្ឋភាពកាន់តែស៊ីជម្រៅនៃការប្រើប្រាស់ទិន្នន័យផងដែរ ដែលក្នុងនោះ ប្រភេទផ្សេងៗនៃការស្រាវជ្រាវដែលមានទស្សនៈខុសគ្នា សុទ្ធតែបានផ្ដល់ធាតុចូលដល់ដំណើរការអភិវឌ្ឍគោលនយោបាយ។ នេះគឺផ្ទុយពីគំនិតនៃការធ្វើការសម្រេចចិត្ត ដោយផ្អែកលើឯកសារស្រាវជ្រាវតែមួយ ឬទស្សនទាន 'ឥទ្ធិពលគោលនយោបាយ' ដែលជាធម្មតា ផ្ដោតលើឯកសារស្រាវជ្រាវតែមួយ ដើម្បីព្យាយាមរកច្រកចូលទៅក្នុងគោលនយោបាយ។

---

### ដំណើរការនៃការប្រែក្លាយទិន្នន័យទៅជាគោលនយោបាយ ( Evidence-to-policy chain )

សំដៅលើដំណើរការវិលចុះឡើង ដែលទិន្នន័យ និងចំណេះដឹងត្រូវបានបង្កើតឡើង បកស្រាយ ផ្សព្វផ្សាយ និងប្រើប្រាស់តាមរយៈការពិភាក្សា និងការចូលរួម ដើម្បីជះឥទ្ធិពលលើដំណើរការគោលនយោបាយ សេចក្ដីសម្រេច និងការអនុវត្ត ដោយយកចិត្តទុកដាក់ទៅលើ ថាតើចំណេះដឹងរបស់នរណាត្រូវបានដាក់បញ្ចូល និងថាតើសំឡេងរបស់នរណាមានឥទ្ធិពលលើលទ្ធផល។

### វិស័យស្រាវជ្រាវ ( Knowledge sector )

ប្រព័ន្ធអេកូឡូស៊ីនៃស្ថាប័ន បណ្ដាញ និងបុគ្គល ដែលពាក់ព័ន្ធនឹងការបង្កើត ការផ្សព្វផ្សាយ និងការប្រើប្រាស់ចំណេះដឹង ដើម្បីផ្ដល់ព័ត៌មានដល់គោលនយោបាយសាធារណៈ និងការធ្វើសេចក្ដីសម្រេច រួមមានសាកលវិទ្យាល័យ វិទ្យាស្ថានស្រាវជ្រាវ ស្ថាប័នthink tanks អង្គការសង្គមស៊ីវិល អង្គភាពស្រាវជ្រាវរបស់រដ្ឋ និងវេទិកាពិភាក្សាគោលនយោបាយ។ វិស័យស្រាវជ្រាវគឺជាប្រព័ន្ធមួយ មិនមែនគ្រាន់តែជាបណ្ដុំនៃតួអង្គនោះទេ។ វិស័យនេះរួមបញ្ចូល៖

- អ្នកបង្កើតចំណេះដឹង៖ សាកលវិទ្យាល័យ ស្ថាប័នស្រាវជ្រាវ និងស្ថាប័ន think tanks
- អ្នកប្រើប្រាស់ចំណេះដឹង៖ អ្នកតាក់តែងគោលនយោបាយ ក្រសួង ស្ថាប័នសាធារណៈ
- អន្តរការី៖ ប្រព័ន្ធផ្សព្វផ្សាយ បណ្ដាញ អង្គការដែលបកស្រាយទិន្នន័យ
- បរិយាកាសអំណោយផល៖ វិធាន បទដ្ឋាន និងការលើកទឹកចិត្ត ដែលជះឥទ្ធិពលលើរបៀបដែលចំណេះដឹងត្រូវបានបង្កើតឡើង និងប្រើប្រាស់។

---

### ការស្រាវជ្រាវប្រកបដោយបរិយាបន្ន ( Inclusive research )

សំដៅលើអភិក្រមស្រាវជ្រាវ ដែលមានចេតនាទាក់ទាញការចូលរួមពីភាគីពាក់ព័ន្ធជាច្រើន រួមទាំងអ្នកដែលមានសាវតារចម្រុះ និងទស្សនៈយល់ឃើញផ្សេងៗគ្នា ដូចជា ស្ត្រី ជនមានពិការភាព ជនជាតិភាគតិច និងក្រុមងាយរងគ្រោះផ្សេងទៀត។ អភិក្រមនេះធានាថា ដំណើរការ វិធីសាស្ត្រ និងលទ្ធផលនៃការស្រាវជ្រាវមានបរិយាបន្ន និងតំណាងឱ្យប្រជាជនកាន់តែច្រើន ដែលនាំទៅរកការយល់ដឹងអំពីគោលនយោបាយ ដែលកាន់តែគ្រប់ជ្រុងជ្រោយ និងប្រកបដោយសមធម៌។

### ការពិភាក្សាប្រកបដោយបរិយាបន្ន (Inclusive dialogue)

ការពិភាក្សាប្រកបដោយបរិយាបន្ន ពាក់ព័ន្ធនឹងការជំរុញការសន្ទនាបែបបើកចំហ និងមានការចូលរួម ក្នុងចំណោមភាគីពាក់ព័ន្ធចម្រុះ រួមមាន ស្ត្រី ជនមានពិការភាព ជនជាតិភាគតិច អ្នកមានទំនោរផ្លូវភេទផ្សេងៗ និងក្រុមផ្សេងទៀតដែលមិនសូវមានតំណាង។ ការពិភាក្សាបែបនេះមានគោលបំណងធានាថា សំឡេងទាំងអស់ត្រូវបានគេស្តាប់ គោរព និងអាចរួមចំណែកយ៉ាងសកម្មដល់ការពិភាក្សាគោលនយោបាយ។ ការពិភាក្សាប្រកបដោយបរិយាបន្នលើកកម្ពស់ការធ្វើសេចក្តីសម្រេចចិត្តដោយមានការសហការ និងអាចឱ្យគេដាក់បញ្ចូលទស្សនៈចម្រុះទៅក្នុងដំណើរការគោលនយោបាយ

---

### ឥទ្ធិពលគោលនយោបាយ (Policy influence)

ឥទ្ធិពលគោលនយោបាយនៅក្នុងវិស័យស្រាវជ្រាវ និងចំណេះដឹង គឺជាដំណើរការរយៈពេលវែង និងមានគោលបំណងច្បាស់លាស់ ដែលតាមរយៈនោះ តួអង្គស្រាវជ្រាវ បង្កើតធ្វើជាអន្តរការី និងផ្សព្វផ្សាយទិន្នន័យ ដើម្បីជះឥទ្ធិពលលើរបៀបដែលបញ្ហាគោលនយោបាយត្រូវបានគេយល់ដឹង ជជែកដេញដោល និងសម្រេច ដោយមានការចូលរួមពីអ្នកតាក់តែងគោលនយោបាយ និងភាគីពាក់ព័ន្ធផ្សេងទៀត តាមរយៈទំនាក់ទំនង ការពិភាក្សា និងការរៀបចំក្របខណ្ឌយុទ្ធសាស្ត្រ នៅក្នុងបរិយាកាសគោលនយោបាយដ៏ស្មុគស្មាញ។

---

### ដំណើរការគោលនយោបាយ (Policy processes)

សម្រាប់កម្មវិធីពន្លកចំណេះ ដំណាក់កាលទី២ "ដំណើរការគោលនយោបាយ" សំដៅលើវដ្ត និងដំណាក់កាលផ្សេងៗនៃគោលនយោបាយ។ កម្មវិធីនេះទទួលស្គាល់ថា ដំណើរការគោលនយោបាយមិនមែនជាព្រឹត្តិការណ៍ដាច់តែឯងនោះទេ ប៉ុន្តែជាដំណើរការបន្តបន្ទាប់គ្នាដែលមានដំណាក់កាលជាច្រើន។ ដំណើរការនេះលាតសន្ធឹងលើសពីការកំណត់របៀបវារៈ ឬការបង្កើតគោលនយោបាយ និងគ្របដណ្តប់លើវិសាលភាពទាំងមូលនៃការវិវត្តរបស់គោលនយោបាយ។

- **ការកំណត់បញ្ហា៖** ការកំណត់រក និងការឱ្យនិយមន័យបញ្ហាដែលទាមទារការយកចិត្តទុកដាក់លើគោលនយោបាយ។
- **ការកំណត់របៀបវារៈ៖** កំណត់រក និងផ្តោតអាទិភាពលើបញ្ហាដែលត្រូវការអន្តរាគមន៍ពីរដ្ឋាភិបាល។
- **ការតាក់តែងគោលនយោបាយ៖** កំណត់គោលបំណង វាយតម្លៃដំណោះស្រាយ ប៉ាន់ប្រមាណការចំណាយ និងផលប៉ះពាល់ និងជ្រើសរើសឧបករណ៍គោលនយោបាយ។
- **ការរៀបចំថវិកា៖** បែងចែកធនធានហិរញ្ញវត្ថុ និងធានាថាការផ្តល់មូលនិធិស្របតាមគោលបំណងនៃគោលនយោបាយ។
- **ការធ្វើឱ្យមានភាពស្របច្បាប់៖** ធានាការផ្តល់ការគាំទ្រដល់គោលនយោបាយដែលបានជ្រើសរើស តាមរយៈការអនុម័តដោយអំណាចនីតិប្បញ្ញត្តិ និងអំណាចនីតិប្រតិបត្តិ ឬការពិគ្រោះយោបល់។
- **ការអនុវត្ត៖** ចាត់តាំងស្ថាប័នសម្រាប់ការអនុវត្ត ដោយធានាថាស្ថាប័ននោះមានធនធានចាំបាច់ និងការត្រួតពិនិត្យ។
- **ការតាមដានត្រួតពិនិត្យ៖** តាមដាន និងរាយការណ៍ជាប្រចាំអំពីការអនុវត្តគោលនយោបាយ និងវឌ្ឍនភាព។
- **ការវាយតម្លៃ៖** ពិនិត្យមើលប្រសិទ្ធភាពគោលនយោបាយ ភាពត្រឹមត្រូវនៃការអនុវត្ត និងលទ្ធផល។
- **ការរក្សាទុក ឬការបញ្ចប់៖** សម្រេចថាតើគោលនយោបាយគួរតែបន្ត កែប្រែ ឬបញ្ចប់។

---

### ការស្រាវជ្រាវគោលនយោបាយ (Policy research)

ការស្រាវជ្រាវដែលត្រូវបានរៀបចំ និងធ្វើឡើង ដើម្បីផ្តល់ព័ត៌មានដល់ការអភិវឌ្ឍ ការកែប្រែ ឬការវាយតម្លៃគោលនយោបាយសាធារណៈ។ ការស្រាវជ្រាវគោលនយោបាយគឺជាសកម្មភាពគន្លឹះនៅក្នុងកម្មវិធី ដែលពាក់ព័ន្ធនឹងការបង្កើតទិន្នន័យ និងចំណេះដឹង ដើម្បីគាំទ្រដល់ការធ្វើសេចក្តីសម្រេចដែលទទួលបានជាតុចូលពីទិន្នន័យ។

# ឧបសម្ព័ន្ធ ២. បញ្ជីរាយនាមអង្គការ និងស្ថាប័នដែលបានពិគ្រោះយោបល់

អង្គការ និងស្ថាប័នដូចខាងក្រោមនេះ បានចូលរួមតាមរយៈបទសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ (KIIs) ការពិភាក្សាក្រុមគោលដៅ ឬការពិគ្រោះយោបល់លើការសហការគ្នាអភិវឌ្ឍ។ ការចូលរួមទាំងអស់ត្រូវបានរក្សាជាការសម្ងាត់ ដោយមិនបញ្ចេញអត្តសញ្ញាណអ្នកចូលរួមឡើយ។ អង្គការទាំងនោះត្រូវបានចាត់ជាក្រុមទៅតាមវិស័យ និងប្រភេទ។

## ក. ក្រសួង និងទីភ្នាក់ងារជាតិ

| ក្រសួង / ស្ថាប័ន | អក្សរកាត់ | ទម្រង់នៃការចូលរួម |
|---|---|---|
| ក្រសួងកិច្ចការនារី | MoWA | KII |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | MoSVY | KII |
| ក្រសួងផែនការ | MoP | KII |
| ក្រសួងអប់រំ យុវជន និងកីឡា | MoEYS | KII |
| ក្រសួងសុខាភិបាល | MoH | KII |
| ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | MAFF | KII |
| ក្រសួងមហាផ្ទៃ | MoI | KII |
| ក្រសួងបរិស្ថាន | MoE | KII |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | MEF | KII |
| ក្រសួងអភិវឌ្ឍន៍ជនបទ | MRD | KII |
| ក្រុមប្រឹក្សាសកម្មភាពជនពិការ | DAC | KII |
| គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ-សង្កាត់ | CCWC | FGD / SGD |

## ខ. ស្ថាប័នស្រាវជ្រាវ សាកលវិទ្យាល័យ និងស្ថាប័នស្រាវជ្រាវ និងផ្តល់យោបល់ (Think Tanks)

| ស្ថាប័ន | ប្រភេទ | ការចូលរួម |
|---|---|---|
| សាកលវិទ្យាល័យភូមិន្ទភ្នំពេញ (RUPP) | សាកលវិទ្យាល័យរដ្ឋ | KII |
| រាជបណ្ឌិត្យសភាកម្ពុជា (RAC) | ស្ថាប័ន think tanks ផ្សារភ្ជាប់នឹងរដ្ឋាភិបាល | KII |
| សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា (PUC) | សាកលវិទ្យាល័យឯកជន | KII |
| សាកលវិទ្យាល័យកម្ពុជា (UC) | សាកលវិទ្យាល័យឯកជន | KII |
| វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) | វិទ្យាស្ថានស្រាវជ្រាវជាតិ | KII |
| វេទិកាអនាគត (Future Forum) | ស្ថាប័ន think tanks ឯករាជ្យ | KII |
| បណ្តាញ SheThinks | បណ្តាញស្ត្រីក្នុងវិស័យស្រាវជ្រាវ | KII |

## គ. ក្រុមអ្នកជំនាញផ្នែក សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម

| អង្គការ | វិស័យផ្តោត | ការចូលរួម |
|---|---|---|
| អង្គការជនពិការកម្ពុជា (CDPO) | សិទ្ធិ និងបរិយាបន្នពិការភាព | KII |
| អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា (GADC) | សមភាពយេនឌ័រ និង ការស្រាវជ្រាវបែបចូលរួមផ្អែកលើគោលការណ៍ហ្វេមីនីស្ត | KII |
| អង្គការនារីដើម្បីសន្តិភាព (WPM) | យេនឌ័រ ការកសាងសន្តិភាព | KII |

## ឃ. ដៃគូអភិវឌ្ឍន៍ និងដៃគូកម្មវិធី

| អង្គការ | តួនាទី / អាណត្តិ |
|---|---|
| រដ្ឋាភិបាលអូស្ត្រាលី-ក្រសួងការបរទេស និងពាណិជ្ជកម្ម ( DFAT ) | ម្ចាស់ជំនួយកម្មវិធី អ្នកផ្តល់ក្របខណ្ឌគោលនយោបាយ សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ( Gender at Work ) |
| កម្មវិធីសហប្រតិបត្តិការ អូស្ត្រាលី-កម្ពុជា ដើម្បីការផ្តល់សេវាប្រកបដោយនិរន្តរភាព និងសមធម៌ ( ACCESS / ACCESS 2 ) | កម្មវិធីផ្តល់មូលនិធិដោយ DFAT ស្តីពីសេវាប្រកបដោយបរិយាបន្នពិការភាព ប្រភពសំខាន់នៃទិន្នន័យបន្ទាប់បន្សំ |
| ដៃគូយុទ្ធសាស្ត្ររបស់កម្មវិធីពន្លកចំណេះ ដំណាក់កាលទី ២ ( ច្រើនស្ថាប័ន ) | ដៃគូស្រាវជ្រាវ ដៃគូគោលនយោបាយ ដៃគូផ្សព្វផ្សាយ ដែលរួមគ្នាអនុវត្តកម្មវិធីពន្លកចំណេះ ដំណាក់កាលទី២ |

## ឧបសម្ព័ន្ធ ៣. ការវិភាគស្រាវជ្រាវបឋម

ឧបសម្ព័ន្ធនេះរាយនាមបុគ្គល និងអង្គការទាំងអស់ដែលត្រូវបានពិគ្រោះយោបល់តាមរយៈបទសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ ( KII ) ការពិភាក្សាក្រុមគោលដៅ ( FGD ) និងការពិភាក្សាជាក្រុមតូចៗ ( SGDs ) ដែលជាផ្នែកមួយនៃការប្រមូលទិន្នន័យបឋមសម្រាប់ការវិភាគ សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម នេះ។ ការពិគ្រោះយោបល់ត្រូវបានធ្វើឡើងចន្លោះខែមិថុនា និងខែសីហា ឆ្នាំ២០២៤។ តារាងនេះត្រូវបានរៀបចំទៅតាមការចូលរួមនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

### អ្នកចូលរួមសរុប

**ថ្នាក់ជាតិ**

៧៤
អ្នកចូលរួម

ស្រី ៣៦

ជនមានពិការភាព ១ នាក់

**ថ្នាក់ក្រោមជាតិ**

២៧៨
អ្នកចូលរួម

ប្រុស ៥៧ នាក់
ស្រី ១៧៤ នាក់
ក្រុមស្រលាញ់ភេទដូចគ្នា ៤៨ នាក់
យុវជន ៥៦ នាក់
ចាស់ជរា ៤៨ នាក់

ជនមានពិការភាព ៣៥ នាក់
ជនជាតិភាគតិច/សហគមន៍ជនជាតិដើមភាគតិច ៦៥ នាក់

## ក. ថ្នាក់ជាតិ - បទសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់

| ល.រ | ប្រភេទ | អង្គការ/ស្ថាប័ន | តួនាទី / មុខតំណែង | ជំនាញ / វិស័យផ្តោតសំខាន់ | វិធីសាស្ត្រ |
|---|---|---|---|---|---|
| ១ | ដៃគូអភិវឌ្ឍន៍ | CAPRED | បុគ្គលិកកម្មវិធី | កំណែទម្រង់គោលនយោបាយ និង សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម | KII, ផ្ទាល់ |
| ២ | រដ្ឋាភិបាល | ក្រសួងកិច្ចការនារី (MoWA) | មន្ត្រីជាន់ខ្ពស់រដ្ឋាភិបាល និងមន្ត្រីបច្ចេកទេស | អ្នកជំនាញ សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម | KII, ផ្ទាល់ |
| ៣ | រដ្ឋាភិបាល | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (MISTI) | មន្ត្រីជាន់ខ្ពស់រដ្ឋាភិបាល | កំណែទម្រង់គោលនយោបាយ និងជីវភាពជនបទ | KII, ផ្ទាល់ |
| ៤ | អង្គការជនជាតិដើមភាគតិច (IPO) | សមាគមយុវជនជនជាតិដើមភាគតិចកម្ពុជា (CIYA)/ សមាគមស្ត្រីជនជាតិដើមភាគតិចកម្ពុជា (CIWA) | បុគ្គលិកកម្មវិធី | បរិយាបន្នសង្គមសម្រាប់ជនជាតិដើមភាគតិច | KII, ផ្ទាល់ |
| ៥ | ក្រុមអ្នកជំនាញផ្នែកសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម | អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា (GADC) / អង្គការនារីដើម្បីសន្តិភាព (WPM) | តំណាងសង្គមស៊ីវិល | អ្នកជំនាញ សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម | KII, ផ្ទាល់ |
| ៦ | សង្គមស៊ីវិល | អង្គការសហគមន៍ឥន្ទធនូកម្ពុជា (ROCK) | បុគ្គលិកកម្មវិធី | បរិយាបន្នសង្គម - LGBTQIA+ | KII, ផ្ទាល់ |
| ៧ | សាកលវិទ្យាល័យ | សាកលវិទ្យាល័យអង្គរ ខេត្តសៀមរាប | អ្នកស្រាវជ្រាវ | ដំណើរការស្រាវជ្រាវ និងដំណើរការគោលនយោបាយ | KII, អនឡាញ |
| ៨ | អ្នកស្រាវជ្រាវជាស្ត្រី | វេទិកាអនាគត ខេត្តសៀមរាប | អ្នកស្រាវជ្រាវ | ស្រាវជ្រាវ និងគោលនយោបាយ - បរិយាបន្នពិការភាព | KII, អនឡាញ |
| ៩ | រដ្ឋាភិបាល | គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ខេត្តសៀមរាប (PWCCC) | មន្ត្រីបច្ចេកទេស | សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម និង ដំណើរការគោលនយោបាយ | KII, អនឡាញ |
| ១០ | ក្រុមអ្នកជំនាញផ្នែកសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម | អង្គការជនពិការកម្ពុជា (CDPO) | តំណាងសង្គមស៊ីវិល | អ្នកជំនាញបរិយាបន្នពិការភាព | KII, អនឡាញ |

| ល.រ | ប្រភេទ | អង្គការ/ស្ថាប័ន | តួនាទី / មុខតំណែង | ជំនាញ / វិស័យផ្តោតសំខាន់ | វិធីសាស្ត្រ |
|---|---|---|---|---|---|
| ១១ | ដៃគូអភិវឌ្ឍន៍ | ACCESS 2 | បុគ្គលិកកម្មវិធី | អ្នកជំនាញបរិយាបន្នយេនឌ័រ | KII, ផ្ទាល់ |
| ១២ | វិទ្យាស្ថានស្រាវជ្រាវ | មជ្ឈមណ្ឌលសិក្សាគោលនយោបាយ (CPS) | អ្នកស្រាវជ្រាវ | ស្រាវជ្រាវ និងគោលនយោបាយ - ការប្រែប្រួលអាកាសធាតុ ជីវភាពជនបទ | KII, ផ្ទាល់ |
| ១៣ | សាកលវិទ្យាល័យ | សាកលវិទ្យាល័យជាតិបាត់ដំបង | អ្នកស្រាវជ្រាវ | ដំណើរការស្រាវជ្រាវ | KII, អនឡាញ |
| ១៤ | វិទ្យាស្ថានស្រាវជ្រាវ | មជ្ឈមណ្ឌលខេមរសិក្សា (CKS) | បុគ្គលិកកម្មវិធី | ដំណើរការស្រាវជ្រាវ | KII, ផ្ទាល់ |
| ១៥ | វិទ្យាស្ថានស្រាវជ្រាវ | វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) | អ្នកស្រាវជ្រាវ | ដំណើរការស្រាវជ្រាវ &គោលនយោបាយ - ការប្រែប្រួលអាកាសធាតុ ជីវភាពជនបទ អាស៊ាន | KII, ផ្ទាល់ |
| ១៦ | កម្មវិធី | Co-water | បុគ្គលិកកម្មវិធី | អ្នកជំនាញបរិយាបន្នពិការភាព | KII, ផ្ទាល់ |
| ១៧ | រដ្ឋាភិបាល | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) | មន្ត្រីជាន់ខ្ពស់ និងបុគ្គលិករដ្ឋាភិបាល | ការបញ្ជ្រាប សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម - កសិកម្ម ជីវភាពជនបទ អាកាសធាតុ អាស៊ាន | KII, ផ្ទាល់ |
| ១៨ | រដ្ឋាភិបាល | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (MoSVY) | មន្ត្រីជាន់ខ្ពស់ រដ្ឋាភិបាល | ការបញ្ជ្រាប សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម - គោលនយោបាយស្តីពីពិការភាព និងបរិយាបន្នសង្គម | KII, ផ្ទាល់ |
| ១៩ | អ្នកស្រាវជ្រាវ | បណ្តាញ SheThinks | អ្នកស្រាវជ្រាវ | ដំណើរការស្រាវជ្រាវ &គោលនយោបាយ - អាកាសធាតុ | KII, ផ្ទាល់ |
| ២០ | កម្មវិធី | អង្គការ UN Women | បុគ្គលិកកម្មវិធី | ដំណើរការស្រាវជ្រាវ &គោលនយោបាយ - អ្នកឯកទេស យេនឌ័រ | KII, ផ្ទាល់ |

| ល.រ | ប្រភេទ | អង្គការ/ស្ថាប័ន | តួនាទី / មុខតំណែង | ជំនាញ / វិស័យផ្តោតសំខាន់ | វិធីសាស្ត្រ |
|---|---|---|---|---|---|
| ២១ | ក្រុមការងារកម្មវិធីពន្លកចំណេះ | | ថ្នាក់ដឹកនាំកម្មវិធី | កម្មវិធីពន្លកចំណេះ ដំណាក់កាលទី២ | ការពិគ្រោះយោបល់ |
| ២២ | ក្រុមការងារកម្មវិធីពន្លកចំណេះ | | ក្រុមការងារកម្មវិធី | កម្មវិធីពន្លកចំណេះ ដំណាក់កាលទី២ | ការពិគ្រោះយោបល់ |
| ២៣ | សាកលវិទ្យាល័យ/ការស្រាវជ្រាវ | វិទ្យាស្ថានជាតិសង្គមកិច្ច (NISA) | សាស្ត្រាចារ្យ | ការបញ្ជ្រាប សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ក្នុងដំណើរការស្រាវជ្រាវ និងគោលនយោបាយ | KII |
| ២៤ | រដ្ឋាភិបាល | ក្រសួងបរិស្ថាន (MoE) | មន្ត្រីកម្មវិធីជាន់ខ្ពស់ | ការបញ្ជ្រាប សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម - គោលនយោបាយស្តីពីការប្រែប្រួលអាកាសធាតុ | KII |
| ២៥ | រដ្ឋាភិបាល | គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (NCDM) | មន្ត្រីបច្ចេកទេស | ការបញ្ជ្រាប សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម - ការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយ | KII |
| ២៦ | រដ្ឋាភិបាល | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF) - អគ្គនាយកដ្ឋានថវិកា | មន្ត្រីបច្ចេកទេស | ការរៀបចំថវិកាឆ្លើយតបនឹងយេនឌ័រ | KII |
| ២៧ | រដ្ឋាភិបាល | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF) - អគ្គនាយកដ្ឋានគោលនយោបាយ | មន្ត្រីបច្ចេកទេស | ការអភិវឌ្ឍគោលនយោបាយជាតិ - គោលនយោបាយសង្គមកិច្ច | KII |
| ២៨ | រដ្ឋាភិបាល | ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ- គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា (CHRC) | មន្ត្រីបច្ចេកទេស | បរិយាបន្នសង្គម និងសិទ្ធិមនុស្ស - របាយការណ៍ថ្នាក់ជាតិដាក់ជូនអង្គការសហប្រជាជាតិ | KII |

## ខ. ថ្នាក់ក្រោមជាតិ - KIIs, FGDs និង SGDs

| ល.រ | ប្រភេទ | អង្គការ/ស្ថាប័ន | តួនាទី | វិធីសាស្ត្រ |
|---|---|---|---|---|
| ២៩ | រដ្ឋាភិបាល (ថ្នាក់ក្រោមជាតិ) | គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររាជធានីភ្នំពេញ | មន្ត្រីបច្ចេកទេស | KII |
| ៣០ | រដ្ឋាភិបាល (ថ្នាក់ក្រោមជាតិ) | គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារខេត្តកំពត | មន្ត្រីបច្ចេកទេស | KII |
| ៣១ | រដ្ឋាភិបាល (ថ្នាក់ក្រោមជាតិ) | គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារខេត្តបាត់ដំបង | មន្ត្រីបច្ចេកទេស | KII |
| ៣២ | រដ្ឋាភិបាល (ថ្នាក់ក្រោមជាតិ) | គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារខេត្តរតនគិរី | មន្ត្រីបច្ចេកទេស | KII |
| ៣៣ | រដ្ឋាភិបាល FGDs ២ លើក × ១០ ស្រុក | គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ស្រុក ក្រុង ខណ្ឌ នៅគ្រប់ទីតាំងគោលដៅ | មន្ត្រីបច្ចេកទេស | FGDs |
| ៣៤ | រដ្ឋាភិបាល FGDs ២ លើក × ១០ ឃុំ-សង្កាត់ | គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំ សង្កាត់ នៅគ្រប់ទីតាំងគោលដៅ | មន្ត្រីបច្ចេកទេស | FGDs |
| ៣៥ | FGDs ២ លើក × ១០ ស្រុក | ក្រុមគោលដៅ សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម (ជនមានពិការភាព ក្រុមស្រលាញ់ភេទដូចគ្នា ស្ត្រី ជនជាតិដើមភាគតិច) នៅគ្រប់ទីតាំងគោលដៅ | អ្នកចូលរួមក្នុងសហគមន៍ | FGDs |
| ៣៦ | អង្គការក្នុងមូលដ្ឋាន ចំនួន ១០ | អង្គការស្ត្រី អង្គការជនជាតិដើមភាគតិច អង្គការតំណាងជនមានពិការភាព (OPD) នៅគ្រប់ទីតាំងគោលដៅ | តំណាងអង្គការOPD | SGDs |

# ឧបសម្ព័ន្ធ ៤. ការណែនាំសម្រាប់បទសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ (KIIs)

ការណែនាំសម្រាប់មន្ត្រីរដ្ឋាភិបាល (អ្នកតាក់តែង និងអ្នកអនុវត្តគោលនយោបាយ)

## ការណែនាំសម្រាប់ក្រុមសម្ភាសន៍៖

**គោលបំណង៖** គោលបំណងនៃការស្រាវជ្រាវ សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម របស់កម្មវិធីពន្លកចំណេះដំណាក់កាលទី ២ គឺដើម្បីស្វែងយល់អំពីបរិយាបន្ននៅក្នុងការស្រាវជ្រាវគោលនយោបាយ និងដំណើរការនៃការពិភាក្សានៅកម្ពុជា។ ព័ត៌មានដែលផ្តល់ដោយអង្គការ-ស្ថាប័ននីមួយៗ និងអ្នកផ្តល់បទសម្ភាសន៍ម្នាក់ៗ នឹងមានភាពខុសគ្នាទៅតាមតួនាទីរបស់ពួកគេនៅក្នុងប្រព័ន្ធអេកូឡូស៊ីនៃការស្រាវជ្រាវ/គោលនយោបាយ (ការស្រាវជ្រាវ/កំណែទម្រង់/ការពិភាក្សា/ការអនុវត្ត/ទិន្នន័យ)។ នៅពេលដែលបទសម្ភាសន៍ចេះតែបន្តទៅមុខ ហើយបញ្ហា/វិស័យផ្តោតសំខាន់របស់អ្នកផ្តល់បទសម្ភាសន៍ត្រូវបានយល់ច្បាស់ អ្នកអាចកែសម្រួលសំណួររបស់អ្នកទៅតាមវិស័យផ្តោតទាំងនោះ។ ការណែនាំនេះមានគោលបំណងស្វែងយល់ពីទស្សនៈ និងបទពិសោធន៍របស់មន្ត្រីរដ្ឋាភិបាល (ទាំងអ្នកតាក់តែងគោលនយោបាយ និងអ្នកអនុវត្ត)។ បទសម្ភាសន៍ (ជាលក្ខណៈបុគ្គល ឬក្រុម) ផ្តោតគោលដៅលើអ្នកដែលចូលរួមក្នុងការងារយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម (ជាពិសេសក្រុមជនជាតិដើមភាគតិច/ជនជាតិភាគតិច ក្រុមស្រលាញ់ភេទដូចគ្នា និងយុវជន)។ អ្នកផ្តល់បទសម្ភាសន៍មួយចំនួន ក៏នឹងមានការចូលរួមជាមួយអ្នកមានអត្តសញ្ញាណអន្តរប្រសព្វ ផងដែរ ដូចជា ស្ត្រីជនជាតិដើមភាគតិច យុវជនមានពិការភាពជាដើម។ សម្រាប់ក្រសួងការបរទេស និងពាណិជ្ជកម្ម (DFAT) យេនឌ័រគឺជាអាទិភាពចម្បង បន្ទាប់មក គឺពិការភាព ចំណែកឯវិស័យផ្សេងទៀតនៃបរិយាបន្នសង្គមគឺជាអាទិភាពទីបី។

**ក្រុមសម្ភាសន៍៖** យកល្អ គួរមានអ្នកសម្ភាសន៍ម្នាក់ និងអ្នកកត់ត្រាម្នាក់។ ក្នុងករណីខ្លះ អាចចាំបាច់ត្រូវមានការបកប្រែភាសា។

**ការចាប់ផ្តើមបទសម្ភាសន៍៖** អំណរគុណដល់អ្នកចូលរួមដែលបានចំណាយពេលវេលាចូលរួម។ ណែនាំខ្លួនអ្នក និងសហការី ព្រមទាំងតួនាទីរៀងៗខ្លួននៅក្នុងដំណើរការសម្ភាសន៍។ ពន្យល់ពីគោលបំណងនៃការសម្ភាសន៍ – ដើម្បីយល់ដឹងកាន់តែច្បាស់អំពីការស្រាវជ្រាវគោលនយោបាយ/កំណែទម្រង់/ការអនុវត្ត និងដំណើរការនៃការពិភាក្សានៅកម្ពុជា តាមរយៈចក្ខុ សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ដែលផ្តោតលើវិស័យអាទិភាព ក្តីកង្វល់ ឱកាសថ្មីៗ និងបញ្ហាប្រឈមនានា។ ជម្រាបជូនអ្នកផ្តល់បទសម្ភាសន៍ផងដែរថា ការស្រាវជ្រាវបន្ទាប់បន្សំ ក៏កំពុងធ្វើឡើងផងដែរ ហើយយើងចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើបទពិសោធន៍ និងចំណេះដឹងរបស់ពួកគេ។

## ព័ត៌មានលម្អិតស្តីពីបទសម្ភាសន៍៖

| | |
|---|---|
| កាលបរិច្ឆេទនៃបទសម្ភាសន៍៖ | អ្នកសម្ភាសន៍៖<br><br>អ្នកកត់ត្រា៖ |
| អង្គការ/ស្ថាប័ន៖ | ឈ្មោះ/មុខតំណែងរបស់អ្នកផ្តល់បទសម្ភាសន៍៖ |

| សំណួរ | ចម្លើយ |
|---|---|
| **សំណួរចាប់ផ្តើមដំបូង** | |
| ១. តើ 'នាយកដ្ឋាន/អង្គភាព' លោកអ្នកមានតួនាទីអ្វី ក្នុងដំណើរការគោលនយោបាយនៅកម្ពុជា (ការស្រាវជ្រាវ/កំណែទម្រង់/ការពិភាក្សា/ការអនុវត្ត/ទិន្នន័យ)?<br><br>២. តើនាយកដ្ឋាន/អង្គភាពរបស់លោកអ្នក ផ្តោតគោលដៅលើក្រុមជាក់លាក់ណាមួយ ដូចជា ស្ត្រី ជនមានពិការភាព ជនជាតិដើមភាគតិច ឬក្រុមដែលមានអត្តសញ្ញាណត្រួតគ្នាជាក់លាក់ជាងនេះ ដូចជា ស្ត្រីមានពិការភាពដែរ ឬទេ? សូមពណ៌នា។<br><br>៣. តើអ្វីជាតួនាទីជាក់លាក់របស់លោកអ្នក នៅក្នុងការងាររបស់នាយកដ្ឋាន/អង្គភាពនេះ? តើលោកអ្នកបានចូលរួមក្នុងការងារនេះបានប៉ុន្មានឆ្នាំហើយ? សូមពន្យល់ពីបទពិសោធន៍របស់លោកអ្នក ទាក់ទងនឹងក្រុមគោលដៅ និងដំណើរការគោលនយោបាយ (ការស្រាវជ្រាវ/កំណែទម្រង់/ការពិភាក្សា/ការអនុវត្ត/ទិន្នន័យ)។<br><br>៤. តើនាយកដ្ឋាន/អង្គភាពរបស់លោកអ្នកមានជួលបុគ្គលិកមកពីក្រុមគោលដៅ ឬក្រុមងាយរងគ្រោះដទៃទៀតដែរ ឬទេ? សូមពន្យល់ពីតួនាទីរបស់ពួកគេ។ | |
| **សំណួរលម្អិត** | |
| ៥. តើអ្វីជាបញ្ហាធំៗ ដែលប្រឈមមុខដោយក្រុមគោលដៅ ឬវិស័យគោលដៅរបស់នាយកដ្ឋាន/អង្គភាពលោកអ្នក (ឧ. ការងារ សុខាភិបាល ការអប់រំ លទ្ធភាពទទួលបានសេវា កិច្ចគាំពារសង្គម ។ល។) ក្នុងទិដ្ឋភាពពាក់ព័ន្ធនឹងដំណើរការគោលនយោបាយ (ការស្រាវជ្រាវ/កំណែទម្រង់/ការពិភាក្សា/ការអនុវត្ត/ទិន្នន័យ)? សូមពណ៌នាលម្អិត។<br><br>៦. តើលោកអ្នក ឬនាយកដ្ឋាន/អង្គភាព កំពុងដោះស្រាយបញ្ហាប្រឈមជាក់លាក់ដែលបានរៀបរាប់ (ក្នុងសំណួរទី ៥) ដោយរបៀបណា? តើមានសកម្មភាព/គំនិតផ្តួចផ្តើមអ្វីខ្លះដែលបានដាក់ចេញ? តើសកម្មភាពណាខ្លះដែលទទួលបានជោគជ័យ? តើសកម្មភាពណាខ្លះដែលពិបាកអនុវត្តជាងគេ? សូមពន្យល់។ | |

**សំណួរលម្អិត**

៧. យោងទៅលើសំណួរមុន និងបញ្ហាប្រឈមចម្បងពាក់ព័ន្ធនឹងគោលនយោបាយ តើមានបញ្ហាពាក់ព័ន្ធអ្វីខ្លះជុំវិញការពិភាក្សា/ទំនាក់ទំនង ជាមួយនាយកដ្ឋាន/អង្គភាពរដ្ឋាភិបាលដទៃទៀត ឬអង្គការ-ស្ថាប័នខាងក្រៅ (ឧ. ខ្វះការពិភាក្សា/ការប្រាស្រ័យទាក់ទង ឧបសគ្គពេលវេលា បញ្ហាមិនត្រូវបានយល់ដឹង ភាពលំអៀង ឬការរើសអើង ។ល។)? (ចំណុចនេះអាចនឹងត្រូវបានឆ្លើយតបរួចរាល់នៅក្នុងសំណួរទី៥)។

៨. តើលោកអ្នក ឬនាយកដ្ឋាន/អង្គភាព ដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងការពិភាក្សា/ទំនាក់ទំនងទាំងនោះដោយរបៀបណា? តើលោកអ្នកមានអភិក្រម ឬមធ្យោបាយគន្លឹះអ្វីខ្លះ ដើម្បីកែលម្អការពិភាក្សា/ទំនាក់ទំនងជាមួយនាយកដ្ឋានរដ្ឋាភិបាលដទៃទៀត ឬជាមួយក្រុមគោលដៅ បណ្តាញ និងរដ្ឋាភិបាល?

៩. តើលោកអ្នកមើលឃើញឱកាសអ្វីខ្លះ សម្រាប់ការកែលម្អដំណើរការគោលនយោបាយ ពាក់ព័ន្ធនឹងក្រុមគោលដៅរបស់លោកអ្នក (អាចជាគោលនយោបាយជាក់លាក់ អភិក្រម ឬភាពជាដៃគូ ។ល។)? តើលោកអ្នកកំពុងឈានឆ្ពោះទៅរកទិសដៅនេះដែរ ឬទេ – សូមពន្យល់ពីលទ្ធភាពក្នុងការសម្រេចបានវឌ្ឍនភាព និងបញ្ហាប្រឈមដែលនឹងត្រូវជួបប្រទះ។

១០. តើលោកអ្នកបានដឹងអំពីគោលនយោបាយក្នុងវិស័យជាក់លាក់ណាមួយ ដែលបានបញ្ជ្រាបសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គមបានល្អដែរ ឬទេ? តើលោកអ្នកអាចចែករំលែកឧទាហរណ៍ខ្លះបានទេ? តើមានមេរៀនអ្វីខ្លះដែលអាចរៀនសូត្របានពីកិច្ចខិតខំប្រឹងប្រែងបញ្ជ្រាបសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គមដែលមានស្រាប់ ទៅក្នុងវិស័យស្រាវជ្រាវ និងដំណើរការគោលនយោបាយ?

១១. ប្រសិនបើលោកអ្នកអាចផ្តោតអាទិភាពលើវិស័យគន្លឹះមួយ ដើម្បីលើកកម្ពស់គោលនយោបាយ (ការស្រាវជ្រាវ/កំណែទម្រង់/ការពិភាក្សា/ការអនុវត្ត/ទិន្នន័យ) សម្រាប់ក្រុមគោលដៅ ឬវិស័យគោលដៅរបស់លោកអ្នក តើជាវិស័យអ្វី?

**ការបិទបញ្ចប់បទសម្ភាសន៍៖** អំណរគុណដល់អ្នកចូលរួមដែលបានចំណាយពេលវេលា និងការរួមចំណែកដ៏មានតម្លៃដល់ការងារនេះ។ សួរថាតើពួកគេមានអ្វីចង់សួរអ្នកសម្ភាសន៍ដែរ ឬទេ? ជម្រាបពួកគេឱ្យបានដឹងប្រសិនបើត្រូវមានការតាមដានបន្ត។

## ការណែនាំសម្រាប់អង្គការ-ស្ថាប័ន ឬកម្មវិធីដែលធ្វើការជាមួយក្រុមគោលដៅសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម

### ការណែនាំសម្រាប់អ្នកសម្ភាសន៍

**គោលបំណង៖** គោលបំណងនៃការស្រាវជ្រាវ សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម របស់កម្មវិធីពន្លកចំណេះដំណាក់កាលទី ២ គឺដើម្បីស្វែងយល់អំពីបរិយាបន្ននៅក្នុងការស្រាវជ្រាវគោលនយោបាយ និងដំណើរការនៃការពិភាក្សានៅកម្ពុជា។ ព័ត៌មានដែលផ្តល់ដោយអង្គការ-ស្ថាប័ននីមួយៗ និងអ្នកផ្តល់បទសម្ភាសន៍ម្នាក់ៗ នឹងមានភាពខុសគ្នាទៅតាមតួនាទីរបស់ពួកគេនៅក្នុងប្រព័ន្ធអេកូឡូស៊ីនៃការស្រាវជ្រាវ/គោលនយោបាយ។ ការណែនាំនេះ មានគោលបំណងស្វែងយល់ពីទស្សនៈ និងបទពិសោធន៍របស់អ្នកផ្តល់បទសម្ភាសន៍។ បទសម្ភាសន៍ (ជាលក្ខណៈបុគ្គល ឬក្រុម) ផ្តោតគោលដៅលើអ្នកដែលចូលរួមក្នុងការងារយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម (ជាពិសេសក្រុមជនជាតិដើមភាគតិច/ជនជាតិភាគតិច ក្រុម LGBTQIA+ និងយុវជន)។ អ្នកផ្តល់បទសម្ភាសន៍មួយចំនួន ក៏នឹងមានការចូលរួមជាមួយអ្នកមានអត្តសញ្ញាណប្រទាក់ក្រឡាគ្នាផងដែរ ដូចជា ស្ត្រីជនជាតិដើមភាគតិច យុវជនមានពិការភាពជាដើម។ នៅពេលដែលបទសម្ភាសន៍ចេះតែបន្តទៅមុខ ហើយបញ្ហា/វិស័យផ្តោតសំខាន់របស់អ្នកផ្តល់បទសម្ភាសន៍ត្រូវបានយល់ច្បាស់ អ្នកអាចកែសម្រួលសំណួររបស់អ្នកទៅតាមវិស័យផ្តោតទាំងនោះ។ សម្រាប់ក្រសួងការបរទេស និងពាណិជ្ជកម្ម (DFAT) យេនឌ័រគឺជាអាទិភាពចម្បង បន្ទាប់មកគឺពិការភាព ចំណែកឯវិស័យផ្សេងទៀតនៃបរិយាបន្នសង្គមគឺជាអាទិភាពទីបី។

**ក្រុមសម្ភាសន៍៖** យកល្អ គួរមានអ្នកសម្ភាសន៍ម្នាក់ និងអ្នកកត់ត្រាម្នាក់។ ក្នុងករណីខ្លះ អាចចាំបាច់ត្រូវមានការបកប្រែភាសា។

**ការចាប់ផ្តើមបទសម្ភាសន៍៖** អំណរគុណដល់អ្នកចូលរួមដែលបានចំណាយពេលវេលាចូលរួម។ ណែនាំខ្លួនអ្នក និងសហការី ព្រមទាំងតួនាទីរៀងៗខ្លួននៅក្នុងដំណើរការសម្ភាសន៍។ ពន្យល់ពីគោលបំណងនៃការសម្ភាសន៍ – ដើម្បីយល់ដឹងកាន់តែច្បាស់អំពីការស្រាវជ្រាវគោលនយោបាយ និងដំណើរការនៃការពិភាក្សានៅកម្ពុជា តាមរយៈចក្ខុសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ដែលផ្តោតលើវិស័យអាទិភាព ក្តីកង្វល់ ឱកាសថ្មីៗ និងបញ្ហាប្រឈមនានា។ ជម្រាបជូនអ្នកផ្តល់បទសម្ភាសន៍ផងដែរថា ការស្រាវជ្រាវបន្ទាប់បន្សំ ក៏កំពុងធ្វើឡើងផងដែរ ហើយយើងចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើបទពិសោធន៍ និងចំណេះដឹងរបស់ពួកគេ។

### ព័ត៌មានលម្អិតស្តីពីបទសម្ភាសន៍៖

| | |
|---|---|
| កាលបរិច្ឆេទនៃបទសម្ភាសន៍៖ | អ្នកសម្ភាសន៍៖<br><br>អ្នកកត់ត្រា៖ |
| អង្គការ-ស្ថាប័ន៖ | ឈ្មោះ/មុខតំណែងរបស់<br>អ្នកផ្តល់បទសម្ភាសន៍៖ |

| សំណួរ | ចម្លើយ |
|---|---|
| **សំណួរចាប់ផ្តើមដំបូង** | |
| ១. តើអង្គការ-ស្ថាប័នរបស់លោកអ្នកមានតួនាទីអ្វី ក្នុងការស្រាវជ្រាវគោលនយោបាយ និងដំណើរការនៃការពិភាក្សានៅកម្ពុជា? <br><br> ២. តើអង្គការ-ស្ថាប័នរបស់លោកអ្នក ផ្តោតគោលដៅលើក្រុមជាក់លាក់ណាមួយ ដូចជា ស្ត្រី ជនមានពិការភាព ឬក្រុម ដែលមានអត្តសញ្ញាណប្រទាក់ក្រឡាគ្នាជាក់លាក់ជាងនេះ ដូចជា ស្ត្រីមានពិការភាព ដែរ ឬទេ? សូមពណ៌នា។ <br><br> ៣. តើលោកអ្នកមានតួនាទីអ្វី នៅក្នុងការងាររបស់អង្គការ-ស្ថាប័ន? តើលោកអ្នកបានចូលរួមការងារនេះរយៈពេលប៉ុន្មានឆ្នាំហើយ? សូមពន្យល់ពីបទពិសោធន៍របស់លោកអ្នក ទាក់ទងនឹងក្រុមគោលដៅ និងការស្រាវជ្រាវគោលនយោបាយ / ដំណើរការនៃការពិភាក្សា។ <br><br> ៤. តើអង្គការ-ស្ថាប័នរបស់លោកអ្នក មានជួលបុគ្គលិកមកពីក្រុមគោលដៅ ឬក្រុមងាយរងគ្រោះដទៃទៀតដែរ ឬទេ? សូមពន្យល់ពីតួនាទីរបស់ពួកគេ។ | |
| **សំណួរលម្អិត** | |
| ៥. តើអ្វីខ្លះជាបញ្ហាប្រឈមចម្បង ពាក់ព័ន្ធនឹងផលវិបាកគោលនយោបាយ ដែលជួបប្រទះដោយក្រុមគោលដៅរបស់អង្គការ-ស្ថាប័នលោកអ្នក (ឧ. ការងារ សុខាភិបាល ការអប់រំ លទ្ធភាពទទួលបានសេវា កិច្ចគាំពារសង្គម។ល។)? សូមពណ៌នាលម្អិត។ (នេះអាចជាការពិភាក្សាដ៏វែងអន្លាយ ដើម្បីស្វែងយល់ពីបញ្ហាប្រឈមជាក់លាក់ និងរបៀបដែលបញ្ហាទាំងនោះជះឥទ្ធិពលលើការពិភាក្សា និងគោលនយោបាយ។ សូមសួរសំណួរបន្តបន្ទាប់ ដើម្បីស្វែងយល់ឱ្យស៊ីជម្រៅ)។ <br><br> ៦. តើលោកអ្នក ឬអង្គការ-ស្ថាប័នរបស់លោកអ្នក ដោះស្រាយបញ្ហាប្រឈមគោលនយោបាយ ដែលបានរៀបរាប់ (ក្នុងសំណួរទី ៥) ដោយរបៀបណា? តើមានសកម្មភាព/គំនិតផ្តួចផ្តើមអ្វីខ្លះដែលបានដាក់ចេញ? តើសកម្មភាពណាខ្លះដែលទទួលបានជោគជ័យ? តើសកម្មភាពណាខ្លះដែលពិបាកអនុវត្តជាងគេ? សូមពន្យល់។ | |

| សំណួរលម្អិត | |
|---|---|
| ៧. យោងទៅលើសំណួរមុន និងបញ្ហាប្រឈមគោលនយោបាយធំៗ តើមានបញ្ហាពាក់ព័ន្ធអ្វីខ្លះជុំវិញការពិភាក្សា (ឧ. ខ្វះការពិភាក្សា/ការប្រាស្រ័យទាក់ទង បញ្ហាមិនត្រូវបានយល់ដឹង ភាពលំអៀង ឬការរើសអើង។ល។)? (ចំណុចនេះអាចនឹងត្រូវបានឆ្លើយតបរួចរាល់នៅក្នុងសំណួរទី ៥)។<br><br>៨. តើលោកអ្នក ឬអង្គការ-ស្ថាប័នរបស់លោកអ្នកដោះស្រាយបញ្ហាប្រឈមក្នុងការពិភាក្សាដោយរបៀបណា? តើអង្គការ-ស្ថាប័នរបស់លោកអ្នកបានចូលរួមក្នុងដំណើរការនៃការពិភាក្សា ដូចជា សន្និសីទ ក្រុមប្រឹក្សាយោបល់សហគមន៍អនុវត្តន៍ដែរ ឬទេ?<br><br>៩. តើលោកអ្នកមើលឃើញឱកាសអ្វីខ្លះ សម្រាប់ការកែទម្រង់គោលនយោបាយ ពាក់ព័ន្ធនឹងក្រុមគោលដៅរបស់លោកអ្នក (អាចជាគោលនយោបាយជាក់លាក់ អភិក្រម ឬភាពជាដៃគូ ។ល។)? តើលោកអ្នកបានចូលរួមដោយផ្ទាល់ជាមួយអ្នកតាក់តែងគោលនយោបាយ ដើម្បីលើកកម្ពស់ការកែទម្រង់គោលនយោបាយដែរ ឬទេ? សូមពន្យល់។<br><br>១០. ប្រសិនបើលោកអ្នកអាចផ្តោតអាទិភាពលើវិស័យគន្លឹះមួយ ដើម្បីលើកកម្ពស់គោលនយោបាយសម្រាប់ក្រុមគោលដៅរបស់លោកអ្នក តើជាវិស័យអ្វី?<br><br>១១. តើមានមេរៀនអ្វីខ្លះ ដែលអាចរៀនសូត្របានពីកិច្ចខិតខំប្រឹងប្រែងបញ្ជ្រាប សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ដែលមានស្រាប់ទៅក្នុងវិស័យស្រាវជ្រាវនិងដំណើរការគោលនយោបាយ? | |

**ការបិទបញ្ចប់បទសម្ភាសន៍៖** អំណរគុណដល់អ្នកចូលរួមដែលបានចំណាយពេលវេលា និងការរួមចំណែកដ៏មានតម្លៃដល់ការងារនេះ។ សួរថាតើពួកគេមានអ្វីចង់សួរអ្នកសម្ភាសន៍ដែរ ឬទេ? ជម្រាបពួកគេឱ្យបានដឹង ប្រសិនបើត្រូវមានការតាមដានបន្ត។

# ការណែនាំសម្រាប់ស្ថាប័នស្រាវជ្រាវ / ស្ថាប័នស្រាវជ្រាវ និងផ្ដល់យោបល់ / សាកលវិទ្យាល័យ

## ការណែនាំសម្រាប់ក្រុមសម្ភាសន៍

**គោលបំណង៖** គោលបំណងនៃការស្រាវជ្រាវ សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម របស់កម្មវិធីពន្លកចំណេះ ដំណាក់កាលទី ២ គឺដើម្បីស្វែងយល់អំពីបរិយាបន្ននៅក្នុងការស្រាវជ្រាវគោលនយោបាយ និងដំណើរការនៃការពិភាក្សានៅកម្ពុជា។ សម្រាប់ស្ថាប័នស្រាវជ្រាវ ចំណុចនេះមានអត្ថន័យទ្វេដង៖ ទីមួយគឺលើប្រធានបទនៃការស្រាវជ្រាវ និងទីពីរគឺលើការរួមបញ្ចូលស្ត្រី ជនមានពិការភាព និងជនងាយរងគ្រោះដទៃទៀត ជាអ្នកស្រាវជ្រាវ។ ព័ត៌មានដែលផ្ដល់ដោយអ្នកស្រាវជ្រាវម្នាក់ៗ នឹងមានភាពខុសគ្នាទៅតាមតួនាទី និងបទពិសោធន៍របស់ពួកគេ។ ការណែនាំនេះមានគោលបំណងស្វែងយល់ពីទស្សនៈ និងបទពិសោធន៍របស់អ្នកផ្ដល់បទសម្ភាសន៍។ នៅពេលដែលបទសម្ភាសន៍ចេះតែបន្តទៅមុខ ហើយបញ្ហា/វិស័យផ្ដោតសំខាន់របស់អ្នកផ្ដល់បទសម្ភាសន៍ត្រូវបានយល់ច្បាស់ អ្នកអាចកែសម្រួលសំណួររបស់អ្នកទៅតាមវិស័យផ្ដោតទាំងនោះ។ ការសម្ភាសន៍ (ជាលក្ខណៈបុគ្គល ឬក្រុម) ផ្ដោតគោលដៅលើប្រធានបទជុំវិញយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម (ជាពិសេសក្រុមជនជាតិដើមភាគតិច/ជនជាតិភាគតិច ក្រុម LGBTQIA+ និងយុវជន)។ អ្នកផ្ដល់បទសម្ភាសន៍មួយចំនួន នឹងបានចូលរួមជាមួយអ្នកមានអត្តសញ្ញាណប្រទាក់ក្រឡាគ្នា (ឬក៏ពួកគេផ្ទាល់តែម្ដង) ដូចជា ស្ត្រីជនជាតិដើមភាគតិច យុវជនមានពិការភាព។ សម្រាប់ DFAT យេនឌ័រគឺជាអាទិភាពចម្បង បន្ទាប់មកគឺពិការភាព ចំណែកឯវិស័យផ្សេងទៀតនៃបរិយាបន្នសង្គមគឺជាអាទិភាពទីបី។

**ក្រុមសម្ភាសន៍៖** យកល្អ គួរមានអ្នកសម្ភាសន៍ម្នាក់ និងអ្នកកត់ត្រាម្នាក់។ ក្នុងករណីខ្លះ អាចចាំបាច់ត្រូវមានការបកប្រែភាសា។

**ការចាប់ផ្ដើមបទសម្ភាសន៍៖** អំណរគុណដល់អ្នកផ្ដល់បទសម្ភាសន៍ដែលបានចំណាយពេលចូលរួម។ ណែនាំខ្លួនអ្នក និងសហការី ព្រមទាំងតួនាទីរៀងៗខ្លួននៅក្នុងដំណើរការសម្ភាសន៍។ ពន្យល់ពីគោលបំណងនៃការសម្ភាសន៍ – ដើម្បីយល់ដឹងកាន់តែច្បាស់អំពីការស្រាវជ្រាវគោលនយោបាយ និងដំណើរការនៃការពិភាក្សានៅកម្ពុជា តាមរយៈចក្ខុសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ដែលផ្ដោតលើវិស័យអាទិភាព ក្ដីកង្វល់ ឱកាសថ្មីៗ និងបញ្ហាប្រឈមនានា។ ជម្រាបជូនអ្នកផ្ដល់បទសម្ភាសន៍ផងដែរថា ការស្រាវជ្រាវបន្ទាប់បន្សំក៏កំពុងធ្វើឡើងផងដែរ ហើយយើងចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើបទពិសោធន៍ និងចំណេះដឹងរបស់ពួកគេ ព្រមទាំងការសិក្សា ឬរបាយការណ៍ណាមួយ ដែលពួកគេអាចណែនាំបាន។

## ព័ត៌មានលម្អិតស្ដីពីបទសម្ភាសន៍៖

| | |
|---|---|
| កាលបរិច្ឆេទនៃបទសម្ភាសន៍៖ | អ្នកសម្ភាសន៍៖<br><br>អ្នកកត់ត្រា៖ |
| តួនាទី/មុខតំណែង នៅក្នុងស្ថាប័ន/អង្គការ៖ | ឈ្មោះ/មុខតំណែងរបស់អ្នកផ្ដល់បទសម្ភាសន៍៖ |

| សំណួរ | ចម្លើយ |
| --- | --- |
| **សំណួរចាប់ផ្តើមដំបូង** | |
| ១. តើអង្គការ-ស្ថាប័នរបស់លោកអ្នកមានតួនាទីអ្វី ក្នុងការស្រាវជ្រាវគោលនយោបាយ និងដំណើរការនៃការពិភាក្សានៅកម្ពុជា?<br><br>២. តើអង្គការ-ស្ថាប័នរបស់លោកអ្នក ផ្តោតគោលដៅលើក្រុមជាក់លាក់ណាមួយ ដូចជា ស្ត្រីជនមានពិការភាព ឬក្រុមដែលមានអត្តសញ្ញាណប្រទាក់ក្រឡាជាក់លាក់ជាងនេះ ដូចជាស្ត្រីមានពិការភាពដែរ ឬទេ? សូមពណ៌នា។<br><br>៣. តើលោកអ្នកមានតួនាទីអ្វី នៅក្នុងការងាររបស់អង្គការ-ស្ថាប័ន? តើលោកអ្នកបានចូលរួមការងារនេះរយៈពេលប៉ុន្មានឆ្នាំហើយ? សូមពន្យល់ពីបទពិសោធន៍របស់លោកអ្នក ទាក់ទងនឹងក្រុមគោលដៅ និងការស្រាវជ្រាវគោលនយោបាយ/ដំណើរការនៃការពិភាក្សា។<br><br>៤. តើអង្គការ-ស្ថាប័នរបស់លោកអ្នក មានជួលបុគ្គលិកមកពីក្រុមគោលដៅឱ្យធ្វើជាអ្នកស្រាវជ្រាវដែរ ឬទេ? សូមពន្យល់ពីតួនាទីរបស់ពួកគេ។ | |
| **សំណួរលម្អិត** | |
| ៥. តើអ្វីជាវិស័យ/ចំណុចផ្តោតសំខាន់ នៃការស្រាវជ្រាវរបស់លោកអ្នក ( ឧ. ការងារ សុខាភិបាល ការអប់រំ លទ្ធភាពទទួលបានសេវា កិច្ចគាំពារសង្គម។ល។) ហើយតើនរណាជាក្រុមគោលដៅចម្បងរបស់លោកអ្នក?<br><br>៦. តើអ្វីខ្លះជាបញ្ហាប្រឈមគោលនយោបាយធំៗ នៅក្នុងវិស័យ/ក្រុមគោលដៅ ដែលលោកអ្នកបានសិក្សា? សូមពណ៌នាលម្អិត។ (នេះអាចជាការពិភាក្សាដ៏វែងអន្លាយ ដើម្បីស្វែងយល់ពីបញ្ហាប្រឈមជាក់លាក់ និងរបៀបដែលបញ្ហាទាំងនោះជះឥទ្ធិពលលើការពិភាក្សា និងគោលនយោបាយ។ សូមសួរសំណួរបន្តបន្ទាប់ ដើម្បីស្វែងយល់ឱ្យស៊ីជម្រៅ)។<br><br>៧. តើនរណាជា 'អ្នកប្រើប្រាស់' ចម្បងនៃការស្រាវជ្រាវរបស់លោកអ្នក – ឧ. អ្នកអនុវត្តន៍ (អង្គការ-ស្ថាប័នដែលធ្វើការក្នុងវិស័យ ឬជាមួយក្រុមគោលដៅ) អ្នកតាក់តែងគោលនយោបាយ/មន្ត្រីរដ្ឋាភិបាល អ្នកសិក្សា/សាស្ត្រាចារ្យ។ល។? តើពួកគេប្រើប្រាស់ការស្រាវជ្រាវនោះយ៉ាងដូចម្តេច – សូមផ្តល់ឧទាហរណ៍ខ្លះៗ? | |

**សំណួរលម្អិត**

៨. តើអង្គការ-ស្ថាប័នរបស់លោកអ្នក លើកកម្ពស់ និង/ឬចូលរួមក្នុងដំណើរការនៃការពិភាក្សា ដូចជា សន្និសីទ ក្រុមប្រឹក្សាយោបល់ សហគមន៍អនុវត្តន៍ដែរ ឬទេ? សូមពន្យល់។

៩. តើលោកអ្នកមើលឃើញឱកាសអ្វីខ្លះ សម្រាប់ការកែទម្រង់គោលនយោបាយពាក់ព័ន្ធនឹងក្រុមគោលដៅ / វិស័យរបស់លោកអ្នក (អាចជាគោលនយោបាយជាក់លាក់ អភិក្រម ឬភាពជាដៃគូ។ល។)? តើលោកអ្នកកំពុងឈានឆ្ពោះទៅរកទិសដៅនេះដែរ ឬទេ – សូមពន្យល់ពីលទ្ធភាពសម្រេចបានវឌ្ឍនភាព និងបញ្ហាប្រឈមដែលនឹងត្រូវជួបប្រទះ។

១០. ផ្តោតលើស្ត្រី ជនមានពិការភាព និងអ្នកមកពីសហគមន៍ងាយរងគ្រោះដទៃទៀត ដែលជាអ្នកស្រាវជ្រាវនៅក្នុងអង្គការ-ស្ថាប័នរបស់លោកអ្នក ឬនៅក្នុងសហគមន៍ស្រាវជ្រាវទូទៅ។ តើពួកគេប្រឈមមុខនឹងបញ្ហាជាក់លាក់ដែរ ឬទេ? ឧទាហរណ៍ តើស្ត្រីមានឱកាសរីកចម្រើន ក្នុងដេប៉ាតឺម៉ង់នានានៅសាកលវិទ្យាល័យដែរ ឬទេ? តើស្ថាប័នស្រាវជ្រាវ និងផ្តល់យោបល់ មានជួលមនុស្សមកពីសហគមន៍ងាយរងគ្រោះដទៃទៀតដែរ ឬទេ? តើលោកអ្នកគិតថាមានភាពលំអៀងដោយអចេតនាដែរ ឬទេ?។ល។

១១. តើអាចអនុវត្តវិធានការអ្វីខ្លះ ដើម្បីបង្កើនសំឡេង និងការចូលរួមរបស់ស្ត្រីក្នុងការស្រាវជ្រាវ និងការពិភាក្សាគោលនយោបាយ?

១២. តើអ្វីខ្លះជាឧបសគ្គធំៗសម្រាប់ក្រុម LGBTQIA+ ជនជាតិដើមភាគតិច ជនជាតិភាគតិច និងសហគមន៍មកពីតំបន់ដាច់ស្រយាល ក្នុងការចូលរួមជាមួយវិស័យស្រាវជ្រាវ?

១៣. តើលទ្ធផលពីការវិភាគ សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម អាចត្រូវបានផ្សព្វផ្សាយប្រកបដោយប្រសិទ្ធភាពទៅកាន់ភាគីពាក់ព័ន្ធចម្រុះយ៉ាងដូចម្តេច ដើម្បីជះឥទ្ធិពលដល់ការផ្លាស់ប្តូរគោលនយោបាយ?

**ការបិទបញ្ចប់បទសម្ភាសន៍៖** អំណរគុណដល់អ្នកចូលរួមដែលបានចំណាយពេលវេលា និងការរួមចំណែកដ៏មានតម្លៃដល់ការងារនេះ។ សួរថាតើពួកគេមានអ្វីចង់សួរអ្នកសម្ភាសន៍ដែរ ឬទេ? ជម្រាបពួកគេឱ្យបានដឹង ប្រសិនបើត្រូវមានការតាមដានបន្ត។

# ឧបសម្ព័ន្ធ ៥. ការណែនាំសម្រាប់ការពិភាក្សាក្រុមគោលដៅ (FGD)

ការណែនាំខាងក្រោមនេះ ត្រូវបានប្រើប្រាស់សម្រាប់ការពិភាក្សាក្រុមគោលដៅ (FGDs)។

## ការណែនាំសម្រាប់ក្រុមសម្ភាសន៍

**គោលបំណង៖** គោលបំណងនៃការស្រាវជ្រាវ សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម របស់កម្មវិធីពន្លកចំណេះ ដំណាក់កាលទី ២ គឺដើម្បីស្វែងយល់ពីបរិយាបន្ននៅក្នុងការស្រាវជ្រាវគោលនយោបាយ និងដំណើរការនៃការពិភាក្សានៅកម្ពុជា។ ព័ត៌មានដែលផ្តល់ដោយអង្គការ-ស្ថាប័ននីមួយៗ និងអ្នកចូលរួមម្នាក់ៗ នឹងមានភាពខុសគ្នាទៅតាមតួនាទីរបស់ពួកគេនៅក្នុងប្រព័ន្ធអេកូឡូស៊ីនៃការស្រាវជ្រាវ និងគោលនយោបាយ។ ការណែនាំនេះមានគោលបំណងស្វែងយល់ពីទស្សនៈ និងបទពិសោធន៍របស់អ្នកចូលរួម។ ការពិភាក្សាក្រុមគោលដៅ (FGDs) (ជាលក្ខណៈបុគ្គល ឬក្រុម) ផ្តោតគោលដៅលើអ្នកដែលចូលរួមការងារយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម (ជាពិសេសក្រុមជនជាតិដើមភាគតិច/ជនជាតិភាគតិច ក្រុម LGBTQIA+ និងយុវជន)។ អ្នកចូលរួមមួយចំនួនក៏នឹងចូលរួមជាមួយអ្នកដែលមានអត្តសញ្ញាណប្រទាក់ក្រឡាផងដែរ ដូចជា ស្ត្រីជនជាតិដើមភាគតិច យុវជនមានពិការភាព។ល។ នៅពេលដែលការពិភាក្សានេះចេះតែបន្តទៅមុខ ហើយបញ្ហា/វិស័យផ្តោតសំខាន់របស់អ្នកចូលរួមត្រូវបានយល់ច្បាស់ អ្នកអាចកែសម្រួលសំណួររបស់អ្នកទៅតាមវិស័យផ្តោតទាំងនេះ។ សម្រាប់ DFAT យេនឌ័រគឺជាអាទិភាពចម្បង បន្ទាប់មកគឺពិការភាព ចំណែកឯផ្នែកផ្សេងទៀតនៃបរិយាបន្នសង្គមគឺជាអាទិភាពទីបី។

**ក្រុមអ្នកចុះស្រាវជ្រាវនៅមូលដ្ឋាន៖** គួរតែមានអ្នកសម្របសម្រួលម្នាក់ និងអ្នកកត់ត្រាម្នាក់។ ក្នុងករណីខ្លះអាចចាំបាច់ត្រូវមានការបកប្រែ។

**ការចាប់ផ្តើមការពិភាក្សា៖** អំណរគុណដល់អ្នកចូលរួមដែលបានចំណាយពេលវេលា។ ណែនាំខ្លួនអ្នក និងសហការី និងតួនាទីរៀងៗខ្លួននៅក្នុងដំណើរការនៃការពិភាក្សា។ ពន្យល់ពីគោលបំណងនៃការពិភាក្សា – ដើម្បីយល់ដឹងកាន់តែច្បាស់អំពីការស្រាវជ្រាវគោលនយោបាយ និងដំណើរការនៃការពិភាក្សានៅកម្ពុជា តាមរយៈចក្ខុ សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ដែលផ្តោតលើវិស័យអាទិភាព ក្តីកង្វល់ ឱកាសថ្មីៗ និងបញ្ហាប្រឈមនានា។ ជម្រាបប្រាប់អ្នកចូលរួមថា ការស្រាវជ្រាវបន្ទាប់បន្សំក៏កំពុងធ្វើឡើងផងដែរ ហើយយើងចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើបទពិសោធន៍ និងចំណេះដឹងរបស់ពួកគេ។

## ព័ត៌មានលម្អិតស្តីពីបទសម្ភាសន៍

| | |
|---|---|
| កាលបរិច្ឆេទនៃបទសម្ភាសន៍៖ | អ្នកសម្ភាសន៍៖<br><br>អ្នកកត់ត្រា៖ |
| អង្គការ-ស្ថាប័ន៖ | ឈ្មោះ/តួនាទីរបស់អ្នកចូលរួម៖ |
| ទីតាំងសម្ភាសន៍៖ (ឃុំ ស្រុក ខេត្ត) | ចំនួនអ្នកចូលរួមសរុប៖<br><br>ចំនួនស្ត្រី៖<br>ចំនួនបុរស៖<br>ចំនួនជនមានពិការភាព៖<br>ចំនួនក្រុម LGBTQIA+<br>(ប្រសិនបើមានការលាតត្រដាង)៖ |

| សំណួរ | ចម្លើយ |
| --- | --- |
| **សំណួរចាប់ផ្ដើមដំបូង** | |
| ១. តើអង្គការ-ស្ថាប័នរបស់លោកអ្នកមានតួនាទីអ្វី នៅក្នុងសង្គមស៊ីវិល/សហគមន៍? ពោលគឺ តើលោកអ្នកផ្ដោតលើបញ្ហាអ្វីខ្លះ (ឧ. សុខាភិបាល ការអប់រំ សិទ្ធិមនុស្ស។ល។)? <br><br> ២. តើអង្គការ-ស្ថាប័នរបស់លោកអ្នក ផ្ដោតគោលដៅលើក្រុមជាក់លាក់ ឧទាហរណ៍ ស្ត្រី ជនមានពិការភាព ឬក្រុមមានអត្តសញ្ញាណប្រទាក់ក្រឡាជាក់លាក់ ដូចជា ស្ត្រីមានពិការភាពដែរ ឬទេ? សូមពណ៌នា។ <br><br> ៣. តើលោកអ្នកមានតួនាទីអ្វី នៅក្នុងការងាររបស់អង្គការ-ស្ថាប័ន? តើលោកអ្នកបានចូលរួមការងារនេះរយៈពេលប៉ុន្មានឆ្នាំហើយ? (ស្ទង់មតិក្រុម ដើម្បីស្វែងយល់ពីវិស័យផ្ដោត និងកម្រិតជំនាញផ្សេងៗគ្នារបស់ពួកគេ។) <br><br> ៤. តើអង្គការ-ស្ថាប័នរបស់លោកអ្នក មានសមាសភាព ឬបុគ្គលិកមកពីក្រុមគោលដៅ ឬក្រុមងាយរងគ្រោះដទៃទៀតដែរ ឬទេ? សូមពន្យល់ពីតួនាទីរបស់ពួកគេ។ | |
| **សំណួរលម្អិត៖** | |
| ៥. តើអ្វីខ្លះជាបញ្ហាប្រឈមធំៗ ដែលជួបប្រទះដោយក្រុមគោលដៅរបស់អង្គការ-ស្ថាប័នលោកអ្នក (ឧ. ការងារ សុខាភិបាល ការអប់រំ លទ្ធភាពទទួលបានសេវា  កិច្ចគាំពារសង្គម ។ល។)? សូមពណ៌នាលម្អិត។ (នេះអាចជាការពិភាក្សាដ៏វែងអន្លាយ ដើម្បីយល់ពីបញ្ហាប្រឈមជាក់លាក់ និងរបៀបដែលបញ្ហាទាំងនោះជះឥទ្ធិពលទៅលើការពិភាក្សា និងគោលនយោបាយ។ សូមសួរសំណួរបន្តបន្ទាប់ ដើម្បីស្វែងយល់ឱ្យស៊ីជម្រៅ – ត្រូវពិភាក្សាជាមួយអ្នកចុះស្រាវជ្រាវនៅមូលដ្ឋាន។) | |

**សំណួរលម្អិត៖**

៦. តើលោកអ្នក/អង្គការ-ស្ថាប័នរបស់លោកអ្នក កំពុងដោះស្រាយដោយផ្ទាល់លើបញ្ហាប្រឈមដែលបានរៀបរាប់ខាងលើ (ក្នុងសំណួរទី ៥) ដោយរបៀបណា? តើលោកអ្នកបានអនុវត្តសកម្មភាព/គំនិតផ្តួចផ្តើមអ្វីខ្លះ? តើសកម្មភាពណាខ្លះដែលទទួលបានជោគជ័យ (រឿងរ៉ាវជោគជ័យនឹងមានប្រយោជន៍ខ្លាំងណាស់)? តើសកម្មភាពណាខ្លះដែលពិបាកអនុវត្តជាងគេ? សូមពន្យល់។ (សំណួរនេះក៏អាចទាមទារពេលវេលាយូរផងដែរ។)

៧. តើលោកអ្នកមើលឃើញឱកាសអ្វីខ្លះ សម្រាប់ការផ្លាស់ប្តូរនៅកម្រិតរដ្ឋាភិបាល ពាក់ព័ន្ធនឹងក្រុមគោលដៅរបស់លោកអ្នក និងបញ្ហាប្រឈមដែលបានពិភាក្សានៅទីនេះ (អាចជាគោលនយោបាយជាក់លាក់ ឬអភិក្រម ឬភាពជាដៃគូ។ល។)?

៨. តើលោកអ្នកធ្វើការនៅកម្រិតគោលនយោបាយ ឬសេវារដ្ឋាភិបាល ទាំងក្នុងនាមជាអង្គការ-ស្ថាប័ន ឬជាសម្ព័ន្ធអង្គការ-ស្ថាប័ន ដើម្បីចែករំលែកក្តីកង្វល់ និងបញ្ចុះបញ្ចូលឱ្យមានការផ្លាស់ប្តូរដែរ ឬទេ?

៩. តើមានមធ្យោបាយ/ដំណើរការស្តង់ដារ ណាមួយដែលអង្គការ-ស្ថាប័ន/សម្ព័ន្ធរបស់លោកអ្នក អាចបង្ហាញក្តីកង្វល់ទៅកាន់រដ្ឋាភិបាលដែរ ឬទេ?

១០. តើអ្វីជាបញ្ហាប្រឈមដែលលោកអ្នកជួបប្រទះក្នុងការធ្វើឱ្យរដ្ឋាភិបាលយល់ និងគាំទ្រលើបញ្ហាសំខាន់ៗរបស់លោកអ្នក (ឧទាហរណ៍ ទិន្នន័យ/ភស្តុតាង ការរើសអើង កង្វះការយល់ដឹង ឧបសគ្គពេលវេលា និងថវិកា)?

១១. តើអង្គការ-ស្ថាប័នរបស់លោកអ្នក ត្រូវការអ្វីបន្ថែមទៀត (មិនត្រឹមតែពីរដ្ឋាភិបាលប៉ុណ្ណោះទេ ប៉ុន្តែគឺជារួម) ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់សហគមន៍? តើបច្ចុប្បន្ន លោកអ្នកកំពុងព្យាយាមស្វែងរកការគាំទ្រដែលត្រូវការចាំបាច់នោះ ដោយរបៀបណា?

**ការបិទបញ្ចប់បទសម្ភាសន៍៖** អំណរគុណដល់អ្នកចូលរួមដែលបានចំណាយពេលវេលា និងការរួមចំណែកដ៏មានតម្លៃដល់ការងារនេះ។ សួរថាតើពួកគេមានអ្វីចង់សួរអ្នកចុះស្រាវជ្រាវនៅមូលដ្ឋានដែរ ឬទេ? ជម្រាបពួកគេឱ្យបានដឹង ប្រសិនបើត្រូវមានការតាមដានបន្ត។

# ឧបសម្ព័ន្ធ ៦. ក្របខណ្ឌវិភាគយេនឌ័រនៅកន្លែងការងារ (Gender at Work)

ក្នុងការវិភាគ យើងប្រើប្រាស់ក្របខណ្ឌវិភាគ  សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ដ៏ពេញនិយមរបស់ DFAT គឺក្របខណ្ឌយេនឌ័រនៅកន្លែងការងារ (Gender at Work Framework) ដូចដែលបានកំណត់នៅក្នុង ការវិភាគសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម៖ កំណត់ត្រានៃការអនុវត្តល្អ  (DFAT, May 2023)។ ក្របខណ្ឌនេះត្រូវបានបង្កើតឡើងដោយ Gender at Work ដែលជាសម្ព័ន្ធអង្គការសិទ្ធិស្ត្រីអន្តរជាតិមួយ ហើយត្រូវបាន ប្រើប្រាស់យ៉ាងទូលំទូលាយនៅទូទាំងកម្មវិធីអភិវឌ្ឍន៍របស់អូស្ត្រាលី។ ខាងក្រោមនេះគឺជាសេចក្តីសង្ខេបនៃក្របខណ្ឌ និងការអនុវត្តនៅក្នុងការវិភាគនេះ។

## ទិដ្ឋភាពទូទៅនៃក្របខណ្ឌ

ក្របខណ្ឌយេនឌ័រនៅកន្លែងការងារ យល់ឃើញថាយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម គឺជាធាតុផ្សំដែលមាន ទំនាក់ទំនងគ្នាទៅវិញទៅមកនៃការផ្លាស់ប្តូរស្ថាប័ន និងសង្គម ជាជាងជាធាតុផ្សំដាច់ដោយឡែកពីគ្នា។ ក្របខណ្ឌនេះ ផ្តោតការយកចិត្តទុកដាក់ទាំងលើប្រព័ន្ធផ្លូវការ (ច្បាប់ គោលនយោបាយ ការរៀបចំស្ថាប័ន) និងឌីណាមិកក្រៅផ្លូវការ (បទដ្ឋានសង្គម ទំនាក់ទំនងអំណាច ការអនុវត្តប្រចាំថ្ងៃ) និងរបៀបដែលកត្តាទាំងនេះធ្វើជះឥទ្ធិពលលើគ្នា ដើម្បីផ្តល់លទ្ធភាព ឬរឹតត្បិតដល់បរិយាបន្ន។

ក្របខណ្ឌនេះត្រូវបានរៀបចំឡើងជាបួនជ្រុង ដែលតំណាងឱ្យធាតុផ្សំខុសៗគ្នានៃការផ្លាស់ប្តូរ៖

| | ផ្លូវការ / ស្តែងឱ្យឃើញ | ក្រៅផ្លូវការ / មិនស្តែងឱ្យឃើញ |
|---|---|---|
| បុគ្គល | **មនសិការ និងភាពម្ចាស់ការលើខ្លួនឯង** ការទទួលបានសិទ្ធិ ការយល់ដឹងអំពីសិទ្ធិ ទទួលបាន សំឡេងតំណាង ទំនុកចិត្ត និងលទ្ធភាពចូលរួមក្នុងការស្រាវជ្រាវ និងគោលនយោបាយ។ | **បទដ្ឋាន ជំនឿ អាកប្បកិរិយា** បទដ្ឋានយេនឌ័រ ការរើសអើង អាកប្បកិរិយាចំពោះពិការភាព ថាតើនរណាត្រូវបានគេចាត់ទុកថា ជាអ្នកមានចំណេះដឹងគួរឱ្យជឿទុកចិត្ត ថាតើនរណាត្រូវបានអញ្ជើញឱ្យចូលរួម។ |
| ស្ថាប័ន | **គោលនយោបាយ ច្បាប់ ធនធាន** អាណត្តិ សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ការបែងចែកថវិកា ការតម្រូវឱ្យបំបែកទិន្នន័យជាប្រភេទ ស្តង់ដារនៃការបង្កភាពងាយស្រួលរបស់ស្ថាប័ន គោលនយោបាយធនធានមនុស្ស និងការជ្រើសរើសបុគ្គលិក។ | **វិធាន និងការអនុវត្តក្រៅផ្លូវការ** ការរារាំងក្នុងការកំណត់របៀបវារៈ ថាតើការស្រាវជ្រាវរបស់នរណា ត្រូវបានទទួលស្គាល់ ការផាត់ចេញក្រៅផ្លូវការ នៅក្នុងវេទិកាពិគ្រោះយោបល់ វប្បធម៌ស្ថាប័ន។ |

## *ការអនុវត្តចំពោះការវិភាគនេះ*

នៅទូទាំងជ្រុងទាំងបួន ការវិភាគនេះបានពិនិត្យទៅលើ៖

### កម្រិតបុគ្គល

របៀបដែលស្ត្រី ជនមានពិការភាព ក្រុម LGBTQIA+ និងជនជាតិដើមភាគតិច ចូលបានចូលរួមក្នុងការស្រាវជ្រាវ និងគោលនយោបាយ ភាពម្ចាស់ការ និងទំនុកចិត្តរបស់ពួកគេ ការយល់ដឹងរបស់ពួកគេអំពីសិទ្ធិ និងសិទ្ធិទទួលបាន។

### បទដ្ឋាន និងអាកប្បកិរិយា

របៀបដែលបទដ្ឋានយេនឌ័រ ការរើសអើងជនមានពិការភាព និងអាកប្បកិរិយាចំពោះក្រុមងាយរងគ្រោះកំណត់ថាតើចំណេះដឹងរបស់នរណាត្រូវបានគេចាត់ទុកថាគួរឱ្យជឿទុកចិត្ត និងថាតើនរណាត្រូវបានអញ្ជើញឱ្យចូលរួមក្នុងការពិភាក្សាស្រាវជ្រាវ និងគោលនយោបាយ។

### ប្រព័ន្ធស្ថាប័នផ្លូវការ

របៀបដែលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ត្រូវបានផ្តល់អាណត្តិ ផ្តល់ធនធាន និងពិនិត្យតាមដាន នៅក្នុងក្រសួងពាក់ព័ន្ធ វិទ្យាស្ថានស្រាវជ្រាវ និងអង្គការសង្គមស៊ីវិល ការមាន ឬគ្មានស្តង់ដារនៃការបង្កភាពងាយស្រួល និងយន្តការគណនេយ្យភាព។

### ឌីណាមិកស្ថាប័នក្រៅផ្លូវការ

ថាតើអំណាចជះឥទ្ធិពល/ស្តែងឡើងដូចម្តេចនៅក្នុងការកំណត់របៀបវារៈ ការប្រគល់ភារកិច្ចស្រាវជ្រាវ និងដំណើរការពិគ្រោះយោបល់ ថាតើការផាត់ចេញក្រៅផ្លូវការកើតឡើងដោយរបៀបណា សូម្បីតែនៅក្នុងមជ្ឈដ្ឋានដែលមានបរិយាបន្នជាផ្លូវការ។

ក្របខណ្ឌនេះបានណែនាំអំពីការរៀបចំសំណួរស្រាវជ្រាវ ការជ្រើសរើសប្រធានបទសម្រាប់ការពិភាក្សាក្រុមគោលដៅ (FGD) និងបទសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ (KII) ព្រមទាំងអភិក្រមវិភាគដែលបានអនុវត្តចំពោះរបកគំហើញនានា។ ក្របខណ្ឌនេះក៏ត្រូវបានប្រើប្រាស់ផងដែរ ដើម្បីវាយតម្លៃផ្ទាល់លើផែនការ សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គមរបស់កម្មវិធីពន្លកចំណេះ ដំណាក់កាលទី ២ ដោយពិនិត្យមើលថាតើជ្រុងនីមួយៗនៃការផ្លាស់ប្តូរ ត្រូវបានដោះស្រាយយ៉ាងដូចម្តេចខ្លះ នៅក្នុងទ្រឹស្តីនៃការផ្លាស់ប្តូរ និងការអនុវត្តរបស់កម្មវិធី។

## *ភាពប្រទាក់ក្រឡាជាចក្ក/កញ្ចក់ឆ្លុះអន្តរវិស័យ*

ការវិភាគនេះបានអនុវត្តអន្តប្រសព្វ ជាចក្ក/កញ្ចក់ឆ្លុះអន្តរវិស័យ ជាជាងចាត់ទុកជាធាតុផ្សំដាច់ដោយឡែកមួយ។ ផ្អែកលើស្នាដៃរបស់លោកស្រី Kimberlé Crenshaw និងបញ្ញវន្តសិទ្ធិស្ត្រីផ្សេងៗទៀត ភាពប្រទាក់ក្រឡាទទួលស្គាល់ថា ការផាត់ចេញត្រូវបានបង្កើតឡើងតាមរយៈអន្តរកម្មនៃអត្តសញ្ញាណសង្គមជាច្រើន រួមមានយេនឌ័រ ពិការភាព ជាតិពន្ធុ អាយុ ទំនោរផ្លូវភេទ ភូមិសាស្ត្រនិងស្ថានភាពសេដ្ឋកិច្ចសង្គម ហើយអន្តរកម្មទាំងនេះបង្កើតបានជាឧបសគ្គត្រួតគ្នា ដែលជារឿយៗ មិនអាចមើលឃើញនៅក្នុងការវិភាគតែធាតុផ្សំណាមួយបានឡើយ។

ក្នុងន័យជាក់ស្តែង នេះមានន័យថា ការវិភាគមិនត្រឹមតែពិនិត្យមើលរបៀបដែលស្ត្រីជួបប្រទះការផាត់ចេញ ឬរបៀបដែលជនមានពិការភាពជួបប្រទះការផាត់ចេញប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងពិនិត្យមើលរបៀបដែលស្ត្រីជនជាតិដើមភាគតិចដែលមានពិការភាព និងរស់នៅខេត្តដាច់ស្រយាល ជួបប្រទះឧបសគ្គជាច្រើនដែលមានលក្ខណៈខុសប្លែកគ្នា និងធ្ងន់ធ្ងរជាងអ្វី ដែលប្រភេទអត្តសញ្ញាណតែមួយអាចបង្ហាញឡើង។

# ឧបសម្ព័ន្ធ ៧. ទិដ្ឋភាពទូទៅនៃក្របខណ្ឌគោលនយោបាយ និងច្បាប់ជាតិ

| គោលនយោបាយ / ក្របខណ្ឌ | ឆ្នាំ | ភាពពាក់ព័ន្ធនឹង សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម | ក្រសួងទទួលបន្ទុក |
|---|---|---|---|
| យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី ១ | ២០២៣ –២០២៨ | យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បញ្ចកោណទី៤ រួមបញ្ចូលភាពធន់ផ្នែកប្រជាសាស្ត្រ និងសមភាពយេនឌ័រជាអាទិភាព។ | ទីស្តីការគណៈ រដ្ឋមន្ត្រី |
| ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) | ២០១៩–២០២៣ | ក្របខណ្ឌអភិវឌ្ឍន៍រួម យោងដល់គោលដៅយេនឌ័រ និងបរិយាបន្នសង្គម។ | ក្រសួងផែនការ |
| ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ទី ២ (NDSP2) | ២០១៩–២០២៣ | ក្របខណ្ឌសម្រាប់សេវាបរិយាបន្នពិការភាព ក្រុមការងារសកម្មភាពជនពិការ (DAWGs) និងការអនុវត្តនៅថ្នាក់ក្រោមជាតិ។ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា/ ក្រុមប្រឹក្សាសកម្មភាពជនពិការ |
| ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ទី ៣ (NDSP3) | ២០២៤–២០២៨ | ផែនការយុទ្ធសាស្ត្របច្ចុប្បន្នភាព ដាក់ឱ្យប្រើប្រាស់នៅខែធ្នូ ឆ្នាំ២០២៤ គ្របដណ្តប់លើការពិគ្រោះយោបល់ និងបរិយាបន្នកាន់តែទូលំទូលាយ។ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា/ ក្រុមប្រឹក្សាសកម្មភាពជនពិការ |
| ផែនការយុទ្ធសាស្ត្រនារីរតនៈ ទី ៦ (គោលនយោបាយជាតិស្តីពីយេនឌ័រ) | ២០២៤–២០២៨ | គោលនយោបាយស្នូលស្តីពីសមភាពយេនឌ័រ តម្រូវឱ្យមានការបញ្ជ្រាបយេនឌ័រទៅក្នុងអន្តរក្រសួងតាមរយៈក្រុមការងារបញ្ជ្រាបយេនឌ័រ (GMAG)។ | ក្រសួងកិច្ចការនារី |
| គោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច | ២០០៩ | ក្របខណ្ឌសម្រាប់ការការពារសិទ្ធិ និងការលើកកម្ពស់ការអភិវឌ្ឍប្រកបដោយបរិយាបន្នសម្រាប់ជនជាតិដើមភាគតិច លើផ្នែកដីធ្លី វប្បធម៌ អប់រំ សុខាភិបាល និងការចូលរួម។ | ក្រសួងអភិវឌ្ឍន៍ជនបទ |
| ផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា ដំណាក់កាលទី ២ | ២០២២-២០២៦ | ក្របខណ្ឌអភិវឌ្ឍន៍យុវជន លើកកម្ពស់លទ្ធភាពទទួលបានការអប់រំ ជំនាញ ការងារសុខាភិបាល និងការចូលរួមប្រកបដោយបរិយាបន្នសម្រាប់ក្រុមយុវជនចម្រុះ។ | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍យុវជន ក្រសួងអប់រំ យុវជន និងកីឡា |
| ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម (NSPPF) | ២០១៦–២០២៥ | កំណត់អត្តសញ្ញាណក្រុមងាយរងគ្រោះ រួមមានជនមានពិការភាព ចាស់ជរា និងកម្មករនិយោជិតក្រៅប្រព័ន្ធ សម្រាប់ការទទួលបានកិច្ចគាំពារសង្គម។ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |

| គោលនយោបាយ / ក្របខណ្ឌ | ឆ្នាំ | ភាពពាក់ព័ន្ធនឹង សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម | ក្រសួងទទួលបន្ទុក |
|---|---|---|---|
| ច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ | ២០០៩ | ច្បាប់ចម្បងស្តីពីសិទ្ធិជនពិការ ជាមូលដ្ឋានគ្រឹះសម្រាប់កាតព្វកិច្ចបញ្ជ្រាបពិការភាពទាំងអស់។ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា/ ក្រុមប្រឹក្សាសកម្មភាពជនពិការ |
| ផែនការមេស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ | ២០១៨ –២០៣០ | ដោះស្រាយទំនាក់ទំនងរវាងយេនឌ័រ និងអាកាសធាតុ ត្រូវបានយោងនៅក្នុង NDC 3.0 ។ | ក្រសួងកិច្ចការនារី / ក្រសួងបរិស្ថាន |
| របាយការណ៍ NDC 3.0 | ២០២៥ | ការប្តេជ្ញាចិត្តរបស់កម្ពុជាលើបញ្ហាអាកាសធាតុ រួមបញ្ចូលបទប្បញ្ញត្តិស្តីពីយេនឌ័រ និងបរិយាបន្នសង្គម។ | ក្រសួងបរិស្ថាន |
| ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ | ផ្សេងៗ | ផ្តល់មូលដ្ឋានគតិយុត្តសម្រាប់ការពិគ្រោះយោបល់ជាសាធារណៈ និងគោលការណ៍នៃការយល់ព្រមជាមុន ដោយសេរី និងមានព័ត៌មានគ្រប់គ្រាន់ (FPIC) នៅក្នុងការរៀបចំផែនការបរិស្ថាន។ | ក្រសួងបរិស្ថាន |
| អនុសញ្ញា CEDAW (បានផ្តល់សច្ចាប័ន) | ១៩៩២ | អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី ភេទ ណែនាំអំពីការរាយការណ៍ និងគណនេយ្យភាព។ | ក្រសួងកិច្ចការនារី |
| អនុសញ្ញា CRPD (បានផ្តល់សច្ចាប័ន) | ២០១២ | អនុសញ្ញាស្តីពីសិទ្ធិជនពិការ ណែនាំអំពីកាតព្វកិច្ចបរិយាបន្នពិការភាព។ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា/ ក្រុមប្រឹក្សាសកម្មភាពជនពិការ |
| ផែនការមេអាស៊ានឆ្នាំ២០២៥ ស្តីពីការបញ្ជ្រាបសិទ្ធិជនមានពិការភាព | ២០២៥ | ការបញ្ជ្រាបសិទ្ធិជនមានពិការភាព។ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| បទដ្ឋានបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព | ២០១៨ | អង្គភាពដែលមានសិទ្ធិចេញលិខិតអនុញ្ញាតសាងសង់ ត្រូវតែម្រូវឱ្យហេដ្ឋារចនាសម្ព័ន្ធរូបវន្តថ្មីទាំងអស់ រៀបចំឡើងដើម្បីផ្តល់ភាពងាយស្រួលពេញលេញសម្រាប់ជនមានពិការភាពគ្រប់ប្រភេទ។ | ក្រុមប្រឹក្សាសកម្មភាពជនពិការ |
| ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ | ២០០៥ | ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងការការពារជនរងគ្រោះ។ | ក្រសួងកិច្ចការនារី |
| ក្របខណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDG) - របៀបវារៈឆ្នាំ២០៣០ | ២០១៥ | គោលការណ៍ "មិនទុកនរណាម្នាក់ចោល" ជាមូលដ្ឋានគ្រឹះសម្រាប់រាល់ការប្តេជ្ញាចិត្តចំពោះបរិយាបន្ន សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គមនៅកម្ពុជា។ | ក្រសួងផែនការ / ក្រសួងទាំងអស់ |

Australian Aid

PONLOK CHOMNES